# មេរៀនទី 1 ប្រការសំខាន់នៅការដ្ឋានក្នុងប្រទេសជប៉ុន

## 1.1 ការងារជាក្រុម

នៅក្នុងការងារសំណង់ មានដំណាក់កាលជាច្រើនមុននឹងសាងសង់រួចរាល់ ។ អ្នកម៉ៅការឯកទេសនៃប្រភេទការងារផ្សេងៗ ទទួលការងារពីអ្នកម៉ៅការទូទៅហើយអនុវត្តការងាររបស់ខ្លួន រួចភ្ជាប់បន្តទៅដំណាក់កាលបន្ទាប់ទៀត។ ការងារជាក្រុមក្នុងចំណោមអ្នកម៉ៅការឯកទេសគឺមានសារៈសំខាន់ក្នុងការធ្វើឲ្យការសាងសង់មានដំណើរការរលូន។ កំលុងពេលសាងសង់ មេការពិភាក្សាជាមួយអ្នកគ្រប់គ្រងការដ្ឋានបណ្ដើរ និងផ្ដល់ការណែនាំដល់អ្នកជំនាញបណ្ដើរ។ នៅឯការដ្ឋានសំណង់ អ្នកជំនាញរៀមច្បង ជំរុញការសាងសង់បណ្ដើរ និងផ្ដល់ដំបូន្មានដល់អ្នកជំនាញជំនាន់ក្រោយដែលមិនសូវមានបទពិសោធន៍បណ្ដើរ។

## 1.2 ប្រព័ន្ធអនុវត្តការសាងសង់នៃការងារសំណង់នៅក្នុងប្រទេសជប៉ុន

ប្រព័ន្ធអនុវត្តការសាងសង់នៃការងារសំណង់នៅក្នុងប្រទេសជប៉ុនមានគំរូផ្សេងៗគ្នាជាច្រើន អាស្រ័យទៅលើទំហំការងារ។ ជាឧទាហរណ៍ ការងារសំណង់ខ្នាតធំទូទៅ ត្រូវបានអនុវត្តតាមលំដាប់ចាប់ពីការបញ្ជាទិញសេវាសាងសង់រហូតដល់ការអនុវត្តការងារសំណង់ ដូចប្រព័ន្ធដែលបានបង្ហាញក្នុងរូបភាពទី 1-1 ។ ចំពោះសំណង់ខ្នាតតូចដូចជាលំនៅឋានទូទៅជាដើម ម្ចាស់សំណង់ (អតិថិជនដែលសាងសង់សំណង់) បញ្ជាទិញសេវាទៅកាន់ កូមុតេន (ក្រុមហ៊ុនសំណង់ខ្នាតតូច) ជាដើមហើយ កូមុតេន ក្លាយជាអ្នកម៉ៅការផ្ទាល់ហើយជំរុញដំណើរការសាងសង់លំនៅដ្ឋានដោយគ្រប់គ្រងលើអ្នកម៉ៅការឯកទេសបណ្ដើរ។




រូបភាពទី 1-1 ឧទាហរណ៍នៃប្រព័ន្ធអនុវត្តការសាងសង់

[(1) អតិថិជន]

ការបញ្ជាទិញសេវាការងារសំណង់ទៅក្រុមហ៊ុនសំណង់ហៅថា "ការបញ្ជាទិញសេវា"។ ស្ថាប័នឬក្រុមហ៊ុនដែលបញ្ជាទិញសេវាគឺជា "អតិថិជន"។ ឧទាហរណ៍ "អតិថិជន" អាចជា ក្រសួងដែនដីហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍និងទេសចរណ៍ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមហ៊ុនឯកជន ឬឯកត្តបុគ្គល។

[(2) អ្នកគ្រប់គ្រង] អ្នកជំនាញដែលមានតួនាទីត្រួតពិនិត្យថាតើការសាងសង់កំពុងអនុវត្តស្របតាមប្លង់ដែរឬទេ។

[(3) អ្នករចនា] អ្នកជំនាញដែលបង្កើតឯកសារប្លង់រចនាដើម្បីសម្រេចបាននូវសំណើរបស់អតិថិជន។

[(4) ក្រុមហ៊ុនដែលគ្រប់គ្រងសំណង់ទាំងមូល] ត្រូវបានហៅជាទូទៅថា "អ្នកម៉ៅការទូទៅ"។

[(5) អ្នកគ្រប់គ្រងការដ្ឋាន]  អ្នកជំនាញដែលគ្រប់គ្រង និងដឹកនាំការដ្ឋានសំណង់។

[(6) អ្នកម៉ៅការឯកទេស] អ្នកឯកទេសក្នុងការងារសាងសង់នីមួយៗ។ កម្មករច្រើននាក់ធ្វើការតាមការណែនាំរបស់មេការ។

## 1.3 ប្រព័ន្ធលើកកម្ពស់អាជីពសំណង់

នៅប្រទេសជប៉ុនមាន "ប្រព័ន្ធលើកកម្ពស់អាជីពសំណង់"។ ប្រព័ន្ធលើកកម្ពស់អាជីពសំណង់កំពុងត្រូវបានជំរុញក្នុងនាមជាប្រព័ន្ធដែលចុះបញ្ជីស្នាដៃការងារនិងគុណវុឌ្ឍិរបស់អ្នកជំនាញម្នាក់ៗដែលនាំទៅរកការវាយតម្លៃដោយយុត្តិធម៌លើជំនាញ ការលើកកម្ពស់គុណភាពការងារសំណង់ និងប្រសិទ្ធផលនៃការងារនៅការដ្ឋានជាដើម។ អ្នកជំនាញត្រូវបានបែងចែកជា4កម្រិត ហើយពេលចុះបញ្ជីក្នុងប្រព័ន្ធ នឹងត្រូវបានចេញជូននូវកាតដែលបង្ហាញកម្រិតរបស់ពួកគេ។




រូបភាពទី 1-3 កម្រិតនិងពណ៌កាតនៃប្រព័ន្ធលើកកម្ពស់អាជីព

អ្នកជំនាញត្រូវបានវាយតម្លៃលើចំណុច 3 ខាងក្រោម។

· បទពិសោធន៍ (ចំនួនថ្ងៃធ្វើការ)

· ចំណេះដឹង ជំនាញ (គុណវុឌ្ឍិដែលមាន)

· សមត្ថភាពគ្រប់គ្រង (វគ្គបណ្តុះបណ្តាលអ្នកជំនាញស្នូលដែលបានចុះបញ្ជី បទពិសោធន៍ជាមេការ)

កម្រិត 2 ត្រូវការចំនួនថ្ងៃធ្វើការ 645ថ្ងៃ (3 ឆ្នាំ)ឡើងទៅបន្ទាប់ពីការចុះបញ្ជីក្នុងប្រព័ន្ធ ដូច្នេះគ្រប់គ្នានឹងចាប់ផ្តើមពីកម្រិត1 ។

## 1.4 គារវកិច្ច

អ្វីដែលសំខាន់នៅការដ្ឋានសំណង់ក្នុងប្រទេសជប៉ុនគឺ "ការការពារគ្រោះថ្នាក់នៅការដ្ឋានសំណង់" ។ ដូចនេះ កិច្ចប្រឹងប្រែងផ្សេងៗកំពុងត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ។ ផ្នែកជាមូលដ្ឋាននិងសំខាន់បំផុតនៃកិច្ចប្រឹងប្រែងនេះគឺគារវកិច្ច។ នៅពេលដើរកាត់កម្មករតាមផ្លូវ បើពេលព្រឹកគឺធ្វើគារវកិច្ចថា "អរុណសួស្តី" "អ្នកបាននឿយហត់ហើយ" ។ តាមរយៈការធ្វើគារវកិច្ចរវាងកម្មករនៃប្រភេទការងារផ្សេងៗគ្នា បង្កើតឲ្យមានអារម្មណ៍រួបរួមគ្នា ហើយការងារអាចប្រព្រឹត្តទៅបានដោយអារម្មណ៍ល្អ។ ឃ្លាគារវកិច្ចដែលប្រើជាទូទៅរួមមាន "អ្នកបាននឿយហត់ហើយ" និង "សូមឱ្យមានសុវត្ថិភាព(ពេញ1ថ្ងៃ)" ជាដើម។

## 1.5 ការប្រជុំពេលព្រឹក

នៅការដ្ឋានសំណង់ក្នុងប្រទេសជប៉ុនការប្រជុំដែលកម្មករទាំងអស់ជួបជុំគ្នា ត្រូវបានអនុវត្តរាល់ថ្ងៃមុនពេលចាប់ផ្តើមធ្វើការ។ គេហៅថា "ការប្រជុំពេលព្រឹក" ។ ការប្រជុំពេលព្រឹកមាន2ប្រភេទគឺ ការប្រជុំពេលព្រឹកទូទៅ និងការប្រជុំពេលព្រឹកតាមប្រភេទការងារនីមួយៗ។ ការប្រជុំពេលព្រឹកទាំង 2 មានគោលបំណងចម្បងគឺ "ការពារគ្រោះថ្នាក់នៅការដ្ឋានសំណង់" ហើយគេក៏ហៅថា "ការប្រជុំសុវត្ថិភាពពេលព្រឹក" ផងដែរ។

## 1.5.1 ការប្រជុំពេលព្រឹកទូទៅ

ការប្រជុំពេលព្រឹកទូទៅ ជាចម្បងគឺអនុវត្តចំណុចដូចខាងក្រោម។




### (1) ការរកិច្ចរបស់អ្នកគ្រប់គ្រងការដ្ឋាន

ការរកិច្ចរបស់អ្នកគ្រប់គ្រងការដ្ឋានគឺធ្វើឡើងដើម្បីបង្កើនអារម្មណ៍រួបរួមគ្នាក្នុងចំណោមកម្មករ ដើម្បីអាចជំរុញការងារក្នុងថ្ងៃនោះឲ្យដំណើរការទៅដោយសុវត្ថិភាព និងអារម្មណ៍ល្អ។

### (2) ការហាត់ប្រាណតាមវិទ្យុ

ការហាត់ប្រាណត្រៀមមុនពេលធ្វើការ ធ្វើឱ្យរាងកាយនិងខួរក្បាលស្វាងឡើង ដូច្នេះវាជួយការពារកុំឲ្យរងរបួស។ នៅប្រទេសជប៉ុន "ការហាត់ប្រាណតាមវិទ្យុ" ដែលហាត់ប្រាណតាមភ្លេងពីវិទ្យុ ត្រូវបានស្គាល់យ៉ាងទូលំទូលាយ ហើយវាត្រូវបានអនុវត្តនៅក្នុងការប្រជុំពេលព្រឹក។ ពេលខ្លះគេមិនចាក់លេងភ្លេងផងក៏មាន ប៉ុន្តែនៅពេលនោះគេនិងធ្វើចលនារាងកាយដោយស្រែកថា "1 2 3 4" ឲ្យឮៗ។

### (3) ការបញ្ជាក់ពីខ្លឹមសារការងារ

មេការនីមួយៗដែលធ្វើការនៅថ្ងៃនោះ ប្រាប់សមាជិកគ្រប់គ្នាអំពីខ្លឹមសារការងារនិងចំនួនបុគ្គលិកក្នុងថ្ងៃនោះ។ នៅការដ្ឋាន មានកម្មករដែលប្រភេទការងារផ្សេងគ្នាកំពុងធ្វើការ។ ការដែលអ្នកអនុវត្តការងារដែលប្រភេទការងារផ្សេងទៀតបានដឹងអំពីខ្លឹមសារការងារក្នុងថ្ងៃនោះ គឺសំខាន់ក្នុងការការពារគ្រោះថ្នាក់។ ម្យ៉ាងទៀត ក៏អាចដឹងថាតើវាប៉ះពាល់ដល់ការងាររបស់ខ្លួនបែបណាផងដែរ។ លើសពីនេះនៅពេលនោះ ការណែនាំខ្លួនរបស់កម្មករទើបចូលថ្មីក្នុងថ្ងៃនោះ (ហៅថាអ្នកចំណូលថ្មី) ក៏ត្រូវបានធ្វើឡើងផងដែរ។ ប្រសិនបើអ្នកត្រូវបានណែនាំខ្លួនជាអ្នកចំណូលថ្មី ចូរនិយាយឲ្យឮៗ និងច្បាស់ៗពីឈ្មោះ និងក្រុមហ៊ុនរបស់អ្នក ជាដើម។

### (4) សកម្មភាពព្យាករណ៍គ្រោះថ្នាក់ (សកម្មភាព KY)

សកម្មភាពព្យាករណ៍គ្រោះថ្នាក់ត្រូវបានគេហៅថាសកម្មភាព KY (Kiken Yochi) ហើយត្រូវបានអនុវត្តដើម្បីការពារកុំឲ្យមានគ្រោះថ្នាក់ ដោយប្រមើលមើលករណីដែលឧបទ្ទវហេតុទំនងជានឹងកើតឡើងហើយចាប់ដឹងអំពីគ្រោះថ្នាក់ ក្នុងកំលុងពេលធ្វើការក្នុងថ្ងៃនោះ។ ជាពិសេស ពេលដែលការងារថ្មីខុសពីរាល់ដងត្រូវបានអនុវត្តដូចជា ពេលដឹកជញ្ជូនសម្ភារសំណង់ ពេលដំណើរការគ្រឿងចក្រសំណង់ធំៗ ពេលបន្ថែមប្រភេទការងារថ្មីជាដើម ត្រូវតែព្យាករណ៍គ្រោះថ្នាក់ឲ្យបានត្រឹមត្រូវ និងចែករំលែកដល់មនុស្សគ្រប់គ្នា។

### (5) ការពិនិត្យបញ្ជាក់សុវត្ថិភាព

ជាទូទៅ នៅចុងបញ្ចប់នៃការប្រជុំពេលព្រឹក គេចាប់គូគ្នា 2នាក់ អនុវត្តការពិនិត្យបញ្ជាក់

សុវត្ថិភាពដោយបញ្ចេញសំឡេងឮៗដូចខាងក្រោម។




ទិដ្ឋភាពនៃការពិនិត្យ
សុវត្ថិភាព

**(6) ធ្វើការវកិច្ចហើយចាប់ផ្ដើមការងារ**

ក្រោយពីពិនិត្យបញ្ជាក់សុវត្ថិភាពរួចហើយ គ្រប់គ្នានឹងនិយាយថា "សូមឲ្យមានសុវត្ថិភាពនៅថ្ងៃនេះផងដែរ!" ហើយបញ្ចប់ការប្រជុំពេលព្រឹករួចចាប់ផ្ដើមធ្វើការ។ បន្ទាប់ពីនេះ គេធ្វើការប្រជុំពេលព្រឹកដោយបែងចែកទៅតាមប្រភេទការងារ។

## 1.5.2 ការប្រជុំពេលព្រឹកតាមប្រភេទការងារ

បន្ទាប់ពីការប្រជុំពេលព្រឹកទូទៅ ការប្រជុំពេលព្រឹកតាមប្រភេទការងារនឹងត្រូវធ្វើឡើង។

**(1) ការសូត្រស្រុះគ្នាអំពីសុវត្ថិភាព (ប៉ះហើយហៅ)**

និយាយឱ្យឮៗនូវពាក្យស្លោកសុវត្ថិភាពដោយគ្រប់គ្នាចង្អុល។ នេះត្រូវបានធ្វើមិនត្រឹមតែដើម្បីបញ្ជាក់សុវត្ថិភាពប៉ុណ្ណោះទេ វាក៏ដើម្បីបង្កើនអារម្មណ៍រួបរួមគ្នាក្នុងការងារជាក្រុមផងដែរ។ ជាឧទាហរណ៍ គេសូត្រស្រុះគ្នាដូចខាងក្រោម។

"តោះទៅធ្វើការដោយគ្មានគ្រោះថ្នាក់ តោះ!"



ទិដ្ឋភាពនៃការប៉ះហើយហៅ

**(2) សកម្មភាពព្យាករណ៍គ្រោះថ្នាក់ (សកម្មភាព KY)**

នៅក្នុងការប្រជុំពេលព្រឹកទូទៅ សកម្មភាព KY ទាក់ទងនឹងការដ្ឋានទាំងមូលត្រូវបានធ្វើឡើង ប៉ុន្តែនៅក្នុងប្រភេទការងារនីមួយៗសកម្មភាព KY ក៏ត្រូវបានធ្វើឡើងផងដែរមុនពេលចាប់ផ្តើមការងារ។ សកម្មភាព KY ជាទូទៅត្រូវបានអនុវត្តតាមជំហានដូចខាងក្រោម។




រូបថត 1-4 ទិដ្ឋភាពនៃសកម្មភាព KY

**[ការរកឃើញគ្រោះថ្នាក់]**

ស្រង់ចេញ "ចំណុចសំខាន់នៃគ្រោះថ្នាក់" ។ ឱ្យនិយាយតាមការងារនីមួយៗអំពីស្ថានភាពនិងសកម្មភាពគ្រោះថ្នាក់ដែលអាចនឹកឃើញចំពោះខ្លឹមសារការងារថ្ងៃនេះ។ ពេលខ្លះក៏មានការហៅឈ្មោះឲ្យឡើងធ្វើបទបង្ហាញ ហើយគោលបំណងនេះគឺដើម្បីចែករំលែកបទពិសោធន៍គ្រោះថ្នាក់និងបង្កើនអារម្មណ៍ទទួលយកគ្រោះថ្នាក់ថាជារឿងរបស់ខ្លួន ដើម្បីការពារឧបទ្ទវហេតុ។

**[ការពិចារណាលើវិធានការ]**

ពិភាក្សាលើវិធានការតាម "ចំណុចសំខាន់នៃគ្រោះថ្នាក់" នីមួយៗ ហើយបង្កើតវិធានការ។ ពេលបានកំណត់វិធានការរួចរាល់ហើយ សរសេរបញ្ចូលតារាងសកម្មភាពព្យាករណ៍គ្រោះថ្នាក់។

<table>
<tr><th colspan="4">តារាងសកម្មភាពព្យាករណ៍គ្រោះថ្នាក់ ខែ ថ្ងៃ</th></tr>
<tr><td>ខ្លឹមសារការងាររបស់ក្រុម</td><td colspan="3"></td></tr>
<tr><td colspan="2">ចំណុចសំខាន់នៃគ្រោះថ្នាក់</td><td colspan="2">ពួកយើងធ្វើបែបនេះ</td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td colspan="2"></td><td colspan="2"></td></tr>
<tr><td>គោលដៅសុវត្ថិភាពថ្ងៃនេះ:</td><td colspan="3"></td></tr>
<tr><td>ឈ្មោះក្រុម</td><td></td><td>ឈ្មោះមេក្រុម</td><td>កម្មករ ឈ្មោះ</td></tr>
</table>

**[ការកំណត់គោលដៅសកម្មភាព]**

កំណត់ចំណុចសំខាន់ៗជាពិសេសហើយដាក់ជាគោលដៅសម្រាប់ថ្ងៃនេះ។

**[ស្រែកឡើង]**

ទាំងអស់គ្នាបែរឆ្ពោះទៅកាន់ក្តារ KY ដែលបានសរសេរអំពីគោលដៅសកម្មភាពដែលបានកំណត់ ហើយធ្វើការ "ចង្អុលនិងហៅ" ហើយសូត្រដងដែលៗដូចតទៅ។

"គោះ! ○○○" "គោះថ្ងៃនេះក៏ប្រឹងប្រែងធ្វើការដោយសុវត្ថិភាពពេញមួយថ្ងៃដែរ! .....អូរ!"

# មេរៀនទី 2  ច្បាប់និងបទប្បញ្ញត្តិដែលត្រូវតែគោរពនៅពេលធ្វើការនៅការដ្ឋាននៅប្រទេសជប៉ុន

## 2.1 ច្បាប់ការងារ

ច្បាប់ការងារ គឺជាឈ្មោះសម្រាប់ហៅជារួមសម្រាប់ច្បាប់ទាក់ទងនឹងបញ្ហាការងារ។

### 2.1.1 ច្បាប់ស្តង់ដារការងារ

**(1)ទិដ្ឋភាពទូទៅ**

នៅក្រោមច្បាប់ស្តង់ដារការងារ លក្ខខណ្ឌការងារអប្បបរមាត្រូវបានកំណត់ ហើយផ្នែកណាមួយដែលមិនបំពេញតាមស្តង់ដារគឺចាត់ទុកថាខុសច្បាប់ ហើយបទប្បញ្ញត្តិនៃច្បាប់ស្តង់ដារការងារនឹងត្រូវបានអនុវត្ត។ លក្ខខណ្ឌការងារ សំដៅលើការផ្តល់ទាំងអស់នៅក្នុងកន្លែងធ្វើការដោយរួមបញ្ចូលមិនត្រឹមតែប្រាក់ឈ្នួលនិងម៉ោងធ្វើការប៉ុណ្ណោះទេ គឺទាំងលក្ខខណ្ឌទាក់ទងនឹងការបញ្ឈប់ពីការងារ សំណងគ្រោះថ្នាក់ សុខភាពនិងសុវត្ថិភាព និងកន្លែងស្នាក់នៅជាដើម។

**(2) ចំណុចសំខាន់**

□ ការកំណត់លក្ខខណ្ឌការងារ

និយោជិតនិងនិយោជកចាំបាច់ត្រូវគោរពតាមការសន្យា។

□ គោលការណ៍ឱកាសស្មើគ្នា

និយោជកត្រូវបានកំណត់ថាមិនត្រូវរើសអើងអំពីប្រាក់ឈ្នួល ម៉ោងធ្វើការ និងលក្ខខណ្ឌការងារផ្សេងទៀតដោយផ្អែកលើសញ្ជាតិ ជំនឿ ឬឋានៈសង្គមរបស់និយោជិតឡើយ។

□ ការហាមឃាត់ពលកម្មដោយបង្ខំ

និយោជកត្រូវបានកំណត់ថាមិនត្រូវបង្ខំនិយោជិតឱ្យធ្វើការដោយប្រឆាំងនឹងឆន្ទៈរបស់និយោជិតដោយការប្រើអំពើហិង្សា គំរាមកំហែង បង្ខាំង ឬមធ្យោបាយផ្សេងទៀតដែលរឹតត្បិតសេរីភាពផ្លូវចិត្តឬរាងកាយដោយមិនត្រឹមត្រូវឡើយ។

□ ការទប់ស្កាត់ការបៀតបៀនដោយអំណាច

ការបៀតបៀនដោយអំណាចត្រូវបានកំណត់ថាជាទង្វើផ្តល់ការឈឺចាប់ផ្លូវចិត្តផ្លូវកាយឬធ្វើឱ្យបរិយាកាសការងារមានភាពអាក្រក់ ដោយប្រើប្រាស់ឧត្តមភាពក្នុងកន្លែងធ្វើការដែលហួសពីវិសាលភាពសមស្របនៃការងារ។

□ ការបង្ហាញច្បាស់នូវលក្ខខណ្ឌការងារ

នយោជកត្រូវបានកំណត់ថាត្រូវតែបង្ហាញច្បាស់នូវធាតុទាំង 6 ខាងក្រោម។

(1) រយៈពេលនៃកិច្ចសន្យាការងារ (2) លក្ខណៈវិនិច្ឆ័យនៃការបន្តកិច្ចសន្យាការងារដែលបានកំណត់ (3) កន្លែងធ្វើការនិងខ្លឹមសារការងារ (4) បញ្ហាទាក់ទងនឹងពេលវេលាបញ្ចប់ការងារ មានឬគ្មានការងារបន្ថែមម៉ោង ពេលវេលាសម្រាក ថ្ងៃឈប់សម្រាក ការឈប់សម្រាក (5) បញ្ហាទាក់ទងនឹងការកំណត់ប្រាក់ឈ្នួល វិធីសាស្ត្រទូទាត់ ថ្ងៃចុងក្រោយនៃចន្លោះគិតប្រាក់ឈ្នួល ថ្ងៃទូទាត់ ការដំឡើងប្រាក់ឈ្នួល (6) បញ្ហាទាក់ទងនឹងការលាឈប់ពីការងារនិងការបញ្ឈប់ពីការងារ

□ ការហាមឃាត់ការគ្រោងធ្វើសំណង

មិនត្រូវធ្វើកិច្ចសន្យាដែលកំណត់ប្រាក់ផាកពិន័យឬគ្រោងទុកទឹកប្រាក់សំណងការខូចខាតចំពោះការមិនបំពេញកិច្ចសន្យាការងារឡើយ។

□ ការរឹតត្បិតលើការបញ្ឈប់ពីការងារ

មិនត្រូវបញ្ឈប់ពីការងារក្នុងអំឡុងពេលដែលនិយោជិតឈប់សម្រាកដើម្បីព្យាបាលរបួសឬជំងឺដោយសារការងារ ព្រមទាំងរយៈពេល 30 ថ្ងៃបន្ទាប់ពីនោះ។

□ ការជូនដំណឹងជាមុនអំពីការបញ្ឈប់ពីការងារ

ករណីចង់បញ្ឈប់និយោជិតពីការងារ ត្រូវតែជូនដំណឹងឲ្យបាន 30 ថ្ងៃមុន។

□ ប្រាក់ឈ្នួល

ត្រូវតែធ្វើការទូទាត់ (1)ជាប្រាក់កាស (2)ដោយផ្ទាល់ទៅនិយោជិត (3)នូវទឹកប្រាក់សរុប (4)យ៉ាងហោចណាស់1ដងក្នុងមួយខែ (5)នៅកាលបរិច្ឆេទកំណត់។ (គោលការណ៍ទាំង 5 នៃការទូទាត់ប្រាក់ឈ្នួល)

□ ម៉ោងធ្វើការតាមច្បាប់

ជាគោលការណ៍ មិនត្រូវឲ្យធ្វើការលើស 40ម៉ោងក្នុង 1សប្តាហ៍ និងលើស 8ម៉ោងក្នុង1ថ្ងៃឡើយ។

□ ការសម្រាក

ប្រសិនបើម៉ោងធ្វើការលើសពី 6ម៉ោង ត្រូវតែផ្តល់ពេលសម្រាក 45នាទី ហើយប្រសិនបើម៉ោងធ្វើការលើសពី 8ម៉ោង នោះត្រូវផ្តល់ពេលសម្រាក 1ម៉ោង នៅកំលុងពេលនៃម៉ោងធ្វើការទាំងអស់គ្នា។

□ ថ្ងៃឈប់សម្រាកតាមច្បាប់

ត្រូវផ្តល់ថ្ងៃឈប់សម្រាកយ៉ាងហោចណាស់1ថ្ងៃក្នុង1សប្តាហ៍។

□ ការធ្វើការបន្ថែមម៉ោង ការធ្វើការថ្ងៃឈប់សម្រាក

ការធ្វើការបន្ថែមម៉ោង(ថែមម៉ោង) គឺអាចធ្វើទៅបាន "នៅពេលដែលមានតម្រូវការបណ្តោះអាសន្ន" និង "នៅពេលដែលបានចុះនិងជូនដំណឹងពីកិច្ចព្រមព្រៀង 36 (Saburoku) (កិច្ចព្រម

ព្រៀងនិយោជិតនិយោជកផ្អែកតាមមាត្រា 36 នៃច្បាប់ស្តង់ដារការងារ)" ហើយត្រូវបង់ប្រាក់ថ្លៃឈ្នួលបន្ថែមតាមការកំណត់។ នៅពេលដែលមានតម្រូវការបណ្តោះអាសន្ន គឺសំដៅលើការងារសំណង់ស្តារគ្រោះមហន្តរាយ។ អត្រាបន្ថែមប្រាក់ឈ្នួល គឺ 25% ឡើងសម្រាប់ការបន្ថែមម៉ោងធម្មតា 35% ឡើងសម្រាប់ការធ្វើការថ្ងៃឈប់សម្រាក និង 25% ឡើងសម្រាប់ការថែមម៉ោងនៅយប់ជ្រៅ។

ពេលវេលាច្រើនបំផុតនៃម៉ោងបន្ថែមចំពោះការងារបន្ថែមម៉ោង គឺ 45ម៉ោងក្នុង 1ខែ និង 360 ម៉ោងក្នុង1ឆ្នាំ។ ការកំណត់នៃដែនកំណត់ខាងលើនេះនឹងចាប់ផ្តើមនៅខែមេសា ឆ្នាំ 2024 សម្រាប់វិស័យសំណង់ ប៉ុន្តែវាត្រូវបានផ្តល់អនុសាសន៍ឱ្យចាត់វិធានការមុនឆ្នាំ 2024 ដើម្បីទប់ស្កាត់ការប៉ះពាល់ដល់សុខភាពដោយសារតែធ្វើការច្រើនម៉ោង។

□ ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល

និយោជិតដែលបានធ្វើការបន្តជាប់រយៈពេល 6ខែគិតចាប់ពីថ្ងៃទទួលចូលធ្វើការ ហើយដែលបានធ្វើការ 80% ឡើងនៃថ្ងៃធ្វើការទាំងអស់ ត្រូវបានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួន10ថ្ងៃនៃថ្ងៃធ្វើការ ហើយបន្ថែមម្តង1ថ្ងៃនៃថ្ងៃធ្វើការនៅរាល់ពេលធ្វើការបន្តជាប់បាន 1ឆ្នាំ ហើយបន្ទាប់ពីកន្លងបានពី 2 ឆ្នាំនិង 6ខែ នឹងត្រូវផ្តល់បន្ថែមម្តង2ថ្ងៃនៃថ្ងៃធ្វើការ នៅរាល់ពេលធ្វើការបន្តជាប់បាន 1ឆ្នាំ ដោយចំនួនអតិបរមាគឺ 20ថ្ងៃនៃថ្ងៃធ្វើការ។

## 2.1.2 ច្បាប់ស្ដីពីសុវត្ថិភាពអនាម័យការងារ

### (1)ទិដ្ឋភាពទូទៅ

ជីវិត រាងកាយ និងសុខភាពគឺជារឿងសំខាន់បំផុតសម្រាប់និយោជិត ហើយ "ការធានាសុវត្ថិភាព និងសុខភាពរបស់និយោជិតនៅកន្លែងធ្វើការ" និង "ការបង្កើតបរិយាកាសការងារប្រកបដោយផាសុកភាព" ដើម្បីកុំឱ្យរងគ្រោះដោយសារការងារ គឺជាគោលបំណងនៃច្បាប់ស្ដីពីសុវត្ថិភាពអនាម័យការងារ។

### (2) ចំណុចសំខាន់

□ ទង់សុវត្ថិភាព ជាដើម

ផ្លាកសញ្ញា "សុវត្ថិភាពជាចំបង (Safety First)" និងទង់សុវត្ថិភាព និង ទង់សុវត្ថិភាពអនាម័យ ជាដើម ដែលបង្ហាញនៅការដ្ឋានសំណង់ត្រូវបានបង្ហាញក្នុងគោលបំណងដើម្បីឱ្យមានស្មារតីខ្ពស់លើការគ្រប់គ្រងសុវត្ថិភាពនិងការគ្រប់គ្រងអនាម័យ ហើយទន្ទឹមគ្នានេះសំដៅបំផុសស្មារតីប្រុងប្រយ័ត្នឆ្ពោះទៅ "គ្មានគ្រោះថ្នាក់ គ្មានគ្រោះមហន្តរាយ"។



ឧទាហរណ៍នៃទង់សុវត្ថិភាពអនាម័យ

□ ទំនួលខុសត្រូវរបស់និយោជិត

ដើម្បីទប់ស្កាត់គ្រោះថ្នាក់ការងារ និយោជិតត្រូវបានទាមទារឲ្យគោរពតាមប្រការចាំបាច់ និងសហការជាមួយវិធានការទប់ស្កាត់គ្រោះថ្នាក់ការងារដែលអនុវត្តដោយនិយោជកនិងភាគីពាក់ព័ន្ធផ្សេងទៀត។

□ ការអប់រំសុវត្ថិភាពអនាម័យ

ការអប់រំសុវត្ថិភាពអនាម័យត្រូវបានទាមទារជាចាំបាច់ នៅពេលដែលជួលនិយោជិតថ្មី ឬនៅពេលដែលខ្លឹមសារការងារត្រូវបានផ្លាស់ប្ដូរ។ លើសពីនេះទៀត ដើម្បីបញ្ជាម៉ាស៊ីនស្ទូច(crane)ជាដើម ការអប់រំពិសេសដូចជាការបណ្ដុះបណ្ដាលជំនាញគឺត្រូវបានទាមទារជាចាំបាច់។

□ មូលហេតុនៃគ្រោះថ្នាក់ការងារ

ក្នុងចំណោមគ្រោះថ្នាក់ការងារនៅក្នុងវិស័យសំណង់ បើក្រឡេកមើលចំនួនអ្នកស្លាប់នៅឆ្នាំ 2021 តាមមូលហេតុ ភាគច្រើនលើសលប់គឺ "ការធ្លាក់/ការរអិលធ្លាក់" ដែលមានចំនួន 110 ករណី ក្នុងចំណោម 288ករណី ហើយបន្ទាប់គឺ "ការបាក់រលំ/ការដួលរលំ" ដែលមានចំនួន 31ករណី "ការគាបជាប់/ការរមួលចូល" មានចំនួន 27ករណី "គ្រោះថ្នាក់ចរាចរណ៍(លើផ្លូវថ្នល់)" មានចំនួន 25ករណី និង "ការត្រូវបុកប៉ះ" មានចំនួន 19ករណី។

ជាពិសេសការងារនៅទីខ្ពស់ ចាំបាច់ត្រូវទប់ស្កាត់គ្រោះថ្នាក់ "ការធ្លាក់/ការរអិលធ្លាក់" ហើយឧបករណ៍ការពារការធ្លាក់ ជាគោលការណ៍គឺត្រូវប្រើប្រាស់ "ប្រភេទខ្សែក្រវាត់ពេញរាងកាយ"។

□ ការការពារជំងឺស្ត្រូកកម្ដៅ

នៅរដូវក្ដៅ ចាំបាច់ត្រូវផ្ដល់ម្លប់ ទឹក ស្កររគ្រាប់អំបិល ដើម្បីការពារជំងឺស្ត្រូកកម្ដៅ និងត្រៀមលក្ខណៈឆ្លើយតបបន្ទាន់។

□ ការវាយតម្លៃហានិភ័យ និងសកម្មភាព KY

ការវាយតម្លៃហានិភ័យ គឺជាវិធីសាស្ត្រសម្រាប់ស្វែងរកនិងលុបបំបាត់ហានិភ័យដែលបង្កប់ខ្លួននៅកន្លែងធ្វើការ។

នៅការដ្ឋានសំណង់ សកម្មភាពព្យាករណ៍គ្រោះថ្នាក់ ("សកម្មភាព KY") ត្រូវបានគេប្រើយ៉ាងទូលំទូលាយដើម្បីការពារគ្រោះថ្នាក់ដែលលាក់ខ្លួន ដោយកំណត់ហានិភ័យនៃភាពអាចកើតឡើងនៅការដ្ឋាន។

□ ការពិនិត្យសុខភាព

ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការពិនិត្យសុខភាពដល់បុគ្គលិក។ មាន "ការពិនិត្យសុខភាពទៀងទាត់" ដែលត្រូវធ្វើ1ដងក្នុង1ឆ្នាំ និងការពិនិត្យសុខភាពនៅពេលជួលបុគ្គលិកចូលជាដើម។

□ ការពិនិត្យស្ត្រេស

កន្លែងធ្វើការដែលមាននិយោជិតចាប់ពី 50 នាក់ឡើងទៅ ត្រូវបានតម្រូវជាកាតព្វកិច្ចឲ្យធ្វើការត្រួតពិនិត្យស្ត្រេសដោយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាសាធារណៈជាដើម 1ដងរៀងរាល់ឆ្នាំដើម្បីក្ដាប់ឲ្យបានកម្រិតនៃបន្ទុកផ្លូវចិត្តជាទៀងទាត់។

### 2.1.3 ច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា

**(1)ទិដ្ឋភាពទូទៅ**

ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ ធានាឱ្យមានស្ថិរភាពជីវភាពរបស់និយោជិត ការលើកកម្ពស់គុណភាពនៃកម្លាំងពលកម្ម និងការប្រកួតប្រជែងដោយយុត្តិធម៌ក្នុងអាជីវកម្ម។

**(2) ចំណុចសំខាន់**

□ ប្រាក់ឈ្នួលអប្បបរមាតាមតំបន់

ដោយសារតម្លៃទំនិញ និងកម្រិតប្រាក់ឈ្នួលរបស់និយោជិតជាដើមមានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយ ប្រាក់ឈ្នួលអប្បបរមាតាមតំបន់ដែលគិតតាមរាជធានីខេត្ត ត្រូវបានកំណត់។ ប្រាក់

ឈ្នួលអប្បបរមា ក្រៅពីត្រូវបានបោះពុម្ពផ្សាយក្នុងសារព័ត៌មានផ្លូវការរបស់រដ្ឋ ហើយក៏ត្រូវបានជូនដំណឹងនៅលើគេហទំព័រជាដើមនៃមន្ទីរការងារប្រចាំរាជធានីខេត្តនីមួយៗ។

### 2.1.4 ច្បាប់ធានារ៉ាប់រងសំណងគ្រោះថ្នាក់ការងារ (ធានារ៉ាប់រងគ្រោះថ្នាក់ការងារ)

**(1)ទិដ្ឋភាពទូទៅ**

ប្រសិនបើនិយោជិតរងរបួស ធ្លាក់ខ្លួនឈឺ ធ្លាក់ខ្លួនពិការ ឬស្លាប់ ដោយសារគ្រោះថ្នាក់ក្នុងការងារ ឬគ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ នោះធានារ៉ាប់រងគ្រោះថ្នាក់ការងារ នឹងផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងដល់ជនរងគ្រោះ ឬគ្រួសាររបស់សព។ រាល់ការចំណាយលើការព្យាបាលនៅមន្ទីរពេទ្យត្រូវបានបង់ដោយធានារ៉ាប់រងគ្រោះថ្នាក់ការងារ ហើយបុព្វលាភធានារ៉ាប់រងជាបន្ទុកទាំងស្រុងរបស់និយោជក។

ក្នុងករណីដែលមានគ្រោះថ្នាក់កើតឡើងជាយថាហេតុ ការជួយសង្គ្រោះជនរងគ្រោះត្រូវទុកជាអាទិភាពបន្ទាប់ពីបញ្ជាក់សុវត្ថិភាព។ ម្យ៉ាងទៀត ការវិនិច្ឆ័យថាតើឧបទ្ទវហេតុនោះជាគ្រោះថ្នាក់ការងារឬមិនមែន គឺធ្វើឡើងដោយការស៊ើបអង្កេតឧបទ្ទវហេតុដោយការិយាល័យអធិការកិច្ចស្តង់ដារការងារ។

**(2) ចំណុចសំខាន់**

□ គ្រោះថ្នាក់ដោយសារការងារ

គ្រោះថ្នាក់ដោយសារការងារ គឺជាគ្រោះថ្នាក់ដែល មានដើមហេតុកើតឡើងដោយសារសកម្មភាពក្នុងនាមជាការងាររបស់និយោជិតដែលរងគ្រោះ ឬដោយសារស្ថានភាពនៃការគ្រប់គ្រងគ្រឿងបរិក្ខារឧបករណ៍នៅកន្លែងធ្វើការ។

□ គ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ

គ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ គឺជាគ្រោះថ្នាក់កំលុងពេលធ្វើដំណើរទៅមករវាងលំនៅឋាននិងកន្លែងធ្វើការ ឬនៅពេលធ្វើដំណើរពីកន្លែងធ្វើការមួយទៅកន្លែងធ្វើការមួយទៀត។ ឧបទ្ទវហេតុដោយសារផ្លូវនិងវិធីសាស្ត្រធ្វើដំណើរដែលសមហេតុផល គឺជាលក្ខខណ្ឌចាំបាច់។ ប្រសិនបើអ្នកបានចុះឈ្មោះជាអ្នកប្រើប្រាស់ឡានក្រុង ប៉ុន្តែមានឧបទ្ទវហេតុពេលជិះកង់ជាដើម នោះនិងមិនត្រូវបានរាប់បញ្ចូលទេ។

### 2.1.5 ច្បាប់ស្តីពីធានារ៉ាប់រងការងារ

**(1)ទិដ្ឋភាពទូទៅ**

និយោជកដែលជួលនិយោជិតត្រូវមានកាតព្វកិច្ចចុះឈ្មោះក្នុងធានារ៉ាប់រងការងារ។ នៅពេលចុះឈ្មោះក្នុងការធានារ៉ាប់រងការងារ នោះ "ប័ណ្ណធានារ៉ាប់រងការងារ" នឹងត្រូវបានផ្តល់ជូនសាមីខ្លួន ។ ធានារ៉ាប់រងការងាររួមផ្សំដោយ "ការឧបត្ថម្ភពេលគ្មានការងារធ្វើជាដើម" និង "គម្រោង2នៃធានារ៉ាប់រងការងារ" ។

ការឧបត្ថម្ភពេលគ្មានការងារធ្វើ គឺជាប្រព័ន្ធដែលផ្តល់ការឧបត្ថម្ភ (ការទូទាត់) ដល់មនុស្សដែលបាត់បង់ការងារឬកំពុងទទួលការហ្វឹកហ្វឺនបណ្តុះបណ្តាលជាដើម។ បុព្វលាភធានារ៉ាប់រងត្រូវបានបង់ដោយនិយោជិតសាមីនិងនិយោជក។ **(2) ចំណុចសំខាន់**

□ លក្ខខណ្ឌតម្រូវនៃការផ្តល់អត្ថប្រយោជន៍នៃធានារ៉ាប់រងការងារ

(1) អ្នកត្រូវបានធានារ៉ាប់រងនៃធានារ៉ាប់រងការងារ(អ្នកដែលត្រូវបានធានារ៉ាប់រង) បានឃ្លាតចាកពីការងារហើយស្ថិតក្នុងភាព "គ្មានការងារធ្វើ" ដែលមិនអាចរកការងារធ្វើបានទោះបីមានឆន្ទៈនិងសមត្ថភាពធ្វើការក៏ដោយ។

(2) រយៈពេលដែលនៅជាអ្នកត្រូវបានធានារ៉ាប់រងសរុបចាប់ពី 12ខែឡើង ក្នុងរយៈពេល2ឆ្នាំមុនថ្ងៃឃ្លាតចាកពីការងារ។

## 2.1.6 ច្បាប់កែលម្អការងារនិយោជិតសំណង់

**(1)ទិដ្ឋភាពទូទៅ**

ដើម្បីកែលម្អបញ្ហាបរិយាកាសការងារនៃវិស័យសំណង់ "ផែនការកែលម្អការងារសំណង់" ត្រូវបានរៀបចំឡើង ហើយបានកំណត់ធាតុមូលដ្ឋាននៃវិធានការពាក់ព័ន្ធនឹង ការកែលម្អការងារ ការអភិវឌ្ឍនិងពង្រឹងសមត្ថភាព និងការលើកកម្ពស់សុខុមាលភាពជាដើមរបស់អ្នកធ្វើការក្នុងវិស័យសំណង់។

**(2) ផែនការកែលម្អការងារសំណង់**

·"ផែនការកែលម្អការងារសំណង់លើកទី10" ដែលមានរយៈពេលផែនការពីឆ្នាំ 2021 ដល់ឆ្នាំ 2025 មានខ្លឹមសារដូចតទៅ។

ខ្លឹមសារមានដូចខាងក្រោម។

□ ការធានាឲ្យបាននិងបណ្តុះបណ្តាលយុវជន

□ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដើម្បីបង្កើតបរិយាកាសការងារដ៏ទាក់ទាញ

□ជំរុញការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងការផ្ទេរបន្តជំនាញ

□ រៀបចំប្រព័ន្ធជំរុញការកែលម្អការងារ

□ ឆ្លើយតបទៅនឹងនិយោជិតបរទេស

### 2.1.7 ច្បាប់ជំរុញការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

**(1)ទិដ្ឋភាពទូទៅ**

ច្បាប់ជំរុញការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ គឺជាច្បាប់ដែលមានគោលបំណងលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់និយោជិតតាមរយៈការពង្រឹងខ្លឹមសារនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើតេស្តជំនាញ។ល។

**(2) ចំណុចសំខាន់**

▫ ការបណ្តុះបណ្តាលវិជ្ជាជីវៈ

ការបណ្តុះបណ្តាលវិជ្ជាជីវៈ សំដៅលើការបណ្តុះបណ្តាលដើម្បីអភិវឌ្ឍ និងលើកកម្ពស់សមត្ថភាពរបស់និយោជិត ដោយឱ្យពួកគេទទួលបានជំនាញ និងចំណេះដឹងចាំបាច់សម្រាប់ការងារ។ ក្ន

▫ តេស្តជំនាញ

តេស្តជំនាញគឺជាប្រព័ន្ធរបស់រដ្ឋដែលធ្វើតេស្តកម្រិតជំនាញដែលនិយោជិតមានហើយបញ្ជាក់ដោយរដ្ឋ។

## 2.2 ច្បាប់វិស័យសំណង់

ច្បាប់វិស័យសំណង់ គឺជាច្បាប់ដែលត្រូវបានបង្កើតឡើងដើម្បីចូលរួមចំណែកក្នុង "ការលើកកម្ពស់សុខុមាលភាពសាធារណៈ" ដោយសម្រេចឲ្យបាននូវគោលបំណងចំនួន5។

<u>គោលបំណងទាំង5</u>

1. ការកែលម្អគុណវុឌ្ឍិរបស់អ្នកគ្រប់គ្រងអាជីវកម្មសំណង់ (អាជ្ញាប័ណ្ណអាជីវកម្មសំណង់)
2. ការធ្វើឲ្យមានភាពត្រឹមត្រូវនៃកិច្ចសន្យាម៉ៅការការងារសំណង់ (ឯកសារប៉ាន់ស្មានតម្លៃ កិច្ចសន្យា)
3. ការធានាបានការអនុវត្តការងារសំណង់ដែលសមស្រប (វិស្វករបង្គោល/វិស្វករគ្រប់គ្រង)
4. ការការពារអតិថិជន (ភ្នាក់ងារតំណាងនៅការដ្ឋាន សៀវភៅបញ្ជីប្រព័ន្ធអនុវត្តការសាងសង់/ដ្យាក្រាមប្រព័ន្ធអនុវត្តការសាងសង់)
5. ការជំរុញការអភិវឌ្ឍដ៏ប្រសើរនៃវិស័យសំណង់

## 2.3 ច្បាប់ស្តីពីស្តង់ដារនៃការសាងសង់អគារ

វាគឺជាច្បាប់ដែលកំណត់វិធានអប្បបរមាដែលត្រូវតែគោរពនៅពេលសាងសង់ឬប្រើប្រាស់អគារ។ វាគឺជាច្បាប់ដែលអនុម័តក្នុងគោលបំណងឲ្យជីវភាពរស់នៅប្រកបដោយសុវត្ថិភាពនិងស្ងប់សុខដោយអនុវត្តតាមវិធានទាក់ទងនឹងការសាងសង់និងការប្រើប្រាស់អគារ។ ច្បាប់ស្តីពីស្តង់ដារនៃការ

សាងសង់អគារមាន2ផ្នែកគឺ "បទប្បញ្ញត្តិតែឯង" និង "បទប្បញ្ញត្តិរួម" ។
[បទប្បញ្ញត្តិតែឯង] ស្តង់ដារត្រូវបានបង្កើតឡើងសម្រាប់ សុវត្ថិភាពនិងភាពធន់នៃអគារខ្លួនឯង ភាពធន់នឹងការរញ្ជួយដី ការការពារអគ្គិភ័យ និងស្តង់ដារធន់នឹងការរញ្ជួយដី មុខងាររបស់ដំបូល និងជញ្ជាំងខាងក្រៅ ភ្លើងបំភ្លឺនិងខ្យល់ចេញចូលនៃបន្ទប់ទទួលភ្ញៀវ បង្គន់ និងបរិក្ខារអគ្គិសនី ។ល។
[បទប្បញ្ញត្តិរួម] គឺជាបទប្បញ្ញត្តិដើម្បី "ធានាបាននូវបរិស្ថានទីក្រុងដ៏ល្អ" នៅពេលដែលអគារត្រូវបានសាងសង់ប្រមូលផ្តុំ។ ជាឧទាហរណ៍ មានបទប្បញ្ញត្តិអំពី ស្តង់ដារពាក់ព័ន្ធនឹងដីឡូត៍និងផ្លូវថ្នល់ ផលធៀបផ្ទៃក្រឡាកម្រាលសំណង់ធៀបនឹងផ្ទៃដីឡូត៍ ផលធៀបផ្ទៃក្រឡាកម្រាលសំណង់សរុបធៀបនឹងផ្ទៃដីឡូត៍ កម្រិតកំណត់កម្ពស់ កម្រិតកំណត់ខ្សែទ្រេតផ្សេងៗ និងតំបន់ការពារអគ្គីភ័យជាដើម។ ជាគោលការណ៍ វាត្រូវបានអនុវត្តនៅក្នុងតំបន់ផែនការទីក្រុង និងតំបន់ផែនការត្រៀមបង្កើតជាទីក្រុង។

## 2.4 ច្បាប់ប្រព្រឹត្តកម្មកាកសំណល់

វាគឺជាច្បាប់ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារបរិស្ថានរស់នៅរបស់ប្រជាជនតាមរយៈប្រព្រឹត្តកម្ម
សមស្របនូវកាកសំណល់ដែលកើតមានដូចជាការកែច្នៃឡើងវិញជាដើម ខណៈដែលគ្រប់គ្រងការបញ្ចេញកាកសំណល់។
នៅឯការដ្ឋានសំណង់ មានអ្នកម៉ៅការចេញនិងចូលច្រើន ហើយបង្កើតឲ្យមានកាកសំណល់ដែលត្រូវបោះចោលនៅក្នុងការងារសំណង់រៀងៗខ្លួន។
អ្នកម៉ៅការផ្ទាល់មានកាតព្វកិច្ចបង្កើត "បញ្ជីរាយការណ៍ (សន្លឹកគ្រប់គ្រងកាកសំណល់សំណង់)" ទាក់ទងនឹងប្រព្រឹត្តកម្មកាកសំណល់ឧស្សាហកម្ម ដើម្បីពិនិត្យបញ្ជាក់ដំណាក់ជាស៊េរីរហូតដល់កាកសំណល់ត្រូវបានធ្វើចំណាត់ការចុងក្រោយដោយត្រឹមត្រូវ។ ចំណាត់ការចុងក្រោយក៏រួមទាំងការកែច្នៃឡើងវិញផងដែរ។ អ្នកដែលធ្វើការនៅការដ្ឋានត្រូវតែចាត់ចែងកាកសំណល់ដោយអនុលោមតាមបញ្ជីរាយការណ៍នេះ។

## 2.5 ច្បាប់កែច្នៃឡើងវិញនៃសំណង់

ច្បាប់កែច្នៃឡើងវិញនៃសំណង់គឺជាច្បាប់ដែលជំរុញប្រព្រឹត្តកម្មសមស្របនិងការបំប្លែងជាធនធានឡើងវិញនូវវត្ថុធាតុសំណល់។ ច្បាប់កែច្នៃឡើងវិញនៃសំណង់តម្រូវឱ្យបែងចែកកាកសំណល់សំណង់តាមសម្ភារដើម្បីជំរុញការបំប្លែងជាធនធានឡើងវិញនិងប្រើប្រាស់ឡើងវិញ។ កាកសំណល់ដែលកើតឡើងនៅការដ្ឋានសំណង់ត្រូវតែរក្សាទុកក្នុង

ទីតាំងដែលបានកំណត់ដោយស្របទៅតាមវិធីសាស្ត្រចាត់ថ្នាក់ដែលបានកំណត់នៅការដ្ឋាន។

## 2.6 ច្បាប់ទប់ស្កាត់ការបំពុលខ្យល់

ច្បាប់ទប់ស្កាត់ការបំពុលខ្យល់ កំណត់ស្តង់ដារបញ្ចេញចោលជាដើមចំពោះសារធាតុបំពុលខ្យល់ដែលបញ្ចេញឬសាយភាយពីរោងចក្រនិងការដ្ឋាន ទៅតាមប្រភេទសារធាតុ និងទៅតាមប្រភេទនិងទំហំបរិក្ខារ។

## 2.7 ច្បាប់ដាក់កម្រិតលើសំឡេងរំខាន / ច្បាប់ការពាររំញ័រ

នេះគឺជាច្បាប់ដែលមានគោលបំណងដើម្បីការពារសុខភាពនិងការពារបរិស្ថានរស់នៅរបស់ប្រជាពលរដ្ឋ ដោយធ្វើការដាក់កម្រិតចាំបាច់ចំពោះសំឡេងរំខាននិងរំញ័រដែលកើតឡើងដោយរោងចក្រនិងការងារសំណង់ និងដោយការកំណត់កម្រិតកំណត់អនុញ្ញាតសម្រាប់សំឡេងរំខានរបស់រថយន្ត។ ក្នុងការរចនាការងារសំណង់ ត្រូវតែស្រាវជ្រាវអំពីលក្ខខណ្ឌទីតាំងជុំវិញការដ្ឋានសំណង់ ហើយពិចារណាលើធាតុ ដើម្បីកាត់បន្ថយសំឡេងរំខាន និងរំញ័រទាំងមូល។

## 2.8 ច្បាប់ទប់ស្កាត់ការបំពុលទឹក

នេះគឺជាច្បាប់ដែលត្រូវបានអនុម័តដើម្បីទប់ស្កាត់ការបំពុលទឹកនៃតំបន់ទឹកសាធារណៈ និងទឹកក្រោមដី។ នៅពេលបញ្ចេញទឹកកខ្វក់ដែលបង្កើតចេញពីការដ្ឋានសំណង់ចូលទៅក្នុងប្រព័ន្ធលូឬស្ទឹងទន្លេ ត្រូវតែអនុវត្តតាមស្តង់ដារដែលកំណត់ដោយរាជធានីខេត្តនីមួយៗ។

## 2.9 ច្បាប់ការពារអគ្គីភ័យ

ច្បាប់ការពារអគ្គីភ័យ គឺជាច្បាប់ដែលមានគោលបំណងដូចតទៅ។

1. បង្ការ ប្រកាសអាសន្ន និងពន្លត់អគ្គីភ័យ ដើម្បីការពារអាយុជីវិត រាងកាយ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋពីអគ្គីភ័យ។
2. កាត់បន្ថយការខូចខាតដែលបណ្តាលមកពីគ្រោះមហន្តរាយដូចជាអគ្គីភ័យ ឬរញ្ជួយដី។ល។
3. រក្សាសណ្តាប់ធ្នាប់និងរួមចំណែកលើកកម្ពស់សុខុមាលភាពសាធារណៈ ដោយការដឹកជញ្ជូនអ្នកជំងឺនិងរបួសដោយសារគ្រោះមហន្តរាយជាដើមឱ្យបានត្រឹមត្រូវ។

នៅក្នុងអគារ បទប្បញ្ញត្តិត្រូវបានចែងចំពោះបរិក្ខារពន្លត់អគ្គីភ័យដូចជា បំពង់ពន្លត់អគ្គីភ័យ បង្គោលទឹកអគ្គីភ័យក្នុងអគារ ឧបករណ៍បាចសាចទឹកជាដើម ឧបករណ៍ជម្លៀសដូចជាជណ្តើរ

ជម្លៀសជាដើម បរិក្ខារសម្រាប់ការពារអគ្គីភ័យដូចជាបរិក្ខារប្រកាសអាសន្នជាដើម ដើម្បីបង្ការ អគ្គីភ័យ ផ្តល់ដំណឹងពីអគ្គីភ័យ ពន្លត់និងជួយសង្គ្រោះ។

## 2.10 ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត

ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត គឺជាច្បាប់ដែលចែងអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ ច្បាប់នេះត្រូវបានអនុម័តដោយមានគោលបំណងលើកកម្ពស់សុខភាពសាធារណៈនិងធ្វើឲ្យបរិស្ថានរស់នៅប្រសើរឡើងតាមរយៈការផ្គត់ផ្គង់ទឹកដែលស្អាត សំបូរនិងមានតម្លៃថោក។ ហេតុដូចនេះ ត្រូវតែដាក់ឲ្យមានវិស្វករ/អ្នកជំនាញដែលកំណត់ដោយច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាត ហើយត្រូវធ្វើការងារក្រោមការណែនាំរបស់ពួកគេ។

## 2.11 ច្បាប់ស្តីពីប្រព័ន្ធលូ

ច្បាប់ស្តីពីប្រព័ន្ធលូ គឺជាច្បាប់ដែលមានគោលបំណងរៀបចំប្រព័ន្ធលូសំដៅអភិវឌ្ឍទីក្រុងដ៏ប្រសើរ លើកកម្ពស់អនាម័យសាធារណៈ និងការពារគុណភាពទឹកក្នុងតំបន់ទឹកសាធារណៈ។ មានទឹកកាកសំណល់ដែលត្រូវបានហាមមិនឲ្យបង្ហូរចូលទៅក្នុងប្រព័ន្ធលូសាធារណៈ។ មិនត្រូវបង្ហូរទឹកដែលមានកំហាប់អ៊ីយ៉ុងអ៊ីដ្រូសែន សារធាតុរឹងអណ្តែតក្នុងទឹក កាត់ម្ញូម សំណ ក្រូមសរុប ទង់ដែង ស័ង្កសី ជាដើមដែលលើសពីតម្លៃស្តង់ដារ។

## 2.12 ច្បាប់ស្តីពីអាជីវកម្មហ្គាស

ច្បាប់ស្តីពីអាជីវកម្មហ្គាស គឺជាច្បាប់ពាក់ព័ន្ធនិងអាជីវកម្មហ្គាសទីក្រុងដែលផ្គត់ផ្គង់ហ្គាសតាមបំពង់ ដែលកំណត់បទប្បញ្ញត្តិលើប្រតិបត្តិករក្នុងគោលបំណងធានាសុវត្ថិភាពនិងការពារអ្នកប្រើប្រាស់ហ្គាស។ ការលេចធ្លាយឧស្ម័ន និងខ្យល់ចេញចូលមិនសមស្រប អាចនាំឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដូច្នេះនៅពេលប្រើប្រាស់ហ្គាស មានបទប្បញ្ញត្តិលម្អិតទាក់ទងនឹងម៉ាស៊ីនឧបករណ៍ដែលប្រើការបំភាយជាដើម។

## 2.13 ច្បាប់ស្តីពីអាជីវកម្មអគ្គិសនី

ការគ្រប់គ្រងចរន្តអគ្គិសនីមិនត្រឹមត្រូវអាចនាំឱ្យមានអគ្គីភ័យ ខូចខាងបរិក្ខារ គ្រោះថ្នាក់ដល់មនុស្ស។ ជាឧទាហរណ៍ ការលេចធ្លាយអគ្គិសនីនាំឱ្យកើតមានគ្រោះមហន្តរាយធ្ងន់ធ្ងរ ដូចជាអគ្គីភ័យ

ការឆក់ខ្សែភ្លើងជាដើម។ ច្បាប់ស្តីពីអាជីវកម្មអគ្គិសនី មានគោលបំណងដើម្បីធានាសុវត្ថិភាព សាធារណៈនិងការពារបរិស្ថាន តាមរយៈការបង្កើតស្តង់ដារសម្រាប់ប្រតិបត្តិការត្រឹមត្រូវនិង សមហេតុផលនៃការគ្រប់គ្រងអាជីវកម្មអគ្គិសនី ការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់អគ្គិសនី ហើយទន្ទឹមគ្នានេះដាក់កំណត់លើការងារសាងសង់ដំឡើង ការថែទាំ និងប្រតិបត្តិការនៃបរិក្ខារ អគ្គិសនី។ ម្យ៉ាងទៀត ក្រៅពីច្បាប់ស្តីពីអាជីវកម្មអគ្គិសនី ច្បាប់បទប្បញ្ញត្តិទាក់ទងនឹងការរក្សា សុវត្ថិភាពនៃបរិក្ខារអគ្គិសនីរួមមាន ប្រកាសដែលកំណត់ស្តង់ដារបច្ចេកទេសសម្រាប់បរិក្ខារអគ្គិសនី ច្បាប់ស្តីពីសុវត្ថិភាពគ្រឿងឧបករណ៍សម្រាប់អគ្គិសនី ច្បាប់ស្តីពីអ្នកបច្ចេកទេសអគ្គិសនី និងច្បាប់ ស្តីពីការធានាភាពត្រឹមត្រូវនៃការងារក្នុងអាជីវកម្មការងារសំណង់អគ្គិសនី ជាដើម។

## 2.14 ច្បាប់ស្តីពីអាជីវកម្មទូរគមនាគមន៍

ច្បាប់ស្តីពីអាជីវកម្មទូរគមនាគមន៍ គឺជាច្បាប់ដែលកំណត់បទប្បញ្ញត្តិចំពោះអាជីវកម្ម ទូរគមនាគមន៍ដែលដំឡើងបរិក្ខារដូចជាខ្សែជាដើមហើយផ្តល់សេវាទូរគមនាគមន៍ដល់អ្នក ចុះឈ្មោះប្រើប្រាស់។ ច្បាប់ស្តីពីអាជីវកម្មទូរគមនាគមន៍ត្រូវបានអនុវត្ត មិនត្រឹមតែលើការទំនាក់ ទំនងដោយមានខ្សែដែលបញ្ជូនសញ្ញាទៅខ្សែលោហៈប៉ុណ្ណោះទេ វាក៏អនុវត្តចំពោះការទំនាក់ទំនង ឥតខ្សែ និងការទំនាក់ទំនងតាមខ្សែកាបអុបទិកផងដែរ។ បើអនុវត្តការងារសំណង់មិនត្រឹមត្រូវ នៅពេលភ្ជាប់ឧបករណ៍អេឡិចត្រូនិចដូចជា ទូរសព្ទ ឬកុំព្យូទ័រទៅកាន់ខ្សែបណ្តាញរបស់ប្រតិបត្តិករ ទូរគមនាគមន៍ នោះវាអាចបណ្តាលឲ្យខូចខាតខ្សែបណ្តាញ។ ហេតុដូចនេះ វាជាកាតព្វកិច្ចដែលត្រូវ អនុវត្តនិងគ្រប់គ្រងការងារសំណង់ដោយវិស្វករដែលមាន "គុណវុឌ្ឍិអ្នកជំនាញដំឡើង" ។

## 2.15 ច្បាប់ស្តីពីរលកវិទ្យុ

ច្បាប់ស្តីពីរលកវិទ្យុមានគោលបំណងលើកកម្ពស់សុខុមាលភាពសាធារណៈ ដោយធានានូវការប្រើ ប្រាស់រលកវិទ្យុដោយយុត្តិធម៌និងប្រកបដោយប្រសិទ្ធផលខ្ពស់។ ការប្រើប្រាស់ឧបករណ៍បញ្ជូនសញ្ញា តម្រូវឱ្យមានអាជ្ញាប័ណ្ណអាស្រ័យលើធាតុចេញនៃរលកវិទ្យុ និងប្រេកង់ដែលប្រើ។ ការប្រើប្រាស់ ឧបករណ៍ផ្ញើនិងបញ្ជូន(Transceivers)ដែលត្រូវការអាជ្ញាប័ណ្ណដោយគ្មានអាជ្ញាប័ណ្ណគឺជាអំពើខុស ច្បាប់។ ម្យ៉ាងទៀត ការប្រើប្រាស់ឧបករណ៍ផ្ញើនិងបញ្ជូន(Transceivers) ដែលជាផលិតផលបរទេស ក៏ ជាអំពើខុសច្បាប់ផងដែរ ប្រសិនបើមិនត្រូវបានទទួលស្គាល់នៅក្នុងប្រទេសជប៉ុន។ នៅការដ្ឋាន សំណង់សាធារណៈ និងការដ្ឋានសំណង់ធំៗ ដែលប្រើប្រាស់ឧបករណ៍បញ្ជូនសញ្ញា ចាំបាច់ត្រូវគោរព តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងរលកវិទ្យុ។

## 2.16 ច្បាប់អាកាសចរណ៍

ច្បាប់អាកាសចរណ៍ គឺជាច្បាប់ដែលចែងអំពីវិធីសាស្ត្រសម្រាប់ធានាសុវត្ថិភាពនៃការធ្វើដំណើររបស់យន្តហោះ និងការការពារការខូចខាតដែលបណ្តាលមកពីការធ្វើដំណើររបស់យន្តហោះ។ អាស្រ័យលើកម្ពស់អគារនិងគ្រឿងចក្រសំណង់ដូចជាម៉ាស៊ីនស្ទូច(crane)ជាដើម វាអាចក្លាយជាឧបសគ្គរារាំងដល់ការធ្វើដំណើរដោយសុវត្ថិភាពរបស់យន្តហោះ។ អគារដែលមានកម្ពស់ 60m ឬខ្ពស់ជាងនេះពីលើផ្ទៃដីឬផ្ទៃទឹក ត្រូវតែដំឡើងអំពូលសញ្ញាព្រមានដល់អាកាសចរណ៍។

ថ្មីៗនេះ យន្តហោះគ្មានមនុស្សបើក (ដ្រូន) ត្រូវបានប្រើប្រាស់សម្រាប់ការវាស់វែងក្នុងការងារសំណង់។ ដ្រូនដែលមានទម្ងន់ 100ក្រាមឡើង ត្រូវមានកាតព្វកិច្ចចុះបញ្ជីជាយន្តហោះគ្មានមនុស្សបើក។

## 2.17 ច្បាប់ស្តីពីចំណតរថយន្ត

ច្បាប់ស្តីពីចំណតរថយន្ត គឺជាច្បាប់ដែលកំណត់ពាក់ព័ន្ធនឹងការរៀបចំបរិក្ខារសម្រាប់ចតរថយន្តនៅក្នុងទីក្រុង។ គោលបំណងគឺសំដៅធ្វើឲ្យចរាចរណ៍តាមដងផ្លូវប្រព្រឹត្តទៅរលូនដែលរួមចំណែកដល់ភាពងាយស្រួលរបស់សាធារណជន ហើយទន្ទឹមគ្នានេះចូលរួមចំណែកក្នុងការថែរក្សានិងលើកកម្ពស់មុខងាររបស់ទីក្រុង តាមរយៈការកំណត់ធាតុចាំបាច់សម្រាប់ឧបករណ៍បរិក្ខារចំណតរថយន្ត។ ប្រសិនបើអនុវត្តការសាងសង់ចំណតរថយន្ត ចាំបាច់ត្រូវជូនដំណឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិមុននឹងចាប់ផ្តើមការសាងសង់។

# មេរៀនទី 3  ប្រភេទនិងប្រតិបត្តិការការងារនៃការងារសំណង់

## 3.1 ប្រភេទនៃការងារសំណង់

### 3.1.1 ការងារសំណង់ស៊ីវិល

**[ការសាងសង់ទំនប់អាងទឹក]** ទំនប់អាងទឹកត្រូវបានសាងសង់ដើម្បីលៃតម្រូវបរិមាណទឹកដែលហូរទៅស្ទឹងទន្លេ។ ទំនប់ទឹកមានគោលបំណង 2 គឺ "ការគ្រប់គ្រងទឹក" និង "ការប្រើប្រាស់ទឹក"។ ចំពោះការគ្រប់គ្រងទឹក ទឹកត្រូវបានរក្សាទុក ហើយលៃតម្រូវបរិមាណទឹកដែលហូរចូលទន្លេដើម្បីកុំឱ្យទឹកទន្លេជន់ជោរបង្កឲ្យមានទឹកជំនន់ពេលភ្លៀងធ្លាក់ខ្លាំង។ ចំពោះការប្រើប្រាស់ទឹក មានតួនាទីលៃតម្រូវបរិមាណទឹកដែលអាចប្រើប្រាស់ទឹកដោយស្ថិរភាពក្នុងកសិកម្មនិងឧស្សាហកម្ម។


ទំនប់អាងទឹក

**[ការសាងសង់នៅមាត់ស្ទឹងទន្លេ/សមុទ្រ]** ការសាងសង់ផ្សេងៗចំពោះស្ទឹងទន្លេ សមុទ្រ។ ការសាងសង់ដូចជា ទំនប់ការពាររលក ទំនប់ការពារជំនោរសមុទ្រ ខឿនច្រាំងស្ទឹងទន្លេ ទំនប់ទឹកជំនន់ និងផ្លូវទឹកជាដើម ត្រូវបានធ្វើឡើង។ លើសពីនេះ ដើម្បីអភិរក្សបរិស្ថានធម្មជាតិ ការអភិរក្សនិងបង្កើតបរិស្ថានស្ទឹងទន្លេដែលគិតគូរដល់សត្វនិងរុក្ខជាតិជាដើមក៏ត្រូវបានធ្វើឡើងផងដែរ។


ទំនប់ការពាររលក


ទំនប់ការពារជំនោរសមុទ្រ

**[ការសាងសង់ផ្លូវថ្នល់]** ការសាងសង់ដែលកសាងផ្លូវថ្នល់សម្រាប់មនុស្ស និងយានជំនិះឆ្លងកាត់។ ការសាងសង់ឯកទេសផ្សេងៗត្រូវបានធ្វើឡើងមិនមែនត្រឹមតែក្រាលផ្ទៃលើដោយកៅស៊ូនិងស៊ីម៉ងត៍ប៉ុណ្ណោះទេ។ ឧទាហរណ៍ ដូចជាការដំឡើងស្លាកសញ្ញានិងគំនូសសញ្ញាចរាចរណ៍ ការដំឡើងភ្លើងសញ្ញានិងភ្លើងបំភ្លឺផ្លូវនិងការសាងសង់ខាងអគ្គិសនីដែលចាំបាច់សម្រាប់ការដំឡើងនេះ ការបង្កើតសួននិងការដាំរុក្ខ/ឥដ្ឋបេតុងដើម្បីរៀបចំទេសភាព ការសាងសង់ផ្លូវថ្មើរជើង ការដាក់គូសគំនូសពណ៌សលើផ្ទៃផ្លូវ។ល។


ការសាងសង់ផ្លូវថ្នល់

**[ការសាងសង់ផ្លូវរូង]** ផ្លូវរូងត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ផ្លូវដែក ផ្លូវថ្នល់ ផ្លូវទឹក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ផ្លូវរូងក្រោមដីមានបួនប្រភេទ៖ វិធីសាស្ត្រជីកផ្លូវរូងភ្នំ វិធីសាស្ត្រជីកផ្លូវរូងជីកបើកចំហ វិធីសាស្ត្រជីកផ្លូវរូងរបាំង(Shield Tunnel) និងវិធីសាស្ត្រជីកផ្លូវរូងរុញទៅមុខ។


ការសាងសង់ផ្លូវរូង

**[វិធីសាស្ត្រជីកផ្លូវរូងភ្នំ]** វិធីសាស្ត្រជីកផ្លូវរូងភ្នំជាវិធីសាស្ត្រសាងសង់ផ្លូវរូងដែលភាគច្រើនធ្វើការជីកផ្ទាំងថ្មរឹងនៅតំបន់ភ្នំ។ គេជីកដោយបំផ្ទុះឬប្រើគ្រឿងចក្រជីកជាដើម ហើយប្រើប្រាស់វិធីសាស្ត្រម្យ៉ាងហៅថា NATM ដើម្បីទប់ទ្រផ្លូវរូងដោយដំឡើងបេតុងបាញ់ពាស សំណង់ទប់ធ្វើពីដែកនិង

ប៊ូឡុងទម្លុះថ្ម(rock bolt) លើផ្ទៃដែលបានជីក។







**[វិធីសាស្ត្រជីកផ្លូវរូងជីកបើកចំហ]** វិធីសាស្ត្រជីកផ្លូវរូងជីកបើកចំហគឺជីកពីផ្ទៃដីខាងលើដោយការពារការបាក់ដីធម្មជាតិដោយប្រើសំណង់ទប់ដី។ គេហៅវាថាវិធីសាស្ត្រជីកបើកចំហ។ គេសាងសង់ផ្លូវរូងនៅទីចំហដែលបានជីក។ វិធីសាស្ត្រនេះធ្វើការលុបដីវិញនៅកន្លែងដែលក្រៅពីផ្លូវរូងក្រោយ

ពេលសាងសង់ផ្លូវរូងរួច។

**[វិធីសាស្ត្រជីកផ្លូវរូងរបាំង (Shield Tunnel)]** វិធីសាស្ត្រជីកផ្លូវរូងរបាំង(Shield Tunnel) ជាវិធីសាស្ត្រដែលជីកផ្លូវរូងដោយប្រើម៉ាស៊ីនជីកផ្លូវរូងទៅមុខសម្រាប់ការជីកផ្លូវរូងដែលគេហៅថា ម៉ាស៊ីនរបាំង (Shield Machine) ។ វិធីនេះក៏អាចអនុវត្តនៅដីទន់បានដែរ ហើយទោះបីមានសំណង់ស្រាប់នៅពីលើផ្ទាល់ក៏ដោយ ក៏អាចអនុវត្តបានដែរ។

**[វិធីសាស្ត្រជីកផ្លូវរូងរុញទៅមុខ]** វិធីសាស្ត្រជីកផ្លូវរូងរុញទៅមុខជាវិធីសាស្ត្រសាងសង់ផ្លូវរូងដោយបំពាក់ម៉ាស៊ីនជីកទៅមុខ ក្បាលនាំមុខឬផ្លែកាំបិត នៅខាងចុងនៃបំពង់រុញទៅមុខដែលផលិតនៅរោងចក្រ ហើយរុញបញ្ចូលបំពង់រុញទៅមុខទៅក្នុងដីដោយកម្លាំងរុញជាដើមរបស់ម៉ាស៊ីនរុញ (jack) នៅរណ្ដៅចាប់ផ្ដើម ចន្លោះពីរណ្ដៅចាប់ផ្ដើមទៅរណ្ដៅបញ្ចប់។ ត្រូវបានប្រើជាចម្បងជាបំពង់សម្រាប់ហេដ្ឋារចនា
សម្ព័ន្ធសង្គម(ប្រព័ន្ធលូ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ទូរគមនាគមន៍ ហ្គាសជាដើម) នៅតំបន់ទីក្រុង។

**[ការសាងសង់ស្ពាន]** សំណង់ជាផ្លូវឆ្លងកាត់ដើម្បីឆ្លងសមុទ្រ ទន្លេ គឺហៅថា "ស្ពាន"។ ការសាងសង់ត្រូវបានអនុវត្តជាពីរដំណាក់កាលគឺ "ការសាងសង់រចនាសម្ព័ន្ធខាងក្រោម" និង "ការសាងសង់រចនាសម្ព័ន្ធខាងលើ" ។ នៅក្នុងការសាងសង់រចនាសម្ព័ន្ធខាងក្រោម គឺសាងសង់គ្រឹះដែលទ្រស្ពាន។


ការសាងសង់ស្ពាន

**[ការងារសំណង់ស៊ីវិលសមុទ្រ]** ការងារសំណង់ដែលសាងសង់បរិក្ខារដូចជាកំពង់ផែ និងអាកាសយានដ្ឋានជាដើមនៅលើសមុទ្រ ទន្លេ ត្រូវបានហៅថា "ការងារសំណង់ស៊ីវិលសមុទ្រ" ។ គេសាងសង់បរិក្ខារកំពង់ផែ ដូចជា ផែសម្រាប់នាវាចត ទំនប់ការពាររលក ផ្លូវនាវាចរណ៍ដើម្បីឲ្យនាវាឆ្លងកាត់ដោយសុវត្ថិភាព ដីចាក់លុបសមុទ្រសម្រាប់សង់រោងចក្រជាដើម និងផ្លូវរូងបាតសមុទ្រ ស្ពានកាត់សមុទ្រ និងសំណង់នៅសមុទ្រផ្សេងទៀតដូចជាប៉មផលិតថាមពលអគ្គិសនីដោយកម្លាំងខ្យល់ជាដើម។


ការងារសំណង់ទំនប់ការពាររលក

ដោយសារបរិក្ខារនិងសំណង់នៃសំណង់ស៊ីវិលសមុទ្រមានទំហំធំខ្លាំង ការងារសំណង់ត្រូវបានអនុវត្តដោយប្រើម៉ាស៊ីនខ្នាតធំហៅថា "នាវាសម្រាប់ការងារសំណង់" ដែលអាចជីកបាតសមុទ្រ ឬស្ទូចយោងវត្ថុធ្ងន់ៗបានដោយ

នាវា។ ម្យ៉ាងទៀត លក្ខណៈពិសេសនៃការងារសំណង់ស៊ីវិលសមុទ្រគឺការប្រើប្រាស់ឧបករណ៍វាស់វែងដើម្បីវាស់ទ្រង់ទ្រាយបាតសមុទ្រ ការប្រើមនុស្សដែលអាចធ្វើការងារក្នុងសមុទ្រដែលគេហៅថា "អ្នកជ្រមុជទឹក"។


អ្នកជ្រមុជទឹក

**[ការងារសំណង់ផ្លូវដែក]** ការងារសំណង់ផ្លូវដែកជាការងារសំណង់ដែលបញ្ចូបដោយការចូលរួមពាក់ព័ន្ធនៃការងារសំណង់ឯកទេសស្ទើរតែទាំងអស់ដែលពាក់ព័ន្ធនឹងការសាងសង់ដូចជា ការងារសំណង់បរិក្ខារអគ្គិសនីនិងការងារសំណង់អគារ មិនត្រឹមតែការងារសំណង់ស៊ីវិលប៉ុណ្ណោះទេ។

**[ការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ]** ការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូមាន ការងារសំណង់ស៊ីវិល ការងារបរិក្ខារផ្គត់ផ្គង់ទឹក និងការងាររត់បំពង់លូ។ ការងារសំណង់ស៊ីវិលគឺអនុវត្តការងារសាងសង់ដូចជាការរៀបចំដីឡត៍ជាដើមសម្រាប់បរិក្ខារប្រព្រឹត្តកម្មទឹកស្អាតនិងរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់។


ការងារប្រព័ន្ធលូ

**[ការងារសំណង់ស្ដារគ្រោះមហន្តរាយ]** នៅប្រទេសជប៉ុនរៀងរាល់ឆ្នាំបរិក្ខារសំណង់ស៊ីវិលដូចជាផ្លូវថ្នល់និងស្ទឹងទន្លេជាដើម រងគ្រោះដោយគ្រោះធម្មជាតិដូចជាព្យុះទីហ្វុង ភ្លៀងធ្លាក់ខ្លាំង និងការរញ្ជួយដី។ល។ នេះជាការងារសំណង់ស្ដារបរិក្ខារដែលរងគ្រោះឲ្យបានឆាប់រហ័ស។ វាសម្រាប់បរិក្ខារសំណង់ស៊ីវិលសាធារណៈផ្សេងៗ ដូចជា ស្ទឹងទន្លេ ឆ្នេរសមុទ្រ បរិក្ខារការពារសំណឹក ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ។


ការងារសំណង់ស្ដារគ្រោះមហន្តរាយ

**[ការងារសំណង់ស៊ីវិលក្រៅពីនេះ]** ក្រៅពីនេះ មានការងារសាងសង់ព្រលានយន្តហោះ ការងាររៀបចំបែងចែកដីឡើងវិញ ការងារសំណង់ស៊ីវិលកសិកម្ម ការងារសំណង់ការពារសំណឹក និងការងារសំណង់ស៊ីវិលព្រៃឈើ។ល។


ការងារសាងសង់ព្រលានយន្តហោះ

### 3.1.2 ការងារសំណង់អគារ

ការងារសាងសង់អគារ គឺហៅថាការងារសំណង់អគារ។

សំណង់អាចបែងចែកតាមរចនាសម្ព័ន្ធជា "រចនាសម្ព័ន្ធបេតុងសរសៃដែក" "រចនាសម្ព័ន្ធធ្នឹងដែក" "រចនាសម្ព័ន្ធបេតុងសរសៃដែកនិងធ្នឹងដែក(SRC)" "រចនាសម្ព័ន្ធឈើ" "រចនាសម្ព័ន្ធឥដ្ឋបេតុង"។ល។

អគារ "រចនាសម្ព័ន្ធបេតុងសរសៃដែក" មានរចនាសម្ព័ន្ធដែលចាក់បេតុងចូលពុម្ពដែលរៀបសរសៃដែកហើយធ្វើឲ្យរឹង។ អគារ "រចនាសម្ព័ន្ធធ្នឹងដែក" មានរចនាសម្ព័ន្ធដែលប្រើធ្នឹងដែកនៅសសរនិងធ្នឹម។ ទាំងពីរនេះខុសគ្នាត្រង់ថាប្រើសរសៃដែកឬប្រើធ្នឹងដែក ប៉ុន្តែរចនាសម្ព័ន្ធដែលប្រើទាំងពីរគឺ "រចនាសម្ព័ន្ធបេតុងសរសៃដែកនិងធ្នឹងដែក(SRC)"។ គេរៀបសរសៃដែកនៅជុំវិញធ្នឹងដែកហើយចាក់បេតុងចូលដើម្បីសាងសង់អគារ។ "រចនាសម្ព័ន្ធឈើ" ជារចនាសម្ព័ន្ធដែលត្រូវបានប្រើច្រើននៅលំនៅដ្ឋានទូទៅហើយជារចនាសម្ព័ន្ធនៃអគារដែលប្រើឈើនៅសសរនិងធ្នឹម។ ក្នុង "រចនាសម្ព័ន្ធឥដ្ឋបេតុង" ឥដ្ឋបេតុងត្រូវបានរៀបបង្គរឡើងខណៈដែលស៊កសរសៃដែកតាមប្រហោងឥដ្ឋបេតុងហើយពង្រឹងដោយបាយអជាដើម។

ការងារសំណង់អគារខ្នាតធំបើប្រៀបធៀបទៅដូចជា អគារ ខុនដូជាដើម ត្រូវបានអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម។

**[ការងាររៀបចំត្រៀម]** ហ៊ុមព័ទ្ធជុំវិញដីឡូត៍ដែលត្រូវសាងសង់អគារ ហើយសាងសង់បណ្ដោះអាសន្ននូវទីស្នាក់ការសម្រាប់ការងារសំណង់ និងកន្លែងសម្រាកសម្រាប់អ្នកអនុវត្តការងារសំណង់។ម្យ៉ាងទៀត ការងារអគ្គិសនីសម្រាប់ការងារសំណង់ និងការងារបរិក្ខារផ្គត់ផ្គង់ទឹកនិងបញ្ចេញចោលទឹក ក៏ត្រូវបានអនុវត្តផងដែរ។

នៅកន្លែងដែលត្រូវសង់អគារ ត្រូវអនុវត្តការអង្កេតដី(អង្កេតដោយជីកខួង) ហើយសិក្សាស្រទាប់ដែលទ្រសសរគ្រឹះ(ស្រទាប់ទ្រ)។


ការងារទប់ដី

**[ការងារទប់ដី]** ការធ្វើកុំឲ្យជញ្ជាំងដីបាក់រលំដោយសារការងារជីកដី ហៅថា "ការងារទប់ដី"។ គេសង់ជញ្ជាំងបណ្ដោះអាសន្នក្នុងដីហើយធ្វើការងារទប់កុំឲ្យដីបាក់រលំ (ហៅថា "សំណង់ទប់")។

**[ការងារសសរគ្រឹះ]** កប់បញ្ចូលសសរគ្រឹះទៅក្នុងដីដើម្បីទ្រអគារ។ ចុងសសរគ្រឹះគឺធ្វើឲ្យដល់ត្រឹមស្រទាប់ទ្រក្នុងដី។ វិធីសាស្ត្រមាន 2 គឺ "សសរគ្រឹះបេតុងបាញ់នៅនឹងកន្លែង" ដែលបង្កើតសសរគ្រឹះនៅការដ្ឋាន និង "សសរគ្រឹះបង្កើតស្រាប់" ដែលផលិតនៅរោងចក្រហើយដឹកមកការដ្ឋាន។

**[ការងារដី]** ជីកផ្ទៃដីដើម្បីបង្កើតរចនាសម្ព័ន្ធខាងក្រោមដី។ ការបូមបញ្ចេញចោលទឹកដែលចេញមកពេលកំពុងជីក ក៏ចាំបាច់ដែរ។


ការលើកដាក់ដីនិងខ្សាច់ដោយអេស្កាវ៉ាទ័របែ៊កហូ(Backhoe)

**[ការងារគ្រឿងបង្គុំក្រោមដី]** ផ្នែកនៃរចនាសម្ព័ន្ធនៃអគារដែលរួមផ្សំដោយ គ្រឹះ សសរ ធ្នឹម ផ្ទៃជញ្ជាំង កម្រាលបាតជាដើម គឺហៅថា "គ្រឿងបង្គុំ" ។ បន្ទាប់ពីបញ្ចប់ការងារដី គេធ្វើការងារគ្រឿងបង្គុំក្រោមដី។ ពីត្រង់នេះ នឹងមានអ្នកម៉ៅការឯកទេសផ្សេងៗចេញនិងចូល។ ឧទាហរណ៍ មានការងារសរសៃដែកទ្រគ្រឿងបង្គុំ ការងារតសរសៃដែកដូចជាការផ្សារដោយសម្ពាធជាដើមដើម្បីតសរសៃដែក ការងារពុម្ពដែលនឹងក្លាយជាពុម្ពពេលចាក់បេតុង ការងារបាញ់បេតុងដែលចាក់បេតុងចូលក្នុងពុម្ព ការងារបរិក្ខារផ្សេងៗ។ល។


ការងារគ្រឿងបង្គុំក្រោមដី

**[ការងារគ្រឿងបង្គុំលើដី]** ក្នុងការសាងសង់អគារធំៗ គេបង្កើតគ្រោងឆ្អឹងដោយប្រើឆ្អឹងដែកធ្ងន់ៗ។ ការងារនេះហៅថា "ការងារឆ្អឹងដែក"។ គេប្រើម៉ាស៊ីនស្ទូចចល័តលើកឆ្អឹងដែក ដាក់តាមទីតាំង ហើយរឹតឲ្យជាប់ដោយប៊ូឡុង។


ការងារគ្រឿងបង្គុំលើដី

**[ការងារបញ្ចប់ផ្ទៃខាងក្នុងនិងខាងក្រៅ]** ពេលបញ្ចប់ការងារគ្រឿងបង្គុំ នឹងចាប់ផ្តើមការងារផ្ទៃខាងក្រៅអគារ។ ការងារផ្ទៃខាងក្នុងខាងក្រៅគឺពាក់ព័ន្ធនឹងការងារឯកទេសជាច្រើនដូចជាការការពារជម្រាបទឹក លោហៈបន្ទះ ដំបូល ការ៉ូ ជញ្ជាំងខណ្ឌ ការងារបូក ការលាបបាញ់ថ្នាំ និងទ្វារបង្អួច។ល។ ដើម្បីឲ្យអគារមើលទៅស្អាត ការងារថ្មដោយប្រើគ្រឿងថ្មដូចជាថ្មម៉ាប ថ្មក្រានីតជាដើម ក៏ត្រូវបានធ្វើឡើងផងដែរ។







**[ការងារការពាររញ្ជួយដី]** ការងារការពាររញ្ជួយដី ជាការងារបង្ការការដួលរលំដោយធ្វើឲ្យអគារធន់នឹងរញ្ជួយនៃរញ្ជួយដី។ ការងារការពាររញ្ជួយដីរួមមានការងារ 3 គឺ ការធ្វើឲ្យធន់នឹងរញ្ជួយ ការគ្រប់គ្រងរញ្ជួយ និងការបំបែករញ្ជួយ។

・ការងារធ្វើឲ្យធន់នឹងរញ្ជួយ៖ សាងសង់សសរនិងធ្នឹមរឹងមាំដើម្បីអាចទប់ទល់នឹងការរញ្ជួយដីខ្លាំង។

・ការងារគ្រប់គ្រងរញ្ជួយ៖ បំពាក់ប្រព័ន្ធស្រូបថាមពលដូចជាបូម(damper)ជាដើមក្នុងសំណង់ដើម្បីគ្រប់គ្រងការរញ្ជួយអគារ។

・ការងារបំបែករញ្ជួយ៖ បំពាក់ឧបករណ៍បំបែករញ្ជួយដូចជាឧបករណ៍ផ្តាច់រញ្ជួយ(isolator) និងបូម(damper)ជាដើម នៅផ្នែកគ្រឹះដើម្បីធ្វើឲ្យថាមពលរញ្ជួយដីពិបាកបញ្ជូនទៅអគារ។






**[ការងារថែរក្សា/តំហែទាំ/ជួសជុល]** ដើម្បីរក្សាសំណង់បានសាងសង់រួចឲ្យស្ថិតក្នុងសភាពល្អបានយូរ វាសំខាន់ដែលត្រូវបង្កើតផែនការថែរក្សានិងតំហែទាំ ហើយធ្វើការជួសជុលតាមផែនការនោះ។ ជាឧទាហរណ៍ គេអនុវត្តការងារជួសជុលដូចខាងក្រោមៈ

・ផ្ទៃខាងក្រៅៈ ការសម្អាតជញ្ជាំងខាងក្រៅ ការបិទភ្ជិតឡើងវិញ ការផ្លាស់ប្តូរការរចនាផ្ទៃខាងក្រៅ ការជួសជុលការពារជម្រាបទឹក ជាដើម

・ផ្ទៃខាងក្នុងៈ ការកម្ចាត់វត្ថុជាឧបសគ្គដល់ការប្រើប្រាស់(barrier-free) ការផ្លាស់ប្តូរប្លង់ ជាដើម

・គ្រឿងបរិក្ខារៈ ការប្តូរឧបករណ៍បំភ្លឺ (LED ជាដើម) ការធ្វើបច្ចុប្បន្នភាពបរិក្ខារកំណត់បរិយាកាសខាងក្នុង ការធ្វើបច្ចុប្បន្នភាពបរិក្ខារផ្គត់ផ្គង់ទឹកនិងបញ្ចេញចោលទឹក ការធ្វើបច្ចុប្បន្នភាពឧបករណ៍អនាម័យ ជាដើម

### 3.1.3 ការងារសំណង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)/បរិក្ខារ

(1) ការងារសំណង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)

**[ការងារអគ្គិសនី]** អគ្គិសនីដែលផលិតនៅរោងចក្រផលិតអគ្គិសនីត្រូវបានបញ្ជូនទៅអគារតាមខ្សែបញ្ជូនពីគ្រង់ស្វូនៅអនុស្ថានីយដោយឆ្លងកាត់តាមបង្គោលភ្លើងឬក្នុងដី។ អគ្គិសនីដែលបញ្ជូនចូលក្នុងអគារ ឆ្លងកាត់តាមបន្ទះចែកចាយអគ្គិសនីហើយផ្គត់ផ្គង់ទៅទីតាំងនីមួយៗក្នុងអគារ។ ការងារទាំងនេះគឺជាការងារអគ្គិសនី។ ក្នុងការងារអគ្គិសនីមានគ្រោះថ្នាក់ប្លែកពីគេគឺ "គ្រោះថ្នាក់ឆក់ខ្សែភ្លើង"។ ដើម្បីបង្ការគ្រោះថ្នាក់ដោយឆក់ខ្សែភ្លើង ចាំបាច់ផ្តល់ដំណឹងឲ្យបានប្រាកដអំពីការបើកនិងផ្តាច់ចរន្តអគ្គិសនីមុនអនុវត្តការងារ ហើយត្រូវពិនិត្យសុវត្ថិភាពដូចជាពិនិត្យថាមានចរន្តអគ្គិសនីឬទេជាដើមនៅផ្នែកផ្គត់ផ្គង់ចរន្តអគ្គិសនី។

**[ការងារហ្គាសទីក្រុង]** ហ្គាសធម្មជាតិរាវដែលដឹកជញ្ជូនដោយកប៉ាល់ធំៗ ត្រូវបានទុកក្នុងអាងស្តុកទុក។ ហ្គាសក្នុងអាងស្តុកទុក ឆ្លងកាត់តាមបំពង់ហ្គាសដែលកប់ក្នុងដីហើយត្រូវបានបំប្លែងជាឧស្ម័ននៅតាមផ្លូវ រួចបន្ទាប់ពីបន្ថែមក្លិន វាត្រូវបានស្តុកទុកក្នុងអាងរាងស្វ៊ែរដែលហៅថា "អាងស្តុកត្រៀមផ្គត់ផ្គង់(gas holder)"។ ហ្គាសដែលស្តុកក្នុងអាងស្តុកត្រៀមផ្គត់ផ្គង់ ត្រូវបានបញ្ជូនដោយលៃតម្រូវសម្ពាធក្នុងពេលជាមួយគ្នានោះ ទៅរោងចក្រ មណ្ឌលផ្សេងៗ គេហដ្ឋាន ដោយឆ្លងកាត់តាមបំពង់។ នៅក្នុងការងារហ្គាសទីក្រុង ជាចម្បងគេអនុវត្តការងារបំពង់បញ្ជូនដែលសម្រាប់ហ្គាសឆ្លងកាត់ និងការងារដំឡើងបរិក្ខារសម្រាប់ប្រើប្រាស់ហ្គាស។




**[ការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ]** នៅក្នុងការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ទឹកដែលយកពីស្ទឹងទន្លេជាដើម ត្រូវបានធ្វើឲ្យក្លាយជាទឹកស្អាតនៅរោងចក្រប្រព្រឹត្តកម្មទឹកស្អាត ហើយស្តុកទុកក្នុងអាងស្តុកទឹកស្អាតនិងអាងចែកចាយទឹកស្អាត។ ទឹកក្នុងអាងស្តុកទឹកត្រូវបានបញ្ជូនទៅសព្វទិសទីក្នុងតំបន់ផ្គត់ផ្គង់ទឹកដោយបំពង់មេនាំទឹកដែលបង្កប់ក្នុងដី។ បន្ទាប់មកគេចោះបំពង់មេនាំទឹកហើយតបំបែកបំពង់ចែកចាយទឹកពីត្រង់នោះ ដើម្បីទាញយកទឹកចូលទៅគេហដ្ឋាននិងផ្នែកខាងក្នុងអគារ។ នៅក្នុងការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត គេអនុវត្តការងារបង្កប់បំពង់មេនាំទឹក ការងារទាញបញ្ចូលទៅអគារ។ នៅក្នុងការងារប្រព័ន្ធលូ ទឹកកខ្វក់ក្រោយពីប្រើប្រាស់ក្នុងអគារត្រូវបានប្រមូលចូលបំពង់លូមេ ហើយសម្អាតជាទឹកស្អាតនៅរោងចក្រប្រព្រឹត្តកម្មទឹកកខ្វក់រួចបង្ហូរទៅស្ទឹងទន្លេឬសមុទ្រ។




**[ការងារទូរគមនាគមន៍]** នៅក្នុងការងារទូរគមនាគមន៍ គេកសាងបណ្តាញសម្រាប់បញ្ជូននិងប្រើប្រាស់ព័ត៌មានជាចម្បងដូចជាការងារប្រព័ន្ធទូរសព្ទនិងអ៊ីនធឺណិត។ល។ ខ្សែកាបសម្រាប់បរិក្ខារទូរគមនាគមន៍មានខ្សែកាបលោហៈនិងខ្សែកាបអុបទិក។ ថ្មីៗនេះខ្សែកាបអុបទិកត្រូវបានប្រើប្រាស់យ៉ាងច្រើន។

(2) ការងារបរិក្ខារ

ការងារបរិក្ខារមានដូចជាភ្លើងបំភ្លឺ ផលិតផលអគ្គិសនី ម៉ាស៊ីនឧបករណ៍IT ម៉ូទ័រអគ្គិសនីជាដើម ក៏ដូចជាបរិក្ខារការពារគ្រោះមហន្តរាយ បរិក្ខារអគ្គិសនីដែលផ្គត់ផ្គង់ប្រភពអគ្គិសនី បរិក្ខារកំណត់បរិយាកាសក្នុងបន្ទប់ឲ្យមានផាសុកភាព បរិក្ខារផ្គត់ផ្គង់ទឹកស្អាតបញ្ចេញចោលទឹកកាកសំណល់និងអនាម័យ។

**【ការងារបរិក្ខារបង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់】** គេអនុវត្តការងារបរិក្ខារដែលលៃតម្រូវសីតុណ្ហភាពនិងកម្រិតសំណើម និងបន្សុទ្ធខ្យល់ដើម្បីឲ្យមានផាសុកភាព។



ឧបករណ៍ធ្វើឲ្យទឹកត្រជាក់វិលជុំ

**[ការងារបរិក្ខារផ្គត់ផ្គង់ទឹកស្អាត បញ្ចេញចោលទឹកកខ្វក់ អនាម័យ]** ជាការងារបំពាក់បរិក្ខារចាំបាច់ដើម្បីរក្សាបរិស្ថានរស់នៅឲ្យមាន
អនាម័យនិងស្អាតដោយប្រើទឹកនិងទឹកក្តៅ។

**[ការងាររក្សាកម្តៅរក្សាភាពត្រជាក់]** គេអនុវត្តការងារពាក់ព័ន្ធនឹងបំពង់និងបរិក្ខារដែលត្រូវការការពារកម្តៅ រក្សាកម្តៅ រក្សាភាពត្រជាក់ ការពារអ័ព្ទ។



ឧបករណ៍បូមផ្គត់ផ្គង់ទឹក



ការងាររក្សាកម្តៅ
រក្សាភាពត្រជាក់



ការងាររក្សាកម្តៅ
រក្សាភាពត្រជាក់

**[ការងារបរិក្ខារការពារអគ្គីភ័យ]** អនុវត្តការងារបរិក្ខារសម្រាប់ការពារមនុស្សនិងសំណង់ពីអគ្គីភ័យ។ ឧទាហរណ៍ ការងារដំឡើង "ម៉ាស៊ីនទទួលសញ្ញាអគ្គីភ័យ" ដែលទទួលសញ្ញាពីឧបករណ៍ចាប់ដឹងនិងម៉ាស៊ីនបញ្ជូនសញ្ញាដែលបំពាក់ក្នុងអគារ ហើយផ្តល់ដំណឹងអំពីការកើតឡើងអគ្គីភ័យទៅក្នុងអគារព្រមទាំងទៅនាយកដ្ឋានពន្លត់អគ្គីភ័យ ការងារដំឡើង "ឧបករណ៍បាចសាចទឹក" ដែលបាចសាចទឹកដោយស្វ័យប្រវត្តិដោយសារកម្តៅរបស់អគ្គីភ័យ ការងារដំឡើង "ម៉ាស៊ីនបូមពន្លត់អគ្គីភ័យ" សម្រាប់ផ្គត់ផ្គង់ទឹកពេលធ្វើសកម្មភាពពន្លត់អគ្គីភ័យ។ល។









## 3.2 ការងារនៃការងារសំណង់ឯកទេសចម្បងៗ

### 3.2.1 ការងារដី

ការអនុវត្តការងារដូចជា ការជីកដី លើកដាក់/ដឹកជញ្ជូនដី និងខ្សាច់/លើកដី ការលុបដីវិញ ការបង្ហាប់ ការឈូសដី/ពង្រាបដីជាដើម ដោយកម្លាំងមនុស្ស ហៅថាការងារដី។


អេស្កាវ៉ាទ័រអ៊ីដ្រូលីក

**[ការងារជីក]** ការងារជីកដីនិងផ្ទាំងថ្មយកចេញហៅថា "ការងារជីក" ។ ក៏មានការបំបែកផ្ទាំងថ្ម
ជាដើមដោយប្រើគ្រឿងផ្ទុះផងដែរ ហើយគេហៅថា "ការបំផ្ទុះ"។ គ្រឹះនៃអគារគឺកប់នៅក្រោមដី។
ការជីកដីសម្រាប់គោលបំណងនេះគេហៅថា "ការជីករណ្ដៅគ្រឹះ"។

**[ការងារលើកដាក់/ដឹកជញ្ជូនដីនិងខ្សាច់]** នៅកន្លែងដែលមិនអាចលើកដាក់/ដឹកជញ្ជូនដីនិងខ្សាច់ដោយប្រើម៉ាស៊ីនដូចជា អេស្កាវ៉ាទ័រអ៊ីដ្រូលីកនិងរថយន្តបែនជាដើម គេធ្វើការងារដោយកម្លាំងមនុស្ស។

**[ការងារលើកដី/កាត់ដី]** "ការលើកដី" ជាការលើកពូនដីហើយពង្រាបឲ្យស្មើចំពោះទីជម្រាលឬដីដែលមិនរាបស្មើ។ "ការកាត់ដី" ជាការកាត់ដីចេញហើយពង្រាបឲ្យស្មើ។

**[ការងារលុបដីវិញ]** ការងារលុបដីវិញជាការងារលុបដីចំពោះចន្លោះលើសដែលលេចឡើងនៅសំណង់ឬក្បែរនោះបន្ទាប់ពីបញ្ចប់ការងារក្រោមដីនិងការងារគ្រឹះដោយជីកដី។

**[ការងារបង្ហាប់]** "ការបង្ហាប់" ជាការងារធ្វើឲ្យចន្លោះរវាងដីនិងខ្សាច់មានតិចតួចដើម្បីកុំឲ្យដីស្រុតតាមរយៈការវាយឬផ្ដល់រំញ័រ។

**[ការបំពាក់ម៉ាស៊ីនបូមក្នុងទឹកនិងការបញ្ចេញទឹក]** នៅកន្លែងដែលទឹកចេញច្រើន គេបញ្ចេញទឹកដោយបំពាក់ម៉ាស៊ីនបូមក្នុងទឹកជាដើម។


ការបង្ហាប់ដោយប្រើរ៉ូឡូប្រើដៃ

**[ការងារលាប/ដាំដើមឈើនៅជម្រាល]**

ដើម្បីការពារការបាក់រលំនៃជម្រាល គេបាញ់បាយអលាបលើជម្រាល។ ក៏មានវិធីសាស្ត្រដែលដាំដើមឈើលើផ្ទៃទាំងមូលនៃជម្រាលដោយពព្ចកកន្ទេលដែលមានភ្ជាប់គ្រាប់ពូជ/ជី/សម្ភារថ្នាលដាំជាដើមផងដែរ។

### 3.2.2 ការសាងសង់ផ្លូវរូងដោយរុញទៅមុខ

ការសាងសង់ផ្លូវរូងដោយរុញទៅមុខ អាចនិយាយបានថាជាវិធីសាស្ត្រដូចគ្នានឹងវិធីសាស្ត្រជីកផ្លូវរូងរបាំង(Shield Tunnel) ត្រង់ចំណុចដែលជីកផ្លូវរូងដោយប្រើម៉ាស៊ីនជីកផ្លូវរូងទៅមុខ។ ពេលដែលបានត្រៀមបើកដំណើរការម៉ាស៊ីនជីកផ្លូវរូងទៅមុខរួចហើយ គេចាប់ផ្ដើមជីកផ្លូវរូងដោយបើកដំណើរការម៉ាស៊ីនជីកផ្លូវរូងទៅមុខពីរណ្ដៅចាប់ផ្ដើមដែលបានសាងសង់ទុកជាមុន។ នៅក្នុងការសាងសង់ផ្លូវរូងដោយរុញទៅមុខ គេភ្ជាប់បំពង់ដែលផលិតទុកជាមុននៅរោងចក្រ ទៅនឹងម៉ាស៊ីនជីកទៅមុខ ហើយរុញបញ្ចូលក្នុងដីដោយម៉ាស៊ីនរុញ (jack)ដែលដំឡើងនៅរណ្ដៅចាប់ផ្ដើម។ គេកសាងផ្លូវរូងដោយធ្វើការងារនេះម្ដងហើយម្ដងទៀត។




### 3.2.3 ការងារសំណង់ស៊ីវិលសមុទ្រ

ការងារសំណង់ស៊ីវិលសមុទ្រដែលសាងសង់បរិក្ខារកំពង់ផែនិងសំណង់នៅសមុទ្រ មានការងារជាតំណាងដូចខាងក្រោម។

**[ការងារជីកយកខ្សាច់]** ការងារជីកយកខ្សាច់ជាការងារយកចេញដីខ្សាច់នៅបាតសមុទ្រនិងទន្លេជាដើម។




**[ការងារចាក់លុប]** ការងារចាក់លុបជាការងារប្រមូលដីនិងខ្សាច់បង្កើតដីថ្មី។ ការងារនេះគឺដឹកជញ្ជូនដីនិងខ្សាច់ដែលយកពីការងារជីកយកខ្សាច់ ដោយនាវាឬម៉ាស៊ីនហើយដាក់ចូលក្នុងសមុទ្រដើម្បីកសាងដីប្រើប្រាស់។

**[ការងារសាងសង់ផែ]** ផែជាបរិក្ខារសម្រាប់នាវាចតដើម្បីលើកដាក់អីវ៉ាន់ពីនាវានៅកំពង់ផែ។

**[ការងារសំណង់ទំនប់ការពាររលក]** ទំនប់ការពាររលកជាបរិក្ខារការពារកុំឲ្យរលកចូលមកកំពង់ផែ ដើម្បីឲ្យនាវាអាចចត លើកដាក់អីវ៉ាន់ដោយសុវត្ថិភាព។




## 3.2.4 ការងារខួងអណ្តូង

"ការងារខួងអណ្តូង" ជាការងារជីកដីបង្កើតអណ្តូង។ ការងារខួងអណ្តូងមានប្រភេទមួយចំនួន។

**[ការសាងសង់អណ្តូងប្រភពទឹក]** ជាការសាងសង់ដើម្បីបូមទឹកក្រោមដីឡើង។

**[ការសាងសង់អណ្តូងសង្កេត]** "អណ្តូងសង្កេត" ជាអណ្តូងសម្រាប់ស្វែងយល់ពីស្ថានភាពនៃស្រទាប់ដី។

**[ការសាងសង់អណ្តូងទឹកក្តៅធម្មជាតិ]** ជាការសាងសង់ដើម្បីបូមទឹកក្តៅធម្មជាតិឡើង។

**[ការសាងសង់អណ្តូងកម្តៅក្នុងផែនដី]** ជាការសាងសង់អណ្តូងដើម្បីផលិតថាមពលអគ្គិសនីពីកម្តៅក្នុងផែនដី។ វាទាមទារបច្ចេកវិទ្យាខ្ពស់ជាងការសាងសង់អណ្តូងផ្សេងទៀត។

## 3.2.5 ការសាងសង់បំពង់ស្រូបទឹក well point

ក្នុងករណីជីកដល់ខាងក្រោមជាងទឹកក្រោមដីនៅក្នុងការងារគ្រឹះអគារ ការងារដាក់បំពង់ក្រោមដី ឬការងារសង់បង្កប់អាងសិបទិចជាដើម ចាំបាច់ត្រូវបូមទឹកក្រោមដីបញ្ចេញចោល។ ការសាងសង់បំពង់ស្រូបទឹក well point គឺជាវិធីសាស្ត្រមួយសម្រាប់បញ្ចេញទឹកក្រោមដីចោល។ បំពង់បូមទឹកមួយចំនួនដែលបំពាក់បំពង់ចែកចាយទឹកដែលហៅថាបំពង់ស្រូបទឹក well point ត្រូវបានវាយបញ្ចូលទៅក្នុងដី ហើយបូមទឹកក្រោមដីឡើងដោយប្រើម៉ាស៊ីនបូមសុញ្ញកាស។ ទឹកក្រោមដីដែលបានបូមឡើង ត្រូវបានបញ្ចេញចោលតាមបំពង់ប្រមូលទឹក។




### 3.2.6 ការងារកម្រាលផ្លូវថ្នល់

"ការងារកម្រាលផ្លូវថ្នល់" ជាការងារក្រាលកៅស៊ូឬបេតុងលើផ្លូវថ្នល់។ ក្រោយពីវាស់វែងទីតាំងរួចការងារដូចខាងក្រោមត្រូវបានអនុវត្ត។

**[ការងារស្រទាប់ដីសម្រាំង]** "ស្រទាប់ដីសម្រាំង" ជាស្រទាប់ក្រោមបង្អស់ហើយជាផ្នែកដែលរងទម្ងន់ទាំងអស់។ ក្រោយពីជីកបានប្រហែល1m ដោយប្រើគ្រឿងចក្រផុនធូន់ គេក្រាលខ្សាច់ឲ្យបានសព្វ។

**[ការងារគ្រឹះថ្នល់]** ស្រទាប់ខាងលើនៃស្រទាប់ដីសម្រាំងហៅថា "គ្រឹះថ្នល់"។ នៅពីលើស្រទាប់ដីសម្រាំងគេក្រាលថ្មម៉ិចជាដើមបង្កើត 2 ស្រទាប់។ គេប្រើគ្រឿងចក្រផុនធូន់ហៅថារ៉ូឡូដើម្បីបង្ហាប់ឲ្យហាប់ល្អ។

**[ការងារស្រទាប់ទ្រនាប់កម្រាលថ្នល់]** គេប្រើម៉ាស៊ីនហៅថាគ្រឿងចក្រក្រាលកៅស៊ូ(asphalt finisher) ដើម្បីក្រាលកៅស៊ូឲ្យរាបស្មើលើគ្រឹះថ្នល់។


គ្រឿងចក្រក្រាលកៅស៊ូ(asphalt finisher)

**[ការងារស្រទាប់ផ្ទៃខាងលើកម្រាលថ្នល់]** ជាចុងក្រោយ គេក្រាលឲ្យរាបស្មើនិងបង្ហាប់កៅស៊ូដែលធន់ជាប់បានយូរធន់នឹងទឹក មិនងាយរអិល។

### 3.2.7 ការងារដីដោយម៉ាស៊ីន

ការអនុវត្តការងារដីដែលបានពន្យល់ក្នុង 3.2.1 ដោយប្រើម៉ាស៊ីនហៅថា "ការងារដីដោយម៉ាស៊ីន" ។ ដើម្បីបើកបរនិងដំណើរការគ្រឿងចក្រ ត្រូវតែបញ្ចប់ការបណ្ដុះបណ្ដាលជំនាញនិងការបណ្ដុះ

បណ្ដាលអំពីសុវត្ថិភាពដែលត្រូវបានកំណត់។

**[ការងារជីក]** ការជីកត្រូវបានអនុវត្តដោយប្រើអេស្កាវ៉ាទ័រអ៊ីដ្រូលិក។ ប្រសិនបើមានថ្មធំៗឬផ្ទាំងថ្ម គេប្រើម៉ាស៊ីនបំបែកថ្ម។

**[ការងារឈូសដី/លើកដាក់/ដឹកជញ្ជូន]** "ការឈូសដី" ជាការប្រើគ្រឿងចក្រដូចជាប៊ុលដូហ្ស៊ែរជាដើម រុញឈូសដីនិងខ្សាច់។ ការលើកដាក់ចូលរថយន្តបែនគឺប្រើសាកស័រ អេស្កាវ៉ាទ័រអ៊ីដ្រូលិកជាដើម។







**[ការលើកដី/បង្ហាប់]** ដីទំនាបត្រូវបានលើកដីហើយបង្ហាប់ដោយប្រើប៊ុលដូហ្ស៊ែរ។ ចំពោះជម្រាល គេភ្ជាប់ដៃបង្កើតជម្រាលទៅនឹងអេស្កាវ៉ាទ័រអ៊ីដ្រូលិកដើម្បីបង្កើតជម្រាល។ ម៉ាស៊ីនកិនបង្ហាប់សម្រាប់បង្ហាប់ជាដើមក៏ត្រូវបានប្រើប្រាស់ដែរ។







## 3.2.8 ការងារសសរគ្រឹះ

ការងារសសរគ្រឹះ ជាការងារបង្កើតគ្រឹះដោយសសរគ្រឹះបេតុងឬបំពង់ដែកដើម្បីទ្រសំណង់ រចនាសម្ព័ន្ធ។ ចំពោះរចនាសម្ព័ន្ធខ្នាតធំដូចជាអគារខ្ពស់ ស្ពានជាដើម ការងារសង់សសរគ្រឹះត្រូវបាន អនុវត្ត។




**[វិធីសាស្ត្រសសរគ្រឹះផលិតជាស្រេច]** ជាវិធីសាស្ត្រដែលជញ្ជូនសសរគ្រឹះដែលផលិតនៅរោងចក្រមកការដ្ឋានដើម្បីវាយបញ្ចូល។

**[វិធីសាស្ត្រសសរគ្រឹះចាក់នៅនឹងកន្លែង]** ជាវិធីសាស្ត្របង្កើតសសរគ្រឹះនៅការដ្ឋានសាងសង់។ គេជីករន្ធសម្រាប់ដាំសសរគ្រឹះ ហើយដាក់ដែកសសរគ្រឹះរាងស៊ីឡាំងធ្វើពីសរសៃដែកទៅក្នុងរន្ធនោះ

ហើយចាក់បេតុងលាយស្រេចចូលបង្កើតសសរគ្រឹះ។

### 3.2.9 ការងារទីខ្ពស់

ជាឧទាហរណ៍ នៅពេលធ្វើការងារលាបបាញ់ថ្នាំជាដើម បើគ្មានរន្ទាធ្វើការទេនោះ នឹងមិនអាចអនុវត្តការងារបានឡើយ។ ជាងធ្វើការទីខ្ពស់ដែលបង្កើតរន្ទានេះហៅថា "ជាងធ្វើការទីខ្ពស់ខាងរន្ទា" ។ ក្រៅពីនេះ ជាងធ្វើការទីខ្ពស់ក៏មានប្រភេទដូចខាងក្រោមដែរ។

**[ជាងធ្វើការទីខ្ពស់ខាងឆ្អឹងដែក]** ធ្វើការងារដំឡើងគ្រោងនៃអគារខ្ពស់និងខុនដូដោយប្រើសម្ភារឆ្អឹងដែក។



ជាងធ្វើការទីខ្ពស់ខាងឆ្អឹងដែក

**[ជាងធ្វើការទីខ្ពស់ខាងស្ពាន]** ធ្វើការងារផ្គុំឆ្អឹងដែកនៃស្ពាន ទំនប់អាងទឹក ប៉មដែក និងផ្លូវល្បឿនលឿន។

**[ជាងធ្វើការទីខ្ពស់ធុនធ្ងន់]** ដឹក និងដំឡើងម៉ាស៊ីន ឬបរិក្ខារដែលមានទម្ងន់រាប់រយតោន។

**[ជាងធ្វើការទីខ្ពស់ខាងខ្សែបញ្ជូនអគ្គិសនី]** ធ្វើការងារខាងអគ្គិសនីនៅទីខ្ពស់ដូចជា ការងាររត់ខ្សែបញ្ជូនអគ្គិសនីពីប៉មដែក ការត្រួតពិនិត្យ/តំហែទាំខ្សែបញ្ជូនអគ្គិសនី។ល។

**[ជាងធ្វើការទីខ្ពស់អគារក្នុងស្រុក]** ជាងធ្វើការទីខ្ពស់ដែលធ្វើការងារដំឡើងរន្ទានៃសំណង់ជាពិសេសក្នុងស្រុកដូចជាលំនៅដ្ឋាន ខុនដូជាដើម ហៅថា "ជាងធ្វើការទីខ្ពស់អគារក្នុងស្រុក"។

### 3.2.10 ការងារឆ្អឹងដែក

ការងារឆ្អឹងដែកជាការងារដំឡើងគ្រោងសំណង់ដូចជាសសរនិងធ្នឹមជាដើមដោយប្រើឆ្អឹងដែក។ តាមទម្រង់នៃផ្ទៃមុខកាត់ ឆ្អឹងដែកត្រូវបានបែងចែកធំៗជាប្រភេទដូចខាងក្រោម។



ការងារឆ្អឹងដែក

ប្រភេទនៃ
ផ្ទឹងដែក



ដែករាង H ដែករាង I ដែករាង V ដែករាង U ដែកទីបជ្រុង ដែកទីបមូល

ប្រភេទការងារផ្ទឹងដែកមាន "វិធីសាស្ត្រសង់ហើយគេច" និង "វិធីសាស្ត្របង្គរផ្ទៃដេក"។ វិធីសាស្ត្រសង់ហើយគេច ជាវិធីសាស្ត្រផ្គុំដំឡើងពីខាងក្រោយនៃដីឡូត៍ឆ្ពោះទៅខាងមុខដោយប្រើម៉ាស៊ីនស្ទូចចល័ត។ វិធីសាស្ត្របង្គរផ្ទៃដេក ជាវិធីសាស្ត្រផ្គុំដំឡើងទៅលើម្តង 1 ជាន់ៗដោយប្រើម៉ាស៊ីនស្ទូចលើប៉ម។ នេះជា
វិធីសាស្ត្រដែលគេប្រើពេលសាងសង់អគារខ្ពស់ៗ។

### 3.2.11 ការងារសរសៃដែក

រចនាសម្ព័ន្ធដែលគ្របដោយបេតុងដូចជាអគារនិងស្ពាន គឺប្រើប្រាស់សរសៃដែកជាគ្រោងឆ្អឹង។ ការងារនេះគេហៅថា "ការងារសរសៃដែក" ។ សរសៃដែកត្រូវបានកាត់ កែច្នៃពត់នៅកន្លែងកែច្នៃ ហើយដឹកជញ្ជូនមកដំឡើងនៅការដ្ឋានសំណង់។

### 3.2.12 ការងារតសរសៃដែក

សរសៃដែកត្រូវបានផលិតឡើង ប្រសិនបើមិនវែងគ្រប់គ្រាន់ គេតភ្ជាប់សរសៃដែក 2 ដើមបង្កើតជាសរសៃដែកវែង 1 ដើម។ ការងារនេះហៅថា "ការងារតសរសៃដែក"។ វិធីសាស្ត្រតមានប្រភេទមួយចំនួនដូចខាងក្រោម។



ការកែច្នៃពត់សរសៃដែក

**[ការតដោយផ្សារដោយសម្ពាធឧស្ម័ន]** ការតដោយសម្ពាធឧស្ម័នជាវិធីសាស្ត្រដុតកម្ដៅផ្នែកតំណរវាងសរសៃដែកដើម្បីតភ្ជាប់ដោយបន្ថែមសម្ពាធតាមទិសដៅអ័ក្ស។


ការតដោយផ្សារដោយសម្ពាធឧស្ម័ន

**[ការតដោយផ្សារ]** ជាវិធីសាស្ត្រតផ្ទៃតសរសៃដែកដោយ "ការផ្សារធ្នូអគ្គិសនី" ។ នេះជាវិធីសាស្ត្រដែលត្រូវបានប្រើចំពោះសរសៃដែកអង្កត់ផ្ចិតធំ សសរបេតុងចាក់ស្រេច សរសៃមេនៃធ្នឹម "សរសៃដែកដំឡើងទុកមុន"ដែលមិនអាចផ្សារដោយសម្ពាធបានជាដើម។


ការតដោយផ្សារ

**[ការតបែបមេកានិក]** ការតបែបមេកានិកជាវិធីសាស្ត្រតសរសៃដែកថ្នាំងអំពៅដោយប្រើសម្ភារដែលហៅថាតំណដែក (Coupler)។

**[ការតផ្គុំបគ្នា]** ជាវិធីសាស្ត្រត្រូវបានប្រើជាមួយសរសៃដែកស្តើង។ ផ្នែកដែលសរសៃដែកតគ្នាគឺត្រូវបានធ្វើឲ្យទៅជាដើមតែមួយដោយវិធីសាស្ត្រណាមួយដូចជាការផ្សារធ្នូអគ្គិសនីជាដើម។ កន្លែងដែលសរសៃដែកនៃកម្រាលខណ្ឌប្រសព្វគ្នាគឺគេប្រើការតផ្គុំបគ្នា ហើយរួមបញ្ចូលគ្នាតែមួយដោយបេតុង។


ការតបែប
មេកានិក


ការតផ្គុំបគ្នា

### 3.2.13 ការងារផ្សារ

ការផ្សារជាការតភ្ជាប់សម្ភារ 2 ឡើងទៅដោយផ្តល់កម្តៅ សម្ពាធ។


ការងារផ្សារធ្នូអគ្គិសនី

លក្ខណៈពិសេសរបស់វាគឺ ភាពបិទជិតគ្មានខ្យល់ចូលល្អជាង ហើយស្រាលជាងការតភ្ជាប់ដោយវីសឬប៊ូឡុង។ វិធីសាស្ត្រផ្សារមានច្រើនប៉ុន្តែបើបែងចែកធំៗគឺមាន 3 ប្រភេទគឺ ការផ្សាររលាយ ការផ្សារដោយសម្ពាធ និងការផ្សារដោយលោហៈបន្សារ។

**[ការផ្សាររលាយ]** ជាវិធីសាស្ត្រផ្សារទូទៅបំផុត។ មានវិធីសាស្ត្រផ្សារដោយធ្វើឲ្យរលាយលោហៈដើម (លោហៈដែលចង់ផ្សារ) និងវិធីសាស្ត្រផ្សារដោយធ្វើឲ្យរលាយធូបផ្សារនិងលោហៈដើម។

**[ការផ្សារដោយសម្ពាធ]** ជាវិធីសាស្ត្រផ្សារដែលតភ្ជាប់ដោយផ្តល់កម្តៅនិងសម្ពាធត្រង់ផ្នែកត្រូវតភ្ជាប់នៃលោហៈដើមទាំងនោះ។ មានវិធីសាស្ត្រផ្សារដោយសម្ពាធមួយចំនួន ប៉ុន្តែនៅការដ្ឋានសំណង់ ពេលតសរសៃដែកនិងសរសៃដែក ការផ្សារដោយសម្ពាធឧស្ម័នត្រូវបានប្រើជាញឹកញាប់។

**[ការផ្សារដោយលោហៈបន្សារ]** ជាវិធីសាស្ត្រផ្សារដែលធ្វើឲ្យសារធាតុរលាយដែលមានសីតុណ្ហភាពរលាយទាបជាងលោហៈដើម រលាយឲ្យមានតួនាទីជាសម្ភារការ។

### 3.2.14 ការងារពុម្ព

"ការងារពុម្ព" ជាការងារសំណង់ដែលបង្កើតពុម្ពដើម្បីគ្របសរសៃដែកដែលសង់ឡើងដោយការងារសរសៃដែក។


ការងារពុម្ព

ដោយសារក្នុងពុម្ពគឺចាក់បេតុងចូល ដូច្នេះពុម្ពរងសម្ពាធខ្លាំងពីខាងក្នុង។ បើមិនអាចទប់ទល់នឹងសម្ពាធនេះបានទេនោះ ពុម្ពនឹងបែកហើយហៀរបេតុងចេញមកក្រៅ។ ដើម្បីបង្ការបញ្ហានេះ ចាំបាច់ត្រូវពង្រឹងដោយទប់ឲ្យបានល្អពីខាងក្រៅពុម្ព។ ដើម្បីពង្រឹងគេប្រើបំពង់ដែក។ ការងារពង្រឹងពុម្ពដោយបំពង់ដែកហៅថា "ការទប់ទ្រ"។

## 3.2.15 ការងារបាញ់បេតុង




ពេលពុម្ពរួចរាល់ គេចាក់បេតុងចូលក្នុងនោះ (ហៅថា "ការចាក់បេតុង")។ បេតុងដែលគ្រប់គ្រងគុណភាពនៅរោងចក្រ (ហៅថា "បេតុងលាយស្រេច") ត្រូវដឹកមកការដ្ឋានសំណង់ដោយរថយន្តក្រឡុកបេតុង(រថយន្តដឹកបេតុង) ហើយផ្ទេរទៅរថយន្តបាញ់។ បេតុងលាយស្រេចត្រូវបានបាញ់ចូលក្នុងពុម្ពដោយម៉ាស៊ីនបាញ់បេតុងដោយប្រើសម្ពាធប្រេងឬសម្ពាធមេកានិក។ គេហៅថា "ការបាញ់បេតុង" ។

កំលុងពេលចាក់បេតុង មានខ្យល់ចូលហើយបង្កើតជាពពុះខ្យល់ក្នុងបេតុង។ ដើម្បីការពារការធ្លាក់ចុះនៃភាពរឹងរបស់បេតុង គេប្រើម៉ាស៊ីនរំញ័រផ្តល់រំញ័រដល់បេតុងឲ្យជ្រាបសព្វកន្លែកកន្លៀតក្នុងពុម្ពបំបាត់ខ្យល់ដែលមិនចាំបាច់។ ការងារនេះហៅថា "ការបង្ហាប់"។






### 3.2.16 ការងារលាបបាញ់ថ្នាំ

 ការងារលាបបាញ់ថ្នាំ ជាការងារធ្វើឡើងដើម្បីការពារ បង្កើនភាពធន់ជាប់នៃដំបូល ជញ្ជាំងសំណង់ និងលើកកម្ពស់សោភ័ណភាព។ ដើម្បីបែងចែកប្រើប្រាស់ថ្នាំពណ៌ទៅតាមផ្ទៃសាច់ដែលត្រូវលាបបាញ់ថ្នាំ ត្រូវការចំណេះដឹងខ្ពស់អំពីថ្នាំពណ៌។

**[ការលាបដោយជក់]** ជាវិធីសាស្ត្រលាបដោយប្រើឧបករណ៍ហៅថា "ជក់"។ គេបែងចែកប្រើប្រាស់ជក់ផ្សេងៗគ្នាអាស្រ័យតាមកន្លែងលាប។



ការលាបថ្នាំជញ្ជាំងខាងក្រៅដោយរ៉ូឡូ

**[ការលាបដោយរ៉ូឡូ]** ជាវិធីសាស្ត្រលាបដោយប្រើរ៉ូឡូ។ វាស័ក្តិសមនឹងការលាបផ្ទៃទូលាយដូចជាជញ្ជាំងខាងក្រៅជាដើមដោយសារអាចលាបផ្ទៃទូលាយដោយប្រសិទ្ធផលខ្ពស់។

**[ការបាញ់ថ្នាំ]** ជាវិធីសាស្ត្របាញ់ថ្នាំពណ៌ក្នុងទម្រង់ជាចំហាយទៅលើផ្ទៃត្រូវលាបបាញ់ថ្នាំ។ ខ្យល់បណ្ដែនដោយកុំប្រេះស័រខ្យល់ត្រូវបានលាយជាមួយវត្ថុរាវហើយបាញ់ដោយកាំភ្លើងបាញ់ខ្យល់។



ការបាញ់ថ្នាំ

### 3.2.17 ការងារបង្កើតសួន

ការបង្កើតទេសភាពដោយប្រើដើមឈើ រុក្ខជាតិ ថ្មប្រភេទផ្សេងៗជាដើម គឺហៅថា "ការបង្កើតសួន" ។ លើសពីនេះ ក៏ទាមទារការចេះវិនិច្ឆ័យភាពស្រស់ស្អាតដូចជាគុល្យភាពនៃការរៀបដើមឈើនិងថ្មជាដើមផងដែរ។

**[ការងារដាំ]** ជាការងារដាំដើមឈើ រុក្ខជាតិក្នុងដីឡូត៍ជុំវិញសំណង់ (ហៅថា "បរិវេណជុំវិញ")។

**[ការងារបង្កើតបៃតងលើដំបូល]** ជាការងារបង្កើតបៃតងលើដំបូង ផ្ទៃជញ្ជាំងនៃសំណង់។

**[ការងារទីលាន]** ជាការងារបង្កើតសួនស្មៅ ទីលានហាត់ប្រាណជាដើម។

**[ការងារបរិក្ខារសួនឧទ្យាន]** ក្រៅពីការបង្កើតកន្លែងដាំផ្កាក្នុងសួនឧទ្យាន ការងារដូចជាកន្លែងសម្រាក អាងបាញ់ទឹក ផ្លូវដើរលេងជាដើម ក៏ត្រូវបានអនុវត្តផងដែរ។

**[ការងារដាំដុះតំបន់បៃតង]** គេធ្វើការកែលម្អដី ដំឡើងបង្គោលទប់ដើមឈើជាដើម ហើយដាំដុះដើមឈើ ស្មៅ និងផ្កាជាដើម។







### 3.2.18 ការងារបូក




"ការងារបូក" ជាការងារលាបបៀកសម្ភារសម្រេចប្រភេទផ្សេងៗដោយប្រើឧបករណ៍ហៅថា "ស្លាបព្រាបូក" បន្ទាប់ពីសំណង់បញ្ចប់។ វាស្រដៀងនឹងការងារលាបបាញ់ថ្នាំដែរ ប៉ុន្តែឧបករណ៍ដែលប្រើគឺខុសគ្នា។

សម្ភារដែលប្រើប្រាស់មាន ដីឥដ្ឋជញ្ជាំង បាយអកំបោរជប៉ុន កំបោរធម្មតា និងសរសៃជាដើម។ ជាពិសេស ដីឥដ្ឋជញ្ជាំង និងកំបោរជប៉ុន គឺសម្ភារដែលប្រើប្រាស់ក្នុងប្រទេសជប៉ុនជាយូរមកហើយ។ ដោយសារការងារបូកជារឿយៗធ្វើឡើងនៅជញ្ជាំងខាងក្រៅនិងផ្ទៃខាងក្នុងនៃសំណង់ ទឹកដៃគឺសំខាន់ជាពិសេស ដូច្នេះគឺទាមទារបច្ចេកទេសខ្ពស់ដើម្បីអាចសម្រេចដោយស្រស់ស្អាត។



## 3.2.19 ការងារជាងឈើសំណង់អគារ

ការសាងសង់សំណង់ឈើទាំងនេះជាការងាររបស់ "ជាងឈើសំណង់អគារ"។ ការងារដែលប្រើប្រាស់ពាក្យថា "ជាងឈើ" មានច្រើនដូចខាងក្រោម។

**[ជាងឈើក្នុងស្រុក]** ជាជាងឈើដែលធ្វើការងារសាងសង់លំនៅដ្ឋានឈើ ហើយពេលនិយាយថា "ជាងឈើ" គឺជនជាតិជប៉ុនជាច្រើននឹកឃើញដល់ជាងឈើក្នុងស្រុកនេះ។

**[ជាងឈើខាងបំពាក់]** បន្ទាប់ពីរចនាសម្ព័ន្ធសំណង់បានបញ្ចប់ គេធ្វើការបំពាក់ផ្ទៃខាងក្នុងដូចជាទ្វារ ទ្វាររុញស្បូជិ ទ្វាររុញហ្វ៊ូស៊ុម៉ាជាដើម។

**[ជាងឈើវត្តវិហារ]** ជាជាងឈើសាងសង់ ជួសជុលវត្ត វិហារជាដើម។ ដើម្បីបង្កើតសំណង់ដែលអាចទប់ទល់នឹងភ្លៀងខ្យល់រាប់រយឆ្នាំ គឺទាមទារបច្ចេកទេសខ្ពស់ដូចជាចំណេះដឹងអំពីឈើ និងរបៀបភ្ជាប់ឈើនិងឈើជាដើម។

**[ជាងឈើពុម្ព]** → សូមមើល 3.2.14

## 3.2.20 ការងារដំបូល

ផ្ទះជប៉ុនជាច្រើនប្រើសម្ភារដំបូលហៅថា "ក្បឿង"។ ក្បឿងធ្វើពីដីឥដ្ឋបង្កើតជាទ្រង់ទ្រាយហើយដុតដោយឡ។ សម្ភារដំបូលក៏មានជាសន្លឹកលោហៈ និងវត្ថុធាតុដើមផ្សេងទៀតដែរ។ ទោះបីប្រើវត្ថុធាតុដើមណាក៏ដោយ គឺទាមទារចំណេះដឹងនិងបច្ចេកទេសសំណង់ពាក់ព័ន្ធនឹងការងារធ្វើកុំឲ្យភ្លៀងជ្រាបចូល(ហៅថា "អាម៉ាជិម៉ៃ")។

ការងារដំបូលមិនមែនតែប្រក់ដំបូលនោះទេ គឺធ្វើការងារដូចខាងក្រោម។


ការងារជួសជុលកំបោរ

**[ការងារប្រក់ប្តូរដំបូល]** ដកចេញសម្ភារដំបូលនិងផ្ទាំងការពារជម្រាបទឹកដែលមានស្រាប់ ហើយប្រក់សម្ភារដំបូលថ្មី។

**[ការងារប្រក់ត្រួតដំបូល]** ជាការងារប្រក់សម្ភារដំបូលថ្មីពីលើដំបូលដែលមានស្រាប់។

**[ការងារជួសជុលកំបោរជប៉ុន]** ដើម្បីការពារផ្នែកដែលលេចចេញជាដើមនៃដីដែលប្រើដើម្បីប្រក់ក្បឿង គេប្រើសម្ភារម្យ៉ាងហៅថា "កំបោរ"។ ការងារជួសជុលកំបោរចាំបាច់ត្រូវធ្វើជាទៀងទាត់។




**[ការងារប្តូរទបង្ហូរទឹកភ្លៀង]** ជាការងារប្តូរទបង្ហូរទឹកភ្លៀងដែលខូច។

**[ការងារលាបថ្នាំដំបូល]** ជាការងារលាបថ្នាំដំបូល។ គេធ្វើវាពេលសម្ភារដំបូងដែលមានស្រាប់ បាន
បាត់បង់
មុខងារការពារជម្រាបទឹក។

### 3.2.21 ការងារលោហៈបន្ទះសំណង់

ការងារកែច្នៃបន្ទះលោហៈដើម្បីបង្កើតផលិតផលលោហៈចាំបាច់សម្រាប់សំណង់ ហើយបំពាក់ទៅសំណង់ហៅថា "ការងារលោហៈបន្ទះសំណង់"។ បន្ទះលោហៈគឺប្រើរបស់ដែលស្តើងជាចម្បង។ គេធ្វើការកែច្នៃដូចជា កាត់ បត់ពត់ ប្តូររូបរាង ក្រាលភ្ជាប់។ល។ ក្នុងការងារលោហៈបន្ទះសំណង់ អនុវត្តការងារដូចខាងក្រោម។




**[ការងារដំបូល]** ការភ្ជាប់ដំបូលទៅនឹងសំណង់ហៅថា "ការប្រក់ដំបូល"។ សម្ភារដំបូលមានប្រភេទផ្សេងៗដូចជា "ក្បឿង" ជាដើម ប៉ុន្តែជាពិសេសការងារប្រក់ដំបូលដោយប្រើបន្ទះដែកគឺជាការងារលោហៈបន្ទះសំណង់។ ម្យ៉ាងទៀត ដើម្បីការពារសំណង់ពីទឹកភ្លៀងដែលធ្លាក់ពីលើដំបូល ចាំបាច់ត្រូវបញ្ចេញទឹកភ្លៀងជាលក្ខណៈផែនការ។ ការងារនេះហៅថា "អាម៉ាជិម៉ៃ"។ ការកែច្នៃនិងបំពាក់គ្រឿងលោហៈដែលចាំបាច់សម្រាប់អាម៉ាជិម៉ៃ ក៏ជាការងារលោហៈបន្ទះសំណង់ដែរ។



**[ការងារបំពង់ផ្លូវខ្យល់]** បំពង់ដឹកនាំខ្យល់ហៅថាបំពង់ផ្លូវខ្យល់។ បំពង់ផ្លូវខ្យល់ក៏ត្រូវបានហៅថាផ្លូវខ្យល់ដែរ ហើយមានបំពង់បញ្ចេញផ្សែងដែលនាំផ្សែងទៅខាងក្រៅពេលកើតមានអគ្គីភ័យ បំពង់កំណត់បរិយាកាសដែលនាំខ្យល់ត្រជាក់/ខ្យល់ក្ដៅ/ខ្យល់ស្រស់ថ្លាពីខាងក្រៅមកខាងក្នុង បំពង់បញ្ចេញខ្យល់ដែលបញ្ចេញកម្ដៅនិងក្លិនមិនល្អដែលកើតមាននៅបន្ទប់ម៉ាស៊ីន/បន្ទប់អគ្គិសនី/បង្គន់ជាដើម ចេញទៅខាងក្រៅ។


បំពង់បញ្ចេញខ្យល់នៃបរិក្ខារផលិតអគ្គិសនីក្នុងផ្ទះ

**[ការងារជញ្ជាំងខាងក្រៅ]** គេអនុវត្តការងារជញ្ជាំងខាងក្រៅនៃសំណង់ដោយប្រើសម្ភារជញ្ជាំងដូចជាបន្ទះជញ្ជាំងខាងក្រៅនិងបន្ទះមានភ្លីជាដើម។

**[ស្លាកយីហោនិងគ្រឿងលោហៈ]** ការកែច្នៃនិងដំឡើងស្លាកយីហោនិងគ្រឿងលោហៈដែលប្រើនៅកន្លែងផ្សេងៗ ក៏ជាការងារលោហៈបន្ទះសំណង់ដែរ។ គ្រឿងលោហៈដែលប្រើនៅកន្លែងមើលឃើញគឺទាមទារភាពស្រស់ស្អាតមិនមែនត្រឹមតែភាពសុក្រឹតឡើយ។


ការងារការ៉ូ

### 3.2.22 ការងារក្រាលការ៉ូ

ការងារក្រាលភ្ជាប់ការ៉ូទៅនឹងជញ្ជាំង កម្រាលបាតហៅថា "ការងារក្រាលការ៉ូ"។

### 3.2.23 ការងារសម្រេចផ្ទៃខាងក្នុង

ការងារផ្ទៃខាងក្នុងសំណង់ហៅថា "ការងារសម្រេចផ្ទៃខាងក្នុង" ។


ការងារស្រទាប់បាត ធ្វើពីដែក

**[ការងារស្រទាប់បាតធ្វើពីដែក]** ជាការងារបង្កើតគ្រោងឆ្អឹងនៃជញ្ជាំងនិងពិដានដោយប្រើសម្ភារដែលហៅថា LGS(Light Gauge Steel ឬ Light Gauge Stud)។ ការសាងសង់គ្រោងឆ្អឹងនេះក៏ហៅថា "កេតេនកូជិ" ផងដែរ។ LGS ជួនកាលត្រូវបានគេហៅថា "Stud (សសរឆ្អឹង)" ។

**[ការបិទបន្ទះម្នាងសិលា]** ជាការងារបិទបន្ទះម្នាងសិលាលើស្រទាប់បាតធ្វើពីដែក។ ដើម្បីកុំឲ្យថ្នេរតភ្ជាប់បន្ទះម្នាងសិលាលេចចេញច្បាស់ពេលបិទក្រដាសបិទជញ្ជាំងលើបន្ទះម្នាងសិលា ថ្នេរតភ្ជាប់បន្ទះម្នាងសិលាត្រូវបៀកឲ្យរាបរលោងដោយថ្នាំបៀក។



ការបិទបន្ទះម្នាងសិលា

**[ការបិទក្រដាសបិទជញ្ជាំង]** ជាការងារបិទក្រដាសបិទជញ្ជាំងដែលជាសម្ភារសម្រេច លើស្រទាប់បាតដែលប្រើបន្ទះម្នាងសិលា។

**[ការសម្រេចដោយលាបបាញ់ថ្នាំ]** ជាការងារសម្រេចដោយប្រើថ្នាំពណ៌ជំនួសក្រដាសបិទជញ្ជាំង។

**[ការសម្រេចកម្រាលបាត]** ជាការងារក្រាលការ៉ូ កម្រាលព្រំ កន្ទេលតាតាមិជាដើមលើកម្រាលបាត។

**[ការងាររាំងនន]** កាត់ក្រណាត់ដេរភ្ជាប់ធ្វើរាំងននហើយដំឡើង។ ក៏អនុវត្តការងាររាំងនន(រាំងននខ្នាតធំ)ដែលប្រើនៅឆាកជាដើមដែរ។

**[ការសម្រេចកម្រាលបាត (ការ៉ូជ័រPVC)]** ជាការងារកែច្នៃវត្ថុធាតុដើមស្របតាមទ្រង់ទ្រាយជញ្ជាំង។



ការសម្រេចកម្រាលបាតដោយជ័រPVC

## 3.2.24 ការងារផ្ទៃលើនៃផ្ទៃខាងក្នុង

ក្នុងចំណោមការងារសម្រេចផ្ទៃខាងក្នុងនៃសំណង់ដែលពន្យល់នៅ 3.2.23 ការងារដែលមិនរាប់បញ្ចូលស្រទាប់បាតធ្វើពីដែកនិងការបិទបន្ទះម្នាងសិលាហៅថា "ការងារផ្ទៃលើនៃផ្ទៃខាងក្នុង" ។ ជាចម្បងគេអនុវត្តការងារសម្រេចជញ្ជាំង ពិដាន កម្រាលបាត។ វិធីសាស្ត្រសម្រេចមានផ្សេងៗទៅតាមវត្ថុធាតុដើមដែលប្រើ។

**[ការសម្រេចជញ្ជាំង (ក្រដាសបិទជញ្ជាំង)]** បិទក្រដាសបិទជញ្ជាំងលើបន្ទះម្នាងសិលា។ មុខតំណនៃបន្ទះម្នាងសិលាត្រូវបៀកឲ្យរាបរលោងដោយថ្នាំបៀកដើម្បីកុំឲ្យចេញកំពីកកំពកពេលបិទក្រដាសបិទជញ្ជាំង។






**[ការសម្រេចពិដាន (ក្រដាសបិទជញ្ជាំង)]** ជាការងារដែលបែរមុខទៅលើ ហើយត្រូវការបច្ចេកទេសបិទដោយពន្លាក្រដាសបិទជញ្ជាំងកុំឲ្យមានផ្នត់។






### 3.2.25 ការងារទ្វារបង្អួច

សំណង់មានផ្នែកមាត់ច្រកជាច្រើន។ ទ្វារ បង្អួច ទ្វាររុញហ្វ៊ូស៊ុម៉ា ទ្វាររុញស្បូជិជាដើមដែលដំឡើងនឹងផ្នែកមាត់ច្រកទាំងនោះ ព្រមទាំងស៊ុមសម្រាប់ដំឡើងពួកវា ហៅថា "ទ្វារបង្អួច"។ ទ្វារបង្អួចមានធ្វើពីឈើ ធ្វើពីអាលុយមីញ៉ូមដូចជាស៊ុមទ្វារបង្អួចជាដើម ធ្វើពីជ័រ ធ្វើពីដែក និងអ៊ីណុក ។ល។ ការងារដំឡើងទ្វារបង្អួចដែលផលិតនៅរោងចក្រនៅការដ្ឋានហៅថា "ការងារទ្វារបង្អួច"។ ការងារទ្វារបង្អួចរួមទាំងការងារដំឡើងទ្វាររមូរ និងការងារដំឡើងទ្វារស្វ័យប្រវត្តិផងដែរ។



### 3.2.26 ការងារស៊ុមទ្វារបង្អួចលោហៈ

ក្នុងចំណោមទ្វារបង្អួច ការងារដំឡើងទ្វារបង្អួចលោហៈហៅថា "ការងារស៊ុមទ្វារបង្អួចលោហៈ"។ មិនមែនតែស៊ុមទ្វារបង្អួចអាលុយមីញ៉ូមដែលដំឡើងនៅបង្អួចទេ គឺរួមបញ្ចូលទាំងការងារដំឡើងទ្វារបង្អួចលោហៈដូចជាទ្វារបន្ទប់ទឹក ទ្វារសំណាញ់ ជញ្ជាំងខណ្ឌជាដើម។

### 3.2.27 ការងារការពារកម្ដៅដោយអ៊ុយរ៉េតាន(Urethane)សម្រាប់បាញ់

ស្នោអ៊ុយរ៉េតាន(Urethane)រឹងមានប្រសិទ្ធភាពការពារកម្ដៅ ដូច្នេះគេប្រើវាជាសម្ភារការពារកម្ដៅសម្រាប់សំណង់។ "ការងារការពារកម្ដៅដោយអ៊ុយរ៉េតាន(Urethane)សម្រាប់បាញ់" ជាការងារបាញ់ថ្នាំរាវដើមសម្រាប់ការងារការពារកម្ដៅដោយអ៊ុយរ៉េតាន(Urethane)សម្រាប់បាញ់ដោយផ្ទាល់លើគ្រឿងបង្គុំជាដើមដោយប្រើម៉ាស៊ីនបាញ់ពិសេសបង្កើតជាស្នោអ៊ុយរ៉េតាន(Urethane)រឹងនៅការដ្ឋាន។ តាមរយៈវិធីសាស្ត្រនេះ អាចបង្កើតស្រទាប់ការពារកម្ដៅដែលគ្មានចន្លោះ។



ការងារការពារកម្ដៅដោយអ៊ុយរ៉េតាន(Urethane)សម្រាប់បាញ់

មុនធ្វើការងារ គេពិនិត្យកំហាប់នៃពពុះដោយបាញ់សាកល្បងលើបន្ទះរាងការ៉េមានជ្រុងប្រហែល 450mm។ កំលុងពេលធ្វើការងារ គេពិនិត្យកម្រាស់ដោយប្រើម៉ាស៊ីនវាស់កម្រាស់អ៊ុយរ៉េតាន(Urethane)ក្នុងចន្លោះ 4-5m។

### 3.2.28 ការងារការពារជម្រាបទឹក

ការងារដើម្បីកុំឲ្យទឹកភ្លៀងឬព្រិលជ្រាបចូលផ្នែកខាងក្នុងសំណង់ហៅថា "ការងារការពារជម្រាបទឹក"។ ការងារការពារជម្រាបទឹកអាចបែងចែកជាធំៗជា 5ប្រភេទទៅតាមវត្ថុធាតុដើមដែលប្រើ។

**[ការងារការពារជម្រាបទឹកដោយអ៊ុយរ៉េតាន(Urethane)]** ជាវិធីសាស្ត្រការពារជម្រាបទឹកដោយលាបសម្ភារការពារជម្រាបទឹកដែលមានលក្ខណៈរាវ លើផ្ទៃត្រូវធ្វើការងារ។ វិធីនេះអាចការពារជម្រាបទឹកនៅកន្លែងដែលមានទ្រង់ទ្រាយស្មុគស្មាញបាន។ ក្រៅពីការការពារជម្រាបទឹកនៅរ៉ង់ដារានហាល ដំបូលជាដើម វាក៏សក្ដិសមនឹងការជួសជុលកន្លែងដែលលេចជ្រាបទឹកភ្លៀងដែរ។

**[ការងារការពារជម្រាបទឹកដោយ FRP]** ជាវិធីសាស្ត្រដែលក្រាលកម្រាលសរសៃកញ្ចក់(glass fiber) ហើយលាបជ័រប៉ូលីអេស្ទ័រ(polyester)ពីលើ។ វាមានលក្ខណៈពិសេសគឺធន់ ហើយអាចស្ងួតលឿន។

**[ការងារការពារជម្រាបទឹកដោយផ្ទាំង]** ជាវិធីសាស្ត្របិទភ្ជាប់ផ្ទាំងជ័រកៅស៊ូសំយោគឬជ័រឈើសំយោគដោយប្រើកាវ។ វិធីនេះអាចអនុវត្តការងារលើផ្ទៃធំទូលាយក្នុងពេលតែមួយបាន។


ការការពារជម្រាបទឹកដោយផ្ទាំងកៅស៊ូ(asphalt)

**[ការងារការពារជម្រាបទឹកដោយកៅស៊ូ(Asphalt)]** ជាវិធីសាស្ត្រដែលក្រាលផ្ទៃបាតដោយផ្ទាំងដែលបានដោយស្រោចកៅស៊ូ(asphalt) លើក្រណាត់សរសៃសំយោគ។ ដើម្បីធ្វើឲ្យផ្ទាំងស្អិតជាប់ល្អនឹងផ្ទៃបាត គេលាបផ្ទៃបាតដោយថ្នាំលាបទ្រនាប់(asphalt primer) រួចទើបក្រាលផ្ទាំង។

**[ការងារការពារជម្រាបទឹកដោយបិទភ្ជិត]** ជាវិធីសាស្ត្រដើម្បីការពារជម្រាបនៅចន្លោះនៃផ្នែកតភ្ជាប់រវាងសម្ភារ។ គេលាបថ្នាំលាបទ្រនាប់(primer)នៅចន្លោះរួចបិទភ្ជិតដោយសម្ភារបិទភ្ជិត។


ការងារការពារជម្រាបទឹកដោយបិទភ្ជិត

### 3.2.29 ការងារថ្ម

ការងារកែច្នៃថ្មដែលយកពីតំបន់នានាលើពិភពលោកហើយដំឡើងនៅកន្លែងដែលត្រូវការហៅថា "ការងារថ្ម"។

ថ្មដែលប្រើគឺមិនមែនតែថ្មធម្មជាតិដូចជា "ថ្មម៉ាប" និង "ថ្មក្រានីត" ជាដើមទេ គឺទាំង "ថ្មសិប្បនិម្មិត" ដែលស្រដៀងថ្ម និង "ឥដ្ឋបេតុង" ជាដើមផងដែរ។


ការងាររៀបឥដ្ឋបេតុង


ការកែច្នៃថ្មរាងមិនទៀងទាត់

### 3.2.30 ការងារបរិក្ខារអគ្គិសនី

ការងារពាក់ព័ន្ធនឹងតង់ស្យុងខ្ពស់គឺគ្រោះថ្នាក់ណាស់។ ហេតុនេះ មានការងារជាច្រើនដែលមិនអាចធ្វើបានបើគ្មានគុណវុឌ្ឍិត្រូវបានទទួលស្គាល់គឺ "អ្នកជំនាញការងារអគ្គិសនី"។ គុណវុឌ្ឍិ អ្នក

ជំនាញការងារអគ្គិសនី មានកម្រិត1 និងកម្រិត2។ ដើម្បីធ្វើការងារអគ្គិសនីឱ្យបានគ្រប់គ្រាន់នៅអគារនិងរោងចក្រធំៗ ត្រូវការគុណវុឌ្ឍិកម្រិត1។ ការងារអគ្គិសនីអាចបែងចែកធំៗជា 2 បើប្រើឈ្មោះហៅទូទៅគឺ "ការងារខ្សែខាងក្រៅ" និង "ការងារខ្សែខាងក្នុង"។

**[ការងារខ្សែខាងក្រៅ]** តភ្ជាប់ខ្សែភ្លើងដោយបង្គោលភ្លើង ក្រោមដីជាដើម ដើម្បីផ្គត់ផ្គង់អគ្គិសនីដល់ក្នុងអគារ។ ការរត់ខ្សែចូលក្នុងអគារដោយប្រើបង្គោលភ្លើងហៅថា "ការរត់ខ្សែលើអាកាស" ។


ការងាររត់ខ្សែលើអាកាស

**[ការងារខ្សែខាងក្នុង]** គេអនុវត្តការងារផ្សេងៗដើម្បីប្រើប្រាស់អគ្គិសនីក្នុងអគារ។ ការងារជាតំណាងមានដូចខាងក្រោម។

- ការងារខ្សែដីដើម្បីការពារឆក់ខ្សែភ្លើង ការពារការលេចធ្លាយអគ្គិសនី
- ការងារបរិក្ខារទទួលនិងបំប្លែងអគ្គិសនី
- ការងារបរិក្ខារអគ្គិសនី
- ការងារបរិក្ខារស្តុកថាមពលអគ្គិសនី
- ការងារបរិក្ខារផលិតអគ្គិសនី
- ការងារដំឡើងបន្ទះចែកចាយអគ្គិសនី
- ការផ្គត់ផ្គង់អគ្គិសនីទៅបរិក្ខារម៉ាស៊ីនត្រជាក់និងកម្តៅ
- ការងារបរិក្ខារបំភ្លឺ
- ការងាររត់ខ្សែ/ដំឡើងដូចជាកុងតាក់ ព្រីជាដើម


ការដំឡើងប្រអប់ព្រី

## 3.2.31 ការងារទូរគមនាគមន៍

ក្នុងចំណោមការងារអគ្គិសនី ការងារដែលពាក់ព័ន្ធនឹងបរិក្ខារបញ្ជូនព័ត៌មានដូចជា ទូរសព្ទ ទូរទស្សន៍ និងអ៊ីនធឺណិតជាដើមគឺហៅថា "ការងារទូរគមនាគមន៍"។ វិធីសាស្ត្របញ្ជូនព័ត៌មានមានវិធីសាស្ត្រមានខ្សែដែលប្រើខ្សែកាប និងវិធីសាស្ត្រគ្មានខ្សែដែលប្រើរលកវិទ្យុ។ ខ្សែកាបចែកចេញជាខ្សែកាបលោហៈដែលប្រើខ្សែទង់ដែង និងខ្សែកាបអុបទិកដែលប្រើហ្វាយប៊ឺរអុបទិក។

ហេតុនេះ មានការងារដែលមិនអាច

អនុវត្តបានឡើយបើគ្មានគុណវុឌ្ឍិទទួលស្គាល់ដូចជា "អ្នកជំនាញដំឡើង" "វិស្វករបង្គោលទូរគមនាគមន៍"។


ការងារតភ្ជាប់ខ្សែកាបអុបទិក

### 3.2.32 ការងាររត់បំពង់

ជាការងារដើម្បីបញ្ជូនទឹក ប្រេង ហ្គាស ចំហាយទឹក ជាដើម ទៅកន្លែងដែលត្រូវការដោយប្រើបំពង់លោហៈជាដើម។ វាក៏រួមបញ្ចូលទាំងការរត់បំពង់សម្រាប់ការផ្គត់ផ្គង់ទឹក ប្រព័ន្ធលូ ឧបករណ៍ពន្លត់អគ្គីភ័យ ម៉ាស៊ីនខ្យល់ត្រជាក់ក្នុងបន្ទប់ និងម៉ាស៊ីនត្រជាក់ជាដើម។

ជំនាញជាមូលដ្ឋានដែលទាមទារគឺ កាត់សម្ភារបំពង់ (ការកាត់) ការតបំពង់និងបំពង់ (ការត) ការផ្គុំបំពង់ ឱ្យបានត្រឹមត្រូវ។


ការងាររត់បំពង់

### 3.2.33 ការងារម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់

ម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់ សំដៅលើម៉ាស៊ីនឧបករណ៍ដែលប្រើប្រាស់សារធាតុធ្វើឲ្យត្រជាក់ដូចជាម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបង្កកប្រភេទផ្សេងៗជាដើម។
ការងារម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់រួមមានការងារដោះបំបែក ផ្គុំដំឡើង លៃតម្រូវ និងរត់បំពង់ សម្រាប់ម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់ ដូចជាឧបករណ៍បង្កក/ឧបករណ៍ធ្វើឲ្យខ្យល់ត្រជាក់/ម៉ាស៊ីនបង្កក/ម៉ាស៊ីនកំណត់បរិយាកាសក្នុងបន្ទប់បែបជាកញ្ចប់និងបែបដាច់ពីគ្នា/ម៉ាស៊ីនត្រជាក់សម្រាប់គេហដ្ឋាន/ទូទឹកកកសម្រាប់អាជីវកម្ម/ទូត្រជាក់និងបង្កកតាំងបង្ហាញ/ម៉ាស៊ីនក្លាសេនិងបង្កកសម្រាប់ការដឹកជញ្ជូនជាដើម។

### 3.2.34 ការងារបរិក្ខារផ្គត់ផ្គង់ទឹកស្អាតបញ្ចេញចោលទឹកកាកសំណល់និងអនាម័យ

បរិក្ខារដែលប្រើប្រាស់ទឹក ទឹកក្តៅ ដើម្បីអគារឲ្យស្អាតមានអនាម័យ និងទ្រទ្រង់ការរស់នៅរបស់ប្រជាជនដោយសុវត្ថិភាពនិងផាសុកភាពហៅថា "បរិក្ខារផ្គត់ផ្គង់ទឹកស្អាតបញ្ចេញចោលទឹកកាកសំណល់និងអនាម័យ"។

**[ការងារបរិក្ខារផ្គត់ផ្គង់ទឹកស្អាត]** គឺម៉ាស៊ីនបូមនិងអាងទទួលទឹកនិងការរត់បំពង់ដែលសម្រាប់ផ្គត់ផ្គង់ទឹកដែលត្រូវបានផ្គត់ផ្គង់ពីបំពង់មេនាំទឹកតាមរយៈបំពង់ចែកចាយទឹក ទៅកាន់បង្គន់

និងផ្ទះបាយជាដើម។

**[ការងារបរិក្ខារបញ្ចេញចោលទឹកកាកសំណល់និងខ្យល់ចេញចូល]** អនុវត្តការងារបង្ហូរទឹកកខ្វក់ពីបង្គន់ និងផ្ទះបាយ ចូលទៅក្នុងបំពង់លូមេ។



បង្គន់

**[ការងារបរិក្ខារផ្គត់ផ្គង់ទឹកក្ដៅ]** អនុវត្តការងារដែលកម្ដៅទឹកហើយផ្គត់ផ្គង់ទឹកក្ដៅ។

**[ការងារឧបករណ៍បរិក្ខារអនាម័យ]** អនុវត្តការងារដំឡើងចានបង្គន់ ឡាបូលាងមុខជាដើម។

## 3.2.35 ការងាររក្សាកម្ដៅរក្សាភាពត្រជាក់

ជាការងារដែលធ្វើឲ្យរបស់ដែលក្ដៅមិនចុះត្រជាក់ របស់ដែលត្រជាក់មិនឡើងក្ដៅ។ តាមរយៈការបំពាក់សម្ភាររក្សាកម្ដៅ/រក្សាភាពត្រជាក់(សម្ភារដែលមិនងាយចម្លងកម្ដៅ) ទៅនឹងបំពង់ផ្លូវខ្យល់និងបំពង់ចែកចាយ នោះនឹងអាចកាត់បន្ថយការបាត់បង់កម្ដៅ ហើយកាត់បន្ថយចំណាយឥន្ធនៈបាន។ ម្យ៉ាងទៀត ការបំពាក់សម្ភាររក្សាកម្ដៅលើផ្ទៃវត្ថុដែលក្ដៅ នឹងក្លាយជា "វិធានការសុវត្ថិភាព" ដែលការពាររលាក។




ការរក្សាកម្ដៅរក្សាភាពត្រជាក់ចំពោះបំពង់

## 3.2.36 ការងារសាងសង់ឡ

គឺជាការសាងសង់និងថែទាំបរិក្ខារដែលដុតឬរំលាយវត្ថុផ្សេងៗដោយផ្ដល់កម្ដៅ។

**[ឡដុត]** ឡសម្រាប់ដុតសំរាមពីគេហដ្ឋាន និងកាកសំណល់ឧស្សាហកម្មជាដើម។

**[ឡដែក]** ឡសម្រាប់រំលាយដែក។ រំលាយដែកដោយកម្ដៅពេលដុតធ្យូងកូក។

**[ឡដុតបន្ទន់(Annealing)]** ឡសម្រាប់ធ្វើឱ្យវត្ថុធាតុលោហៈមានលក្ខណៈស្មើសាច់។

**[ឡបំបាត់ក្លិនស្អុយ]** ឡសម្រាប់កម្ចាត់ក្លិនស្អុយរបស់ឧស្ម័នបញ្ចេញចោលដែលមានក្លិនស្អុយ។

**[ឡរំលាយអាលុយមីញ៉ូម]** ឡសម្រាប់រលាយសំណល់កម្ទេចអាលុយមីញ៉ូម និងដុំអាលុយមីញ៉ូមសុទ្ធដើម្បីផលិតផលិតផល។ អាលុយមីញ៉ូមដែលបានរលាយហៅថាអាលុយមីញ៉ូរលាយ។

### 3.2.37 ការងារបរិក្ខារការពារអគ្គីភ័យ




ជាការងារបរិក្ខារដែលចាំបាច់ដើម្បីកាត់បន្ថយការខូចខាតដល់អគារ មនុស្ស និងទ្រព្យសម្បត្តិ ឲ្យដល់កម្រិតទាបបំផុតក្នុងករណីមានគ្រោះមហន្តរាយដូចជាអគ្គីភ័យជាដើម។

**[បរិក្ខារពន្លត់អគ្គីភ័យ]** បរិក្ខារដូចជា បរិក្ខារដែលអ្នកស្នាក់នៅក្នុងអគារអាចធ្វើសកម្មភាពពន្លត់បាន (បំពាក់នៅផ្លូវដើរជាដើម) ឧបករណ៍បាចសាចទឹកជាដើម។

**[បរិក្ខារប្រកាសអាសន្ន]** បរិក្ខារដូចជាបរិក្ខារប្រកាសអាសន្នដែលចាប់ដឹងផ្សែងនិងកម្ដៅដោយស្វ័យប្រវត្តិ កណ្ដឹងអាសន្ន និងការផ្សព្វផ្សាយអាសន្នជាដើម។

**[បរិក្ខារជម្លៀស]** ឧបករណ៍សម្រាប់ជម្លៀសនៅពេលមានអគ្គីភ័យ។ គេដំឡើងស្លាយរអិលឬជណ្ដើរសម្រាប់ជម្លៀស។

### 3.2.38 ការងាររុះរើ

អគារនិងសំណង់ ចាំបាច់ត្រូវសាងសង់ឡើងវិញឬរុះរើចេញដោយសារចាស់លែងប្រើបានជាដើម។ ការងាររុះរើអគារឬសំណង់ត្រូវបានហៅថា "ការងាររុះរើ"។ ការងាររុះរើនៅតំបន់ដែលមានមនុស្សរស់នៅច្រើនឬកន្លែងដែលមានមនុស្សឆ្លងកាត់ច្រើន ចាំបាច់ត្រូវយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់លើរញ្ជួរ សំឡេងរំខាន និងការធ្លាក់នៃវត្ថុដែលរុះរើជាដើម។ វត្ថុធាតុសំណល់ដែលបានរុះរើ ហៅថា "កម្ទេចកម្ទីរុះរើ"។ កម្ទេចកម្ទីរុះរើត្រូវបានបែងចែកជាបេតុង ដែក ជាដើម ហើយបោះចោល។






## 3.3 គុណវុឌ្ឍិចាំបាច់សម្រាប់ការងារសំណង់

ក្នុងការងារសំណង់មានការងារដែលត្រូវការប័ណ្ណអនុញ្ញាត(ពែកមី) និងការងារដែលមិនត្រូវធ្វើដោយមិនបានទទួលការការបណ្តុះបណ្តាលជំនាញឬការបណ្តុះបណ្តាលពិសេស។

### 3.3.1 ប្រភេទនៃគុណវុឌ្ឍិដោយផ្អែកលើច្បាប់ស្តីពីសុវត្ថិភាពអនាម័យការងារ

គុណវុឌ្ឍិដោយផ្អែកលើច្បាប់ស្តីពីសុវត្ថិភាពអនាម័យការងារមាន 3 ប្រភេទគឺ "គុណវុឌ្ឍិជាតិដែលប័ណ្ណអនុញ្ញាត(ពែកមី)ជាតិត្រូវបានចេញជូន" "ការបណ្តុះបណ្តាលជំនាញ" និង "ការបណ្តុះបណ្តាលពិសេស" ។ ការបណ្តុះបណ្តាលជំនាញគឺជាការបណ្តុះបណ្តាលជំនាញដែលធ្វើឡើងដោយស្ថាប័នដែលបានចុះបញ្ជីនៅមន្ទីរការងាររាជធានីខេត្តនីមួយៗ។ សម្រាប់ការងារដែលកំណត់ដោយច្បាប់ស្តីពី

សុវត្ថិភាពអនាម័យការងារ ចាំបាច់ត្រូវចាត់តាំងឲ្យមាន "ប្រធានក្រុមការងារ" នៅការដ្ឋានដើម្បីដឹកនាំនិយោជិតដែលធ្វើការងារនោះ។

# មេរៀនទី 4 គារវកិច្ច ពាក្យបច្ចេកទេស និងប្រការប្រុងប្រយ័ត្នក្នុងការរស់នៅជុំគ្នានៅការដ្ឋានសំណង់

នៅការដ្ឋានសំណង់ ពាក្យនិងពាក្យបច្ចេកទេសពិសេសៗដែលកម្រប្រើក្នុងជីវិតប្រចាំថ្ងៃត្រូវបានប្រើប្រាស់។ ការយល់ដឹងពាក្យទាំងនេះ មិនត្រឹមតែសម្រាប់ធ្វើឲ្យទំនាក់ទំនងរលូនប៉ុណ្ណោះទេ គឺថែមទាំងសំខាន់ក្នុងការជំរុញការងារឲ្យមានសុវត្ថិភាព និងមានប្រសិទ្ធផលផងដែរ។

## 4.1 គារវកិច្ច/ការហៅនៅគ្រាអាសន្ន

មនុស្សងាយនឹងមានអារម្មណ៍ល្អចំពោះដៃគូដែលធ្វើគារវកិច្ចចំពោះពួកគេ។ម្យ៉ាងទៀត អាស្រ័យលើពាក្យដែលអ្នកនិយាយទៅកាន់ដៃគូ វាក៏មានឥទ្ធិពលធ្វើឱ្យដៃគូមានអារម្មណ៍វិជ្ជមានផងដែរ។ ទោះបីជាអ្នកមិនស្គាល់ដៃគូក៏ដោយ ក៏សូមធ្វើគារវកិច្ចចំពោះពួកគេដោយស្វាហាប់។

### 4.1.1 "អរុណសួស្តី"(Ohayogozaimasu)

"អរុណសួស្តី" (Ohayogozaimasu)គឺជាមូលដ្ឋាននៃគារវកិច្ចនៅពេលព្រឹក។ សូមនិយាយថា "អរុណសួស្តី"(Ohayogozaimasu) ទៅកាន់មនុស្សដែលអ្នកជួបជាលើកដំបូងនៅពេលព្រឹក។

### 4.1.2 "សូមឲ្យមានសុវត្ថិភាព"(Goanzenni)

មានគ្រោះថ្នាក់ជាច្រើននៅការដ្ឋានសំណង់។ ការប្រើប្រាស់ពាក្យ "សូមឲ្យមានសុវត្ថិភាព" (Goanzenni) នេះមិនត្រឹមតែគិតពីសុវត្ថិភាពខ្លួនឯងប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីក្តីសង្ឃឹមថានឹងមិនមានគ្រោះថ្នាក់ឬរបួសដល់ដៃគូម្ខាងទៀត ហើយការងារប្រចាំថ្ងៃនឹងប្រព្រឹត្តទៅដោយរលូន។ ដោយសារវាជាពាក្យដែលបង្ហាញពីអារម្មណ៍នៃការយកចិត្តទុកដាក់ចំពោះដៃគូ ដៃគូដែលត្រូវបានគេនិយាយដាក់ក៏អាចធ្វើការជាមួយនឹងអារម្មណ៍វិជ្ជមានផងដែរ។

ជាឧទាហរណ៍ នៅពេលបញ្ចប់កិច្ចប្រជុំពេលព្រឹក គេចាប់ផ្តើមការងារដោយបួងសួងឲ្យមិនជួបបញ្ហាអ្វីឲ្យគ្នាទៅវិញទៅមកដោយគ្រប់គ្នានិយាយថា "សូមឲ្យសុវត្ថិភាពពេញមួយថ្ងៃនៅថ្ងៃនេះផងដែរ!" (Kyo mo ichinichi goanzenni)។ សូមនិយាយថា "សូមឲ្យសុវត្ថិភាព!" (Goanzenni) ទាំងពេលអ្នកដើរកាត់មនុស្សដែលកំពុងតែនឹងចាប់ផ្តើមការងារដ៏គ្រោះថ្នាក់ណាមួយ។ ដៃគូម្ខាងទៀតអាចទៅការដ្ឋានដោយមានអារម្មណ៍ល្អ និងប្រយ័ត្នប្រយែងពីសុវត្ថិភាព។

### 4.1.3 "អ្នកបាននឿយហត់ហើយ"(Otsukaresamadesu)

"អ្នកបាននឿយហត់ហើយ"(Otsukaresamadesu) គឺជាពាក្យដែលបង្ហាញការគោរពអរគុណចំពោះការងារនិងភាពលំបាករបស់ដៃគូ។ ខុសពី "សូមឲ្យសុវត្ថិភាព!" (Goanzenni) "អ្នកបាននឿយហត់ហើយ"(Otsukaresamadesu) អាចប្រើមិនត្រឹមតែនៅការដ្ឋានសំណង់ប៉ុណ្ណោះទេ ប៉ុន្តែនៅគ្រប់ទីកន្លែងដែលមានបុគ្គលិកធ្វើការ។ វាក៏អាចប្រើនៅពេលដែលអ្នកដើរកាត់ជួបគ្នានៅក្នុងទីស្នាក់ការកន្លែងសម្រាក ឬនៅផ្លូវដើរ ជាដើម។ សូមនិយាយដោយស្វាហាប់ថា "អ្នកបាននឿយហត់ហើយ" (Otsukaresamadesu) ចំពោះអ្នកដែលរៀបនឹងត្រលប់ទៅផ្ទះបន្ទាប់ពីធ្វើការងារចប់។

### 4.1.4 "សូមអរគុណចំពោះការខិតខំរបស់អ្នក"(Gokurou-sama)

"សូមអរគុណចំពោះការខិតខំរបស់អ្នក"(Gokurou-sama) គឺជាពាក្យដែលបង្ហាញការអរគុណសម្រាប់អ្វីដែលដៃគូបានធ្វើសម្រាប់អ្នក។ ពាក្យនេះក៏អាចប្រើចំពោះឋានៈខ្ពស់ជាងដូចជាអ្នកគ្រប់គ្រងការដ្ឋាន មេការ និងរៀមច្បងជាដើមដែរ ប៉ុន្តែប្រជាជនជប៉ុនជាច្រើនហាក់គិតថាវាមិនសមរម្យក្នុងការប្រើវានិយាយទៅកាន់មនុស្សមានឋានៈខ្ពស់ជាងឡើយ។ ជាការល្អសូមកុំប្រើពាក្យ "សូមអរគុណចំពោះការខិតខំរបស់អ្នក"(gokaratsu-sama) ចំពោះមនុស្សមានឋានៈខ្ពស់ជាង។

ផ្ទុយមកវិញ ប្រសិនបើត្រូវបានមនុស្សមានឋានៈខ្ពស់ជាងនិយាយដាក់ថា "សូមអរគុណចំពោះការខិតខំរបស់អ្នក"(gokaratsu-sama) នោះមានន័យថាគេថ្លែងអំណរគុណចំពោះអ្នក។ សូមឆ្លើយតបដោយស្វាហាប់ថា "អរគុណច្រើន!"( Arigatogozaimasu!)។

### 4.1.5 "សុំអភ័យទោស"(Shitsureishimasu)

"សុំអភ័យទោស"(Shitsureishimasu) ជាពាក្យដែលគ្រប់គ្នាតែងតែប្រើ មិនត្រឹមតែនៅការដ្ឋានសំណង់ប៉ុណ្ណោះទេ។ "Rei" មានន័យថាសុជីវធម៌ ហើយ "shitsu" មានន័យថាបាត់បង់។ ខ្វះសុជីវធម៌គឺជាអត្ថន័យដើម ប៉ុន្តែវាមិនមែនជាពាក្យដែលធ្វើឲ្យដៃគូមានអារម្មណ៍មិនល្អនោះទេ។

ជាឧទាហរណ៍ នៅពេលអ្នកចូលទៅក្នុងបន្ទប់មួយ អ្នកនិយាយថា "សុំអភ័យទោស (ដែលរំខានការនិយាយ)" ដែលបង្ហាញពីអារម្មណ៍ដែលអ្នកប្រហែលជារំខានដៃគូដែលកំពុងធ្វើការនៅក្នុងបន្ទប់។

នៅពេលដៃគូដែលអ្នកចង់និយាយជាមួយ កំពុងសន្ទនាជាមួយនរណាម្នាក់ ហើយអ្នកមានការដែលត្រូវនិយាយជាបន្ទាន់ យើងនិយាយថា "សុំអភ័យទោស"(Shitsureishimasu)។

នៅពេលដែលត្រូវទៅផ្ទះមុនអ្នកផ្សេងដែលកំពុងធ្វើការ គេនិយាយថា "ខ្ញុំសុំទៅមុនហើយ" (Osakini shitsureishimasu)។ ជាការឆ្លើយតប សូមនិយាយថា "អ្នកបាននឿយហត់ហើយ" (Otsukaresamadeshita)។

### 4.1.6 "ប្រយ័ត្ន!"(Abunai)

នៅពេលដែលកំពុងផ្តោតលើការងារ អាចនឹងមិនចាប់អារម្មណ៍ពីគ្រោះថ្នាក់ដែលខិតមកជិតនោះទេ។ នៅពេលដែលមនុស្សនៅជុំវិញអ្នកមានអារម្មណ៍ថាអ្នកស្ថិតក្នុងគ្រោះថ្នាក់ ពាក្យដំបូងដែលគេនិយាយចេញមកគឺ "ប្រយ័ត្ន!"(Abunai)។ ប្រសិនបើគ្រោះថ្នាក់ដោយមានអ្វីមួយធ្លាក់ពីខាងលើ ឬអ្វីមួយនឹងមកបុកអ្នកពីចំហៀង គេនិយាយថា "ប្រយ័ត្ន! គេច!"(Abunai! Yokero!)។ ប្រសិនបើអ្នកឮនរណាម្នាក់ស្រែកថា "ប្រយ័ត្ន!" សូមប្រតិកម្មភ្លាមៗ។

## 4.2 ពាក្យបច្ចេកទេសដែលប្រើនៅការដ្ឋានសំណង់

ត្រង់ 4.2 យើងធ្វើការពន្យល់ពីពាក្យបច្ចេកទេសដែលអ្នកគួរដឹងនៅពេលធ្វើការក្រោមការដឹកនាំរបស់មេការ ឬរៀមច្បង។

### 4.2.1 ពាក្យបច្ចេកទេសទាក់ទងនឹងគំនូសសម្គាល់

**[គំនូសសម្គាល់]** គឺជាការគូសខ្សែគោលផ្សេងៗដែលចាំបាច់សម្រាប់ការសាងសង់នៅលើផ្ទៃដីជាដើម។ គេប្រើប្រាស់ហ្វឹតគូសខ្សែដែលមានមកពីបុរាណ និងប្រដាប់គូសគំនូសសម្គាល់ឡាស៊ែរ។

**[គំនូសគោល]** ជាបន្ទាត់ត្រង់ផ្តេកនិងបញ្ឈរដែលនឹងក្លាយជាគោលនៅពេលសាងសង់អគារ។ តាមរយៈគំនូសគោល គេគូសខ្សែកណ្តាល (ខ្សែអ័ក្ស) នៃសសរ និងជញ្ជាំង។

**[ខ្សែអ័ក្ស]** គឺជាខ្សែដែលកាត់តាមចំកណ្តាល។ វាក៏ត្រូវបានគេប្រើដើម្បីនិយាយសំដៅទៅលើ "អ័ក្សនៃជញ្ជាំង" ឬ "អ័ក្សនៃសសរ" ផងដែរ ។

**[ខ្សែគូសគេច]** ខ្សែដែលគូសក្នុងករណីដែលមិនអាចគូសសម្គាល់ដោយសារមានឧបសគ្គជាដើម។ វាក៏ត្រូវបានគេហៅថា "កាអិរិស៊ុមិ" ផងដែរ។ ខ្សែនេះត្រូវបានគូសឲ្យឃ្លាតពីគំនូសដែលនឹងក្លាយជាគោលក្នុងរង្វាស់មួយឲ្យស្របឬបន្ទាយ។ គេសរសេរចំណាំរង្វាស់ដែលឃ្លាត(គេច) ដើម្បីឲ្យដឹងថាបានគូសឃ្លាតចេញចម្ងាយប៉ុន្មានពីគំនូសដែលនឹងក្លាយជាគោល។

**[គំនូសនីវ៉ូកម្ពស់]** គឺជាគំនូសផ្តេកដែលជាកម្ពស់គោល ហើយក៏ត្រូវបានគេហៅថា "រិកុហ៊្សុមិ" ផងដែរ។ វាក៏ត្រូវបានគេហៅថា "កុស៊ិហ៊្សុមិ" "មិហ៊្សុហ៊្សុមិ" "ស៊ុយហេហ៊្សុមិ"។

**[គំនូសបញ្ឈរ]** គឺជាខ្សែបញ្ឈរត្រង់ដែលបង្ហាញលើផ្ទៃដូចជាជញ្ជាំង និងសសរជាដើម។

**[គំនូសលើបាត]** ជាគំនូសដែលគូសដោយផ្ទាល់ទៅលើផ្ទៃរាបដូចជាកម្រាលបាតជាដើម។

**[គំនូសសម្រេច]** ជាគំនូសដែលបង្ហាញពីវិមាត្រសម្រេចដោយផ្អែកលើខ្សែអ័ក្សនិងផ្ទៃគ្រឿងបង្គុំ។







**[អ័ក្សជញ្ជាំង]** ជាខ្សែដែល កាត់តាមកណ្តាលជញ្ជាំង។

**[អ័ក្សសសរ]** ជាខ្សែដែលកាត់តាមកណ្តាលសសរ។

**[គំនូសមេ]** "គំនូសមេ" សំដៅលើខ្សែដែលនឹងក្លាយជាគោលនៃការងារគូសគំនូសសម្គាល់នៅដំណាក់កាលបន្ទាប់ដូចជាអ័ក្ស គំនូសនីវ៉ូកម្ពស់។

**[គំនូសសម្គាល់]** ជាការគូសសញ្ញាសម្គាល់លើសម្ភារឈើសម្រាប់កែច្នៃ។

## 4.2.2 ពាក្យបច្ចេកទេសទាក់ទងនឹងការហ៊ុមព័ទ្ធបណ្តោះអាសន្ន

**[ការហ៊ុមព័ទ្ធបណ្តោះអាសន្ន]** ជា "របងហ៊ុមព័ទ្ធបណ្តោះអាសន្ន" ដែលបង្កើតឡើងដើម្បីឱ្យគេអាចដឹងពី ខ្សែគោលសម្រាប់ការសាងសង់អគារ (ខ្សែកណ្តាលនៃសសរនិងជញ្ជាំង ខ្សែផ្តេក) ទីតាំងនៃអគារ មុំកែង នីវ៉ូ(គោលនៃកម្ពស់)។ វាត្រូវបានគេបង្កើតឡើងដោយប្រើបង្គោលឈើ និងបន្ទះក្តារដែលមានឈ្មោះថា "មិហ្សឺនុគិ"។ នៅក្នុងការងារសំណង់ស៊ីវិល គេប្រើពាក្យថា "ឆូបារិ" ។

**[ក្តារ(មិហ្សឺនុគិ)]** ជាក្តារដែលត្រូវបានវាយភ្ជាប់ដោយទិសដៅផ្តេកនឹងបង្គោលនៅពេលបង្កើតការហ៊ុមព័ទ្ធបណ្តោះអាសន្ន។

**[ការក្រិតនីវ៉ូ(មិហ្សឺម៉ុរិ)]** ជាការកំណត់នីវ៉ូដែលនឹងក្លាយជាគោលនៃកម្ពស់របស់អគារ។ វាត្រូវបានគេហៅយ៉ាងដូចនេះ ដោយសារតែវាប្រើឧបករណ៍ដែលហៅថា មិហ្សឺម៉ុរិកាន់។

**[ខ្សែនីវ៉ូ]** ជាខ្សែបង្ហាញពីនីវ៉ូដែលពន្លាតនៅចន្លោះក្តារ(មិហ្សឺនុគិ)។ វាក្លាយជាគោលនៃខ្សែអ័ក្ស។

### 4.2.3 ពាក្យបច្ចេកទេសទាក់ទងនឹងការងារដី

**[ការងារដី]** ជាការងារដើម្បីសាងសង់ដីបាត/គ្រឹះ និងសំណង់ក្រោមដីរបស់អគារ។

**[ការលើកដី]** ជាការបង្កើតផ្ទៃដីរាបស្មើដោយចាក់លើកដីជម្រាល ដីមិនរាបស្មើ ឬដីទាប ដោយដីខ្សាច់។

**[ការកាត់ជាកាំជណ្ដើរ]** ជាការកាត់ដីជារាងកាំជណ្ដើរពេលលើកដីនៅផ្ទៃជម្រាលចោតដើម្បីការពារកុំឲ្យដីលើករអិលធ្លាក់។

**[ការបង្ហាប់]** ជាការបង្កើតភាពហាប់(ហៅថា "មីតឡូជីតឡូ")ធ្វើឲ្យមានចន្លោះតិចរវាងភាគល្អិតដូចគ្នា តាមរយៈការបន្ថែមកម្លាំងសង្កត់ទៅលើដីខ្សាច់ កៅស៊ូ។ ឧទាហរណ៍ ពេលអនុវត្តការងារកម្រាលផ្លូវថ្មល់ជាដើម គេធ្វើការបង្ហាប់ដើម្បីបង្កើតគ្រឹះថ្មល់ឲ្យមាំល្អ។

**[ការបង្ហាប់(ដោយម៉ាស៊ីន)(តេនអាត់ឡូ)]** ជាការបង្ហាប់ដីដោយប្រើរ៉ូឡូកិនកៅស៊ូ។ល។ ការបង្ហាប់ថ្មបំបែក ក្រួសជាដើម ដោយម៉ាស៊ីនខ្នាតតូចដូចជាម៉ាស៊ីនបុកបង្ហាប់ ក៏ហៅថា តេនអាត់ឡូផងដែរ។

**[ការលុបដីវិញ]** ជាការលុបដីដល់ក្រោមដុម៉ា(ក្រោមជាន់ផ្ទាល់ដី) នៅក្នុងនិងក្រៅអគារបន្ទាប់ពីបញ្ចប់ការងារក្រោមដីដូចជាថ្នឹមក្រោមដីជាដើម។

**[ការបុកបង្ហាប់]** ជាការបង្ហាប់ដីដែលបានធ្វើការលុបដីវិញ ដោយម៉ាស៊ីនបុកបង្ហាប់ឬម៉ាស៊ីនកិនបង្ហាប់ជាដើម។

**[ការជីករណ្ដៅគ្រឹះ]** ជាការជីករណ្ដៅ(ហៅថា "គុសសាគុ") ដល់ផ្នែកដែលក្លាយជាបាតនៃគ្រឹះដោយប្រើគ្រឿងចក្រធុនធ្ងន់ជាដើម។

**[ការទប់ដី]** ជាការទប់ដីដើម្បីការពារកុំឲ្យជម្រាល ដីដែលបានលើក ចង្អូរដែលបានជីកជាដើមបាក់រលំ។

**[ជញ្ជាំងទប់ដី]** ក្នុងចំណោម "ការទប់ដី" រចនាសម្ព័ន្ធដែលមានរាងជញ្ជាំងត្រូវបានហៅជាពិសេសថា "ជញ្ជាំងទប់ដី"។

**[ការចាក់(អ៊ុឡូ)]** "អ៊ុឡូ" មានន័យថាវាយ ប៉ុន្តែជាពាក្យបច្ចេកទេសសំណង់ ការចាក់បញ្ចូលបេគុងគឺនិយាយថា "អ៊ុឡូ" ឬ "ដាសេឡូ ស៊ុរុ" (ចាក់បេគុង)។

**[ការជីកបែបកាំជណ្ដើរ]** ក្នុងករណីការជីករណ្ដៅគ្រឹះជ្រៅ ដើម្បីចោលដីដែលបានជីកទៅក្រៅ(ហៅថា "បញ្ចេញចោលដី") គេបន្សល់ដីធម្មជាតិជារាងកាំជណ្ដើរហើយបោះដីដែលបានជីកទៅកាំលើបន្ទាប់ជាបន្តបន្ទាប់។

**[ជម្រាល]** ផ្ទៃនៃជម្រាលក៏ត្រូវបានគេហៅថា "ណូរិ" ផងដែរ។ នៅការដ្ឋានសំណង់ វាសំដៅទៅលើផ្ទៃដីកដែលមានជម្រាល។

**[ការទប់ដី]** គឺការរារាំងដីដោយប្រើបន្ទះបាំងទប់កុំឲ្យដីបាក់រលំ។ ប្រសិនបើមានកន្លែងទំនេរគ្រប់គ្រាន់នៅជុំវិញ គេប្រើ "វិធីសាស្ត្រកាត់បើកចំហ(open-cut method)" ដើម្បីកាត់ដីបញ្ឆិត។

ប្រសិនបើមិនមានកន្លែងទំនេរគ្រប់គ្រាន់នៅជីឡូក៍ គេប្រើ "វិធីសាស្ត្រកាត់បើកចំហជញ្ជាំងទប់ដី" ដែលសង់ជញ្ជាំងនិងសំណង់ទប់។
**[បន្ទះបាំងទប់]** ជាបន្ទះសម្រាប់ទប់ដី។
**[បន្ទះបាំងទប់ដែក]** ជាបន្ទះបាំងទប់ធ្វើពីដែកដែលផ្នែកគែមមានរាងចង្អូរដើម្បីអាចតភ្ជាប់គ្នាបាន។
**[ការបញ្ចេញទឹក]** ជាការបញ្ចេញទឹកដែលផ្តុំនៅបាតគ្រឹះដែលជីកដោយរណ្តៅផ្តុំទឹកនិងម៉ាស៊ីនបូម។
**[រណ្តៅផ្តុំទឹក]** ជារណ្តៅដែលមានបំពាក់ម៉ាស៊ីនបូមទឹកដើម្បីបញ្ចេញទឹក។

## 4.2.4 ពាក្យបច្ចេកទេសទាក់ទងនឹងការងារជើងក្រោមគ្រឹះ/ការងារគ្រឹះ

**[ជើងក្រោមគ្រឹះ]** ជាផ្នែកខាងក្រោមនៃកម្រាលខណ្ឌបាតគ្រឹះ ឬការងារដែលពាក់ព័ន្ធ។ ដើម្បីទ្រកម្រាលខណ្ឌបាតគ្រឹះ គេដាក់ខ្សាច់ ក្រួស ថ្មបំបែក បេតុងគ្មានសរសៃដែក សសរគ្រឹះ។ល។ ជើងក្រោមគ្រឹះមានប្រភេទផ្សេងៗអាស្រ័យលើប្រភេទសម្ភារ។
**[គ្រឹះ]** ជាផ្នែកដែលបញ្ជូនទម្ងន់នៃសំណង់ (ហៅថា "បន្ទុកទម្ងន់សំណង់") ទៅកាន់ដីដោយផ្ទាល់។ មានគ្រឹះរាក់ គ្រឹះជម្រៅ។
**[គ្រឹះរាក់]** ជាគ្រឹះដែលបញ្ជូនបន្ទុកទម្ងន់សំណង់ទៅដីដោយផ្ទាល់។ គ្រឹះដែលគេសាងសង់គ្រឹះសព្វពេញបាតអគារហៅថា "គ្រឹះចាក់ពេញ"។ម្យ៉ាងទៀត គ្រឹះដែលមានរាងដូចអក្សរ "T" បញ្ច្រាសដែលសាងសង់តែផ្នែកដែលរងបន្ទុកទម្ងន់ជាពិសេស ត្រូវបានហៅថា "គ្រឹះជើងតាង"។ ទាំងពីរនេះត្រូវបានប្រើនៅកន្លែងដែលដីរឹងមាំល្អ។
**[គ្រឹះជម្រៅ]** គឺជាគ្រឹះសាងសង់នៅកន្លែងដែលដីអន់។ វាទ្របន្ទុកទម្ងន់សំណង់ដោយធ្វើបុកសសររាងស៊ីឡាំងដែលហៅថា "សសរគ្រឹះ" ទៅដល់ដីរឹង។
**[ការងារសសរគ្រឹះនៃគ្រឹះជម្រៅ]** ជាការងារសសរគ្រឹះសម្រាប់គ្រឹះជម្រៅ។ មានការងារសសរគ្រឹះបេតុងផលិតជាស្រេចសម្រាប់គ្រឹះជម្រៅ ការងារសសរគ្រឹះដែកសម្រាប់គ្រឹះជម្រៅ ការងារសសរគ្រឹះចាក់នៅនឹងកន្លែងសម្រាប់គ្រឹះជម្រៅ។

## 4.2.5 ពាក្យបច្ចេកទេសទាក់ទងនឹងការងាររន្ទា/សំណង់បណ្តោះអាសន្ន

**[រន្ទា]** មានរន្ទាប្រភេទផ្សេងៗគ្នាអាស្រ័យលើគោលបំណងប្រើប្រាស់និងរចនាសម្ព័ន្ធ។ នៅការដ្ឋានសំណង់ វាសំដៅកម្រាលបាតឬផ្លូវដើរដែលសង់បណ្តោះអាសន្នដោយផ្គុំបំពង់ទីបនិងសម្ភារសម្រាប់ការងារនេះ។ រន្ទាគ្រោងដែក រន្ទាបំពង់ទីប រន្ទាថ្នក់កង(ringlock) ជាដើម ត្រូវបានគេប្រើជាញឹកញាប់។
**[បន្ទារ]** ជាកម្រាលបាតនៃរន្ទាដែលបង្កើតឡើងដោយក្រាលបន្ទះរន្ទា (ហៅថា "បន្ទះក្រាលមាន

តម្លក់") ដើម្បីឱ្យមនុស្សអាចធ្វើការបាននៅពីលើវាបាន។

**[របងហ៊ុមព័ទ្ធបណ្តោះអាសន្ន]** ជារបងហ៊ុមព័ទ្ធបណ្តោះអាសន្នដែលខណ្ឌរវាងការដ្ឋានសំណង់និងដីជិតខាងឬផ្លូវថ្នល់ជាដើម ដើម្បីរឹតត្បិតការចេញចូលការដ្ឋានពីសំណាក់អ្នកមិនពាក់ព័ន្ធនឹងការងារសំណង់ដើម្បីការពារគ្រោះថ្នាក់និងចោរលួចជាដើម។

### 4.2.6 ពាក្យបច្ចេកទេសទាក់ទងនឹងការងារសរសៃដែក/ពុម្ព/ចាក់បេតុង

**[ការរៀបសរសៃដែក]** ជាការរៀបដាក់តាមទីតាំងនិងផ្គុំសរសៃដែក។ មានវិធីសាស្ត្ររៀបសរសៃដែកដូចជា ការរៀបសរសៃដែកពីរជាន់ ការរៀបសរសៃដែកមួយជាន់ ការរៀបសរសៃដែកពីរជាន់ឆ្លាស់ជាដើម។

**[ការគណនា]** ជាការគណនាសម្ភារចាំបាច់និងចំនួនបរិមាណ កម្លាំងពលកម្ម(ត្រូវការមនុស្សប៉ុន្មាននាក់) ពីគំនូសប្លង់និងប្លង់បទដ្ឋានបច្ចេកទេស។

**[ចន្លោះទំនេរ]** សំដៅលើចន្លោះសល់ទំនេរ។

**[គម្លាត(សរសៃដែក)]** ជាចម្ងាយរវាងសរសៃដែក។

**[គម្លាត(ចំណុចកណ្តាលសរសៃដែក)]** ជាចម្ងាយរវាងចំណុចកណ្តាលនៃសរសៃដែក។

**[បេតុងគ្មានសរសៃដែក(ស៊ុតិ កុងគុរីតុ)]** ជាបេតុងដែលចាក់រាបស្មើកម្រាស់ 5cm-10cm សម្រាប់គូសគំនូសសម្គាល់ និងបញ្ឈរពុម្ពចូលទីតាំង។ គេហៅកាត់ថា "ស៊ុតិកុង"។ បន្ថែមពីលើគោលបំណងបង្កើតស្តង់ដារសម្រាប់កម្ពស់ដែលបានធ្វើគំនូសសម្គាល់ គេចាក់បេតុងគ្មានសរសៃដែកធ្វើជាស្រទាប់បាតដើម្បីកំណត់ទីតាំងពុម្ពនិងសរសៃដែកឲ្យបានត្រឹមត្រូវ។

**[ការចង]** ជាការចង។ នៅក្នុងការងារសរសៃដែក ត្រង់កន្លែងដែលសរសៃដែកប្រសព្វគ្នា គេចងលួសចំណងសម្រាប់ការងារនេះដោយប្រើឧបករណ៍ដែលហៅថា "ដែកចងលួស"។ របៀបចងមាន "ចំណងខ្វែង" និង "ចំណងសាមញ្ញ"។

**[កម្រាស់បេតុងការពារសរសៃដែក]** ជាគម្លាតពីសរសៃដែកទៅផ្ទៃលើបេតុងដែលស្រោបវា។

**[ការបញ្ឈរពុម្ពចូលទីតាំង]** ជាការងារដាក់បញ្ឈរពុម្ពឲ្យត្រូវនឹងខ្សែគំនូសសម្គាល់។

**[ការស៊ីម៉ងត៍(cement slurry)]** ល្បាយស៊ីម៉ងត៍លាយទឹកហៅថា "ការស៊ីម៉ងត៍" ។ ក្នុងការងារពុម្ពមានការលេចធ្លាយបេតុងពីចន្លោះនៃមុខតំណរបស់ពុម្ព ហើយវាក៏ហៅថាការស៊ីម៉ងត៍ដែរ។

**[ការប្រើឡើងវិញ]** ជាការប្រើសម្ភារពុម្ពដដែលនៅការដ្ឋានផ្សេង។ ក្នុងករណីរចនាសម្ព័ន្ធនៃជាន់នីមួយៗគឺដូចគ្នានៅក្នុងការសាងសង់ដូចជាអគារជាដើម គេប្រើពុម្ពឡើងវិញដោយលើកពុម្ពដែលបានប្រើទៅជាន់ខាងលើ។

**[ការបែកធ្លាយ]** ជាការដែលពុម្ពបាក់បែកពេលកំពុងចាក់បេតុងឬកំពុងកករឹង ហើយបេតុងហូរចេញមកក្រៅ។ វាកើតឡើងពេលដែល "ការទប់ទ្រ" មិនបានគ្រប់គ្រាន់។

**[ការដកដែកគោល]** ជាការដកដែកគោលពីពុម្ពដើម្បីប្រើឡើងវិញជាសម្ភារពុម្ព។ ដោយសារហេតុនេះ

ពាក្យនេះត្រូវបានប្រើដោយមានន័យថារៀបចំទុកដាក់ពុម្ពក្រោយប្រើរួច។

**[ការចាក់បេតុង]** ជាការចាក់បញ្ចូលបេតុងទៅក្នុងពុម្ពញាត់ឲ្យគ្មានចន្លោះ។

**[ការចាក់បេតុងភ្ជាប់]** ជាការចាក់បេតុងពីលើបេតុងដែលកករឹងហើយ។ គេធ្វើ "ការចាក់បេតុងភ្ជាប់" ក្នុងករណីដែលវិនិច្ឆ័យថាមិនមានបញ្ហាខាងផ្នែករចនាសម្ព័ន្ធនិងការការពារជម្រាបទឹក។

**[ការបង្ហាប់]** ជាពាក្យដែលប្រើប្រាស់ក្នុងការងារដីផងដែរ ប៉ុន្តែក្នុងការងារចាក់បេតុង វាសំដៅលើការបង្ហាប់បេតុងដែលបានចាក់កុំឲ្យមានចន្លោះដោយផ្តល់រំញ័រដោយម៉ាស៊ីនរំញ័របេតុង ឬគោះវាយពុម្ពដោយញញួរកៅស៊ូ។

**[ការបុកបង្ហាប់]** ជាការគោះវាយផ្ទៃលើនៃពុម្ពកម្រាលខណ្ឌដើម្បីឲ្យបេតុងដែលបានចាក់នៅកម្រាលខណ្ឌមានសភាពហាប់។

**[ការលាយច្របល់]** ជាការលាយច្របល់ស៊ីម៉ងត៍និងថ្ម(aggregate)ឲ្យស្មើសាច់។

**[អត្រាលាយ]** ជាអត្រានៃសម្ភារនីមួយៗដើម្បីបង្កើតបេតុង។

### 4.2.7 ពាក្យបច្ចេកទេសដែលបង្ហាញគុណភាព/សភាព

**[គុណភាព]** ជាពាក្យដែលបង្ហាញគុណភាពនៃការរៀបចំចាត់តាំងវត្ថុ។ គេប្រើរបៀបនិយាយគឺ "គុណភាពល្អ" "គុណភាពមិនល្អ"។

**[ចំណុចប្រសព្វ]** ជាផ្នែកដែលសម្ភារខុសគ្នា 2ឡើងប្រសព្វគ្នា ឬចំណាត់ការចំពោះផ្នែកនោះ។ ក្នុងករណីដែលសម្ភារប្រសព្វគ្នានៅចំណុចដែលមិនគួរប្រសព្វ គឺនិយាយថា "ចំណុចប្រសព្វមិនល្អ(ទើសគ្នា)"។ របៀបនិយាយ "គុណភាពមិនល្អ" ក៏ត្រូវបានប្រើក្នុងន័យដូចគ្នាដែរ។ ក្នុងករណីនិយាយថា "ចំណុចប្រសព្វនៃពិដាននិងជញ្ជាំង" គឺសំដៅលើផ្នែកតភ្ជាប់រវាងពិដាននិងជញ្ជាំង។

**[ត្រង់]** ជាសភាពដែលក្លាយជាបន្ទាត់ត្រង់។ ក្នុងករណីដែលកោងឬវៀច គេនិយាយថា "មិនត្រង់"។ ការងារពិនិត្យមើលថាតើមានសភាពត្រង់ឬទេហៅថា "មើលភាពត្រង់"។

**[ផ្ទៃ(ទ្សុរ៉ា)]** ពាក្យនេះសំដៅលើផ្ទៃលើ។ គេក៏ហៅថា "ម៉េន" ផងដែរ។

**[ផ្ទៃស្របគ្នា]** ពាក្យនេះបង្ហាញពីសភាពដែលផ្ទៃនៃសម្ភារពីររាបស្មើហើយតម្រៀបត្រូវគ្នា។ គេប្រើដោយនិយាយថា "ធ្វើឲ្យផ្ទៃស្របគ្នា"។

**[ផត]** ពាក្យដែលសំដៅលើខ្សែឬផ្ទៃកោងដែលមានសភាពខុប។

**[ប៉ោង]** ពាក្យដែលសំដៅលើខ្សែឬផ្ទៃកោងដែលមានសភាពប៉ោងឡើង។

**[ការបម្រុង]** សំដៅលើកម្រិតលើសក្នុងរង្វាស់ឬគុណភាពដែលត្រៀមទុកជាមុន។ ដើម្បីត្រៀមចំពោះកំហុសក្នុងការកែច្នៃសម្ភារ កំហុសក្នុងការដំឡើងនៅការដ្ឋានជាដើម គេត្រៀមទុក "ការបម្រុង"។

**[ពេញ]** ពាក្យដែលបង្ហាញពីសភាពដែលពេញសព្វផ្ទៃទាំងមូលដោយគ្មានចន្លោះ។ "គ្រឹះចាក់ពេញ" គឺគ្រឹះដែលចាក់បេតុងពេញផ្ទៃបាតនៃអគារ។ "លាបពេញ" មានន័យថាលាបថ្នាំពេញផ្ទៃទាំងមូល។

**[លើសរង្វាស់(ហ្វ៊ុកាស៊ុ)]** សំដៅទៅលើផ្នែកដែលបានសម្រេចធំជាងលើសពីពេលរចនា។ម្យ៉ាងទៀត វា

ក៏ត្រូវបានគេប្រើដើម្បីពណ៌នាពីការដែលធ្វើឲ្យផ្នែសម្រេចលយមកមុខផងដែរ។ ការធ្វើ "ហ្វ៊ិកាសុិ" ហៅថា "ហ្វ៊ិកាស៊ុ"។
**[ការត្រូវធ្វើឡើងវិញ]** ជាការធ្វើដំណាក់កាលការងារដែលបានបញ្ចប់ហើយសាឡើងវិញ ហើយគេប្រើវាដូចជា "កើតមានការត្រូវធ្វើឡើងវិញ"។
**[ការរៀបលំដាប់ការងារ]** ជាការរៀបផែនការលំដាប់អនុវត្តការងារដោយគិតពីវិធីសាស្រ្តអនុវត្តការងារទុកជាមុនដើម្បីកុំឲ្យមានការត្រូវធ្វើឡើងវិញ។
**[កែតម្រូវ]** ជាការកែតម្រូវមួយផ្នែកចំពោះការងារដែលបានបញ្ចប់រួច។ ក្នុងករណីដែលមានផ្នែកដែលខុសពីប្លង់រចនាឬផ្នែកមិនល្អក្នុងការសាងសង់ គេធ្វើការកែតម្រូវ។
**[ចំណុចខ្វះខាត]** គេប្រើពាក្យនេះដើម្បីបង្ហាញថាមានចន្លោះប្រហោងឬផ្នែកនៅសល់ក្នុងដំណាក់កាលដែលការសាងសង់អគារស្ទើរតែបញ្ចប់ទាំងស្រុង។ ការសម្រេចផ្នែកទាំងនោះហៅថា "ការកែតម្រូវចំណុចខ្វះខាត"។

### 4.2.8 ពាក្យបច្ចេកទេសទាក់ទងនឹងប្រវែង/ទំហំ/ទទឹង

**[គម្លាត]** សំដៅលើគម្លាតរវាងការកំណត់ទីតាំង។
**[ទាញរង្វាស់]** ជាការទាញបញ្ចេញរង្វាស់ពីទីតាំងគោល។
**[រង្វាស់]** សំដៅលើប្រវែង។
**[1 កេន]** ជាឯកតាប្រវែងដែលត្រូវបានប្រើតាំងពីបុរាណនៅប្រទេសជប៉ុន។ វាប្រហែល 1.8m។ ប្រវែងជាក់លាក់គឺ 1818 mm។
**[1 ស្សាគុ]** ជាឯកតាប្រវែងដែលត្រូវបានប្រើតាំងពីបុរាណនៅប្រទេសជប៉ុន។ វាប្រហែល 30.3cm។
**[1 ឡ៊ូបុ]** ជាឯកតាផ្ទៃក្រឡាដែលត្រូវបានប្រើតាំងពីបុរាណនៅប្រទេសជប៉ុន។
1 ឡ៊ូបុ = 1 កេន x 1 កេន

### 4.2.9 ពាក្យបច្ចេកទេសពណ៌នារចនាសម្ព័ន្ធអគារ

**[រចនាសម្ព័ន្ធ RC]** RC ជាអក្សរកាត់នៃ Reinforced Concrete។ ជារចនាសម្ព័ន្ធនៃសំណង់ដែលចាក់បេតុងឲ្យកករឹងក្នុងពុម្ពដែលបានរៀបសរសៃដែក។ គេក៏ហៅថា "រចនាសម្ព័ន្ធបេតុងសរសៃដែក" ផងដែរ។
**[រចនាសម្ព័ន្ធ S]** S ជាអក្សរកាត់នៃ Steel។ វាជារចនាសម្ព័ន្ធសំណង់ដែលប្រើឆ្អឹងដែកសម្រាប់សសរនិងធ្នឹម។ គេក៏ហៅថា "រចនាសម្ព័ន្ធឆ្អឹងដែក" ផងដែរ។
**[រចនាសម្ព័ន្ធ SRC]** រចនាសម្ព័ន្ធសំណង់ដែលរួមផ្សំរចនាសម្ព័ន្ធ S និង រចនាសម្ព័ន្ធ RC ។ គេរៀបសរសៃដែកនៅជុំវិញឆ្អឹងដែកហើយចាក់បេតុងចូល។ គេក៏ហៅថា "រចនាសម្ព័ន្ធបេតុងសរសៃដែក

និងឆ្អឹងដែក" ផងដែរ។
**[រចនាសម្ព័ន្ធឈើ]** វាជារចនាសម្ព័ន្ធសំណង់ដែលប្រើឈើសម្រាប់សសរនិងធ្នឹម។

### 4.2.10 ពាក្យបច្ចេកទេសទាក់ទងនឹងការងារអគ្គិសនី/ការងារទូរគមនាគមន៍

**[ការតភ្ជាប់]** ជាទូទៅ ការតរបស់ 2 ឡើងហៅថា "ការតភ្ជាប់"។ ក្នុងករណីដែលភ្ជាប់ខ្សែទំនាក់ទំនងដូចគ្នាហៅថា "ការតខ្សែ" ផងដែរ។
**[ការរត់ខ្សែ]** ជាការរត់ខ្សែកាបលោហៈឬខ្សែកាបអុបទិកជាដើម។
**[ការបំបែក]** ជាការបំបែកការរត់ខ្សែនិងការរត់បំពង់ដូចគ្នាចេញពីគ្នា។ ចម្ងាយនេះហៅថា "ចម្ងាយបំបែក" ។
**[អ៊ីសូឡង់]** ជាការធ្វើឲ្យចរន្តមិនឆ្លងកាត់ពីផ្នែកដែលមានអគ្គិសនីឆ្លងកាត់ទៅផ្នែកមួយទៀត។
**[ការចោះ]** ជាការចោះរន្ធជញ្ជាំង កម្រាលបាត ពិដានជាដើមដល់ម្ខាងទៀត។
**[បំពង់]** ជាបំពង់សម្រាប់ខ្សែភ្លើងឆ្លងកាត់។ វិធីសាស្ត្របង្កប់ខ្សែភ្លើងក្នុងដីដោយប្រើបំពង់ហៅថា "វិធីសាស្ត្របំពង់"។
**[ការបង្កប់]** ជាការបង្កប់ខ្សែភ្លើងជាដើមក្នុងដី។

- វិធីសាស្ត្របំពង់៖ វិធីសាស្ត្រដែលបង្កប់បំពង់ជ័ររឹងឬបំពង់លោហៈហើយឲ្យខ្សែកាបឆ្លងកាត់ក្នុងនោះ។
- វិធីសាស្ត្របង្កប់ផ្ទាល់៖ វិធីសាស្ត្រនៃរត់ខ្សែដោយប្រើខ្សែកាបសម្រាប់បង្កប់ផ្ទាល់។
- រូងក្រោមដីសម្រាប់រត់បំពង់ខ្សែ៖ វិធីសាស្ត្រឲ្យខ្សែភ្លើងឆ្លងកាត់ដោយប្រើផ្លូវរូងឬចង្អូររួម។

**[ការរត់ខ្សែលើអាកាស]** ជាវិធីសាស្ត្ររត់ខ្សែកាបដល់ក្នុងអគារដោយប្រើបង្គោលភ្លើង។
**[រត់បំពង់]** ជាការបំពាក់បំពង់សម្រាប់ខ្សែកាបឆ្លងកាត់។
**[ការឲ្យខ្សែឆ្លងកាត់]** ជាការឲ្យខ្សែកាបឆ្លងកាត់បំពង់។
**[ការរត់បំពង់ក្នុងកម្រាលខណ្ឌ]** ជាការរត់បំពង់ដោយវិធីសាស្ត្របង្កប់ក្នុងកម្រាលបាតឬពិដាននៃអគារ។
**[MDF]** អក្សរកាត់របស់ Main Distribution Frame ដែលជាបន្ទះរត់ខ្សែសម្រាប់គ្រប់គ្រងនិងតភ្ជាប់ខ្សែទំនាក់ទំនងពីខាងក្នុងទៅខាងក្រៅអគារ។
**[ការឆក់ខ្សែភ្លើង]** ជាការដែលចរន្តអគ្គិសនីឆ្លងកាត់រាងកាយមនុស្ស។
**[ការលេចធ្លាយអគ្គិសនី]** ជាការដែលអគ្គិសនីឆ្លងកាត់ទៅផ្នែកដែលមិនគួរឆ្លងកាត់។
**[ម៉ាស/ដី]** ជាការភ្ជាប់បែបអគ្គិសនីនូវឧបករណ៍ឬសៀគ្វីអគ្គិសនីទៅនឹងដី។ ការធ្វើវាដើម្បីបង្ការការឆក់ខ្សែភ្លើងពេលលេចធ្លាយអគ្គិសនីហើយទន្ទឹមគ្នានេះការពារបរិក្ខារទំនាក់ទំនងពីការខូចខាត។
**[បង្គោលការពាររន្ទះ]** ជាបរិក្ខារសម្រាប់ការពារអគារនិងមនុស្សពីរន្ទះ។
**[ឧបករណ៍ការពាររន្ទះ]** ជាឧបករណ៍ដែលការពារឧបករណ៍ទំនាក់ទំនង និងឧបករណ៍ចុងបណ្តាញ

ជាដើមពីរន្ទះ។

**[សៀគ្វីខ្លី]** ជាការភ្ជាប់រវាងចំណុចពីរនៅក្នុងសៀគ្វីអគ្គិសនីដោយអង្គធាតុចម្លងដែលមានរេស៊ីស្តង់តូច។ គេក៏ហៅថា "ស្យូត(short)" ផងដែរ។

**[ការគាបសំប៉ែត]** ជាការតដោយបន្ថែមកម្លាំងសង្កត់។ នៅក្នុងការងារអគ្គិសនី មានឧបករណ៍ពិសេស (ដង្កាប់គាបក្បាលកូសគាបសំប៉ែត (Crimpers) ជាដើម) សម្រាប់តភ្ជាប់រវាងបណ្តូលខ្សែនិងក្បាលកូសគាបសំប៉ែត (Crimp terminal)ដោយគាបសំប៉ែត។

**[ស្រោម]** សំដៅលើផ្នែកជ័រឬអ៊ីសូឡង់ដែលស្រោបលើបណ្តូលខ្សែ។

**[មានចរន្តឆ្លងកាត់]** ជាការដែលមានអគ្គិសនីឆ្លងកាត់។

**[ត្រួតពិនិត្យ]** ជាការត្រួតពិនិត្យអ្វីមួយ។ នៅក្នុងការងារអគ្គីសនី គេប្រើវាពេលធ្វើការត្រួតពិនិត្យស្ថានភាពចរន្តឆ្លងកាត់ដោយប្រើប៊ិចតេស្តអគ្គិសនី ឬត្រួតពិនិត្យតង់ស្យុងឬចរន្តដោយប្រើឧបករណ៍វាស់ស្ទង់។

**[គាបឲ្យសំប៉ែត]** ជាការភ្ជាប់ផ្នែកតភ្ជាប់នៃខ្សែភ្លើងដោយគាបក្បាលកូសគាបសំប៉ែត (Crimp terminal)ដូចជាតំណសុង (Ring sleeve)ជាដើម ដោយប្រើដង្កាប់គាបក្បាលកូសគាបសំប៉ែត (Crimpers) ជាដើម។

**[បញ្ចៀស]** ជាការផ្លាស់ប្តូរផ្លូវរត់បំពង់ឬរត់ខ្សែដើម្បីជៀសឧបសគ្គ។

**[លោត]** ជាការដែលឌីសង់ទ័រធ្វើចលនាហើយសៀគ្វីត្រូវបានចំហ។

## 4.2.11 ពាក្យបច្ចេកទេសប្រើក្នុងការងារហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)/បរិក្ខារ

**[ការកំណត់បរិយាកាសខាងក្នុង(គូឆូ)]** គឺជាការលៃតម្រូវសីតុណ្ហភាព កម្រិតសំណើមជាដើមនៅក្នុងបន្ទប់។ វាគឺជាពាក្យកាត់នៃពាក្យ "គូគិ ឆូវ៉ា សេឡ៊ូប៊ិ"។

**[សីតុណ្ហភាព]** គឺជាពាក្យដែលបង្ហាញពីកម្រិតនៃភាពក្តៅឬត្រជាក់។ នៅប្រទេសជប៉ុនគេប្រើឯកតា "℃" (អង្សាសេ) ។

**[កម្រិតសំណើម]** គឺជាភាគរយនៃជាតិទឹកដែលមាននៅក្នុងបរិយាកាស។ គេប្រើរបៀបនិយាយពណ៌នាពីសំណើមដូចជា ប្រសិនបើមានជាតិទឹកច្រើន គេនិយាយថា "ស្អិតៗហើយមានសំណើមខ្ពស់" ហើយប្រសិនបើមានជាតិទឹកតិច គេនិយាយថា "ស្រស់ស្រាយហើយមានសំណើមទាប"។ គេប្រើជាឯកតា "%" (ភាគរយ)។

**[ការផ្លាស់ប្តូរខ្យល់]** គឺជាការប្តូរជំនួសខ្យល់កខ្វក់ក្នុងបន្ទប់ដោយខ្យល់ស្អាត។

**[ការបញ្ចេញចោលផ្សែង]** គឺជាការបញ្ចេញចោលផ្សែងជាដើមដែលកើតមានពេលមានអគ្គិភ័យ ឲ្យចេញពីក្នុងបន្ទប់ទៅខាងក្រៅ។

**[អនាម័យ]** គឺជាការពារសុខភាពមនុស្ស និងរក្សាភាពស្អាតបាត។ នៅពេលនិយាយថា "បរិក្ខារអនាម័យ" គេសំដៅទៅលើបរិក្ខារទាក់ទងនឹងទឹកដែលក្រៅពីផ្ទះបាយ (បង្គន់

បន្ទប់ងូតទឹក ជាដើម)។

**[ផ្នែកគគ្រើម]** គឺជាផ្នែកលើសដែលលេចចេញពីគែមជាដើមនៃផលិតផលក្នុងដំណាក់កាលកែច្នៃលោហៈឬប្លាស្ទិច។ ការសម្អាតផ្នែកគគ្រើមឲ្យស្អាតហៅថា "ការសម្អាតផ្នែកគគ្រើម" ។

**[ការស្រោប(Lining)]** គឺជាការស្រោបផ្ទៃលើនៃបំពង់ឬបំពង់ផ្លូវខ្យល់ដោយភ្នាសស្តើង ហើយក៏ត្រូវបានហៅថា "Coating" ផងដែរ។ អាស្រ័យលើកម្រាស់ស្រោប បើក្រាស់គេនិយាយថា Lining បើស្តើងគេនិយាយថា Coating ប៉ុន្តែភាគច្រើនវាត្រូវបានប្រើប្រាស់ក្នុងន័យដូចគ្នា។

**[ការធ្វើតេស្តការលេចធ្លាយ]** ជាការធ្វើតេស្តដើម្បីពិនិត្យថាមិនមានការលេចធ្លាយទឹក(ហៅថាការលេចជ្រាប) បន្ទាប់ពីបញ្ចប់ការរត់បំពង់។ វាមានដូចជា ការធ្វើតេស្តសម្ពាធទឹក និងការធ្វើតេស្តចាក់បំពេញទឹក។ល។

**[ការធ្វើតេស្តសម្ពាធទឹក]** ជាការធ្វើតេស្តដើម្បីបញ្ជាក់ថាមិនមានការលេចធ្លាយ ដោយការដាក់ទឹកចូលក្នុងបំពង់ ដូចជាបំពង់ចែកចាយទឹក និងបំពង់ផ្គត់ផ្គង់ទឹកក្តៅ ជាដើម ហើយបន្ថែមសម្ពាធ។

**[ការធ្វើតេស្តទឹកពេញ]** ជាការធ្វើតេស្តដើម្បីបញ្ជាក់ថាមិនមានការលេចធ្លាយដោយបញ្ចូលទឹកឲ្យពេញបំពង់បញ្ចេញចោលទឹក។

**[ជម្រាល]** គឺជាចំណោតទាបដើម្បីធ្វើឱ្យទឹកហូរ។

## 4.3 ប្រការប្រុងប្រយ័ត្នក្នុងការរស់នៅជុំគ្នា

### 4.3.1 សកម្មភាព "ស5"

នៅប្រទេសជប៉ុន គេអនុវត្តសកម្មភាពដែលហៅថា "ស5" ដើម្បីបង្កើតបរិយាកាសការងារប្រកបដោយសុវត្ថិភាព ភាពរីករាយនិងងាយស្រួលធ្វើការងារ។ "ស5" សំដៅលើពាក្យប្រាំដែលចាប់ផ្តើមដោយ អក្សរ "ស" ដែលមាន សម្រិតសម្រាំង(Seiri) សណ្តាប់ធ្នាប់(Seiton) សម្អាត(Seisou) ស្តង់ដារ (Seiketsu) និង ស្ថិតស្ថេរ(Shituke) ។

**① សម្រិតសម្រាំង**

សម្រិតសម្រាំងមានន័យថា ការបែងចែងអ្វីដែលត្រូវការនិងអ្វីដែលមិនត្រូវការ ហើយបោះបង់អ្វីដែលមិនត្រូវការ ហើយរក្សាទុកអ្វីដែលនឹងត្រូវប្រើនៅពេលក្រោយ។

**② សណ្តាប់ធ្នាប់**

សណ្តាប់ធ្នាប់មានន័យថាជាការទុកដាក់សម្ភារដែល ចាំបាច់នៅកន្លែងដែលបានកំណត់។ ចំពោះសម្ភារដែលបានយកចូលក្នុងការដ្ឋាន សូមរៀបចំឲ្យមានសណ្តាប់ធ្នាប់ដើម្បីងាយស្រួលទាញយកដោយយកចិត្តទុកដាក់ចំពោះភាពស្រប និងកែងគ្នា។ ជាពិសេសឧបករណ៍ជាដើមដែលបានប្រើប្រាស់រួចរាល់ ត្រូវយកត្រឡប់ទៅទីតាំងដែលបានកំណត់ ដើម្បីធ្វើឱ្យងាយស្រួលប្រើសម្រាប់អ្នកប្រើប្រាស់បន្ទាប់។

**③ សម្អាត**

សូមធ្វើការសម្អាតក្រោយពីបញ្ចប់ការងារ ដើម្បីឱ្យអាចអនុវត្តការងារនៅថ្ងៃបន្ទាប់ដោយអារម្មណ៍ល្អ។

④ **ស្អង់ងារ**

ស្អង់ងារ មានន័យថា អនុវត្តការសម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត និងរក្សាសភាពស្អាតគ្មានភាពកខ្វក់។

⑤ **ស្ថិតស្ថេរ**

ស្ថិតស្ថេរ គឺជាការកំណត់វិធាន និងផ្តល់ការអប់រំឬការណែនាំ ដើម្បីធានាដល់ការអនុវត្តឲ្យបានប្រាកដនូវការសម្រិតសម្រាំង សណ្តាប់ធ្នាប់ ការសម្អាត និងស្អង់ងារ។ វាសំខាន់ដែលគ្រប់គ្នាគោរពតាមវិធានដែលបានកំណត់។

### 4.3.2 ទីសំណាក់កម្មករ

នៅការដ្ឋានសំណង់ គេសាងសង់ទីស្នាក់ការការដ្ឋាន និងទីសំណាក់កម្មករ ជាសំណង់បណ្តោះអាសន្ន។ ទីស្នាក់ការការដ្ឋាន គឺជាកន្លែងសម្រាប់ការងាររដ្ឋបាល និងការប្រជុំ ជាដើម។ល។ ទីសំណាក់កម្មករជាកន្លែងសម្រាប់កម្មករផ្លាស់ប្តូរសម្លៀកបំពាក់ ហូបចុក និងសម្រាក ជាដើម។ នៅក្នុងទីសំណាក់កម្មករ សូមធ្វើតាមវិន័យដែលបានកំណត់ដើម្បីឲ្យកម្មករទាំងអស់គ្នាអាចចំណាយពេលដោយផាសុកភាព។

① **ការជក់បារីត្រូវជក់នៅក្នុងតំបន់ដែលបានកំណត់**

នៅការដ្ឋានសំណង់និងទីសំណាក់កម្មករ ការជក់បារីត្រូវបានហាមឃាត់។ សូមជក់បារីនៅក្នុងកន្លែងដែលត្រូវបានរៀបចំ។ មិនត្រូវលួចលាក់ជក់បារីនៅកន្លែងដែលអ្នកដទៃមើលមិនឃើញ។

② **ហាមចោលសំរាមពាសវាលពាសកាល**

នៅប្រទេសជប៉ុន ការចោលសំរាមនៅកន្លែងផ្សេងក្រៅពីកន្លែងដែលបានកំណត់ត្រូវបានគេហៅថា "poisute"(ការចោលសំរាមពាសវាលពាសកាល)។ ការចោលសំរាមពាសវាលពាសកាល ត្រូវបានហាមឃាត់។ ត្រូវយកចិត្តទុកដាក់ចំពោះការកែច្នៃឡើងវិញនិងបោះចោលសំរាមដោយបែងចែកឱ្យបានត្រឹមត្រូវនៅកន្លែងដែលបានកំណត់។ ប្រសិនបើប្រទះឃើញសំរាមជ្រុះ សូមរើសវាទៅបោះចោលនៅកន្លែងដែលបានកំណត់ឲ្យបានសកម្ម។

③ **ទុកដាក់មួកសុវត្ថិភាព និងខ្សែក្រវាត់សុវត្ថិភាពនៅកន្លែងដែលបានកំណត់**

មួកសុវត្ថិភាព និងខ្សែក្រវាត់សុវត្ថិភាព មិនត្រូវទុកចោលពាសវាលពាសកាល ក្រោយការប្រើប្រាស់ឡើយ។ សូមទុកដាក់វានៅកន្លែងដែលបានកំណត់រួចសឹមសម្រាក។

④ **ទុកដាក់សម្ភារផ្ទាល់ខ្លួននៅក្នុងទូ**

ការបាត់បង់សម្ភារផ្ទាល់ខ្លួនអាចបង្កបញ្ហា។ សូមទុកសម្ភារផ្ទាល់ខ្លួននៅក្នុងទូ។

⑤ **អនុវត្តការលាងដៃ សម្លាប់មេរោគ និងខ្ពុរមាត់**

ពេលចូលនិងចេញពីទីសំណាក់ សូមយកចិត្តទុកដាក់លើអនាម័យដោយលាងដៃ សម្លាប់មេរោគ និងខ្ពុរមាត់ជាដើម ។

**⑥ ពិនិត្យក្តារប្រកាសដំណឹង**

ក្តារប្រកាសដំណឹងមិនត្រឹមតែមានព័ត៌មានដែលចង់ឲ្យគ្រប់គ្នាដឹងប៉ុណ្ណោះទេ ប៉ុន្តែក៏មានព័ត៌មានមានប្រយោជន៍សម្រាប់បុគ្គលផងដែរដូចជាព័ត៌មានធានារ៉ាប់រងជាដើម។ សូមបង្កើតទម្លាប់មើលក្តារប្រកាសដំណឹង។

## 4.3.3 ការប្រុងប្រយ័ត្នចំពោះសម្លៀកបំពាក់

នៅប្រទេសជប៉ុនមានសុភាសិតមួយឃ្លាថា "សម្លៀកបំពាក់រញ៉េរញ៉ៃគឺចិត្តរញ៉េរញ៉ៃ"។ មានន័យថា "អ្នកដែលមានសម្លៀកបំពាក់មិនស្អាតបាត ក៏មិនស្អាតពីខាងក្នុងដែរ" ប៉ុន្តែនៅការដ្ឋានសំណង់វាមានបន្ថែមន័យថាសុវត្ថិភាព។ មិនត្រូវស្លៀកពាក់ដូចខាងក្រោមៈ

**① ចូលការដ្ឋានដោយពាក់អាវដៃខ្លី ខោខ្លី**

មានគ្រោះថ្នាក់ជាច្រើននៅលើការដ្ឋានសំណង់។ អ្វីដែលមិនមានបិទបាំងពេលកំពុងធ្វើការគឺមានតែប្រអប់ដៃនិងមុខប៉ុណ្ណោះ។ សូមស្លៀកសម្លៀកបំពាក់ការងារដែលសក្តិសមសម្រាប់ការងារនៅការដ្ឋាននោះ។ មិនត្រូវស្លៀកខោខ្លីឬពាក់អាវដៃខ្លីចូលក្នុងការដ្ឋានឡើយ។ ដូចគ្នានេះផងដែរ សូមយកចិត្តទុកដាក់នឹងអនាម័យដោយបោកគក់សម្លៀកបំពាក់ការងារ។

**② ចំហឡេវផ្នែកខាងមុខនៃអាវក្រៅ**

សូមជៀសវាងដោះឡេវអាវក្រៅចំហខាងមុខ។ នៅការដ្ឋានមានវត្ថុលៀនចេញជាច្រើន ហើយអាចទាក់ជាប់បណ្តាលឱ្យមានរបួស និងគ្រោះថ្នាក់។

**③ លាត់ដៃអាវ**

សូមទម្លាក់ដៃអាវដល់កដៃ ដើម្បីការពារកុំឲ្យមានរបួស។

**④ ដើរដោយដាក់ដៃក្នុងហោប៉ៅ**

មិនត្រូវដើរដោយដាក់ដៃនៅក្នុងហោប៉ៅឡើយ។ វាធ្វើមិនអាចឆ្លើយតបពេលដួលភ្លាមៗ ហើយអាចនាំឱ្យមានរបួសឬគ្រោះថ្នាក់។

## 4.3.4 ការប្រើប្រាស់ពាក្យសម្តី

ការប្រាស្រ័យទាក់ទងមានសារៈសំខាន់សម្រាប់ដំណើរការរលូននៃការងារនៅការដ្ឋានសំណង់ ហើយមានពាក្យ "Horenso" ដែលបង្ហាញពីចំណុចសំខាន់នៃការប្រាស្រ័យទាក់ទងនេះ។ វាជារបៀបនិយាយ ដើម្បីឲ្យត្រូវនឹងបន្ថែដែលមានឈ្មោះថា "Horenso" (ស្ពៃអេពីណា)។ "Horenso" គឺជាពាក្យដែលរួមបញ្ចូលគ្នានូវពាក្យ រាយការណ៍ ទាក់ទង និងប្រឹក្សា។ សូមនិយាយដោយស្វាហាប់ ផ្តោតលើ

ចំណុចសំខាន់ដែលចង់និយាយឲ្យងាយស្រួលយល់ ហើយផ្តើមពីសេចក្តីសន្និដ្ឋានជាមុនសិន។

រាយការណ៍៖ គឺជាការប្រាប់ពីវឌ្ឍនភាព និងលទ្ធផលជាដើមនៃការងារដល់រៀមច្បង និងមេការ។

ទាក់ទង៖ វាគឺជាការផ្តល់ព័ត៌មានអំពីការងារ និងកាលវិភាគជាដើមរបស់ខ្លួនទៅកាន់រៀមច្បង និងមេការ ។

ប្រឹក្សា៖ វាគឺជាការប្រាប់រៀមច្បងនិងមេការ នៅពេលមានបញ្ហាកើតឡើង ឬរឿងដែលមិនយល់។

### 4.3.5 ការរៀបចំទុកដាក់ក្រោយចប់ការងារ

ត្រូវសម្អាតជានិច្ចបន្ទាប់ពីធ្វើការងារចប់។ សូមសម្អាតដោយចេតនាក្នុងការត្រៀម និងរៀបចំសម្រាប់ការងារថ្ងៃបន្ទាប់។ ប្រសិនបើអ្នកប្រើភ្លើងត្រូវប្រាកដថាវាត្រូវបានពន្លត់។

# មេរៀនទី5 ចំណេះដឹងអំពីឧបករណ៍ ម៉ាស៊ីន សម្ភារ និងឧបករណ៍វាស់ដែលប្រើនៅការដ្ឋានសំណង់

## 5.1 ឧបករណ៍ ម៉ាស៊ីន សម្ភារ និងឧបករណ៍វាស់ សម្រាប់ប្រភេទការងារជាក់លាក់

### 5.1.1 គ្រឿងចក្រសំណង់


អេស្កាវ៉ាទ័រអ៊ីដ្រូលីក

**[អេស្កាវ៉ាទ័រអ៊ីដ្រូលីក(ប៊ែកហូ(Backhoe)) ]** ជាគ្រឿងចក្រសម្រាប់អនុវត្តការងារជីក/លើកដាក់តាមរយៈចលនារបស់ដង ដៃ ប៉ែល ដែលដំណើរការដោយស៊ីឡាំងអ៊ីដ្រូលីក និងតាមរយៈរង្វិលនៃតួខ្លួនខាងលើ។ តាមរយៈការផ្លាស់ប្តូរដៃភ្ជាប់ វាអាចប្រើសម្រាប់គោលបំណងផ្សេងៗដូចជា ម៉ាស៊ីនបុកបំបែក ម៉ាស៊ីនកាយបំបែក ម៉ាស៊ីនកិនកម្ទេចជាដើម។

**[ម៉ាស៊ីនស្ទូច]** ជាគ្រឿងចក្រដែលអាចស្ទូចយោងអីវ៉ាន់ដោយកម្លាំងចលករហើយដឹកជញ្ជូនតាមទិសផ្តេក។ មានប្រភេទជាច្រើនប្រភេទដូចជា ម៉ាស៊ីនស្ទូចលើប៉ម រថយន្តស្ទូច និងម៉ាស៊ីនស្ទូចបរបែបវារ(crawler crane)ជាដើម។

**[ម៉ាស៊ីនស្ទូចលើប៉ម]** ជាម៉ាស៊ីនស្ទូចដែលប្រើក្នុងការសាងសង់អគារខ្ពស់ៗជាដើម។ ផ្នែកស្ទូចត្រូវបានភ្ជាប់នឹងសសរទ្រដែលហៅថា សសរបង្គោល(mast)។ មានពីរប្រភេទគឺ "ការឡើងតាមសសរបង្គោល(mast climbing)" ដែលផ្នែកស្ទូចឡើងសសរបង្គោលដែលបន្តគ្នា និង "ការឡើងលើជាន់អគារ(floor climbing)" ដែលជើងទ្រទាំងមូលឡើងលើអគារ។

**[រថយន្តស្ទូច]** ជាគ្រឿងចក្រសំណង់ប្រភេទដែលបំពាក់ម៉ាស៊ីនស្ទូចលើរថយន្តដឹកទំនិញ។

**[ម៉ាស៊ីនស្ទូចបរបែបវារ(crawler crane)]** ជាម៉ាស៊ីនស្ទូចប្រភេទបរបែបវារ។ វាអាចធ្វើការនៅកន្លែងផ្សេងៗគ្នាដូចជាលើព្រិលនិងលើផ្ទៃដែលមិនទាន់ក្រាលថ្នល់ជាដើម។


រថយន្តស្ទូច


ម៉ាស៊ីនស្ទូចបរបែបវារ(crawler crane)


ម៉ាស៊ីនស្ទូចលើប៉ម

## 5.1.2 ការងារបរិក្ខារអគ្គិសនី




**[ប៊ិចតេស្តអគ្គិសនី (voltage tester)]** វាគឺជាឧបករណ៍ដែលពិនិត្យមើលថាតើមានចរន្តអគ្គិសនីឬមិនមាន។ វាមានប្រភេទសម្រាប់តង់ស្យុងទាប និងសម្រាប់តង់ស្យុងខ្ពស់។

**[ឧបករណ៍តេស្តផាស (phase tester)]** គឺជាឧបករណ៍ដែលត្រួតពិនិត្យទិសដៅនៃការបង្វិល (លំដាប់នៃផាស) នៅក្នុងការរត់ខ្សែ 3 ផាស 2 ខ្សែ។

**[ឧបករណ៍តេស្តសៀគ្វី (Tester/Multimeter)]** គឺជាឧបករណ៍សម្រាប់ពិនិត្យមើលស្ថានភាពនៃសៀគ្វីអគ្គិសនី និងតង់ស្យុងអគ្គិសនីជាដើម។

**[ប្រដាប់តេស្តព្រីភ្លើង (outlet tester)]** គឺជាឧបករណ៍វាស់ស្ទង់សម្រាប់ពិនិត្យ ភាពវិជ្ជមាន ឬអវិជ្ជមាន ឬម៉ាស់(ដី) របស់ព្រីភ្លើង។

**[អំពែម៉ែត្រគាប (Clamp meter)]** គឺជាឧបករណ៍វាស់ស្ទង់ដែលអាចវាស់ចរន្តអគ្គិសនីដោយគ្រាន់តែគាបខ្សែភ្លើងចន្លោះតង្កៀបនៃផ្នែកស៊ែនស័រ។

**[បំពង់ខ្សែភ្លើង (Conduit)]** បំពង់ធ្វើពីដែកឬជ័រសំយោគដែលអាចដាក់ខ្សែភ្លើងនៅខាងក្នុងវាបាន។

**[ហ្គេន (Flexible Conduit)]** បំពង់ខ្សែភ្លើងដែលអាចបត់បានដោយសេរី។

**[ហ្គេនធ្វើពីលោហៈ (Metal Flexible Conduit)]** បំពង់ខ្សែភ្លើងធ្វើពីដែកដែលអាចបត់បានដោយងាយស្រួល។







**[បំពង់PF (PF pipe)]** PF ជាអក្សរកាត់នៃ Plastic Flexible conduit ។ វាគឺជាហ្គេនធ្វើពីជ័រសំយោគដែលមិនធន់នឹងភ្លើង។

**[បំពង់ CD (CD tube)]** CD ជាពាក្យកាត់នៃ Combined Duct។ វាគឺជាហ្គេនធ្វើពីជ័រសំយោគដែលមិនធន់នឹងភ្លើង។ ជាញឹកញាប់ត្រូវបានប្រើសម្រាប់ការបង្កប់នៅក្នុងបេតុង។

**[ក្បាលកូសគាបបង្ហាប់ (Compression terminal)]** ជាក្បាលសម្រាប់ភ្ជាប់ខ្សែភ្លើងទៅនឹងឧបករណ៍ ឬខ្សែភ្លើងដូចគ្នា ។ ខ្សែភ្លើងត្រូវបានតភ្ជាប់តាមរយៈការប្រើកម្លាំងសង្កត់គាបក្បាលកូសនៅផ្នែកដែលត្រូវតភ្ជាប់។ វាមានរូបរាង និងទំហំផ្សេងៗគ្នា អាស្រ័យលើការប្រើប្រាស់។

**[ឧបករណ៍គាបបង្ហាប់ (compression tool)]** វាជាឧបករណ៍ដែលភ្ជាប់ក្បាលកូសគាបបង្ហាប់និងខ្សែភ្លើង តាមរយៈការបន្ថែមកម្លាំងសង្កត់គាបទៅលើក្បាលកូសគាបបង្ហាប់។

**[ដង្កាប់គាបក្បាលកូស(Crimpers)]** វាជាឧបករណ៍ដែលភ្ជាប់ក្បាលកូសនិងខ្សែភ្លើង តាមរយៈការបន្ថែមកម្លាំងសង្កត់គាបទៅលើក្បាលកូស។ មានពីរប្រភេទគឺមួយសម្រាប់ក្បាលកូស (ផ្នែកដងកាន់មានពណ៌ក្រហម) និងមួយទៀតសម្រាប់តំណសុង (ផ្នែកដងកាន់មានពណ៌លឿង) ។




**[ក្បាលកូសគាបសំប៉ែត (Crimp terminal)]** វាគឺជាក្បាលកូសសម្រាប់តភ្ជាប់ដែលភ្ជាប់ទៅនឹងចុងខ្សែភ្លើង។ គេភ្ជាប់ខ្សែឲ្យនឹងដោយគាបខ្សែដែលបានដាក់ចូលក្នុងរន្ធតំណក្បាលកូសឲ្យសំប៉ែតតាមផ្នែកតំណនីមួយៗនៃក្បាលកូស។ គេប្រើឧបករណ៍ដែលសមស្របសម្រាប់ក្បាលកូសគាបសំប៉ែត។

**[តំណសុង(Ring sleeve)]** ជាគ្រឿងសម្រាប់តភ្ជាប់ខ្សែភ្លើងច្រើន។ បញ្ចូលបណ្ដូលខ្សែទៅក្នុងរន្ធដែលមានរាងជាកង ហើយគាបឲ្យសំប៉ែតដោយប្រើឧបករណ៍គាបសំប៉ែតសម្រាប់តំណសុង។

**[ក្បាលកូសម្ជុល (Rod terminal)]** វាគឺជាក្បាលកូសគាបសំប៉ែតដែលមានចុងរាងដូចជាម្ជុល។










**[គ្រឿងតំណប្រភេទអក្សរT (T-connector)]** គឺជាតំណសម្រាប់គាបខ្សែមេនិងខ្សែបំបែកឲ្យសំប៉ែតនៅពេលបំបែកខ្សែភ្លើងចេញពីផ្នែកកណ្ដាលនៃខ្សែមេ។

**[គ្រឿងតំណស៊ក(Plug connector)]** ជាគ្រឿងសម្រាប់ប្រើនៅពេលតភ្ជាប់ខ្សែភ្លើង។ គេអាចតភ្ជាប់ដោយគ្រាន់តែសូកបញ្ចូលបណ្ដូលខ្សែ។




**[COS]** អក្សរកាត់របស់ពាក្យ Change Over Switch ។ វាសំដៅទៅលើកុងតាក់ផ្លាស់ប្ដូរ។

**[ស្កុតមុខពីរ (self-amalgamating tape)]** គឺជាស្កុតដែលនៅពេលដែលទាញសន្ធឹង 2 ទៅ 3 ដង ហើយរុំជុំវិញបំពង់មួយ នោះផ្នែកខាងក្រោយនិងផ្នែកខាងមុខនៃស្កុត ស្អិតជាប់គ្នា។ វាត្រូវបានប្រើសម្រាប់រុំបំពង់ទឹកនិងការការពារការលេចធ្លាយទឹក។ល។

**[បង្គោលអេឡិចត្រូតដី(Grounding rod)]** គឺជាបង្គោលដែលត្រូវបានវាយបញ្ចូលទៅក្នុងដីសម្រាប់ធ្វើជាម៉ាស់។ ជាធម្មតាវាត្រូវបានធ្វើពីដែកដែលក្រូម៉េទង់ដែង។ វាក៏ត្រូវបានគេហៅថាដែកទែរបុកដីផងដែរ។




**[ប្រអប់តំណខ្សែកាបកប់ដីខ្នាតតូច(handhole)]** គឺជាប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole)ធ្វើពីឥដ្ឋបេតុង ប្រើសម្រាប់រត់ខ្សែភ្លើង ខ្សែទូរគមនាគមន៍។

**[ខ្សែត្រៀម (Fish tape)]** ខ្សែដែលរត់ឆ្លងកាត់បំពង់ទុកជាមុន ដើម្បីងាយស្រួលរត់ខ្សែមេឆ្លងកាត់នៅពេលរត់ខ្សែភ្លើងឬខ្សែកាបឆ្លងកាត់បំពង់។ គេអាចរត់ខ្សែមេឆ្លងកាត់បំពង់ដោយភ្ជាប់ខ្សែមេនិងខ្សែត្រៀម ហើយទាញខ្សែត្រៀម។

**[ធ្នើរខ្សែភ្លើង (Cable rack)]** គឺជាធ្នើរដែលមានរាងដូចជណ្តើរ ប្រើសម្រាប់ប្រមូលរៀបចំខ្សែច្រើនប្រភេទដូចជាខ្សែភ្លើងជាដើម។ ករណីប្រសិនបើចំនួនខ្សែតិច គេប្រើតម្លក់ព្យួរខ្សែភ្លើង។

**[ទូអគ្គិសនី (electric control panel)]** គឺជាបរិក្ខារសម្រាប់បំបែកប្រភពចរន្តផ្គត់ផ្គង់អគ្គិសនីទៅកាន់ឧបករណ៍ផ្សេងៗ។ វាមានឌីសង់ទ័រជាដើមនៅខាងក្នុង។ វាមាន "ទូបញ្ឈរខ្លួនឯង" ដែលត្រូវបានដាក់នៅលើកម្រាលឥដ្ឋនិង "ទូភ្ជាប់ជញ្ជាំង" ដែលត្រូវបានភ្ជាប់ទៅនឹងជញ្ជាំង។

**[ខ្សែស្រោបអ៊ីសូឡង់ (insulated wire)]** គឺជាខ្សែចម្លងចរន្តធ្វើពីទង់ដែងជាដើមដែលស្រោបដោយស្រទាប់អ៊ីសូឡង់។

**[ដង្កាប់បកខ្សែភ្លើង (Wire stripper)]** គឺជាឧបករណ៍សម្រាប់បកស្រោមខ្សែភ្លើងដែលស្រោប។




**[ម៉ែត្របកខ្សែភ្លើង (Strip gauge)]** គឺជាម៉ែត្រប្រើនៅពេលបកស្រោមខ្សែភ្លើង ដើម្បីវាស់ប្រវែងខ្សែដែលនឹងត្រូវបក។ គេប្រើវាដោយភ្ជាប់វាទៅនឹងដង្កាប់បកខ្សែភ្លើង (Wire stripper)
។

**[កាំបិតជាង]** គឺជាកាំបិតដែលប្រើសម្រាប់បកស្រោមខ្សែភ្លើង ពេលធ្វើការងារអគ្គិសនី។




**[IV]** គឺជាអក្សរកាត់នៃពាក្យ Indoor PVC។ ជាខ្សែភ្លើងស្រោបអ៊ីសូឡង់ជ័រសម្រាប់រត់ខ្សែភ្លើងក្នុងផ្ទះ។

**[VVF]** គឺជាអក្សរកាត់សម្រាប់ពាក្យ Vinyl insulated Vinyl sheathed Flat-type cable។ វាជាខ្សែអគ្គិសនីស្រោបអ៊ីសូឡង់ជ័ររាងសំប៉ែត។

**[VVR]** គឺជាអក្សរកាត់សម្រាប់ពាក្យ Vinyl insulated Vinyl sheathed Round-type cable។ វាជាខ្សែអគ្គិសនីស្រោបអ៊ីសូឡង់ជ័ររាងមូល។








**[ដង្កាប់បកខ្សែភ្លើង VVF (VVF stripper)]** គឺជាឧបករណ៍សម្រាប់បកស្រោមខាងក្រៅនិងស្រោមបណ្ដូលខ្សែរបស់ខ្សែ VVF ។

**[ឧបករណ៍ផ្ដាច់ចរន្តលើស (circuit breaker)]** ជាឧបករណ៍សុវត្ថិភាពដែលកាត់ផ្ដាច់ការផ្គត់ផ្គង់អគ្គិសនីដោយស្វ័យប្រវត្តិទៅម៉ាស៊ីនឧបករណ៍នៅពេលដែលមានចរន្តលើសនៅក្នុងសៀគ្វី។ ក៏ត្រូវបានហៅថាឌីសង់ទ័រផងដែរ។ សព្វថ្ងៃនេះ ឌីសង់ទ័រគ្មានហ្វ៊ុយស៊ីប (NFB) ត្រូវបានប្រើសម្រាប់រត់ខ្សែភ្លើង។




**[ព្រីភ្លើង(outlet)]** វាជារន្ធដែលត្រូវបានភ្ជាប់ជញ្ជាំង ហើយនៅគេហដ្ឋានជម្មតាគឺ 1 ហ្វា 100V។ មានប្រភេទបង្កប់ និងប្រភេទបណ្ដែតជាដើម។ ប្រភេទបង្កប់ត្រូវបានភ្ជាប់ទៅនឹងស៊ុមភ្ជាប់សម្រាប់បង្កប់។








## 5.1.3 ការងារទូរគមនាគមន៍

**[ប្រអប់បិទ (Closure)]** គឺជាប្រអប់សម្រាប់តភ្ជាប់បណ្ដូលខ្សែកាបនិងបណ្ដូលខ្សែកាប នៅក្នុងការរត់ខ្សែលើអាកាស។ វាត្រូវបានដំឡើងនៅលើបង្គោលភ្លើង។

**[ម៉ាស៊ីនរ៉ូឡូខ្សែកាប (Cable feeder)]** ម៉ាស៊ីនបញ្ជូនខ្សែកាបដែលប្រើរ៉ក។ គេអាចទាញខ្សែកាបចេញបានយ៉ាងងាយស្រួលពីដុំរ៉ូឡូ។


ម៉ាស៊ីនរ៉ូឡូខ្សែកាប
(Cable feeder)

**[ខ្សែស្ទ (suspension wire)]** ខ្សែនេះត្រូវបានប្រើដើម្បីការពារខ្សែកាបកុំឲ្យរងកម្លាំងទាញនៅក្នុងការរត់ខ្សែលើអាកាស។ គេក៏ហៅថា "ខ្សែនាំសារ" (messenger wire) ផងដែរ។

**[ឧបករណ៍បំប្លែងចរន្ត (Rectifier)]** គឺជាឧបករណ៍បំប្លែងចរន្តឆ្លាស់ទៅជាចរន្តជាប់។

**[អាគុយ (storage battery)]** ឧបករណ៍ដែលអាចសាកថ្មនិងរក្សាទុកអគ្គិសនី។

**[សរសៃខ្សែអុបទិក(Optical fiber)]** សរសៃខ្សែអុបទិកប្រើកញ្ចក់ស៊ីលីកាពីរប្រភេទដែលមានសន្ទស្សន៍ចំណាំងផ្សេងគ្នា ហើយផ្នែកកណ្តាលដែលដឹកនាំពន្លឺត្រូវបានគេហៅថា "បណ្តូល" ហើយផ្នែកជុំវិញនោះត្រូវបានគេហៅថា "សំបក (cladding)"។ លើសពីនេះទៀត នៅជុំវិញត្រូវបានស្រោបដោយក្ដាសនីឡុង។ វាមានគុណសម្បត្តិគឺស្តើងហើយស្រាល មានសមត្ថភាពបញ្ជូនធំ កំហាតបង់ទាប និងមិនមានចរន្តអគ្គិសនី ហើយវាក៏មានគុណវិបត្តិផងដែរ ដូចជាមិនធន់នឹងការដាច់រលាត់ ពត់ និងភាពកខ្វក់ជាដើម។


សរសៃខ្សែអុបទិក


ខ្សែកាបអុបទិក

**[ខ្សែកាបអុបទិក (fiber-optic cable)]** សរសៃខ្សែអុបទិកត្រូវបានគ្របាញ់ និងបង្កើតជាទម្រង់ខ្សែកាប។ មានប្រភេទផ្សេងៗដូចជា 20 សរសៃ 100 សរសៃ និង 400 សរសៃ ជាដើម។

**[ខ្សែកាបលោហៈ (Metal cable)]** គឺជាខ្សែកាបដែលប្រើទង់ដែងធ្វើជាបណ្តូលខ្សែ។ វាធ្វើការទំនាក់ទំនងតាមរយៈសញ្ញាអគ្គិសនី។ មានប្រភេទដូចជាខ្សែកាបអ័ក្សរួម(coaxial cable) និងខ្សែកាបស្នូលគូវេញ(twisted pair)។

**[ខ្សែកាបអ័ក្សរួម (coaxial cable)]** គឺជាខ្សែកាបដែលមានរចនាសម្ព័ន្ធស្រោបដោយអ៊ីសូឡង់ជុំវិញអង្គធាតុចម្លងបញ្ជូនសញ្ញា ហើយត្រូវបានស្រោបដោយអង្គធាតុចម្លងផ្សេងទៀត។ ខ្សែកាបអ័ក្សរួមនេះត្រូវបានប្រើជាខ្សែកាបសម្រាប់អង់តែនទូរទស្សន៍។







**[ខ្សែកាបស្លួលគូវេញ UTP (UTP Twisted Pair Cable)]** គឺជាខ្សែកាបដែលបង្កើតឡើងដោយខ្សែចម្លងពីរជាគូហើយវេញចូលគ្នា។ វាមានគុណសម្បត្តិដោយតម្លៃថោកជាង និងទន់ជាងខ្សែកាបអ័ក្សរួម (coaxial cable)។ ខ្សែកាបនេះត្រូវបានបែងចែកប្រភេទតាមអត្រាបញ្ជូនអតិបរមា។ គេបែងចែកប្រើប្រាស់សម្រាប់ទូរសព្ទ ឬតបណ្តាញ អាស្រ័យតាមប្រភេទទាំងនោះ។

**[ខ្សែកាបទ្រខ្លួនឯង]** គឺជាខ្សែកាបដែលមានខ្សែទ្រសម្រាប់ទ្រខ្សែកាបរួមបញ្ចូលគ្នាតែមួយ។ វាអាចព្យួរដោយផ្ទាល់នៅលើបង្គោលភ្លើងបាន។ វាត្រូវបានប្រើសម្រាប់ការរត់ខ្សែលើអាកាស ។

**[ម៉ាស៊ីនភ្ជាប់ដោយរំលាយសរសៃខ្សែអុបទិក (optical fiber fusion splicer)]** គឺជាម៉ាស៊ីនសម្រាប់ភ្ជាប់ដោយរំលាយផ្នែកខាងចុងនៃខ្សែកាបអុបទិកពីរខ្សែ។ វិធីសាស្រ្តនៃការភ្ជាប់នេះត្រូវបានគេហៅថា "ការភ្ជាប់ដោយរំលាយ"(fusion splicing) ។ វិធីសាស្រ្តនៃការតភ្ជាប់ផ្សេងទៀតរួមមានការភ្ជាប់មេកានិច និងការភ្ជាប់តាមរយៈគ្រឿងតំណ។

**[សុងការពារសរសៃអុបទិក (Fiber Protection sleeve)]** គឺជាសុងសម្រាប់ការពារផ្នែកដែលតភ្ជាប់នៅពេលតភ្ជាប់ដោយរំលាយ។ វាត្រូវបានបង្រួញដោយកម្តៅភ្ជាប់នឹងខ្សែកាប។ ត្រូវប្រយ័ត្នថាត្រូវស៊កឲ្យខ្សែកាបឆ្លងកាត់ជាមុនសិនមុននឹងតភ្ជាប់ដោយរំលាយ ព្រោះវាអាចនឹងមិនអាចស៊កចូលពេលតភ្ជាប់ហើយ។

**[ឧបករណ៍កាត់សរសៃខ្សែ (Fiber Cutter)]** ឧបករណ៍សម្រាប់កាត់ខ្សែកាបអុបទិក។ នៅពេលតភ្ជាប់ដោយរំលាយ គេត្រៀមឧបករណ៍ពិសេសសម្រាប់កាត់ផ្ទៃមុខកាត់ខ្សែកាបឲ្យត្រង់ល្អ។

**[គ្រឿងតំណអុបទិក (optical connector)]** គឺជាឧបករណ៍សម្រាប់តភ្ជាប់ខ្សែកាបអុបទិក។ វាមានអត្ថប្រយោជន៍ដោយអាចស៊កចូលនិងដកចេញបានយ៉ាងងាយស្រួលដោយដៃ។ មានប្រភេទដូចជា គ្រឿងតំណSC គ្រឿងតំណFC គ្រឿងតំណLC និង គ្រឿងតំណMU។ល។




**[ឧបករណ៍វាស់ថាមពលអុបទិក (optical power meter)]** គឺជាឧបករណ៍សម្រាប់វាស់អាំងតង់ស៊ីតេនៃពន្លឺដែលប្រើក្នុងការបញ្ជូនទំនាក់ទំនងដោយសរសៃខ្សែអុបទិក។

**[ឧបករណ៍វាស់ចង្វាក់អាំពុលស្យុងស៊ីញ៉ាល់ (optical pulse tester)]** វាអាចវាស់ប្រវែងខ្សែនៃបណ្តូលខ្សែនៃសរសៃខ្សែអុបទិក ហើយពិនិត្យថាតើមានភាពមិនប្រក្រតីដូចជាកំហាតបង់ឬការចាំងឆ្លុះ

ជាដើមដោយសារការតភ្ជាប់។ វាត្រូវបានគេហៅថា OTDR (Optical Time Domain Reflectometer)។

**[រ៉ោតទ័រ (Router)]** ឧបករណ៍ដែលភ្ជាប់បណ្តាញផ្សេងៗច្រើន។ ដោយប្រើរ៉ោតទ័រ គេអាចបំបែកបណ្តាញបានច្រើន។

**[ឧបករណ៍តេស្តLAN (LAN tester)]** ឧបករណ៍ដែលពិនិត្យមើលថាតើខ្សែទាំង8 ចន្លោះក្បាលដោតដែលត្រូវបានភ្ជាប់នឹងចុងសងខាងនៃខ្សែកាបLAN កំពុងកាត់គ្នាឬទេ ឬត្រូវបានកាត់ផ្តាច់ឬទេ។

## 5.1.4 ការងារបំពង់

**[បំពង់/បំពង់ផ្លូវខ្យល់]** បំពង់ដែលឲ្យទឹកឬហ្គាសឆ្លងកាត់ហៅថាបំពង់ ហើយបំពង់ដែលឲ្យខ្យល់ឆ្លងកាត់ហៅថាបំពង់ផ្លូវខ្យល់។ បំពង់ផ្លូវខ្យល់មានបំពង់រាងបួនជ្រុង និងបំពង់រាងមូល (ក៏ហៅថាបំពង់រង្វង់(spiral ducts)ផងដែរ) ។

**[អង្គុំបំពង់(Pipevise)]** ឧបករណ៍សម្រាប់ចាប់ទប់បំពង់នៅពេលកាត់ ឬតភ្ជាប់បំពង់។

**[ម៉ាស៊ីនកាត់ធ្មេញវីសបំពង់]** ម៉ាស៊ីនសម្រាប់កាត់ឲ្យបំពង់មានធ្មេញវីស។

**[ដង្កាប់កាត់ទីប]** ឧបករណ៍សម្រាប់កាត់បំពង់ស្តើងធ្វើពីដែក ដែកថែប លង្ហិន ទង់ដែង អាលុយមីញ៉ូមជាដើម។

**[ឧបករណ៍ពត់ទីប]** ឧបករណ៍សម្រាប់ពត់បំពង់ទង់ដែង។

**[ដង្កាប់កាត់បំពង់]** គឺជាឧបករណ៍សម្រាប់កាត់**បំពង់**ធ្វើពីដែកថែប លង្ហិន ទង់ដែង ដែកស្ទិតនិងសំណ ។ វាអាចកាត់បំពង់ក្រាស់ជាងដង្កាប់កាត់ទីប។



ដង្កាប់កាត់បំពង់

**[ឧបករណ៍ពង្រីក]** ជាឧបករណ៍ដែលប្រើសម្រាប់ពង្រីកចុងបំពង់ទង់ដែងដើម្បីភ្ជាប់បំពង់។ ក៏ត្រូវបានហៅថាឧបករណ៍ពង្រីកបំពង់ផងដែរ។

**[ឃ្នាបពង្រីកបំពង់ផ្កាត្រកួន (Flaring tool)]** ជាឧបករណ៍សម្រាប់ពង្រីកមុខចុងនៃបំពង់ទន់ដូចជាបំពង់ទង់ដែងជាដើម។

**[ឧបករណ៍សម្អាតមាត់បំពង់]** ជាឧបករណ៍ដែលសម្អាតផ្ទៃដោយជម្រះផ្នែកគគ្រើមដែលជាប់នឹងបំពង់លោហៈឬបំពង់ជ័រPVC។

**[ឧបករណ៍តេស្តសម្ពាធទឹក (water pressure tester)]** ជាឧបករណ៍ប្រើសម្រាប់ការធ្វើតេស្តសម្ពាធទឹកនៃបំពង់ចែកចាយទឹកឬបំពង់ផ្គត់ផ្គង់ទឹកក្តៅជាដើម។ វាត្រូវបានគេហៅថា "ម៉ាស៊ីនបូមតេស្ត" ផងដែរ។




**[សម្ភារបិទភ្ជិត]** គឺជាសម្ភារដែលប្រើដើម្បីការពារការលេចធ្លាយសារធាតុរាវនៅខាងក្នុងបំពង់ នៅពេលមួលបំពង់បញ្ចូល។ មានជាសម្ភារបិទភ្ជិតប្រភេទរាវ និងស្កុតទឹក។

**[កាវសម្រាប់ជ័រ PVC]** គឺជាសម្ភារដែលប្រើដើម្បីការពារការលេចធ្លាយសារធាតុរាវនៅខាងក្នុងបំពង់ នៅពេលភ្ជាប់ជាមួយបំពង់ជ័រ PVC។

**[បំពង់ដែកថែបកាបូនសម្រាប់រត់បំពង់]** ជាបំពង់ដែកថែបដែលប្រើយ៉ាងទូលំទូលាយដូចជាការរត់បំពង់សម្រាប់ ចំហាយ ទឹក ប្រេង ហ្គាស និងខ្យល់ ជាដើម។ អាស្រ័យលើមានក្រូម៉េឬគ្មាន វាមានបំពង់ស (មានក្រូម៉េ) និងបំពង់ខ្មៅ (គ្មានក្រូម៉េ)។ វាក៏ត្រូវបានគេហៅថា បំពង់ហ្គាស SGP ផងដែរ ។

**[បំពង់PVCរឹង]** ជាបំពង់ធ្វើពីជ័រPVC រឹង។ មានប្រភេទបំពង់VU (បំពង់ស្តើង) និងបំពង់ VP (បំពង់ក្រាស់) ។ ពណ៌គឺពណ៌ប្រផេះ ហើយវាត្រូវបានគេហៅថាបំពង់ អ៊ិនប៊ីប៉ៃពុ និង បំពង់ជ័រPVC ផងដែរ។ វាមានគុណសម្បត្តិដូចជាផ្ទៃខាងក្នុងរលោងខ្លាំង កម្រិតកកិតទាប ទម្ងន់ស្រាល និងងាយស្រួលកែច្នៃ។ ផ្ទុយទៅវិញ វាមានគុណវិបត្តិដូចជា ងាយរងការប៉ះទង្គិចពីខាងក្រៅ និងមិនធន់នឹងកម្តៅ ។

**[បំពង់ដែកស្រោបPVCរឹងខាងក្នុងសម្រាប់ផ្គត់ផ្គង់ទឹក]** ជាបំពង់ដែកសម្រាប់ផ្គត់ផ្គង់ទឹកដែលខាងក្នុងស្រោបដោយ PVC រឹង។ វាមានភាពធន់នឹងច្រែះ និងធន់នឹងប្រតិកម្មធាតុគីមីយ៉ាងល្អ។ ក៏ត្រូវបានគេហៅថាបំពង់ស្រោប ឬបំពង់VLP ផងដែរ។

**[បំពង់ទុយោទង់ដែងសម្រាប់សារធាតុធ្វើឲ្យត្រជាក់]** ជាបំពង់សម្រាប់ទទួលនិងផ្ទេរសារធាតុធ្វើឲ្យត្រជាក់ខណៈពេលដែលចល័តវិលជុំរវាងកន្ទុយខាងក្រៅនិងតួខាងក្នុងរបស់ម៉ាស៊ីនត្រជាក់។ បំពង់គ្មានថ្នេរតំណធ្វើពីទង់ដែងនិងសំលោហៈនៃទង់ដែង ត្រូវបានប្រើប្រាស់។

**[ម៉ាស៊ីនបូម]** ម៉ាស៊ីនសម្រាប់បញ្ជូនទឹកទៅឆ្ងាយ ឬឲ្យឡើងពីកន្លែងទាបទៅកន្លែងខ្ពស់ ដោយផ្តល់ថាមពលដល់ទឹកក្នុងបំពង់។




**[ផ្លែង (Flange)]** ឧបករណ៍រាងជារង្វង់ដែលភ្ជាប់ទៅនឹងចុងបំពង់។

**[ស៊ុង(Sleeve)]** បំពង់រាងស៊ីឡាំងដែលដំឡើងនៅជញ្ជាំង កម្រាលឥដ្ឋ ធ្នឹម ជាដើមនៃអគារដើម្បីឲ្យបំពង់ បំពង់ផ្លូវខ្យល់ ឆ្លងកាត់ ។ គេបង្កប់វាមុនពេលចាក់បេតុង។

**[តំណ]** គឺជាគ្រឿងដែលប្រើសម្រាប់បត់ ឬបំបែកបំពង់។ វាមានប្រភេទ "កែង" ដែលផ្លាស់ប្តូរទិសដៅនៃលំហូរនិង "កែងអក្សរT" សម្រាប់បំបែកខ្នែងជាដើម។







## 5.1.5 ការងារម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់

**[តម្រងខ្យល់]** ប្រើដើម្បីចាប់យកធូលីនិងសំរាមតូចៗជាដើមនៅក្នុងខ្យល់។

**[កញ្ច្រែងត្រជាក់]** ជាឧបករណ៍សម្រាប់បញ្ចុះត្រជាក់សីតុណ្ហភាពខ្យល់ដោយឲ្យខ្យល់ប៉ះនឹងបំពង់ដែលមានទឹកត្រជាក់ឆ្លងកាត់ ហើយគេប្រើវានៅពេលបញ្ចុះត្រជាក់។

**[កញ្ច្រែងក្តៅ]** ជាឧបករណ៍សម្រាប់ដំឡើងកម្តៅសីតុណ្ហភាពខ្យល់ដោយឲ្យខ្យល់ប៉ះនឹងបំពង់ដែលមានទឹកក្តៅឆ្លងកាត់ ហើយគេប្រើវានៅពេលដំឡើងកម្តៅ។

**[ឧបករណ៍បង្កើនសំណើម]** ជាឧបករណ៍ដែលបន្ថែមសំណើមដល់ខ្យល់ស្ងួត។ ប្រើជាចម្បងនៅពេលដំឡើងកម្តៅ។

## 5.1.6 ការងារបរិក្ខារផ្គត់ផ្គង់ទឹកស្អាតបញ្ចេញចោលទឹកកាកសំណល់និងអនាម័យ

**[បរិក្ខារអនាម័យ]** ជាឈ្មោះកាត់នៃបរិក្ខារផ្គត់ផ្គង់ទឹកស្អាតបញ្ចេញចោលទឹកកាកសំណល់និងអនាម័យ ដែលរួមមានបរិក្ខារផ្គត់ផ្គង់ទឹកស្អាត បរិក្ខារបញ្ចេញចោលទឹកកាកសំណល់ បរិក្ខារឧបករណ៍អនាម័យ ឧបករណ៍ផ្គត់ផ្គង់ទឹកក្តៅ បរិក្ខារហ្គាស និងបរិក្ខារពន្លត់អគ្គីភ័យ។

**[បរិក្ខារឧបករណ៍អនាម័យ]** ជាបរិក្ខារដែលបញ្ចេញ ស្តុកទុក ឬបញ្ចេញចោលនូវទឹកឬទឹកក្តៅ ដូចជាក្បាលរ៉ូប៊ីណេ ចានបង្គន់ ចានបង្គន់នោម ឡាបូលាងមុខ អាងត្រាំទឹក និងកន្លែងលាងជាដើម។

**[វ៉ាល់/វ៉ាល់បំពង់ខ្យល់ (Valves/Dampers)]** ជាឧបករណ៍(ហៅថា វ៉ាល់ ផងដែរ) ដែលបញ្ឈប់លំហូរទឹកឬលៃតម្រូវបរិមាណទឹកក្នុងបំពង់។ វ៉ាល់ដែលបញ្ឈប់ឬលៃតម្រូវបរិមាណខ្យល់ក្នុងបំពង់ផ្លូវខ្យល់ហៅថា វ៉ាល់បំពង់ខ្យល់។




## 5.1.7 ការងាររក្សាកម្ដៅរក្សាភាពត្រជាក់

**[សម្ភាររក្សាកម្ដៅសំឡីកែវ(Glass Wool)]** កញ្ចក់ (ជាចម្បងកញ្ចក់កែច្នៃឡើងវិញ) ត្រូវបានរំលាយនៅសីតុណ្ហភាពខ្ពស់ បង្កើតជាសរសៃស្ដើង ហើយវាត្រូវបានគេប្រើយ៉ាងទូលំទូលាយជាសម្ភាររក្សាកម្ដៅដែលរួមបញ្ចូលគ្នានូវភាពបត់បែននៃសរសៃជាមួយនឹងភាពធន់នឹងកម្ដៅនិងដុតមិនឆេះ។ មានបំពង់រក្សាកម្ដៅរាងស៊ីឡាំង ក្រវាត់រក្សាកម្ដៅរាងជាក្រវាត់ និងក្រវាត់រក្សាកម្ដៅរាងជាបន្ទះ។

**[សម្ភាររក្សាកម្ដៅសំឡីថ្ម(Rock Wool)]** ថ្មបាសាល់(Basalt) និង ថ្មអង់ដេស៊ីដ(andesite) ត្រូវបានរំលាយនៅសីតុណ្ហភាពខ្ពស់ និងបង្កើតជាសរសៃដោយកម្លាំងចាកផ្ចិត។ ដោយសារតែវាត្រូវបានផលិតចេញពីថ្ម វាមានភាពធន់ទ្រាំនឹងភ្លើងប្រសើរជាងសំឡីកែវ ហើយក៏ត្រូវបានគេប្រើជាសារធាតុបំពេញនៃប្លុកបែងចែងការពារអគ្គិភ័យផងដែរ។ មានបំពង់រក្សាកម្ដៅរាងស៊ីឡាំង ក្រវាត់រក្សាកម្ដៅរាងជាក្រវាត់ និងក្រវាត់រក្សាកម្ដៅរាងជាបន្ទះ។

**[សម្ភាររក្សាកម្ដៅស្នោប៉ូលីស្ទីរ៉ែន (polystyrene heat insulation)]** បង្កើតឡើងដោយដុតកម្ដៅចំហាយបង្កើតជាពពុះនូវសារធាតុប៉ូលីស្ទីរ៉ែនដែលត្រូវបានលាយថ្នាំបង្កើតពពុះ (មិនមែនហ្វ្លូរ៉ូកាបូន (fluorocarbon)) និងថ្នាំធ្វើឲ្យមិនងាយឆេះ រួចហើយសង្កត់វា រួចដុតកម្ដៅចម្ហាយម្ដងទៀតហើយចាក់បង្កើតរូបរាង។ វាមានរាងស៊ីឡាំង និងរាងបន្ទះ ។ ប៉ូលីស្ទីរ៉ែន (Polystyrene) មិនអាចប្រើនៅសីតុណ្ហភាពពី 70°C ឡើងបានទេ ដូច្នេះវាត្រូវបានគេប្រើជាញឹកញាប់នៅក្នុងបំពង់ផ្គត់ផ្គង់ទឹកស្អាត និងបញ្ចេញចោលទឹកកាកសំណល់។

## 5.1.8 ការសាងសង់មណ្ឌលពន្លត់អគ្គិភ័យ

**[បរិក្ខារពន្លត់អគ្គិភ័យ]** គឺជាបរិក្ខារសម្រាប់ពន្លត់អគ្គិភ័យ និងណែនាំមនុស្សទៅកាន់កន្លែងមានសុវត្ថិភាពក្នុងករណីមានអគ្គិភ័យ។

**[បំពង់ពន្លត់អគ្គិភ័យ]** គឺជាឧបករណ៍អាចជញ្ជូនតាមខ្លួនសម្រាប់ពន្លត់ភ្លើងនៅដំណាក់កាលដំបូងតែម្តងពេលកើតមានអគ្គិភ័យ។

**[បរិក្ខារបង្គោលទឹកអគ្គិភ័យក្នុងអគារ]** គឺជាបរិក្ខារដែលដំណើរការដោយមនុស្សដែលប្រើក្នុងគោលបំណងពន្លត់អគ្គិភ័យនៅដំណាក់កាលដំបូង។

**[បង្គោលទឹកអគ្គិភ័យក្រៅអគារ]** គឺជាបរិក្ខារដែលបានដំឡើងនៅខាងក្រៅអគារសម្រាប់ការពន្លត់ភ្លើង


បរិក្ខារពន្លត់អគ្គិភ័យក្រៅអគារ

ដំណាក់កាលដំបូង និងការពារភ្លើងពីការរីករាលដាលដល់អគារដែលនៅជាប់គ្នា។ វាមានគោលបំណងដើម្បីពន្លត់ងនៅជាន់ទីមួយ និងជាន់ទីពីរនៃអគារ។

**[បរិក្ខារបាចសាចទឹក]** វាគឺជាឧបករណ៍ដែលភ្ជាប់ទៅនឹងបំពង់ទឹកពន្លត់អគ្គិភ័យ ហើយបាចសាចទឹកពីពិដានក្នុងករណីមានអគ្គិភ័យ។ នៅក្បាលឧបករណ៍បាចសាចទឹក រួមមានក្បាលឧបករណ៍បាចសាចទឹកបែបបិទជិត ក្បាលឧបករណ៍បាចសាចទឹកបែបបើកចំហ និងក្បាលឧបករណ៍បាចសាចទឹកបែបបង្ហូរទឹក។


ក្បាលឧបករណ៍បាចសាចទឹកបែបបិទជិត


ក្បាលឧបករណ៍បាចសាចទឹកបែប បើកចំហ

**[បរិក្ខារពន្លត់អគ្គិភ័យដោយចំហាយទឹក]** បរិក្ខារនេះមានគោលបំណងពន្លត់ភ្លើងនៅក្នុងតំបន់ដូចជាផ្លូវថ្នល់និងចំណតរថយន្ត កន្លែងដែលមានការរក្សាទុកឬប្រើប្រាស់វត្ថុអាចឆេះដែលបានកំណត់។ល។

**[បរិក្ខារពន្លត់អគ្គិភ័យដោយហាឡៃដ៍ (halide)]** ជាបរិក្ខារពន្លត់អគ្គិភ័យដែលប្រើសារធាតុពន្លត់អគ្គិភ័យ ហាឡៃដ៍ (halide) ។ សារធាតុ Halogen (ហ្វ្លូរីន(fluorine) ក្លរីន(chlorine) ប្រូមីន(bromine)) បញ្ឈប់អគ្គិភ័យដោយរឹតត្បិតប្រតិកម្មគបចំហេះ រារាំងការផ្គត់ផ្គង់ខ្យល់ និងបន្ថយកំហាប់អុកស៊ីសែននៅក្នុងខ្យល់។ វាស័ក្តិសមសម្រាប់អគ្គិភ័យចំពោះប្រេង អគ្គិភ័យចំពោះឧបករណ៍អគ្គិសនីកំពុងមានចរន្តឆ្លងកាត់ កុំព្យូទ័រ សៀវភៅ ស្នាដៃសិល្បៈសំខាន់ៗ។ល។

## 5.2 ឧបករណ៍ ម៉ាស៊ីន សម្ភារ និងឧបករណ៍វាស់ សម្រាប់ទូទៅ

### 5.2.1 ឧបករណ៍ប្រើអគ្គីសនី

ឧបករណ៍អគ្គិសនីមានប្រភេទឥតខ្សែដែលប្រើថ្មដែលអាចសាកបាន និងប្រភេទមានខ្សែដែលប្រើភ្លើងអគ្គីសនី AC ។

**[ម៉ូទ័រស្វានបាញ់វីស]** ម៉ូទ័រអគ្គិសនីដែលអាចប្រើរឹតវីសនិងចោះរន្ធដោយប្តូរផ្លែ។ អាចប្តូរល្បឿនវិលនិងកម្លាំងរមួលបាន។

**[ម៉ូទ័របាញ់វីសមានប្រព័ន្ធបុក]** ម៉ូទ័រអគ្គិសនីដែលអាចរឹតវីសខណៈពេលដែលបន្ថែមកម្លាំងបុកដោយញញួរដែលបំពាក់នៅខាងក្នុង។ វាមានកម្លាំងខ្លាំងជាងម៉ូទ័រស្វានបាញ់វីស។ វាវិលក្នុងល្បឿនវិលនិងកម្លាំងរមួលក្នុងកម្រិតមួយ។







**[ម៉ូទ័រឆាប]** ឧបករណ៍ប្រើអគ្គីសនីដែលអាចកាត់ ខាត់ និងជម្រះថ្នាំលាបពីបំពង់លោហៈនិងបេតុងដោយប្តូរផ្លែដែលភ្ជាប់នឹងខាងចុង(ថ្មឆាបរាងមូលសំប៉ែតសម្រាប់ខាត់និងសម្រាប់កាត់)។ ប្រភេទកម្លាំងរមួលល្បឿនខ្ពស់គឺសក្តិសមសម្រាប់ការកាត់លោហៈ ហើយប្រភេទកម្លាំងរមួលល្បឿនទាបគឺសក្តិសមសម្រាប់ការខាត់។






**[ម៉ូទ័រកាត់]** ឧបករណ៍អគ្គិសនីសម្រាប់កាត់សម្ភារដូចជាក្ដារកុងផ្លាកេជាដើមឲ្យត្រង់។ វាមានប្រភេទកាន់ដៃនិងប្រភេទដាក់នៅនឹង។ ប្រភេទកាន់ដៃពេលដាក់ចំសម្ភារដែលត្រូវកាត់ វាអាចនឹងធ្វើចលនាតាមទិសមិននឹកស្មានដោយសារកម្លាំងដែលព្យាយាមលើកឡើងពីសម្ភារនោះ(ហៅថា "ការធាក់ត្រឡប់(kickback)")។ គ្រោះថ្នាក់ដោយសារបញ្ហានេះមានច្រើន ហើយពេលខ្លះអាចធ្ងន់ធ្ងរដល់អាយុជីវិត។ មុននឹងប្រើ សូមពិនិត្យបញ្ជាក់ថាគម្របសុវត្ថិភាពដំណើរការបានត្រឹមត្រូវជាមុនសិន។



ម៉ូទ័រកាត់

**[ម៉ាស៊ីនកាត់ល្បឿនលឿន]** ឧបករណ៍អគ្គិសនីដែលកាត់បំពង់លោហៈ សរសៃដែក ឆ្អឹងដែកស្រាលជាដើម ដោយបង្វិលថ្មឆាបសម្រាប់កាត់។


ម៉ាស៊ីនកាត់
ល្បឿនលឿន

## 5.2.2 ការជីក ពង្រាប បង្ហាប់

**[ប៉ែលក្បាលស្រួច(កេន ស៊ុកុបព)]** ឧបករណ៍សម្រាប់ជីកដីដោយដាក់ជើងលើផ្នែកខាងលើនៃក្បាលប៉ែល។ វាក៏ត្រូវបានហៅកាត់ខ្លីថា "កេនស៊ុកុ" ផងដែរ។ មិនត្រូវប្រើវាជា "ឃ្នាស់" ឡើយ។







**[ប៉ែលក្បាលជ្រុង(កាគុ ស៊ុកុបព)]** ឧបករណ៍សម្រាប់ចូកជញ្ជូនដី កៅស៊ូជាដើម។ វាស្រដៀងនឹងប៉ែលក្បាលស្រួចដែរ ប៉ុន្តែចុងក្បាលវាគឺត្រង់មិនស្រួចដើម្បីងាយចូកដីជាដើម។ ម្យ៉ាងទៀត ផ្នែកខាងលើនៃក្បាលប៉ែលមានរាងមូល ហើយមិនអាចដាក់ជើងលើបានទេ។ មិនត្រូវប្រើវាជា "ឃ្នាស់" ឡើយ។ វាក៏ត្រូវបានហៅកាត់ខ្លីថា "កាគុស៊ុកុ" ផងដែរ។

**[ម៉ាស៊ីនបុកបង្ហាប់]** ម៉ាស៊ីនសម្រាប់បង្ហាប់ដី។ វាបង្ហាប់ដោយទម្ងន់របស់ម៉ាស៊ីនបុកបង្ហាប់និងកម្លាំងនៃបាតជើងដំរីដែលធ្វើចលនាចុះឡើងៗ។ វាមានកម្លាំងបុកខ្លាំង ហើយសក្តិសមនឹងការបង្ហាប់ឲ្យហាប់ល្អ។ មានប្រភេទប្រើម៉ាស៊ីន និងប្រភេទប្រើអគ្គិសនី។




## 5.2.3 ការគូសគំនូសសម្គាល់ សញ្ញា

**[ហ្វីតគូសខ្សែ]** ឧបករណ៍ដែលប្រើសម្រាប់គូសគំនូសសម្គាល់(ដៅគំនូសសម្គាល់)ជាខ្សែត្រង់វែងលើផ្ទៃសម្ភារ។

**[ស្លាបប៉ាកកាឫស្សី]** ឧបករណ៍ដែលផ្នែករាបប្រើសម្រាប់គូសខ្សែ ហើយផ្នែកមួយប្រើដូចគ្នានឹងជក់។



【ប្រដាប់គូសគំនូសសម្គាល់ឡាស៊ែរ】 ម៉ាស៊ីនដែលបញ្ចាំងពន្លឺឡាស៊ែរទៅលើជញ្ជាំង ពិដាន កម្រាលបាត ដើម្បីគូសខ្សែគោលនៃសំណង់ដូចជាខ្សែផ្ដេក ខ្សែបញ្ឈរជាដើម។ ពន្លឺឡាស៊ែរមានពណ៌ក្រហម និងបៃតង។ ពណ៌បៃតងគឺងាយស្រួលមើលជាងសូម្បីតែនៅកន្លែងភ្លឺក៏ដោយ។ ដើម្បីកុំឲ្យពន្លឺឡាស៊ែរចូលភ្នែកដោយផ្ទាល់ គេធ្វើការងារដោយពាក់វ៉ែនតាការពារសម្រាប់ការងារឡាស៊ែរ។


ប្រដាប់គូសគំនូស សម្គាល់ឡាស៊ែរ

**[ដែកដាប់(punch)]** ឧបករណ៍ដែលអាចប្រើដើម្បីធ្វើឱ្យមានស្នាមទ្រុឌតូចលើផ្ទៃលោហៈដោយវាយនឹងញញួរ ឬចោះរន្ធមូលលើក្រណាត់ឬស្បែកជាដើម។ "ដែកដាប់(center punch)" ត្រូវបានប្រើដើម្បីដៅសញ្ញាលើផ្ទៃលោហៈ (ហៅថា "ការដៅសញ្ញា") ។


ដែកដាប់ (punch)

## 5.2.4 ការវាស់វែង/ត្រួតពិនិត្យ

**[ឧបករណ៍វាស់កម្ពស់]** ម៉ាស៊ីនវាស់នីវ៉ូដែលប្រើដើម្បីកំណត់កម្ពស់ចាំបាច់សម្រាប់ធ្វើការ។ វាភ្ជាប់ទៅនឹងទម្រជើងបី ហើយគេមើលបំពង់កែវមានពពុះដែលបំពាក់នៅខាងក្នុងបណ្ដើរតម្រឹមឲ្យផ្ដេកដោយដៃ។ ឧបករណ៍វាស់កម្ពស់ដែលមានមុខងារធ្វើឲ្យផ្ដេកដោយស្វ័យប្រវត្តិហៅថា "ឧបករណ៍វាស់កម្ពស់ស្វ័យប្រវត្តិ" ។


ឧបករណ៍

**[ឧបករណ៍វាស់កម្ពស់ដោយឡាស៊ែរ]** ជាឧបករណ៍សម្រាប់វាស់នីវ៉ូដោយឡាស៊ែរ ដែលប្រើដើម្បីកំណត់កម្ពស់ចាំបាច់សម្រាប់ធ្វើការ។

**[ឧបករណ៍វាស់មុំ]** ឧបករណ៍សម្រាប់វាស់មុំនៃទិសលើក្រោម ទិសផ្ដេក ដោយយកចំណុចគំហើញដែលទ្រកែវយឺតខ្នាតតូចជាចំណុចគោល។ គេប្រើវាដោយដាក់លើទម្រជើងបី។ បច្ចុប្បន្ននេះ ឧបករណ៍ដែលគេហៅថា "ឧបករណ៍ឆ្លុះវាស់មុំ theodolite" ដែលជាប្រភេទបង្ហាញជាឌីជីថល ត្រូវបានប្រើប្រាស់យ៉ាងច្រើន។


ឧបករណ៍វាស់មុំ

[ម៉ែត្រទឹក] ឧបករណ៍សម្រាប់ពិនិត្យថាតើផ្ទៃសាងសង់ឬវត្ថុ គឺផ្ដេករាបស្មើឬទេធៀបនឹងផ្ទៃដី។ គេមើលពពុះក្នុងបំពង់កែវមានពពុះដើម្បីពិនិត្យថាផ្ដេករាបស្មើ។ ក៏មានប្រភេទដែលពិនិត្យថាផ្ដេករាបស្មើដោយមើលទ្រនិច និងម៉ែត្រទឹកឌីជីថលផងដែរ។ ម្យ៉ាងទៀត ក្នុងការដំឡើងនៅគេហដ្ឋាន ក៏ប្រើប្រាស់ម៉ែត្រទឹកដែលមានរួមបញ្ចូលជម្រាល(ទ្រេត)ផងដែរ។


ម៉ែត្រទឹក

[កូនប្រយោល] កូនទម្ងន់ដែលមានចុងស្លួចរាងសាជីដែលប្រើសម្រាប់ពិនិត្យភាពបញ្ឈរត្រង់នៃសសរជាដើម។ គេពិនិត្យភាពបញ្ឈរត្រង់ដោយព្យួរទម្លាក់ដោយប្រើខ្សែអំបោះពីប្រដាប់ទុកកូនប្រយោលដែលភ្ជាប់នឹងជាប់សសរ ហើយពិនិត្យថាតើគម្លាតរវាងផ្ទៃដែលភ្ជាប់ប្រដាប់ទុកកូនប្រយោលទៅនឹងខ្សែអំបោះគឺថេរឬទេ។


កូនប្រយោល

[ម៉ែត្រសំពត់] ឧបករណ៍រាងជាខ្សែបន្ទះសម្រាប់វាស់ប្រវែង។ គេក៏ហៅវាថា "ម៉ែត្រមួរ" ផងដែរ។ មានធ្វើពីដែកនិងធ្វើពីជ័រ។

[ម៉ែត្ររុំ(កុមបិកគុស៊ុ)] ម៉ែត្រដែលផ្នែកបន្ទះសម្រាប់វាស់ប្រវែងគឺធ្វើពីលោហៈស្តើង ហៅថា "ម៉ែត្ររុំ" ។


ម៉ែត្ររុំ

[ម៉ែត្របន្ទាត់] ឧបករណ៍ប្រើសម្រាប់វាស់ប្រវែង និងគូរបន្ទាត់ត្រង់។ វាធ្វើពី អាលុយមីញ៉ូម អ៊ីណុក ឬឬស្សីជាដើម។ ប្រសិនបើមិនចង់ធ្វើឱ្យខូចខាតសម្ភារដូចជាទ្វារបង្អួចជាដើម គេប្រើប្រាស់ម៉ែត្របន្ទាត់ធ្វើពីឫស្សី។


ម៉ែត្របន្ទាត់អាលុយមីញ៉ូម


ម៉ែត្របន្ទាត់អ៊ីណុក


ម៉ែត្របន្ទាត់ឫស្សី

### 5.2.5 ការកាត់/ពត់/បំបែក


ដង្កាប់កាត់

【ដង្កាប់កាត់】 ដង្កាប់កាត់ជាឧបករណ៍កាត់វត្ថុដោយគាប ដោយផ្លែកាំបិត។ គេប្រើសម្រាប់កែច្នៃការ៉ូ កាត់ខ្សែជាដើម។ វាក៏អាចកាត់ក្បាលដែកគោលបានដែរ។

[កាំបិតរុញ] កាំបិតដែលអាចរក្សាភាពមុតរបស់វាដោយកាច់ផ្លែកាំបិត។

[ដង្កាប់] ឧបករណ៍ប្រើប្រាស់ធ្វើការកែច្នៃដូចជា ពត់ កាត់ជាដើម។ វាមានផ្នែកដែលមានគន្លាក់ល្អិតៗដើម្បីកុំឲ្យរអិល និងផ្នែកដែលមានផ្លែសម្រាប់កាត់។


កាំបិតរុញ


ដង្កាប់

### 5.2.6 ការវាយ/ទាញ


ឧទាហរណ៍នៃញញួរ (សម្រាប់រន្ទាថ្នក់កង(ringlock))

[ញញួរ] ឧបករណ៍សម្រាប់វាយវត្ថុ។ វត្ថុធាតុដើមនៃក្បាលសម្រាប់វាយមាន លោហៈ កៅស៊ូ ឈើជាដើម ហើយត្រូវបានបែងចែកប្រើប្រាស់ទៅតាមគោលបំណងប្រើប្រាស់។ ញញួរដែលក្បាលសម្រាប់វាយធ្វើពីលោហៈក៏ត្រូវបានគេហៅថា "កាណាហ្សឺឈិ (ញញួរលោហៈ)" ផងដែរ។


ដែកគាស់

[ដែកគាស់] ឧបករណ៍ធ្វើពីលោហៈដែលអាចប្រើជាឃ្នាស់។ ផ្នែករាងអក្សរ L ដែលនៅខាងចុង មានចង្អូរសម្រាប់ដកដែកគោលដោយដាក់ក្បាលដែកគោលចូលហើយគាស់ដែកគោលចេញដោយប្រើគោលការណ៍ឃ្នាស់។ ចុងម្ខាងទៀតអាចមានរាងសម្រាប់គាស់ដែកគោល ឬរាងសំប៉ែតដូចវែកកូរ។ ក្រៅពីការដកដែកគោល ចំពោះដែកគាស់ធំៗគឺអាចគាស់បង្វើបវត្ថុធ្ងន់ៗបាន។ ម្យ៉ាងទៀត វាក៏អាចប្រើដោយស៊កចូលចន្លោះដើម្បីមួលឬគាស់ផងដែរ។ ក្នុងការងាររុះរើពុម្ព ដែកគាស់ធំត្រូវប្រើប្រាស់។

### 5.2.7 ការឆាប/ខាត់/ចោះរន្ធ

**[ថ្មឆាប]** ឧបករណ៍សម្រាប់កាត់ ខាត់លោហៈនិងថ្មជាដើម។ ថ្មឆាបទំហំតូចរាងចតុកោណកែងត្រូវបានប្រើដើម្បីសំលៀងផ្លែរបស់ "ពន្លាក" និង "ដែកឈូស" ឲ្យមុតល្អ។

**[ប្រាសដែក]** ប្រាសរឹងធ្វើពីសរសៃលោហៈ។ គេប្រើវាសម្រាប់ដុះជម្រះស្នឹមច្រែះរបស់លោហៈ ជម្រះថ្នាំលាប និងសម្អាតមុខដែកឆាបជាដើម។







### 5.2.8 ការរឹត/ភ្ជាប់

**[ម៉ាឡេត]** សោរឹតដែលអាចសារេបិទបើកបាន។ វាអាចប្តូរទំហំដង្កៀបលើដង្កៀបក្រោមតម្រូវតាមអង្កត់ផ្ចិតរបស់ប៊ូឡុង ឬក្បាលឡោស៊ី។ ដោយសារដង្កៀបលើនិងដងកាន់គឺជាតួតែមួយ ដូច្នេះគេបង្វិលធ្វើយ៉ាងណាឲ្យបន្ទុកកម្លាំងទៅលើដង្កៀបលើ។ ដោយសារមាត់វាបើកចំហ វាត្រូវបានចាត់ថ្នាក់ជា "សោមាត់អក្សរអ៊ុយ" ប៉ុន្តែជាករណីលើកលែង ម៉ាឡេតក្នុងភាសាជប៉ុនមានប្រើពាក្យថាសោមាត់ចិញ្ចៀននៅក្នុងនោះ។




**[សោគាន់(រ៉ុកកាគុ រ៉េនឈិ)]** ឧបករណ៍សម្រាប់បង្វិលប៊ូឡុងដែលមានរន្ធរាងប្រាំមួយជ្រុង។ វាក៏ត្រូវបានគេហៅថា "រ៉ុកកាគុបូ រ៉េនឈិ" ផងដែរ។



[ទួណឺវីស] ឧបករណ៍សម្រាប់មួលវីស។ មានទួណឺវីសមាត់ស្រួចនិងមាត់សំប៉ែតទៅតាមចង្អូរនៃក្បាលវីស។ ដើម្បីកុំឲ្យខូចចង្អូរនៃក្បាលវីស(ហៅថា "ខូចក្បាល") វាសំខាន់ដែលត្រូវប្រើទួណឺវីសដែលត្រូវទំហំ។ ទ្រង់ទ្រាយនៃដងកាន់ក៏សំខាន់ផងដែរ ឧទាហរណ៍ ទួណឺវីសសម្រាប់ការងារអគ្គិសនីមានដងកាន់ជុំមូលដើម្បីងាយស្រួលកាន់ក្តោប។




## 5.2.9 ការច្របល់/លាយ

[ម៉ាស៊ីនលាយបេតុង] ម៉ាស៊ីនលាយសម្រាប់បេតុង ដោយមានភាពរឹងជាងម៉ាស៊ីនលាយបាយអ។




[ស្នូក(គុរ៉ុបាកុ)] ជាប្រអប់រឹងមាំសម្រាប់ដាក់សម្ភារបង្កើតបេតុងឬបាយអចូលលាយច្របល់។ វាក៏ត្រូវបានគេហៅថា "គុរ៉ុប៊ុណិ" ឬ "ហ្វ៊ុណិ" ផងដែរ។ សម្ភារដែលដាក់ចូលស្នូកគឺលាយច្របល់ដោយប្រើម៉ាស៊ីនកូរ ឬ ប៉ែលសម្រាប់លាយច្របល់។

## 5.2.10 ការគ្របបាំងថែទាំ

[សំណាញ់ការពារហោះខ្ទាត] ផ្ទាំងសំណាញ់សម្រាប់រន្ទាដែលគ្របដណ្តប់លើអគារទាំងមូល។ វាក៏ត្រូវបានប្រើផងដែរដើម្បីការពារការហោះខ្ទាតនៃសម្ភារសំណង់ដែលប្រមូលផ្តុំនៅការដ្ឋាន និងការពារការធ្លាក់អីវ៉ាន់ពីតួដាក់អីវ៉ាន់នៃយានជំនិះដឹកជញ្ជូន។




[សំណាញ់បាំងការពារផ្តេក] ជាសំណាញ់សម្រាប់ការពារការធ្លាក់មនុស្សឬសម្ភារពីទីខ្ពស់នៅការដ្ឋានសំណង់។

## 5.2.11 ការជម្រះប្រឡាក់

**[ក្រណាត់ជូត]** ក្រណាត់សម្រាប់ជូតសម្អាតប្រឡាក់ពីវត្ថុរាវដូចជាប្រេងម៉ាស៊ីនជាដើម។

**[ធុង]** ឧបករណ៍ផ្ទុកទឹកមានដៃសម្រាប់ដាក់ទឹកចូលហើយជញ្ជូន។ សម្រាប់ការសាងសង់ គេប្រើធុងមាំដែលធ្វើពីបន្ទះដែកស័ង្កសី។

【ប៉ោយទឹក】 ឧបករណ៍សម្រាប់ដួសទឹកដោយមានដៃកាន់។

## 5.2.12 ការជញ្ជូនវត្ថុ







**[រទេះរុញអីវ៉ាន់]** រទេះមានកង់បួននៅផ្ទាំងផ្ទុកអីវ៉ាន់ដែលប្រើសម្រាប់ជញ្ជូនវត្ថុ។ វាមានប្រភេទដែលមានដៃកាន់ និងគ្មានដៃកាន់។ ក៏មានរទេះរុញអីវ៉ាន់ដែលមានហ្វ្រាំងផងដែរ។

**[រថយន្តចូកលើកដាក់អីវ៉ាន់]** រថយន្តដែលមានភ្ជាប់សមដែលផ្លាស់ទីឡើងចុះដោយអ៊ីដ្រូលិក។ គេដាក់វត្ថុនៅលើសមដើម្បីលើកវត្ថុទៅទីខ្ពស់ឬយកវត្ថុនៅទីខ្ពស់ដាក់ចុះ។

## 5.2.13 ការយោងស្ទូច/លើក/ទាញ




**[ម៉ាស៊ីនរវៃយោង(winch)]** ម៉ាស៊ីនមូរខ្សែពួរ។ គេក៏ហៅវាថា "ម៉ាស៊ីនរ៉ក" ផងដែរ។

**[ខ្សែពួរដែក]** ខ្សែដែកដែលមានភាពរឹងនៃតំណឹងខ្លាំងមួយចំនួនត្រូវបានត្របាញ់បង្កើតជា "របុំ" ហើយរបុំនេះមួយចំនួនត្រូវបានត្របាញ់បន្ថែមទៀតបង្កើតជាខ្សែពួរនេះ។ វាមានលក្ខណៈពិសេសគឺ កម្លាំងតំណឹងខ្លាំង កម្លាំងធូន់នឹងការប៉ះទង្គិចល្អប្រសើរ នឹងងាយស្រួលប្រើដោយមានភាពបត់បែន។ ខ្សែពួរដែលចុងសងខាងត្រូវបានកែច្នៃ ត្រូវបានប្រើសម្រាប់ការងារថ្លក់។ ម្យ៉ាងទៀតក៏មានខ្សែពួរសម្រាប់ចងថ្លក់ភ្ជាប់ផងដែរ។




**[កៅឡាក់]** ម៉ាស៊ីនដែលអាចលើកឡើងចុះវត្ថុធូន់ៗដោយប្រើគោលការណ៍ឃ្នាស់និងរ៉ក។ គេប្រើវាដោយភ្ជាប់វាទៅនឹងទម្រដើងបីជាដើម។

**[ឧបករណ៍បន្តឹងខ្សែពួរមេសុវត្ថិភាព]** ឧបករណ៍ដែលអាចបន្តឹងកុំឲ្យធូរនូវខ្សែពួរមេសុវត្ថិភាពដែលថ្លក់តម្លក់ខ្សែក្រវាត់សុវត្ថិភាព។ វាត្រូវបានប្រើនៅពេលធ្វើការងារទីខ្ពស់ដូចជាពេលប្រើរន្ទាជាដើម។

**[ដូយ]** ឧបករណ៍សម្រាប់លើកវត្ថុធូន់ៗដោយប្រើកម្លាំងតិច។ យន្តការនៃការលើកមានដូចជា វីស/ស្ពឺ/អ៊ីដ្រូលិកជាដើម។



### 5.2.14 បន្ទារ/ជណ្ដើរ




[ជណ្ដើរជ្រែង] ឧបករណ៍ដែលជាការរួមផ្សំដោយជណ្ដើរផ្អែក 2។ ពេលបើកជ្រែងវា នឹងអាចប្រើជាជណ្ដើរផ្អែកបាន។ ពេលប្រើជណ្ដើរជ្រែង មិនត្រូវអង្គុយឬឈរលើថាសជណ្ដើរឡើយ។ ម្យ៉ាងទៀត បើធ្វើការដោយជិះជ្រែងជើងច្រកកៀរលែងថាសជណ្ដើរ វាមានគ្រោះថ្នាក់ដោយមិនមានលំនឹង ហេតុនេះសូមជៀសវាង។




[បន្ទារចល័ត] ឧបករណ៍ដែលមានបន្ទារនៅចន្លោះជើង 2 ដែលពន្លូតវែងខ្លីបាន។ វាត្រូវបានហៅថា "ណុប៊ិរិអ៊ុម៉ា" ផងដែរ។ នៅលើបន្ទារមានបង្កាន់ដៃ។ ការទ្រោបបែរទៅក្រៅ ឬរុញជញ្ជាំង អាចមានហានិភ័យដួលដោយសារបាត់លំនឹង។

[យានជំនិះធ្វើការទីខ្ពស់] យានជំនិះដែលបំពាក់ឧបករណ៍ដែលអាចលើកឡើងចុះកន្ត្រកសម្រាប់ធ្វើការដល់កម្ពស់ 2m ឡើង។

### 5.2.15 ការសម្អាត

【អំបោស】 ឧបករណ៍សម្រាប់បោសសម្អាត។ នៅខាងចុងដងមានភ្ជាប់ មែកឬស្សី រុក្ខជាតិឬសរសៃសំយោគគីមីជាដើម ដែលរុំជាបាច់។

[ស្នូកសំរាម] ឧបករណ៍សម្រាប់ប្រមូលសំរាមនិងធូលីកម្ទេចកម្ទីដែលប្រមូលបានដោយអំបោស។






# មេរៀនទី 6 ចំណេះដឹងទាក់ទងនឹងការអនុវត្តការងារនៅការដ្ឋានសំណង់

## 6.1 ចំណុចរួមនៅក្នុងការដ្ឋានសំណង់

នៅការដ្ឋានសំណង់ មានអ្នកជំនាញនៃប្រភេទការងារជាច្រើនចេញចូល។ ការងារដែលធ្វើគឺមើលទៅដូចជាខុសគ្នារៀងៗខ្លួន ប៉ុន្តែអ្នកជំនាញដឹងច្បាស់តែងតែមានចំណុចដែលយកចិត្តទុកដាក់ជានិច្ច។ ចំណុចនោះនឹងនាំទៅរកគុណភាពខ្ពស់និងសុវត្ថិភាព។ នៅផ្នែកនេះ យើងពន្យល់អំពីចំណុចរួមដែលអ្នកជំនាញគ្រប់គ្នាគួរដឹងទុកជាមុន។

### 6.1.1 លក្ខណៈពិសេសនៃការងារសំណង់

(1) ការងារសំណង់ គឺជា "ការផលិតតាមការកម្ម៉ង់"។

"ការផលិតតាមការកម្ម៉ង់" គឺមិនមែនផលិតដដែលៗនូវរបស់ដែលរចនាតែមួយនៅរោងចក្រដូចជារថយន្តនោះទេ វាគឺជាការផលិតរបស់តែមួយដែលរចនាឡើងពីដំបូងតម្រូវតាមបំណងអតិថិជន។ ការងារសំណង់ត្រូវបានធ្វើឡើងតាមបែប "ការផលិតតាមការកម្ម៉ង់"។ ការងារមានទំហំផ្សេងៗគ្នាចាប់ពីខ្នាតធំរហូតដល់ខ្នាតតូច ហើយទោះបីជាមើលទៅការងារដូចគ្នាមែន ប៉ុន្តែលក្ខខណ្ឌនិងលក្ខណៈពិសេសនៃការងារនីមួយៗគឺមានភាពខុសៗគ្នា។ ការយល់ដឹងថា "ការផលិតតាមការកម្ម៉ង់" សម្រាប់អតិថិជនម្នាក់ គឺជាការសំខាន់។

(2) ការងារសំណង់ គឺជាការងារដែលរងលក្ខខណ្ឌកំហិតពាក់ព័ន្ធនឹងដី។

ការងារសំណង់  ភាគច្រើនគឺសាងសង់អាស្រ័យតាមដីដែលមានលក្ខណៈពិសេសរៀងៗខ្លួនតាមអគារនីមួយៗ ដូច្នេះហើយមិនមានការសាងសង់ដូចគ្នាក្រោមលក្ខខណ្ឌដូចគ្នានោះទេ។

(3) ការងារសំណង់ គឺទទួលរងឥទ្ធិពលពីធម្មជាតិ។

ការងារសំណង់ ភាគច្រើនធ្វើការងារនៅខាងក្រៅ ដូច្នេះហើយតែងតែទទួលឥទ្ធិពលពីកត្តាមិនជាក់លាក់ដូចជាទទួលឥទ្ធិពលពីលក្ខខណ្ឌធម្មជាតិដូចជាអាកាសធាតុ រដូវកាល និងសណ្ឋានដីជាដើម។

(4) ការងារសំណង់ គឺជាការងារដែលរងលក្ខខណ្ឌកំហិតពាក់ព័ន្ធនឹងសង្គម។

ការងារសំណង់គឺជាការផលិតនៅទីតាំងផ្ទាល់ ដូច្នេះវាទទួលរង "លក្ខខណ្ឌកំហិតពាក់ព័ន្ធនឹងសង្គម" នៅក្នុងការដ្ឋាន។ ការគ្រប់គ្រងដោយផ្អែកលើវិធានការសុវត្ថិភាពនិងវិធានការរក្សាបរិស្ថាន

ចំពោះតំបន់ជុំវិញ គឺជារឿងសំខាន់។ ដោយសារតែបរិស្ថានសង្គមជុំវិញនិងច្បាប់បទប្បញ្ញត្តិដែលត្រូវបានអនុវត្ត មានលក្ខណៈខុសគ្នាទៅតាមកន្លែងដែលត្រូវសាងសង់ ដូច្នេះគឺទាមទារការងារសំណង់ដោយគោរពតាមលក្ខខណ្ឌទាំងនេះ។

(5) គុណភាព គឺបង្កើតតាមរយៈ "ដំណាក់កាលសុវត្ថិភាព"។

ទាំងការងារសំណង់ផងដែរ "គុណភាពរបស់សំណង់" ដែលបានសាងសង់រួច គឺត្រូវបានបង្កើតឡើងតាមរយៈ "ដំណាក់កាលនៃការអនុវត្តការសាងសង់ដោយសុវត្ថិភាព" នៃគ្រប់ការងារសំណង់ទាំងអស់។

### 6.1.2 ផែនការសាងសង់

ផែនការសាងសង់ គឺជាផែនការដើម្បីអនុវត្តការសាងសង់ដោយផ្អែកតាមឯកសារប្លង់រចនា ដូចជាលក្ខខណ្ឌកិច្ចសន្យានៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ គំនូសប្លង់ ប្លង់បទដ្ឋានបច្ចេកទេស និងឯកសារណែនាំអំពីការដ្ឋានជាដើម។ គេបង្កើតផែនការសាងសង់ដោយពិចារណាលើចំណុចដូចខាងក្រោម។

□បង្កើតផែនការក្នុងលក្ខខណ្ឌកំហិតពាក់ព័ន្ធនឹងសង្គមដូចជាច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាដើម។

□បង្កើតផែនការនៃវិធីសាស្ត្រគ្រប់គ្រងជារួមចំពោះ "គុណភាព" "ថវិកាសាងសង់" "ដំណាក់កាល" "សុវត្ថិភាព" "ការការពារបរិស្ថាន" ។

□បង្កើតផែនការដើម្បីធ្វើឲ្យសម្រេចបាននូវ "របស់ដែលមានគុណភាពខ្ពស់" ដោយ "ចំណាយទាបបំផុត" ក្នុង "រយៈពេលសាងសង់" ដោយរួមបញ្ចូល "មធ្យោបាយនៃការសាងសង់" ប្រកបដោយប្រសិទ្ធផល។

□បង្កើតផែនការដោយគិតគូរដល់ "ការការពារបរិស្ថាន" ដោយ "គ្មានគ្រោះថ្នាក់និងគ្មានគ្រោះមហន្តរាយ"។

□បង្កើតផែនការដោយប្រើប្រាស់ "មធ្យោបាយអនុវត្ត 5M"។ មធ្យោបាយអនុវត្ត 5M សំដៅលើ "មនុស្សឬកម្លាំងពលកម្ម(Men) សម្ភារ(Materials) វិធីសាស្ត្រ(Methods) ម៉ាស៊ីន(Machinery) ហិរញ្ញវត្ថុ(Money)។

□អនុវត្ត "ការស្រាវជ្រាវទុកមុន" ឲ្យបានគ្រប់គ្រាន់ដើម្បីក្តាប់ឲ្យបាននូវស្ថានភាព "ទីតាំង/ការដ្ឋាន" ជាដើម ហើយបង្កើតផែនការវិធីសាស្រ្តគ្រប់គ្រងនិងវិធានការ "មុនធ្វើការសាងសង់" និង "ពេលកំពុងធ្វើការសាងសង់"។

### 6.1.3 ការគ្រប់គ្រងការសាងសង់

ការគ្រប់គ្រងការសាងសង់ គឺការគ្រប់គ្រងដែលចាំបាច់ដើម្បីឲ្យអ្នកសាងសង់សម្រេចបាននូវរបស់ដែលជាគោលដៅនៃការងារសាងសង់ដែលមានគុណភាពដូចដែលបានកំណត់ ដោយយោងទៅតាមផែនការសាងសង់។ នៅការដ្ឋានសំណង់ ការសាងសង់ត្រូវបានអនុវត្តក្រោមការគ្រប់គ្រងតាមចំណុច 5 (ហៅថា "QCDSE") គឺការគ្រប់គ្រងគុណភាព(Quality) ការគ្រប់គ្រងថវិកា(Cost) ការគ្រប់គ្រងដំណាក់កាលការងារ(Delivery) ការគ្រប់គ្រងសុវត្ថិភាព(Safety) ការគ្រប់គ្រងការការពារបរិស្ថាន(Environment)។

### 6.1.4 ការរៀបចំត្រៀមមុនពេលធ្វើការសាងសង់

（1） ចំណុចដែលត្រូវពិចារណាជាចម្បងសម្រាប់ឯកសារណែនាំពីការអនុវត្តការសាងសង់

ដើម្បីអនុវត្តការសាងសង់ដែលត្រូវធ្វើនៅក្នុងថ្ងៃនោះឲ្យមានគុណភាពខ្ពស់ ចាំបាច់ត្រូវពិនិត្យបញ្ជាក់ពីខ្លឹមសារការងារ ហើយស្វែងយល់វាឲ្យបានត្រឹមត្រូវ។

□ ពិនិត្យនិងយល់ពីប្រការនីមួយៗនៃកិច្ចសន្យាម៉ៅការសាងសង់។

□ ពិនិត្យនិងយល់ពីខ្លឹមសារនៃការម៉ៅការសាងសង់(លក្ខខណ្ឌប៉ាន់ស្មានតម្លៃ) និងវិសាលភាពនៃការសាងសង់។

□ ពិនិត្យនិងយល់ពីប្លង់រចនា និងគំនូសប្លង់សាងសង់។

□ ពិនិត្យនិងយល់ពីលក្ខខណ្ឌការសាងសង់នៅការដ្ឋាន និងវិធាននៅការដ្ឋាន។

□ ពិនិត្យនិងយល់ពីកាលវិភាគការងារជាមួយអ្នកម៉ៅការផ្សេងទៀត ទំនាក់ទំនងជាមួយការងារសំណង់មុននិងក្រោយ។

□ ពិនិត្យបញ្ជាក់ជំហានអនុវត្តការសាងសង់ ចាត់តាំងកម្លាំងមនុស្ស រៀបចំត្រៀមសម្ភារនិងបរិ

ក្ខារ។

□ ពិនិត្យបញ្ជាក់ថាមាន/យកតាមខ្លួននូវកាតនៃប្រព័ន្ធលើកកម្ពស់អាជីព ប័ណ្ណអនុញ្ញាត(ពៃកមី)ដែលចាំបាច់សម្រាប់ការងារ។

□ ពិនិត្យនិងយល់ពីបញ្ហាខាងសុវត្ថិភាព។

(2) ការត្រួតពិនិត្យមុនចាប់ផ្តើមការងារ

នៅពេលធ្វើការងារនៅការដ្ឋានសំណង់ គេប្រើប្រាស់ឧបករណ៍និងម៉ាស៊ីនផ្សេងៗ។ គ្រោះថ្នាក់ដែលនៅក្បែរខ្លួនចំពោះកម្មករ កើតមានឡើងនៅពេលប្រើប្រាស់ឧបករណ៍និងបរិក្ខារ។ សូមធ្វើការត្រួតពិនិត្យមុនពេលចាប់ផ្តើមការងារដូចខាងក្រោមកុំខាន។

□ ការត្រួតពិនិត្យម៉ាស៊ីនមុនចាប់ផ្តើមការងារ

□ ការពិនិត្យបរិក្ខារ ប្រដាប់ ឧបករណ៍

□ ការពិនិត្យបញ្ជាក់ឯកសារជំហានអនុវត្តការងារ

□ ការពិនិត្យបញ្ជាក់សុវត្ថិភាព

### 6.1.5 ការគូសគំនូសសម្គាល់ (គំនូសសម្គាល់)

"ការគូសគំនូសសម្គាល់ (គំនូសសម្គាល់)" គឺសំដៅលើការគូសសញ្ញាសម្គាល់កម្ពស់និងទីតាំងសម្ភារនិងរចនាសម្ព័ន្ធដែលត្រូវធ្វើការសាងសង់នៅការដ្ឋានសាងសង់។ គេធ្វើវាឡើងដំបូងគេបំផុតមុនពេលចាប់ផ្តើមការងារនីមួយៗចាប់តាំងពីការចាប់ផ្តើមសាងសង់សំណង់រហូតដល់ពេលបញ្ចប់។ វាគឺជាការងារដែលចាំបាច់បំផុត ដែលទាមទារឲ្យមានគុណភាព (ភាពសុក្រឹត)។ គេធ្វើ "ការគូសទីតាំងឲ្យត្រឹមត្រូវ" ដូចជាគូសគំនូសគោលនិងនីវ៉ូគោលដែលមានភាពសុក្រឹត និងខ្សែអ័ក្សទៅតាមប្លង់រចនា។ល។ នៅក្នុងការគូសគំនូសសម្គាល់ គេប្រើប្រាស់ឧបករណ៍ដែលមានឈ្មោះថា "ហ្វីគគូសខ្សែ" ប៉ុន្តែបច្ចុប្បន្ននេះ គេក៏ប្រើប្រាស់វិធីសាស្ត្រដែលប្រើប្រាស់ឧបករណ៍បញ្ចាំងឡាស៊ែរដែលបាញ់ពន្លឺឡាស៊ែរហើយគូសតាមខ្សែនោះ។

## 6.2 ចំណេះដឹងអំពីការអនុវត្តការកែច្នៃបំពង់

នៅត្រង់ផ្នែកនេះ យើងពន្យល់អំពីចំណុចជាមូលដ្ឋាននៅក្នុងការកែច្នៃបំពង់ដែកថែបកាបូនសម្រាប់រត់បំពង់ បំពង់PVCរឹង និងបំពង់ដែកស្រោបPVCរឹងខាងក្នុងសម្រាប់ផ្គត់ផ្គង់ទឹក។

### 6.2.1 ការកែច្នៃបំពង់ដែកថែបកាបូនសម្រាប់រត់បំពង់

របៀបតភ្ជាប់បំពង់ដែកថែបកាបូនសម្រាប់រត់បំពង់ដែលជាតំណាង មានរបៀបតភ្ជាប់ដោយធ្មេញវីស របៀបតភ្ជាប់ដោយការផ្សារ របៀបតភ្ជាប់ដោយមេកានិច។

(1) របៀបតភ្ជាប់ដោយធ្មេញវីស

វាគឺជារបៀបតភ្ជាប់ទូទៅដែលគេប្រើប្រាស់តាំងពីបុរាណមក។ គេប្រើប្រាស់សម្រាប់បំពង់ 15A-100A ជាចម្បង។ A គឺបង្ហាញពីអង្កត់ផ្ចិតរបស់បំពង់ដែលគេហៅថា "ខ្នាតA"។ ឯកតារបស់វា គឺmm ។ "ខ្នាតB" ក៏មានដែរ ហើយឯកតារបស់វាគឺអ៊ិញ(inch)។ ជំហាននៃការអនុវត្តការងារគឺដូចខាងក្រោមនេះ។

**(1) ការកាត់បំពង់**

ការកាត់គឺគេប្រើ "ម៉ាស៊ីនកាត់បំពង់(bandsaw pipe cutting machine)" ដាក់បំពង់ដែកឲ្យជាប់នឹងតាមទិសផ្ដេកហើយកាត់ឲ្យកែងនឹងអ័ក្សបំពង់។ ប្រសិនបើកាត់មិនបានកែងទេ វានឹងធ្វើឲ្យមាន "ការកាត់វៀច" ឬ "ការកាត់ចេញគន្លាក់"។ "ការកាត់វៀច" ឬ "ការកាត់ចេញគន្លាក់" ពី 1.0mm ឡើង នឹងក្លាយជាមូលហេតុដែលធ្វើឲ្យលេចធ្លាយទឹក។



ការកាត់បំពង់ដែកដែលត្រឹមត្រូវ
និងការកាត់មិនល

**(2) ការកែច្នៃធ្មេញវីស (ការកាត់ធ្មេញវីស)**

បន្ទាប់ពីកាត់បំពង់ដែករួចហើយ គេភ្ជាប់ក្បាលកាត់(die head) ទៅនឹងម៉ាស៊ីនកាត់ធ្មេញវីស (មានភ្ជាប់ក្បាលកាត់(die head) ស្វ័យប្រវត្តិ) ហើយធ្វើការកែច្នៃធ្មេញវីស។ បើធ្វើការកែច្នៃធ្មេញវីសដោយមានពាក់ស្រោមដៃការងារ អាចធ្វើឲ្យមានគ្រោះថ្នាក់ដោយម៉ាស៊ីនកាត់ធ្មេញវីសទាញដៃចូល។

ដាច់ខាតកុំធ្វើការកែច្នៃផ្នេញវីសដោយពាក់ស្រោមដៃការងារ។ បន្ទាប់ពីបញ្ចប់ការងារកែច្នៃផ្នេញវីសរួចហើយ គេត្រួតពិនិត្យភាពសុក្រឹតនៃការកែច្នៃផ្នេញវីសដោយឧបករណ៍ពិនិត្យផ្នេញវីស។

**(3) ការងាររៀបចំមុនមួលបញ្ចូល**

បន្ទាប់ពីកែច្នៃផ្នេញវីសរបស់បំពង់ដែករួចហើយ គេចាប់ផ្តើមការងារមួលបញ្ចូល។ ប្រសិនបើការសម្អាតនិងការជម្រះប្រេងមិនបានគ្រប់គ្រាន់នៅផ្នែកតំណផ្នេញវីសទេនោះ វានឹងក្លាយទៅជាដើមហេតុលេចធ្លាយទឹក ដូច្នេះហើយចាំបាច់ត្រូវធ្វើការងាររៀបចំមុនមួលបញ្ចូលដូចខាងក្រោមនេះ។

បន្ទាប់ពីបញ្ចប់ការងាររៀបចំ គេនឹងធ្វើការងារមួលបញ្ចូល ប៉ុន្តែមុនធ្វើការងារមួលបញ្ចូល ត្រូវបិទសម្ភារបិទភ្ជិតនៅលើផ្នេញវីស។ សម្ភារបិទភ្ជិតមាន2ប្រភេទ គឺការបិទភ្ជិតនិងស្កុតទឹក។

**(4) ករណីប្រើប្រាស់ការបិទភ្ជិត**

មុនពេលលាបការបិទភ្ជិត ត្រូវជូតសម្អាតទឹក ប្រេង និងធូលីជាដើមចេញពីមុខតំណភ្ជាប់ម្តងទៀត។ កូរការឲ្យបានច្រើនដងមុននឹងប្រើវា។ លាបផ្នែកផ្នេញវីសទាំងមូលរបស់បំពង់ដែកនិងតំណដោយជក់ក្នុងបរិមាណចាំបាច់។ ត្រូវលាបដោយយកចិត្តទុកដាក់ឲ្យស្មើល្អ។

**(5) ករណីប្រើប្រាស់ស្កុតទឹក**

ស្កុតទឹកគឺរុំតម្រូវតាមទិសមួលបញ្ចូល។ ដោយសារទិសមួលបញ្ចូលគឺដូចទ្រនិចនាឡិកា ដូច្នេះត្រូវរុំស្កុតទឹកតាមទិសដៅទ្រនិចនាឡិកា។

**(6) ការមួលបញ្ចូល**

នៅពេលលាបឬរុំសម្ភារបិទភ្ជិតរួចហើយ គេមួលបញ្ចូល។ ដាក់បំពង់នៅអង្គុំឲ្យនឹង រួចហើយមួលបញ្ចូលតំណដោយដៃសិន។ ពេលវីតលែងបានតទៅទៀត ត្រូវមួលបញ្ចូលបន្ថែមដោយម៉ាឡេតបំពង់ដែលត្រូវនឹងអង្កត់ផ្ចិតបំពង់នោះ។ បើមួលបញ្ចូលខ្លាំងពេក វាអាចធ្វើការខូចផ្នេញវីសក៏មាន ដូច្នេះចាំបាច់ត្រូវមានការប្រុងប្រយ័ត្ន។

(2) របៀបតភ្ជាប់ដោយការផ្សារ

របៀបតភ្ជាប់ដោយការផ្សារសម្រាប់បំពង់ដែកថែបកាបូនសម្រាប់រត់បំពង់ មានរបៀបតភ្ជាប់ដោយការផ្សារនិងរបៀបតភ្ជាប់ដោយមេកានិច។ របៀបតភ្ជាប់ដោយការផ្សារ គេច្រើនប្រើលើបំពង់

ដែលមានអង្កត់ផ្ចិតធំ។ វាគឺជារបៀបតភ្ជាប់ដែលមានទំនុកចិត្តខ្ពស់នៅត្រង់ភាពរឹងមាំនៃការតភ្ជាប់ ប៉ុន្តែវាត្រូវការជំនាញខ្ពស់។ របៀបតភ្ជាប់ដោយការផ្សារមាន 2 ប្រភេទ គឺរបៀបតភ្ជាប់ដោយការផ្សារឧស្ម័ន និងរបៀបតភ្ជាប់ដោយការផ្សារធ្នូអគ្គិសនីមានស្រោប។

**【របៀបតភ្ជាប់ដោយការផ្សារឧស្ម័ន】**

វាគឺជារបៀបផ្សារលោហៈដោយប្រើប្រាស់កម្តៅឧស្ម័ន ហើយរបៀបនៃការផ្សារមាន 3ប្រភេទ គឺការផ្សារអុកស៊ីអាសេទីឡែន ការផ្សារអុកស៊ីអ៊ីដ្រូសែន និងការផ្សារខ្យល់អាសេទីឡែន។

**【របៀបតភ្ជាប់ដោយការផ្សារធ្នូអគ្គិសនីមានស្រោប】**

របៀបតភ្ជាប់ដោយការផ្សារធ្នូអគ្គិសនីមានស្រោប ត្រូវបានប្រើប្រាស់ក្នុងការងាររត់បំពង់ ជាមួយនឹងរបៀបតភ្ជាប់ដោយការផ្សារឧស្ម័ន។ នៅក្នុងរបៀបផ្សារធ្នូអគ្គិសនីមានស្រោប គេប្រើប្រាស់ធូបផ្សារមានស្រោបដោយមានលាបសារធាតុរំលាយដែលគេហៅថាម្សៅផ្សារ(flux) ដើម្បីធ្វើឲ្យផលប៉ះពាល់ដូចជាអុកស៊ីតកម្មនៃការផ្សារជាដើមស្ថិតក្នុងកម្រិតតិចតួច។

**(1) ការកាត់បំពង់និងការប៉ិតមុខ**

របៀបកាត់បំពង់ដែក គឺដូចគ្នានឹងករណីបំពង់មួលបញ្ចូលដែរ គឺគេកាត់ឲ្យកែងនឹងអ័ក្សបំពង់។ ប៉ុន្តែ ក្នុងករណីតភ្ជាប់ដោយការផ្សារ ក្រោយពេលកាត់បំពង់រួចចាំបាច់ត្រូវប៉ិតមុខនៅចុងបំពង់ ដើម្បីបង្កើនគុណភាពនៃការផ្សារ។ បើមិនធ្វើការប៉ិតមុខទេ វានឹងធ្វើឲ្យកើតមានការរលាយចូលមិនគ្រប់គ្រាន់ ហើយធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការផ្សារ។




មុខគំណដែលជាតំណាង

**(2) ការផ្សារបណ្តោះអាសន្ន**

មុនពេលធ្វើការផ្សារសម្រេច គេធ្វើការផ្សារបណ្តោះអាសន្នដើម្បីចាប់ភ្ជាប់ទីតាំងផ្នែកត្រូវផ្សារដែល

ត្រូវគ្នាឲ្យបានត្រឹមត្រូវល្អ និងការពារកុំឲ្យខុសទីតាំងមុខតំណដោយសារការរៀចនៃផ្នែកត្រូវផ្សារ។

**(3) ការផ្សារសម្រេច**

ជាការងារផ្សារជុំវិញបំពង់ទាំងមូលក្រោយពីការផ្សារបណ្ដោះអាសន្នរួចហើយ។ ការងារផ្សារ ត្រូវបានធ្វើឡើងដោយលក្ខខណ្ឌផ្សេងៗទៅតាមកម្មករផ្សារ (ជាងផ្សារ) ប៉ុន្តែដើម្បីទទួលបានលទ្ធផលល្អជានិច្ច វាសំខាន់ដែលត្រូវសន្សំបទពិសោធន៍ការងារផ្សារឲ្យបានគ្រប់គ្រាន់ ហើយជៀសវាងបង្កើតកំហុសក្នុងការផ្សារ។

(3) របៀបតភ្ជាប់ដោយមេកានិច

វាក៏ត្រូវបានហៅថារបៀបតភ្ជាប់បែបម៉ាស៊ីនដែរ។ គេធ្វើការតភ្ជាប់ដោយប្រើប្រាស់តំណhousing pipe fitting តំណ MD តំណអ័ក្ស(coupling fitting) និងតំណក្រចាប់(NO-HUB)។



ឧទាហរណ៍នៃតំណ housing pipe fitting

## 6.2.2 ការកែច្នៃបំពង់PVCរឹង

បំពង់PVCរឹងត្រូវបានកែច្នៃតាមលំដាប់លំដោយដូចខាងក្រោម។

**(1) ការកាត់បំពង់**

កាត់ឲ្យកែងនឹងអ័ក្សបំពង់។

**(2) សម្អាតមាត់បំពង់**

បន្ទាប់ពីកាត់បំពង់រួចហើយ គេសម្អាតមាត់បំពង់ខាងក្រៅនិងខាងក្នុងដោយប្រើកាំបិត ដើម្បីឲ្យបំពង់ងាយស្រួលចូលគ្រឿងតំណ។

**(3) ធ្វើសញ្ញាសំគាល់ស៊កចូល**

ដើម្បីបញ្ជាក់ថាបំពង់ចូលដល់ក្នុងគ្រឿងតំណបានត្រឹមត្រូវឬទេ គេត្រូវធ្វើសញ្ញាសំគាល់ប្រវែងដែលស៊កចូលនៃគ្រឿងតំណនៅលើបំពង់។

**(4) លាបកាវនៅលើបំពង់និងគ្រឿងតំណ**

ជូតសម្អាតទឹកនិងស្នាមប្រឡាក់នៅលើផ្ទៃដែលត្រូវលាប រួចហើយធ្វើការលាបកាវនៅលើបំពង់

និងគ្រឿងតំណ។

**(5) ស៊កបំពង់ចូលគ្រឿងតំណ**

ដាក់បំពង់ឲ្យចំមាត់គ្រឿងតំណហើយប្រើកម្លាំងស៊កបញ្ចូលយកតែម្តង។ ពេលស៊កដល់សញ្ញាសំគាល់ហើយ ត្រូវទប់វាឲ្យជាប់កុំបន្ថយកម្លាំងប្រហែល 10 វិនាទីរហូតដល់ការស្ងួត។

**(6) ជូតកាវដែលហៀរចេញ**

កាវដែលហៀរចេញក្រោយពេលស៊កចូល ត្រូវជូតចេញឲ្យបានស្អាត។

## 6.2.3 ការកែច្នៃបំពង់ដែកស្រោបPVCរឹងខាងក្នុងសម្រាប់ផ្គត់ផ្គង់ទឹក

**(1) ការកាត់បំពង់**



ឧទាហរណ៍នៃផ្នែកគគ្រើម

ការកាត់ត្រង់ឲ្យកែងនឹងអ័ក្សបំពង់ គឺដូចទៅនឹងបំពង់ផ្សេងៗទៀតដែរ។ ម្យ៉ាងវិញទៀត ដោយសារតែនៅពេលប្រើឧបករណ៍កាត់ដោយសង្កត់ដែលបំពាក់ម៉ាស៊ីនកាត់ផ្ចេញវីសនឹងធ្វើឲ្យចេញ "ផ្នែកគគ្រើម" ដូច្នេះត្រូវកាត់បំពង់ដោយប្រើម៉ាស៊ីនកាត់បំពង់ដូចជាម៉ាស៊ីនកាត់បំពង់(bandsaw) ឬម៉ាស៊ីនអារជាដើម។

**(2) ការសម្អាតផ្នែកគគ្រើម**

បន្ទាប់ពីធ្វើការងារកាត់បំពង់រួចហើយ ត្រូវធ្វើការសម្អាតផ្នែកគគ្រើមនៅផ្ទៃក្នុងបំពង់ដោយផ្លែចោះ(reamer)សម្រាប់បំពង់ស្រោប ឬប្រដាប់ឈូស។

**(3) ការកែច្នៃផ្ចេញវីស**

ការកែច្នៃផ្ចេញវីស គឺដូចនឹងបំពង់ដែកថែបកាបូនសម្រាប់រត់បំពង់ដែរ ប៉ុន្តែក្នុងករណីដែលបំពង់មានជ័រស្រោបពីខាងក្រៅ ត្រូវធ្វើការកាត់ផ្ចេញវីសដោយប្រើប្រាស់ឧបករណ៍ដែលមិនធ្វើឲ្យខូចដល់ជ័រស្រោបពីខាងក្រៅ។

## 6.3 ការងារម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់

### 6.3.1 ការកែច្នៃបំពង់ទុយោទង់ដែងមានស្រោបសម្រាប់សារធាតុធ្វើឲ្យត្រជាក់

"សារធាតុធ្វើឲ្យត្រជាក់" ដែលទទួលនិងផ្ទេរ "កម្តៅ" ចល័តវិលជុំឆ្លងកាត់បំពង់រវាងកន្ទុយខាងក្រៅនិងតួខាងក្នុងរបស់ម៉ាស៊ីនត្រជាក់។ អ្វីដែលប្រើនៅពេលនោះគឺបំពង់ទុយោទង់ដែងមានស្រោបសម្រាប់សារធាតុធ្វើឲ្យត្រជាក់។ ក្នុងការងាររត់បំពង់សម្រាប់ម៉ាស៊ីនឧបករណ៍បង្កកនិងកំណត់បរិយាកាសក្នុងបន្ទប់ ចាំបាច់ត្រូវធ្វើការងារដូចជាការកែច្នៃនិងតភ្ជាប់បំពង់ទុយោទង់ដែងមានស្រោបសម្រាប់សារធាតុធ្វើឲ្យត្រជាក់ដូចបង្ហាញខាងក្រោម។



បំពង់ទុយោទង់ដែងមានស្រោប
សម្រាប់សារធាតុធ្វើឲ្យត្រជាក់

**(1) ការកាត់សម្ភាររក្សាកម្តៅ**

សម្ភាររក្សាកម្តៅត្រូវកាត់ឲ្យកែងទៅនឹងបំពង់ទុយោទង់ដែងដោយប្រើកាំបិតរុញ។

**(2) ការកាត់បំពង់ទុយោទង់ដែង**

ដាក់ដង្កាប់កាត់បំពង់ឲ្យកែងនឹងបំពង់ហើយបង្វិលដោយរឹតមួយៗបណ្តើរដើម្បីកាត់ធ្វើយ៉ាងណាកុំឲ្យខូចទ្រង់ទ្រាយបំពង់ទុយោទង់ដែង។

**(3) ការសម្អាតផ្នែកគគ្រើម**

បំពង់ទុយោទង់ដែងដែលបានកាត់ដោយដង្កាប់កាត់បំពង់ ផ្ទៃខាងក្នុងនឹងចេញ "ផ្នែកគគ្រើម" ។ ការខាត់សម្អាតវានឹងធ្វើឲ្យការពង្រីកបំពង់រាងផ្កាត្រកួនជាដើមអាចអនុវត្តបានរលូន។ ការងារត្រូវប្រើឧបករណ៍ពិសេសដូចជា ផ្លែចោះ ប្រដាប់ឈូសជាដើម។

**(4) ការកែតម្រូវរាងមូល**

បន្ទាប់ពីធ្វើការសម្អាតផ្នែកគគ្រើម ត្រូវកែតម្រូវរាងមូលដោយឧបករណ៍កំណត់ទំហំសម្រាប់បំពង់សារធាតុធ្វើឲ្យត្រជាក់ជាដើម។

**(5) ការកែច្នៃបត់ពត់**

គេកែច្នៃបត់ពត់បំពង់ទុយោទង់ដែងមានស្រោបសម្រាប់សារធាតុធ្វើឲ្យត្រជាក់តម្រូវតាមការដ្ឋាន។ ការពត់មានពត់ដោយដៃនិងពត់ដោយប្រដាប់ពត់។ ចំណុចត្រូវប្រុងប្រយ័ត្ន 3 នៅក្នុងការកែ

ច្នៃបត់ពត់គឺ កុំឲ្យសំប៉ែត កុំឲ្យប៉ោង កុំឲ្យជ្រួញ។

**[ការពត់ដោយដៃ]**

ដាក់មេដៃទាំងពីរលើផ្នែកខាងក្នុងនៃកន្លែងចង់ពត់ ហើយពត់ដោយរំកិលមេដៃទៅចុងបំពង់បន្តិចម្តងៗបណ្តើរ។ បើពត់ខ្លាំងភ្លាមៗតែម្តង ឬពត់ឲ្យក្រោមកាំកំណោងអប្បបរមា នោះនឹងសំប៉ែតឬប៉ោង។

**[ការពត់ដោយប្រដាប់ពត់]**

ដើម្បីធ្វើឱ្យកាំកំណោងតូចស្អាត គេប្រើប្រដាប់ពត់ដែលត្រូវនឹងលក្ខណៈនិងកម្រាស់របស់បំពង់ទុយោទង់ដែង។ កាំកំណោងអប្បបរមាគឺអាចបានតូចរហូតដល់ត្រឹម 4 ដងឡើងនៃអង្កត់ផ្ចិតខាងក្រៅរបស់បំពង់ទុយោទង់ដែង។

## 6.3.2 ការតភ្ជាប់បំពង់សារធាតុធ្វើឲ្យត្រជាក់

ការតភ្ជាប់បំពង់សារធាតុធ្វើឲ្យត្រជាក់ មានការតភ្ជាប់ដោយពង្រីកបំពង់រាងផ្កាត្រកួន និងការតភ្ជាប់ដោយផ្សារដោយលោហៈបន្សារ។

### (1) ការតភ្ជាប់ដោយពង្រីកបំពង់រាងផ្កាត្រកួន

ការពង្រីកបំពង់រាងផ្កាត្រកួន គឺជាការកែច្នៃពង្រីកបំពង់ទុយោទង់ដែងឲ្យចេញរាងត្រែ។ ដោយការរឹតបន្តឹងដោយក្បាលឡោស៊ីផ្កាត្រកួន ផ្នែកពង្រីកផ្កាត្រកួននឹងត្រូវបានគាបឲ្យដើរតួនាទីបិទភ្ជិត។



ការតភ្ជាប់ដោយពង្រីក
បំពង់រាងផ្កាត្រកួន

### (2) ការតភ្ជាប់ដោយផ្សារដោយលោហៈបន្សារ

វាគឺជាវិធីសាស្ត្រតភ្ជាប់ដោយរំលាយលោហៈផ្សារហើយឲ្យជ្រាបចូលផ្ទៃត្រូវតភ្ជាប់។



ការតភ្ជាប់ដោយផ្សារ
ដោយលោហៈបន្សារ

### (3) ការតភ្ជាប់សម្ភាររក្សាកម្តៅ

សម្ភាររក្សាកម្តៅរួញតាមទិសដៅប្រវែង។ ដោយសារការកកើតំណក់ទឹកពីចន្លោះដោយសារការរួញនៃសម្ភាររក្សាកម្តៅអាចនាំឲ្យមានគ្រោះថ្នាក់ ចាំបាច់ត្រូវចាត់វិធានការកុំឲ្យ

កើតមានចន្លោះ។ ក្រោយរៀបចំផ្នែកភ្ជាប់រួច ដាក់ចុងសម្ភាររក្សាកម្ដៅឲ្យទល់គ្នាដើម្បីឲ្យគ្មានចន្លោះ ហើយរុំស្កុតសម្រាប់សម្ភាររក្សាកម្ដៅធ្វើយ៉ាងណាឲ្យផ្នែកតភ្ជាប់ស្ថិតនៅចំកណ្ដាលស្កុត។

## 6.4 ការងាររក្សាកម្ដៅរក្សាភាពត្រជាក់

### 6.4.1 រូបរាងនិងប្រភេទនៃសម្ភាររក្សាកម្ដៅ




រូបរាងនៃសម្ភាររក្សាកម្ដៅ គឺមានរាងជាបន្ទះ (បន្ទះរក្សាកម្ដៅ) រាងបន្ទះខ្សែ (បន្ទះខ្សែរក្សាកម្ដៅ) និងរាងស៊ីឡាំង (ស៊ីឡាំងរក្សាកម្ដៅ) ។ បន្ទះរក្សាកម្ដៅ និងបន្ទះខ្សែរក្សាកម្ដៅត្រូវបានប្រើសម្រាប់បំពង់ផ្លូវខ្យល់ ហើយស៊ីឡាំងរក្សាកម្ដៅត្រូវបានប្រើសម្រាប់បំពង់ចែកចាយ។ ក្រៅពីនេះ វារួមផ្សំដោយសម្ភារផ្នែកខាងក្រៅដូចជា សន្លឹកបន្ទះដែកពណ៌ និងក្រណាត់កញ្ចក់អាលុយមីញ៉ូមជាដើម ព្រមទាំងសម្ភារជំនួយដូចជា ខ្សែលួសដែក សំណាញ់លួសឆកោណ ស្កុតស្អិត និង ដែកគោលមួកជាដើម។

### 6.4.2 ឧទាហរណ៍នៃការរក្សាកម្ដៅរក្សាភាពត្រជាក់ចំពោះបំពង់

**(1) ផ្នែកបង្កប់ដូចជានៅក្នុងពិដានជាដើម**

ដោយសារគេមិនចាំបាច់ព្រួយបារម្ភអំពីរូបរាងខាងក្នុងនៅក្នុងពិដានឬក្នុងបំពង់ គេរុំស៊ីឡាំងរក្សាកម្ដៅ ដោយក្រណាត់កញ្ចក់អាលុយមីញ៉ូម (ALGC) ឬក្រដាសអាលុយមីញ៉ូម (ALK)  ហើយចាប់ភ្ជាប់បំពង់ ដោយមិនប្រើសម្ភារសម្រេចទេ។

**(2) ផ្នែកបណ្ដែតក្នុងអគារ**

សម្រាប់ការបណ្ដែតខាងក្នុងអគារ ដូចជា នៅក្នុងបន្ទប់ និងនៅផ្លូវដើរ ជាទូទៅគេប្រើប្រាស់គម្របជ័រសំយោគនិងសម្ភារសម្រេចការពារជម្រាប ។

**(3) បន្ទប់ម៉ាស៊ីន ឃ្លាំងរថយន្ត ឃ្លាំង ជាដើម**

គេរុំស៊ីឡាំងរក្សាកម្ដៅដោយក្រណាត់កញ្ចក់អាលុយមីញ៉ូម (ALGC) ឬក្រដាសអាលុយមីញ៉ូម (ALK) ។ សម្ភាររក្សាកម្ដៅក្នុងករណីបំពង់ផ្គត់ផ្គង់ទឹកនិងបំពង់បញ្ចេញចោលទឹកគឺគេប្រើសម្ភាររក្សាកម្ដៅ

ស្នោប៉ូលីស្ទីរ៉ែន(PS)។

**(4) ផ្នែកបណ្តែតខាងក្រៅអគារ**

ដោយសារគេត្រូវការភាពធន់នឹងអាកាសធាតុខ្ពស់សម្រាប់ទីតាំងបណ្តែតខាងក្រៅអគារ ស៊ីឡាំងរក្សាកម្តៅ ត្រូវបានរុំឡើងដោយ "ស្រោមការពារជម្រាប" ដែលត្រូវបានផលិតដោយការកែច្នៃបន្ទះដែកស្តើង។

## 6.4.3 ឧទាហរណ៍នៃការរក្សាកម្តៅរក្សាភាពត្រជាក់ចំពោះបំពង់ផ្លូវខ្យល់

ការងាររក្សាកម្តៅរក្សាភាពត្រជាក់សម្រាប់បំពង់ផ្លូវខ្យល់ ត្រូវបានធ្វើក្នុងគោលបំណងដើម្បីការពារពីការភាយកម្តៅចេញពីបំពង់ផ្លូវខ្យល់ និងការពារការឡើងកម្តៅនៃខ្យល់ក្នុងបំពង់ផ្លូវខ្យល់ដោយសារកម្តៅពីខាងក្រៅ។ តាមរយៈការរុំបំពង់ផ្លូវខ្យល់ដោយសម្ភាររក្សាកម្តៅ អាចបង្កើនប្រសិទ្ធផលនៃម៉ាស៊ីនត្រជាក់និងកម្តៅជាដើមនិងអាចសន្សំសំចៃថាមពល។ ដើម្បីរក្សាកម្តៅរក្សាភាពត្រជាក់ចំពោះបំពង់ផ្លូវខ្យល់ គេប្រើបន្ទះរក្សាកម្តៅស្រោបក្រដាសអាលុយមីញ៉ូម ឬបន្ទះរក្សាកម្តៅស្រោបក្រណាត់កញ្ចក់អាលុយមីញ៉ូមជាដើម ចាប់ភ្ជាប់វាទៅនឹងបំពង់ផ្លូវខ្យល់ ដោយប្រើដែកគោលមួក ឬស្កុតសម្រាប់ក្រណាត់កញ្ចក់អាលុយមីញ៉ូម ឬសំណាញ់លួសឆកោណ។ ផ្នែកបណ្តែតខាងក្រៅអគារ ត្រូវបានគ្របដោយស៊ុមធ្វើពីដែកអ៊ីណុកជាដើម ទៅតាមភាពចាំបាច់។



ការរក្សាកម្តៅរក្សាភាពត្រជាក់ចំពោះបំពង់ផ្លូវខ្យល់

## 6.5 ការងារបំពង់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)

## 6.5.1 ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ការដំឡើងបំពង់ដែក ductile

ជប៉ុនជាប្រទេសដែលកើតមានរញ្ជួយដីច្រើន។ ហេតុនេះ គេប្រើប្រាស់ "បំពង់ដែក ductile" ដែលអាចការពារបំពង់ទប់ទល់នឹងការរងគ្រោះពីរញ្ជួយដី។ បំពង់ដែក ductile មានប្រភេទផ្សេងៗ ប៉ុន្តែ

នៅប្រទេសជប៉ុន ប្រភេទដែលត្រូវបានប្រើប្រាស់ច្រើនជាងគឺ បំពង់ដែក ductile ប្រភេទ GX។




 បំពង់ដែក ductile ត្រូវបានតភ្ជាប់ដោយជំហានដូចខាងក្រោម។

**(1) ដំឡើងបំពង់**

ទម្លាក់បំពង់ដែលព្យួរថ្នមៗដោយឲ្យសញ្ញាសម្គាល់ក្រុមហ៊ុនផលិតបំពង់នៅខាងលើ។

**(2) សម្អាតបំពង់**

កម្ចាត់ចេញវត្ថុចម្លែកផ្សេងនៅចង្អូរនៃមុខខាងទទួលកន្លែងប្រហែល 30cm ពីគែមផ្ទៃមុខខាងស៊ក និងផ្ទៃមុខខាងទទួល។ បន្ថែមពីនេះ ជូតសម្អាតទឹកដែលជាប់នឹងផ្ទៃដែលភ្ជាប់រ៉ងកៅស៊ូ។



រូបពំនុះមុខកាត់នៃតំណភ្ជាប់បំពង់ដែក ductile ប្រភេទ GX

**(3) ពិនិត្យកងទប់(lock ring) និងប្រដាប់ទប់កងទប់(lock ring)**

កងទប់(lock ring) និងប្រដាប់ទប់កងទប់(lock ring) ត្រូវបានដាក់ជាឈុតទុកជាមុន។ ពិនិត្យដោយមើលនឹងភ្នែកនិងប៉ះដោយដៃថាតើវាស្ថិតនៅចង្អូរមុខខាងទទួលដែលបានកំណត់ត្រឹមត្រូវឬទេ។

**(4) ដាក់រ៉ងកៅស៊ូ**

ពិនិត្យបញ្ជាក់ថារ៉ងកៅស៊ូត្រូវបានដាក់ផ្លាកសំគាល់ថាសម្រាប់ប្រភេទ GX ព្រមទាំងពិនិត្យអង្កត់ផ្ចិត(nominal diameter)កុំខាន។ សម្អាតរ៉ងកៅស៊ូ ហើយដាក់ចូលផ្ទៃក្នុងមុខខាងទទួលដោយឲ្យផ្នែកមានជ្រុងបែរទៅមុខ។ បន្ទាប់មក ពាក់នៅទីតាំងដែលបានកំណត់បណ្តើរសង្កត់ដោយដៃឬញញួរប្លាស្ទិចដាដើមកុំឲ្យមានចន្លោះបណ្តើរ។ បន្ទាប់ពីពាក់រួច ប្រើញញួរប្លាស្ទិចវាយរ៉ងកៅស៊ូឲ្យលិចចូលផ្ទៃក្នុងមុខខាងទទួល។

**(5) លាបប្រេងរំអិល**

ប្រេងរំអិលគឺប្រើប្រេងរំអិលសម្រាប់តំណបំពង់ដែក ductile។ លាបប្រេងរំអិលឱ្យស្មើសាច់នៅផ្នែកស្លួចខាងក្នុងរ៉ងកៅស៊ូព្រមទាំងផ្ទៃខាងក្រៅមុខខាងស៊ក ពីខ្សែពណ៌សខាងចុងបំពង់ដល់ចុងបំព

ង់។

**(6) សឹកបញ្ចូលមុខខាងសឹក**

ញូរបំពង់ដោយម៉ាស៊ីនស្ទូចជាដើម ហើយដាក់មុខខាងសឹកថ្នមៗឲ្យត្រូវនឹងមុខខាងទទួល។ ពេលនោះ ត្រូវប្រាកដថារ៉ងកៅស៊ូនិងមុខខាងសឹកគ្មានជាប់វត្ថុចម្លែកផ្សេងដូចជាថ្មឬបំណែកឈើជាដើម។ បញ្ជាកៅឡាក់អង្កៀក(Lever hoist) សឹកមុខខាងសឹកបញ្ចូលមុខខាងទទួលយឺតៗ។

**(7) ពិនិត្យទីតាំងរ៉ងកៅស៊ូ**

ពិនិត្យទីតាំងរ៉ងកៅស៊ូដោយប្រើប្រដាប់វាស់គម្លាត(check gauge)ពិសេស។ ប្រដាប់វាស់គម្លាត(check gauge)ពិសេសត្រូវបានប្រើដើម្បីវាស់កម្រិតសឹកចូលបរិមាត្រទាំងអស់នៃចន្លោះរវាងមុខខាងទទួលនិងមុខខាងសឹក ដើម្បីពិនិត្យបញ្ជាក់ថាទាំងអស់គឺស្ថិតក្នុងកម្រិតទទួលយកបាន។

**(8) ចំណុចសំខាន់នៃការពត់បំពង់ចែកចាយ**

តំណបំពង់ត្រង់ អាចពត់ដល់មុំកម្រិតអនុញ្ញាត បន្ទាប់ពីតភ្ជាប់រួច។ បន្ទាប់ពីបញ្ជាក់ថាការតភ្ជាប់គឺប្រក្រតី គេពត់តំណយឺតៗក្នុងដែននៃមុំកម្រិតអនុញ្ញាត។

## 6.5.2 ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត/ហ្គាស ការតភ្ជាប់EF

បំពង់ប៉ូលីអេទីឡែនដែលប្រើសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងហ្គាស ជាបំពង់ដែលស្រាល មានភាពបត់បែន ធន់នឹងច្រេះស៊ី មានអនាម័យយ៉ាងល្អប្រសើ។ លើសពីនេះ វាគឺជាសម្ភារបំពង់ដែលមានភាពធន់ជាប់ផងដែរក្នុងគ្រាអាសន្ន ដូចជារញ្ជួយដី ការបាក់ស្រុតដីជាដើម។ សម្ភារបំពង់និងតំណសម្រាប់ផ្គត់ផ្គង់ទឹកស្អាតគឺពណ៌ខៀវ សម្រាប់ហ្គាសគឺពណ៌លឿង។



ការតភ្ជាប់EF នៃបំពង់ប៉ូលីអេទីឡែន

ក្នុងការតភ្ជាប់បំពង់ប៉ូលីអេទីឡែន មានការតភ្ជាប់EF (electrofusion) និងការតភ្ជាប់មេកានិច។ ការតភ្ជាប់EF គឺជាវិធីសាស្រ្តតភ្ជាប់ដែលដុតកម្ដៅខ្សែបញ្ចេញកម្ដៅដោយអគ្គិសនី ហើយដុតកម្ដៅរលាយជ័រនៃផ្ទៃខាងក្នុងតំណ

បំពង់និងផ្ទៃខាងក្រៅបំពង់ឲ្យរលាយចូលគ្នា។ បន្ទាប់ពីដាក់បំពង់(មុខខាងស៊ក)ចូលតំណបំពង់(មុខខាងទទួល)ដែលបង្កប់ខ្សែបញ្ចេញកម្ដៅដោយអគ្គិសនីនៅផ្ទៃដែលត្រូវតភ្ជាប់ គេដុតកម្ដៅខ្សែបញ្ចេញកម្ដៅដោយអគ្គិសនីដោយឲ្យចរន្តអគ្គិសនីឆ្លងកាត់ពីឧបករណ៍បញ្ជា(controller)។

ការតភ្ជាប់EF ត្រូវបានអនុវត្តតាមជំហានដូចខាងក្រោម។

**(1) ការកាត់បំពង់**

កាត់បំពង់ឲ្យចុងបំពង់កែងនឹងអ័ក្សបំពង់។

**(2) ការត្រៀមសុង EF (EF socket)**

បន្ទាប់ពីត្រួតពិនិត្យថាបំពង់មានដាច់រលាត់ឬទេហើយ សម្អាតដីនិងស្នាមប្រឡាក់ដែលជាប់នឹងបំពង់ដោយប្រើក្រដាសជូតឬក្រណាត់ស្អាត។ វាស់ពីចុងបំពង់ហើយគូសខ្សែសម្គាល់នៅទីតាំងនៃប្រវែងស៊កដែលត្រូវបានកំណត់។

**(3) ការកោសឈូស**

ប្រើប្រដាប់ឈូសដើម្បីកោសឈូសផ្ទៃលើនៃបំពង់ពីចុងបំពង់ដល់ខ្សែសម្គាល់។

**(4) ការសម្អាតផ្ទៃរលាយភ្ជាប់**

សម្អាតផ្ទៃកោសឈូសរបស់បំពង់និងផ្ទៃក្នុងទាំងមូលរបស់សុង EF (EF socket) ដោយក្រដាសជូតដែលផ្សើមដោយអេតាណុលឬអាសេតូន។

**(5) ការធ្វើសញ្ញាសំគាល់**

ស៊កបំពង់ដែលកោសឈូសនិងសម្អាតរួចចូលសុងហើយធ្វើសញ្ញាសំគាល់នៅបំពង់តាមផ្ទៃគែម។

**(6) ការស៊កនិងចាប់ភ្ជាប់បំពង់និងតំណ**

ស៊កបំពង់ទាំងពីរចូលសុង EF (EF socket) ឲ្យដល់ទីតាំងខ្សែសំគាល់។ បន្ទាប់មក ប្រើក្រចាប់ចាប់ភ្ជាប់បំពង់និងសុង EF (EF socket)។

**(7) ការត្រៀមរំលាយភ្ជាប់**




ដោតឌុយឧបករណ៍បញ្ជា(controller) ចូលព្រី។ ហើយបើកកុងតាក់។ បន្ទាប់មក ភ្ជាប់ខ្សែបញ្ចេញទៅនឹងក្បាលនៃតំណ។ រួចប្រើប្រដាប់អានបារកូតដែលភ្ជាប់នឹងឧបករណ៍បញ្ជា(controller) ដើម្បីអានទិន្នន័យរំលាយភ្ជាប់។

**(8) ការរំលាយភ្ជាប់**

ចុចប៊ូតុងចាប់ផ្តើមនៅលើឧបករណ៍បញ្ជា(controller) ដើម្បីចាប់ផ្តើមឲ្យចរន្តអគ្គិសនីឆ្លងកាត់។ បន្ទាប់មក ការឲ្យចរន្តអគ្គិសនីឆ្លងកាត់នឹងបញ្ចប់ដោយស្វ័យប្រវត្តិ។

**(9) ការត្រួតពិនិត្យ**

ពិនិត្យបញ្ជាក់ថាប្រដាប់ចង្អុលបង្ហាញ(Indicator)របស់សុង EF (EF socket) ទាំងឆ្វេងទាំងស្តាំគឺងើបឡើង។ ហើយពិនិត្យបញ្ជាក់ថាការបង្ហាញរបស់ឧបករណ៍បញ្ជា(controller) គឺបានបញ្ចប់ដោយប្រក្រតី។

**(10) ការបញ្ចុះត្រជាក់**

ក្រោយបញ្ចប់ការរំលាយភ្ជាប់ បញ្ចុះត្រជាក់ដោយទុកចោលក្នុងរយៈពេលដែលកំណត់ទុកជាស្រេច។

## 6.5.3 ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារទូរគមនាគមន៍

**(1) ការរត់បំពង់ក្រោមដី**

គេប្រើតំណលូតរួញជាដើមដើម្បីតភ្ជាប់នៅកន្លែងដែលគេគិតថាបំពង់បញ្ជូននឹងមានការលូតរួញ។

**(2) ការរត់ខ្សែកាប**

រត់ខ្សែធ្វើយ៉ាងណាឲ្យមានសល់ខ្សែខ្លះនៅក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតតូច(handhole)ដែលនៅជិតច្រកទាញចូលនិងច្រកទាញចេញ ។

**(3) ការរត់ខ្សែកាបអុបទិកក្រោមដី**

នៅក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតតូច(handhole) ត្រូវធានានូវប្រវែងចាំបាច់នៃខ្សែកាបអុបទិកសម្រាប់ទាំងផ្នែកតភ្ជាប់ និងផ្នែកទាញចូល ហើយគិតគូរធ្វើយ៉ាងណាកុំឲ្យកើតមានការដាច់ខ្សែដោយសារកំណួចខ្សែនៅពេលផ្លាស់ទីខ្សែកាបក្នុងករណីមានគ្រោះមហន្តរាយ។ល។

### 6.5.4 ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារបង្កប់បំពង់

#### (1) ការធ្វើឲ្យខូចឬដាច់បំពង់បង្កប់ស្រាប់ពេលជីក

អ្វីដែលត្រូវប្រុងប្រយ័ត្ននៅក្នុងការងារបង្កប់បំពង់ គឺការធ្វើឲ្យខូចឬដាច់បំពង់បង្កប់ស្រាប់។ ឧបទ្ទវហេតុធ្វើឲ្យខូចឬដាច់បំពង់បង្កប់ដូចជាបំពង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ បំពង់ហ្គាស បំពង់បណ្តាញទូរគមនាគមន៍ និងបំពង់ខ្សែភ្លើងជាដើម មិនត្រឹមតែរំខានដល់ការដ្ឋានសំណង់ប៉ុណ្ណោះទេ ថែមទាំងរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ជុំទូលាយទៀតផង។ ឧបទ្ទវហេតុធ្វើឲ្យខូចឬដាច់បំពង់បង្កប់កើតឡើងដោយមូលហេតុដូចខាងក្រោម។

□ ការណែនាំមិនជិតដល់

□ គ្មានការជីកសាកល្បង ឬការជីកសាកល្បងមិនគ្រប់គ្រាន់

□ ទីតាំងនៃបំពង់បង្កប់គឺខុសពីប្លង់

□ ការពិនិត្យបញ្ជាក់សៀវភៅបញ្ជីជាដើមទុកជាមុនគឺមិនបានគ្រប់គ្រាន់

□ មិនមានកំណត់ត្រាក្នុងសៀវភៅបញ្ជីផ្លូវថ្នល់។

□ មិនបានត្រួតពិនិត្យរូបរាងរបស់បំពង់ដូចជាការពត់កោង និងការបញ្ឈរជាដើម។

□ បំពង់បង្កប់គឺស្ថិតនៅទីតាំងរាក់

□ មិនបានធ្វើសញ្ញាសម្គាល់វត្ថុបង្កប់នៅលើផ្លូវ

វាមានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរព័ត៌មានរវាងអ្នកម៉ៅការនីមួយៗ ដើម្បីក្តាប់បានត្រឹមត្រូវនូវទីតាំងដំឡើងវត្ថុបង្កប់ក្រោមដីដែលមានស្រាប់។ មុននឹងចាប់ផ្តើមការងារ ត្រូវធ្វើការជីកសាកល្បងឲ្យគ្រប់គ្រាន់ ហើយក្នុងពេលជីក ត្រូវប្រើឧបករណ៍ចាប់ទីតាំងបំពង់ដែក/ខ្សែកាប ដើម្បីរកទីតាំងនៃបំពង់បង្កប់។ ករណីប្រើគ្រឿងចក្រដូចជាអេស្កាវ៉ាទ័រប៉ែកហូ(Backhoe)ជាដើមសម្រាប់ការជីក ត្រូវជីកដោយកម្លាំងមនុស្សនៅបរិវេណក្នុងរង្វង់ 50cm ជុំវិញបំពង់បង្កប់ស្រាប់។

### (2) គ្រោះមហន្តរាយទាក់ទងនឹងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole)

ក្នុងចំណោមគ្រោះមហន្តរាយទាក់ទងនឹងការងារនៅខាងក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ (manhole) ជាញឹកញាប់គេឃើញគ្រោះមហន្តរាយដែលបណ្តាលមកពីអាការខ្វះអុកស៊ីសែននិងការពុលអ៊ីដ្រូសែនស៊ុលផួ។ អ្នកដែលអាចចូលទៅក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole) គឺជាអ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាលជំនាញប្រធានក្រុមការងារអំពីគ្រោះថ្នាក់កង្វះអុកស៊ីសែនប្រភេទទី1 និងប្រភេទទី2 ឬការបណ្តុះបណ្តាលពិសេសអំពីការងារដែលមានគ្រោះថ្នាក់កង្វះអុកស៊ីសែន។ ត្រូវវាស់កំហាប់អុកស៊ីសែននិងកំហាប់អ៊ីដ្រូសែនស៊ុលផួ ហើយធ្វើការផ្លាស់ប្តូរខ្យល់កន្លែងធ្វើការដើម្បីឲ្យកំហាប់អុកស៊ីសែនមាន 18% ឡើងទៅ ហើយកំហាប់អ៊ីដ្រូសែនស៊ុលផួមានមិនលើស 10 ppm ។ ម្យ៉ាងវិញទៀត ក៏មានគ្រោះថ្នាក់ធ្លាក់ពីជណ្តើរដោយសារកង្វះអុកស៊ីសែនផងដែរ។ នៅកន្លែងដែលអាចនឹងខ្វះអុកស៊ីសែនទោះបីជាកម្ពស់មិនលើស 2m ក៏ដោយ ត្រូវពាក់ឧបករណ៍ការពារការធ្លាក់។ ការសាងសង់និងការងារទាក់ទងនឹងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole) ជារឿយៗត្រូវបានអនុវត្តនៅលើផ្លូវថ្នល់ដែលមានរថយន្តធ្វើចរាចរ ដូច្នេះក៏កើតមានគ្រោះថ្នាក់ជាមួយរថយន្តដែលធ្វើចរាចរផងដែរ។ នៅជុំវិញប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole) ត្រូវរៀបចំបរិក្ខារសុវត្ថិភាពដូចជា របងព័ទ្ធ (ឡប់ឡែជុំវិញប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ) ក៏ដូចជារៀបចំឲ្យមានអ្នកធ្វើសញ្ញានាំផ្លូវផងដែរ ។




## 6.6 ការងារលោហៈបន្ទះសំណង់

### 6.6.1 ការកែច្នៃលោហៈបន្ទះ

ការងារលោហៈបន្ទះសំណង់គឺជាការងារកាត់ ពត់ ដំ និងផ្សារជាដើមនូវបន្ទះលោហៈស្តើង ដើម្បីបង្កើតនិងដំឡើងសម្ភារតាមគោលបំណងប្រើប្រាស់។ វាជាការងារដែលពាក់ព័ន្ធយ៉ាងទូលំទូលាយនឹងការរត់បំពង់និងការងារដំបូលជាដើម។ ការងារដែលចាំបាច់សម្រាប់ការកែច្នៃបន្ទះដែក ជាមូលដ្ឋានគឺ ការឆូតសម្គាល់ ការកាត់ ការពត់ និងការផ្សារ។ នៅពេលបង្កើតផលិតផលដែលមានរូបរាងស្មុគស្មាញ ចាំបាច់ត្រូវការបច្ចេកទេសដែលហៅថាដំ។

**(1) ការឆូតសម្គាល់**

គេឆូតសម្គាល់តែម្តងគត់តាមតែអាចធ្វើទៅបាន ដោយប្រើម្ជុលឆូតសម្គាល់ ដែកឈានម្ជុលពីរ បន្ទាត់ធ្វើពីលោហៈជាដើម។ ប្រសិនបើបង្កើតរបស់ដូចគ្នាច្រើន គេបង្កើតឧបករណ៍វាស់ដើម្បីជំរុញការងារឲ្យមានប្រសិទ្ធផល។


ការងារឆូតសម្គាល់

**(2) ការកាត់**


ការងារកាត់

ត្រូវកាត់ដោយប្រុងប្រយ័ត្នដោយប្រើដៃលើកផ្នែកដែលចង់រក្សាទុកបណ្តើរ ដើម្បីឱ្យកន្ត្រៃអាចលូកចូលបានយ៉ាងងាយស្រួល។ ត្រូវខាត់ផ្នែកកាត់ឲ្យរលោងដោយដែកឆាបធ្វើពីលោហៈ។

**(3) ការពត់**


ការងារពត់

គេដំពីលើខ្សែឆូតសម្គាល់នៅផ្នែកខាងក្រោយដោយប្រើដែកដាប់សំប៉ែត និងញញួរ។ បន្ទាប់មក ប្រើជើងទម្រដំដែក (ហៅថា "anvil" ផងដែរ) ឬជ្រុងនៃទម្រដែលហៅថាក្តារទ្រ ហើយប្រើញញួរដំតិចៗពត់ដល់មុំដែលត្រូវការ ។

**(4) ការផ្សារ**

វិធីផ្សារដែលគេប្រើច្រើនបំផុតក្នុងការផ្សារលោហៈបន្ទះគឺ "វិធីសាស្ត្រផ្សាររលាយ" ដែលផ្សារភ្ជាប់ដោយរំលាយសម្ភារផ្សារបំពេញ (ធូបផ្សារឬលួស)។

## 6.6.2 វិធីសាស្ត្រតភ្ជាប់បំពង់ផ្លូវខ្យល់

### (1) ការតភ្ជាប់បំពង់ផ្លូវខ្យល់ជ្រុង

សម្រាប់ការតភ្ជាប់បំពង់ផ្លូវខ្យល់ជ្រុង មានវិធីសាស្ត្រផ្លែងជ្រុង(Angle flange method) និងវិធីសាស្ត្រផ្លែងស៊ក (slip-on flange method) ជាដើម។

**[វិធីសាស្ត្រផ្លែងជ្រុង]**

ដោយសារភាពរឹងមាំនៃការតភ្ជាប់និងភាពបិទជិតគ្មានខ្យល់ចូលគឺល្អខ្លាំង វាត្រូវបានគេប្រើជាញឹកញាប់សម្រាប់បំពង់ផ្លូវខ្យល់បញ្ចេញផ្សែងជាដើម។

**[វិធីសាស្ត្របន្ទះផ្លែងរួម (Integral flange method)]**

ផ្នែកមួយនៃតួបំពង់ផ្លូវខ្យល់ត្រូវបត់ដើម្បីបង្កើតជាផ្លែង (បន្ទះផ្លែងរួម) ហើយត្រូវបានភ្ជាប់ជាមួយបន្ទះផ្លែងដូចគ្នា ដោយកែងទាំងបួននៃបំពង់ផ្លូវខ្យល់ត្រូវបានចាប់ភ្ជាប់ដោយឃ្នាបពិសេស។ បើប្រៀបធៀបទៅនឹងវិធីសាស្ត្រផ្លែងជ្រុង វិធីសាស្ត្រនេះច្រើនតែប្រើសម្រាប់បំពង់ផ្លូវខ្យល់ក្រៅពីបំពង់បញ្ចេញផ្សែង ព្រោះវាត្រូវការពេលតិចដើម្បីបង្កើតផ្លែងនិងងាយស្រួលដំឡើងជាង។



វិធីសាស្ត្រផ្លែងជ្រុង



វិធីសាស្ត្របន្ទះផ្លែងរួម

**[វិធីសាស្ត្រផ្លែងស៊ក]**

ផ្លែងដែលបង្កើតទុករួចជាស្រេចត្រូវបានស៊កបញ្ចូលបំពង់ផ្លូវខ្យល់ ហើយត្រូវបានផ្សារដោយចំណុច(spot welding) និងរឹតបន្តឹងដោយប៊ូឡុងនិងក្បាលឡោស៊ីនៅជ្រុងទាំងបួន ហើយសង្កត់ផ្លែងដោយគ្រឿងលោហៈពិសេសដែលហៅថាឃ្នាបភ្ជាប់។ ភាពរឹងមាំគឺខ្លាំងជាងបន្ទះផ្លែងរួម ហើយវាអាចនិយាយបានថាជាវិធីសាស្ត្រកណ្ដាលរវាងវិធីសាស្ត្របន្ទះផ្លែងរួមនិងវិធីសាស្ត្រផ្លែងជ្រុង។

**(2) ការតភ្ជាប់បំពង់ផ្លូវខ្យល់មូល**

វិធីសាស្ត្រតភ្ជាប់បំពង់ផ្លូវខ្យល់មូលដូចជាបំពង់ផ្លូវខ្យល់មានវីណ្ឌ(spiral duct) រួមមានវិធីសាស្ត្រផ្លែង និងវិធីសាស្ត្រតំណស៊ក។

**[វិធីសាស្ត្រផ្លែង]**

នេះគឺជាវិធីសាស្ត្រដែល គេស៊កបញ្ចូលសុងរបស់ផ្លែងទៅក្នុងបំពង់ផ្លូវខ្យល់មានវីណ្ឌ(spiral duct) ហើយចាប់ភ្ជាប់ផ្លែងនិងផ្លែងដោយប៊ូឡុងនិងក្បាលឡោស៊ី។ គេអាចនិយាយបានថា វិធីសាស្ត្រនេះគឺសក្តិសមសម្រាប់ការតភ្ជាប់ដែលត្រូវការភាពរឹងមាំខ្លាំង។

**[វិធីសាស្ត្រតំណស៊ក]**

ជាវិធីសាស្ត្រដែលតភ្ជាប់ដោយ ស៊កតំណពិសេសមួយហៅថា nipple (សុង) ចូលបំពង់ផ្លូវខ្យល់មានវីណ្ឌ(spiral duct) ហើយចាប់ភ្ជាប់ 2-3 ចំណុចដោយវីសបន្ទះដែក(វីសចោះ) រួចរុំពីខាងក្រៅដោយស្កុតបំពង់ផ្លូវខ្យល់ជាដើម។

## 6.7 ការងារបរិក្ខារអគ្គិសនី

វិសាលភាពការងាររបស់អ្នកបច្ចេកទេសខាងការងារបរិក្ខារអគ្គិសនីគឺទូលំទូលាយ ដោយធ្វើការងារដូចជាការរត់បំពង់ រត់ខ្សែ ដំឡើងគ្រឿងឧបករណ៍ ដំឡើងបរិក្ខារអគ្គិសនីជាដើម។ លក្ខណៈពិសេសគឺប្រដាប់និងគ្រឿងឧបករណ៍ដែលប្រើប្រាស់ក៏មានច្រើនប្រភេទដែរ។ ក្នុងការអនុវត្តការងារត្រូវប្រុងប្រយ័ត្ននឹងការឆក់ខ្សែភ្លើងនិងការលេចធ្លាយអគ្គិសនី។

### 6.7.1 ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារបរិក្ខារទទួលនិងបំប្លែងអគ្គិសនីតង់ស្យុងខ្ពស់

អគ្គិសនី 6600V ដែលទាញយកពីក្រុមហ៊ុនអគ្គិសនីជាដើម ត្រូវបានផ្គត់ផ្គង់ទៅ cubicle(បរិក្ខារប្រមូលផ្តុំម៉ាស៊ីនបំប្លែងតង់ស្យុង) ដែលដំឡើងនៅក្នុងដីឡូត៍ឬជាន់ក្រោមដីឬដំបូលរបស់អគារ ដោយឆ្លងកាត់ PAS (Pole Air Switch ឧបករណ៍បិទបើកសៀគ្វីលើអាកាសតង់ស្យុងខ្ពស់) ដែលដំឡើងនៅលើបង្គោលភ្លើង (ក្នុងករណីរត់ខ្សែលើអាកាស)។ នៅ cubicle(បរិក្ខារប្រមូលផ្តុំម៉ាស៊ីនបំប្លែងតង់ស្យុង) តង់ស្យុង 6600V ដែលទទួលបាន ត្រូវបានបំប្លែងទៅ 100V ឬ 200V ។ នៅខាងក្នុងមានឌីសង់ទ័រនិងកុងតាក់ផ្តាច់ចរន្ត ដែលអាចផ្តាច់ចរន្តអគ្គិសនីបាន។ ដើម្បីបង្ការគ្រោះថ្នាក់ការងារនៅក្នុង ការងារបរិក្ខារទទួលនិងបំប្លែងអគ្គិសនីតង់ស្យុងខ្ពស់ ជាគោលការណ៍ត្រូវចំហ PAS និងធ្វើការក្នុងស្ថានភាពដែលផ្តាច់ចរន្តដោយរួមទាំង cubicle(បរិក្ខារប្រមូលផ្តុំម៉ាស៊ីនបំប្លែងតង់ស្យុង)។ ទោះបីបើកចំហឧបករណ៍ផ្តាច់ចរន្តនិងកុងតាក់ផ្តាច់ចរន្តក៏ដោយក៏មានអគ្គិសនីចូលមកខាងអគ្គិសនីចូលនៃផ្នែកបើកចំហដែរ។ ការធ្វើការក្នុងស្ថានភាពដែលខ្សែភ្លើងកំពុងសកម្ម(មានអគ្គិសនីចូល)នៅខាងអគ្គិសនីចូល អាចកើតមានគ្រោះថ្នាក់ឆក់ខ្សែភ្លើងដោយផ្ទាល់ ឆក់ខ្សែភ្លើងដោយការបញ្ចេញអគ្គិសនី គឺគ្រោះថ្នាក់ណាស់។




### 6.7.2 សៀគ្វីខ្លី Ground Fault(ការលេចធ្លាយអគ្គិសនីទៅដី) ការលេចធ្លាយអគ្គិសនី

សៀគ្វីខ្លី (ហៅថា "ស្សូត(short)" ផងដែរ) គឺជាការដែលខ្សែភ្លើង 2 ឡើងក្នុងចំណោម 2 ផាស ឬ 3 ផាស ភ្ជាប់គ្នាដោយមិនឆ្លងកាត់បន្ទុក។ សៀគ្វីខ្លីកើតឡើងពេលកាត់ខ្សែភ្លើងដែលកំពុងសកម្ម។ ម្យ៉ាងទៀត កំហុសនៃការរត់ខ្សែ ផ្នែកលោហៈនៃឧបករណ៍ដូចជាទួណឺវីសជាដើម អាចនឹងបណ្តាលឲ្យកើតសៀគ្វីខ្លី។

Ground Fault(ការលេចធ្លាយអគ្គិសនីទៅដី) ជាការដែលចរន្តហូរទៅដី។

ការលេចធ្លាយអគ្គិសនីគឺជាការដែលចរន្តអគ្គិសនីហូរទៅសៀគ្វីដែលគួរហូរបណ្តើរហូរទៅកន្លែងដែលមិនគួរហូរបណ្តើរ។ មិនត្រឹមតែធ្វើឲ្យមនុស្សឆក់ខ្សែភ្លើងទេ វាក៏អាចបណ្តាលឲ្យមានអគ្គិភ័យជាដើមផងដែរ។

## 6.7.3 ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារគាបខ្សែភ្លើង

ការគាបខ្សែភ្លើងមិនបានល្អអាចបណ្តាលឲ្យមានគ្រោះថ្នាក់កើតឡើងដោយឡើងកម្តៅឬឆ្លុះផ្កាភ្លើង។ ត្រូវប្រើឧបករណ៍គាបដើម្បីគាបឲ្យជាប់ល្អត្រង់ទីតាំងកណ្តាលនៃសុងរបស់ក្បាលកូសគាបសំប៉ែត (Crimp terminal)។ ម្យ៉ាងទៀត ត្រូវតែប្រើក្បាលកូសគាបសំប៉ែត (Crimp terminal) ដែលត្រូវនឹងទំហំខ្សែភ្លើង។ មិនត្រឹមតែខ្សែភ្លើងទេ ក្បាលកូសគាបសំប៉ែត (Crimp terminal)ផ្ទាល់ក៏មានកម្រិតចរន្តដែលអាចទទួលយកបានដែរ ហេតុនេះសូមប្រុងប្រយ័ត្ន។

## 6.7.4 ការធ្វើឲ្យខូចឬដាច់បំពង់បង្កប់ស្រាប់ ការដាច់ខ្សែរត់លើអាកាស

### (1)ការដាច់បំពង់បង្កប់ស្រាប់នៅពេលជីកចង្អូររណ្តៅរួមខ្សែភ្លើង

ចង្អូររណ្តៅរួមខ្សែភ្លើង គឺជាបរិក្ខារសម្រាប់ដាក់ខ្សែភ្លើងពីបង្គោលភ្លើងលើដីនិងខ្សែភ្លើងលើអាកាស ចូលក្នុងក្រោមដី។ ការសាងសង់ចង្អូររណ្តៅរួមខ្សែភ្លើង ចាំបាច់ត្រូវការការសិក្សាទុកជាមុននិងការងារសាងសង់បណ្តោះអាសន្ន ពីព្រោះអាចកើតមានឧបទ្ទវហេតុដាច់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលមានស្រាប់ ដូចជាបំពង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ បំពង់ហ្គាស បំពង់បណ្តាញទូរគមនាគមន៍ និងបំពង់ខ្សែភ្លើង។ល។ ចំពោះចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារ សូមមើល 6.5.4 "ចំណុចត្រូវប្រុងប្រយ័ត្នក្នុងការងារបង្កប់បំពង់"។






### (2) ឧបទ្ទវហេតុដាច់ខ្សែភ្លើងរត់លើអាកាស



មានករណីឧបទ្ទវហេតុដែលខ្សែភ្លើងរត់លើអាកាសត្រូវបានកាត់ដាច់ដោយសារ ដងដៃនៃគ្រឿងចក្រសំណង់ ការលើកបែនរបស់រថយន្តបែន និងការលើកដាក់គ្រឿងចក្រសាងសង់ពីយានជំនិះដឹកគ្រឿងចក្រសំណង់ជាដើម។ អាចមានករណីទទួលការពឹងពាក់ពីអ្នកម៉ៅការផ្សេងទៀតស្នើសុំឱ្យដំឡើង "គម្របខ្សែកាប" ដើម្បីការពារខ្សែភ្លើងរត់លើអាកាស។

## 6.7.5 ការប្រុងប្រយ័ត្នពេលប្រើប្រាស់ផ្លូវថ្នល់

ពេលធ្វើការនៅលើដងផ្លូវ ត្រូវយកចិត្តទុកដាក់ចំពោះច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ។ ប្រការប្រុងប្រយ័ត្នទូទៅគឺមានដូចខាងក្រោមនេះ។

□ អ្នកទទួលខុសត្រូវលើការងារត្រូវមានលិខិតអនុញ្ញាតប្រើប្រាស់ផ្លូវថ្នល់។ ម្យ៉ាងវិញទៀត ត្រូវគោរពតាមលក្ខខណ្ឌអនុញ្ញាត (ម៉ោងធ្វើការ លក្ខខណ្ឌការងារ ជាដើម)។

□ ត្រូវដំឡើងបរិក្ខារសុវត្ថិភាពនៅការដ្ឋានសំណង់ និងហាមមិនឲ្យមនុស្សដែលមិនពាក់ព័ន្ធនឹងការងារសាងសង់ចូល។

□ ត្រូវចាត់តាំងបុគ្គលិកសម្រួលចរាចរណ៍ ដើម្បីកុំឲ្យប៉ះពាល់ដល់លំហូរចរាចរណ៍ ។

□ ត្រូវចាត់វិធានការដើម្បីឱ្យអ្នកថ្មើរជើងឆ្លងកាត់ដោយសុវត្ថិភាព។

□ កាត់បន្ថយផលប៉ះពាល់លើពលរដ្ឋរស់នៅក្បែរនោះឲ្យដល់កម្រិតទាបបំផុត ដូចជាសំឡេងរំខាន និងរំញ័រជាដើម។

□ នៅពេលដែលអ្នកធ្វើការងារចាកចេញពីការដ្ឋាន ត្រូវ ចាក់បំពេញមកវិញឬគ្រប ដោយមិនត្រូវទុកផ្លូវដែលបានជីករួចហើយទាំងបែបនោះទេ។ ករណីជីកទុកចោលទាំងបែបនោះ ត្រូវដំឡើងរបងការពារសុវត្ថិភាព។

□ នៅពេលដាក់វត្ថុនៅលើផ្លូវជាបណ្ដោះអាសន្ន ដើម្បីកុំឱ្យវាបែកខ្ចាត់ខ្ចាយឬផ្លាស់ទី ត្រូវចាប់ភ្ជាប់ឬដំឡើងបរិក្ខារការពារសុវត្ថិភាព។



ការងារលុបបំបាត់
បង្គោលភ្លើង

□ នៅពេលយប់ ត្រូវដាក់ភ្លើងសញ្ញាឲ្យប្រុងប្រយ័ត្នដើម្បីឲ្យអាចមើលដឹងទទឹងនិងកម្ពស់នៃទីតាំងដំឡើង។

## 6.8 ការងារទូរគមនាគមន៍

### 6.8.1 ប្រភេទនៃបរិក្ខារទូរគមនាគមន៍

បរិក្ខារទូរគមនាគមន៍អាចត្រូវបានបែងចែកទៅជាបរិក្ខារទំនាក់ទំនងមានខ្សែ បរិក្ខារទំនាក់ទំនងឥតខ្សែ បរិក្ខារសំណង់ស៊ីវិលទូរគមនាគមន៍ បរិក្ខារបែងចែក(switch)និងបញ្ជូន និងបរិក្ខារថាមពលអគ្គិសនីសម្រាប់ទូរគមនាគមន៍។ នៅទីនេះ យើងនឹងពន្យល់អំពីបរិក្ខារទំនាក់ទំនងមានខ្សែ និងបរិក្ខារសំណង់ស៊ីវិលទូរគមនាគមន៍។

(1) បរិក្ខារទំនាក់ទំនងមានខ្សែ

បណ្ដាញបញ្ជូនមានខ្សែដែលបង្កើតឡើងដើម្បីផ្តល់សេវាទូរគមនាគមន៍ត្រូវបានហៅថា "បរិក្ខារភ្ជាប់ទំនាក់ទំនង(access facilities)" ។

បរិក្ខារភ្ជាប់ទំនាក់ទំនង ត្រូវបានបែងចែកជាបរិក្ខារខាងក្រៅនិងខាងក្នុង ហើយបរិក្ខារខាងក្រៅត្រូវបានបែងចែកបន្ថែមទៀតទៅជាបរិក្ខារលើអាកាសនិងក្រោមដី។ បរិក្ខារលើអាកាស គឺសំដៅលើបរិក្ខារដែលត្រូវបានបំពាក់ទៅនឹងបង្គោលភ្លើង។ បរិក្ខារដែលត្រូវបានបំពាក់មានដូចខាងក្រោម។




**[ខ្សែកាបអុបទិក]** គឺជាខ្សែកាបដែលបញ្ជូនសញ្ញាអុបទិក។

**[ខ្សែកាបលោហៈ]** គឺជាខ្សែកាបដែលត្រូវបានប្រើក្នុងបរិក្ខារទំនាក់ទំនង។ ខ្សែកាបអុបទិកធ្វើទាក់ទងតាមរយៈសញ្ញាអុបទិក ខណៈពេលដែលខ្សែកាបលោហៈធ្វើទាក់ទងតាមរយៈសញ្ញាអគ្គិសនី។

**[ប្រអប់បិទ (Closure)]** គឺជាឧបករណ៍រាងជាប្រអប់ដែលត្រូវបានដំឡើងនៅកន្លែងតភ្ជាប់ឬចំណុចបំបែកខ្សែកាបអុបទិកឬខ្សែកាបលោហៈ។

**[ខ្សែទាញបញ្ចូល]** គឺជាខ្សែទាញបញ្ចូលសញ្ញាទំនាក់ទំនងទៅក្នុងផ្ទះ។

ចំពោះកម្ពស់ពីដីនៃបរិក្ខារលើអាកាស កម្ពស់ពីដីដែលចាំបាច់ដើម្បីធានាសុវត្ថិភាពត្រូវបានកំណត់។ នៅលើផ្លូវថ្នល់ ចាំបាច់ត្រូវធានាឲ្យបានកម្ពស់ 5m ឡើង។

**●ជំហាននៃការដាំបង្គោលភ្លើង**

បង្គោលភ្លើងត្រូវបានដាំតាមជំហានដូចខាងក្រោម។

1) ពិនិត្យទីតាំងដែលដាំបង្គោលភ្លើង។

2) ពិនិត្យវត្ថុដែលត្រូវបានបង្កប់ដោយប្រើការជីកដោយដៃ ឬដំបងរាវរក។

3) ជីកដោយការជីកដោយដៃនិងរថយន្តជីករណ្ដៅដាំបង្គោល។

4) ដាំបង្គោលភ្លើង។

5) លុបដីឡើងវិញ។

(2) បរិក្ខារសំណង់ស៊ីវិលទូរគមនាគមន៍

បរិក្ខារសំណង់ស៊ីវិលទូរគមនាគមន៍រួមមានបរិក្ខារដូចខាងក្រោម។

**[បំពង់]** គឺជាបំពង់ដែលតភ្ជាប់រវាងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ ប្រអប់តំណខ្សែកាបកប់ដីខ្នាតតូច រូងក្រោមដីសម្រាប់រត់បំពង់ខ្សែ និងបង្គោល។ ជាគោលការណ៍ វាសំដៅទៅលើបំពង់ដែលបានដំឡើងដើម្បីឲ្យមួយផ្នែកនៃខ្សែកាបអាចទាញចូលនិងទាញចេញបានដោយមិនចាំបាច់ជីក។

**[ប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole)]** រចនាសម្ព័ន្ធដែលអាចចូលនិងចេញពីលើដី ហើយវាត្រូវបានដំឡើងនៅក្រោមដីសម្រាប់ទាញចូល ទាញចេញ និងភ្ជាប់ខ្សែកាប។

**[ប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole)]** ជាប្រអប់តំណខ្សែកាបកប់ដីដែលមានទំហំតូចដែលដំឡើងនៅចំណុចបំបែកនៃបំពង់ក្រោមដី។ គេធ្វើតំហែទាំខ្សែកាបដោយមិនចាំបាច់មនុស្សចូលទៅក្នុង។

**[រូងក្រោមដីសម្រាប់រត់បំពង់ខ្សែ]** គឺជាផ្លូវរូងសម្រាប់ដាក់ខ្សែកាបផ្សេងៗសម្រាប់ទំនាក់ទំនង។

**[ចង្អូររណ្តៅរួម]** វាគឺជាវត្ថុដែលកប់នៅក្រោមដីក្នុងទម្រង់ជា "រូងក្រោមដីសម្រាប់រត់បំពង់ខ្សែ" សម្រាប់ផ្ទុកនូវបរិក្ខារ 2 ឡើងដូចជា ទូរគមនាគមន៍ អគ្គិសនី ហ្គាស ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូជាដើម។

**[C・C・BOX]** រចនាសម្ព័ន្ធរាងអក្សរ U ដែលដាក់ខ្សែកាបទំនាក់ទំនង និងខ្សែថាមពលអគ្គិសនីព្រមទាំងប្រភពអគ្គិសនីសម្រាប់ការបញ្ជូនព័ត៌មាន ការផ្សាយ ការគ្រប់គ្រងផ្លូវថ្នល់ជាដើម។

## 6.8.2 ការដំឡើងបំពង់ក្រោមដី

### (1) កម្រាស់គ្របដីនិងជម្រាលបំពង់

កម្រាស់គ្របដីនៃបំពង់សំដៅលើគម្លាតពីផ្ទៃលើនៃផ្លូវថ្នល់ទៅគែមខាងលើនៃបំពង់។ បទបញ្ញាអនុវត្តច្បាប់ស្តីពីផ្លូវថ្នល់បានចែងថាជាគោលការណ៍ នៅគន្លងរថយន្តគឺមិនត្រូវឲ្យក្រោមឬស្មើ 0.8m នៅផ្លូវថ្មើរជើងគឺមិនត្រូវឲ្យក្រោមឬស្មើ 0.6m ឡើយ។ គេកំណត់ជម្រាលដើម្បីឲ្យទឹកឬដីខ្សាច់អាចហូរក្នុងបំពង់ដោយមិនជាប់គាំង។

### (2) ចម្ងាយឃ្លាតពីវត្ថុបង្កប់ក្រោមការគ្រប់គ្រងដោយអ្នកផ្សេង

ចម្ងាយស្តង់ដារឲ្យឃ្លាតគ្នារវាងបំពង់និងបណ្តាញអគ្គិសនី ហ្គាស ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិង

ប្រព័ន្ធលូ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម។

**(3) ការធ្វើតេស្តផ្សេងៗបន្ទាប់ពីការដំឡើងបំពង់**

បន្ទាប់ពីការដំឡើងបំពង់ គេធ្វើតេស្តពីរដូចខាងក្រោមនេះ។

**[ការធ្វើតេស្តឆ្លងកាត់ដំបងដែក Mandrel]** នេះគឺជាការធ្វើតេស្តដើម្បីពិនិត្យមើលថាតើបំពង់ត្រូវបានតភ្ជាប់ទាំងស្រុងឬអត់។ គេធ្វើតេស្តដោយឲ្យដំបងដែលហៅថាMandrel ឆ្លងកាត់។

**[ការធ្វើតេស្តភាពបិទជិតខ្យល់]** គេបង្កើនសម្ពាធក្នុងបំពង់ទៅ 49kPa ហើយទុកវាចោលរយៈពេល 3 នាទី ដើម្បីពិនិត្យមើលថាតើការធ្លាក់ចុះសម្ពាធគឺមិនលើស 1.96kPa ឬទេ។

## 6.9 ការងារសាងសង់ឡ

ការសាងសង់ឡគឺជាការងារដែលសាងសង់ផ្នែកខាងក្នុងនៃឡដូចជា ឡដុត ឡដុតបន្ទន់ (Annealing) ឡដុតសព ឡរំលាយ ឡអគ្គិសនីជាដើម ដែលនឹងក្តៅខ្លាំង ដោយប្រើវត្ថុធាតុដើមធន់នឹងភ្លើង។ ឥដ្ឋដែលប្រើសម្រាប់ឡគឺជាឥដ្ឋធន់នឹងភ្លើង និងឥដ្ឋអ៊ីសូឡង់កម្តៅធន់នឹងភ្លើង។ បាយអដែលភ្ជាប់ឥដ្ឋក៏ខុសពីបាយអទូទៅដែរ គឺគេប្រើបាយអសម្រាប់ឥដ្ឋអ៊ីសូឡង់កម្តៅធន់នឹងកម្តៅ។

ការងារដំណើរការតាមលំដាប់គឺ ការធ្វើគំនូសសម្គាល់ →ការហ៊ុមព័ទ្ធបណ្តោះអាសន្ន→ ការរៀបឥដ្ឋ។ ការរៀបឥដ្ឋធន់នឹងភ្លើង (ការរៀបបង្គរឥដ្ឋ) ត្រូវការជំនាញខ្ពស់ជាងគេក្នុងចំណោមសម្ភារឡ។ ប្រការចាំបាច់ត្រូវអនុវត្តនៅពេលរៀបឥដ្ឋ មាន6ចំណុចដូចខាងក្រោម។

☐ ប្រើប្រាស់សម្ភារឱ្យបានត្រឹមត្រូវ។

☐ វាស់ទំហំឲ្យបានត្រឹមត្រូវ។

☐ ប៉ាតបាយអឱ្យបានគ្រប់គ្រាន់ដើម្បីឱ្យថ្នេររាងស្មើគ្នា។

☐ ពេលរៀបឥដ្ឋនៅជញ្ជាំងរាបស្មើ ត្រូវរៀបបន្តគ្នាកុំខាន។

☐ កុំប្រើឥដ្ឋបំបែកជាតូចៗដែលមានប្រវែងមិនលើស 1/4 ។

☐ ការរៀបឥដ្ឋ ត្រូវយកទិសផ្តេក ទិសបញ្ឈរជាគោលកុំខាន។

## 6.10 ការងារបរិក្ខារការពារអគ្គីភ័យ



មួយផ្នែកនៃបរិក្ខារបូម
ការពារអគ្គីភ័យ

បរិក្ខារការពារអគ្គីភ័យ ភាគច្រើនពេលជម្មតាគឺមិនដំណើរការ ហើយប្រើប្រាស់ក្នុងគ្រាអាសន្ន។ សម្រាប់បង្គោលទឹកអគ្គីភ័យ គេដំឡើងបរិក្ខារទឹកជំនួយ បំពង់ជំនួយសម្រាប់ការពារការកើនឡើងសីតុណ្ហភាពទឹក និងបរិក្ខារធ្វើតេស្តសមត្ថភាព។

**(1) ការដំឡើងបរិក្ខារទឹកជំនួយ**

ប្រសិនបើមិនមានទឹកនៅក្នុងតួម៉ាស៊ីនបូមឬមានខ្យល់ចូល ទោះបីជាម៉ាស៊ីនបូមដំណើរការក៏ដោយ ក៏មិនអាចបញ្ជូនទឹកបានដែរ។ គេដំឡើងបរិក្ខារទឹកជំនួយ ដើម្បីការពារបញ្ហានេះក្នុងករណីប្រភពទឹកនៅទាបជាងម៉ាស៊ីនបូម។

**(2) ការដំឡើងបំពង់ជំនួយសម្រាប់ការពារការកើនឡើងសីតុណ្ហភាពទឹក**

ប្រសិនបើដំណើរការម៉ាស៊ីនបូមនៅពេលដែលផ្នែកខាងបាញ់បញ្ចេញរបស់ម៉ាស៊ីនបូមត្រូវបានបិទ នោះម៉ាស៊ីនបូមនឹងគ្រាន់តែវិល។ ប្រសិនបើទុកចោលទាំងបែបនោះ ម៉ាស៊ីនបូមនឹងឡើងក្តៅជ្រុលហើយគាំង។ ដើម្បីបង្ការបញ្ហានេះ គេដំឡើងបំពង់ជំនួយសម្រាប់ការពារការឡើងសីតុណ្ហភាពទឹក។

**(3) ការដំឡើងបរិក្ខារធ្វើតេស្តសមត្ថភាព**

គេដំឡើងបរិក្ខារធ្វើតេស្តសមត្ថភាព ដើម្បីពិនិត្យមើលថាតើម៉ាស៊ីនបូមមានសមត្ថភាពដូចដែលបានបញ្ជាក់ដែរឬទេ។

**(4) សម្ភារដែលប្រើប្រាស់សម្រាប់ការរត់បំពង់**

ម្យ៉ាងទៀត ប្រសិនបើមិនមានទឹកនៅក្នុងបំពង់ នោះបំពង់អាចនឹងទៅជាក្តៅដោយសារតែអណ្តាតភ្លើង។ ប្រសិនប្រើប្រាស់បំពង់ដែកដែលមានស្រទាប់ស្រោបខាងក្នុង នោះសម្ភារស្រទាប់ស្រោបអាចរលាយហើយកករឹងដែលធ្វើឱ្យមិនអាចបញ្ជូនទឹកបាន ដូច្នេះមិនគួរប្រើបំពង់ដែកដែលមានស្រទាប់ស្រោបខាងក្នុងឡើយ។

# មេរៀនទី 7 សុវត្ថិភាពក្នុងការងារសំណង់

## 7.1 គ្រោះថ្នាក់ស្លាប់ក្នុងការងារសំណង់

នៅការដ្ឋានសំណង់មានគ្រោះថ្នាក់ការងារផ្សេងៗកើតឡើង។ ក្នុងចំណោមគ្រោះថ្នាក់ការងារផ្សេងៗ ដែលកើតឡើង "ការធ្លាក់/ការរអិលធ្លាក់" "គ្រោះថ្នាក់ពាក់ព័ន្ធគ្រឿងចក្រសំណង់/ម៉ាស៊ីនស្លូចជាដើម" "គ្រោះថ្នាក់បាក់រលំ/ដួលរលំ" ត្រូវបានហៅថា "គ្រោះថ្នាក់ធំទាំងបី" ក្នុងវិស័យសំណង់ ហើយក្លាប់ប្រហែល 40-70% នៃគ្រោះថ្នាក់ទាំងមូល។ ភាគច្រើននៃ "ការត្រូវបុកប៉ះ" "ការគាបជាប់/ការរមួលចូល" ក្នុងតារាងខាងក្រោមគឺជា "គ្រោះថ្នាក់ពាក់ព័ន្ធគ្រឿងចក្រសំណង់/ម៉ាស៊ីនស្លូចជាដើម"។

ក្នុងចំណោមគ្រោះថ្នាក់ធំទាំងបី គ្រោះថ្នាក់ដែលច្រើនជាពិសេសនោះគឺ "ការធ្លាក់/ការរអិលធ្លាក់" ដែលកើតឡើងពេលកំពុងធ្វើការនៅទីខ្ពស់។ ម្យ៉ាងទៀត ក្រៅពីគ្រោះថ្នាក់ធំទាំងបី គ្រោះថ្នាក់ដែលច្រើននោះគឺ "គ្រោះថ្នាក់ចរាចរណ៍" ដែលកើតឡើងពេលកំពុងធ្វើដំណើរលើផ្លូវសាធារណៈ។ ក្នុងមេរៀនទី 7 យើងនឹងពន្យល់អំពីប្រភេទនិងមូលហេតុនៃគ្រោះថ្នាក់ដែលកើតឡើងនៅការដ្ឋានសំណង់ស៊ីវិល វិធានការនិងការត្រៀមចិត្តជាដើម។

| | ធ្លាក់/រអិលធ្លាក់ | ដួល | បុកប៉ះ | ខ្ទាត/ធ្លាក់ត្រូវ | បាក់រលំ/ដួលរលំ | ត្រូវបានបុកប៉ះ | គាបជាប់/រមួលចូល | លង់ | ប៉ះវត្ថុក្តៅ/ត្រជាក់ | ប៉ះវត្ថុមានផលប៉ះពាល់ជាដើម | ឆក់ខ្សែភ្លើង | គ្រោះថ្នាក់ចរាចរណ៍ (ផ្លូវថ្នល់) | គ្រោះថ្នាក់ចរាចរណ៍ (ផ្សេងទៀត) | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការងារសំណង់ស៊ីវិល | 19 | 5 | 1 | 4 | 13 | 11 | 15 | 9 | 4 | 3 | 2 | 10 | 1 | 102 |
| ការងារសំណង់ផ្លូវរូង | 0 | 0 | 0 | 0 | 1 | 0 | 0 | 1 | 0 | 0 | 0 | 1 | 0 | 3 |
| ការងារសាងសង់ស្ពាន | 1 | 0 | 0 | 0 | 2 | 0 | 1 | 2 | 0 | 0 | 0 | 0 | 0 | 6 |
| ការងារសាងសង់ផ្លូវថ្នល់ | 3 | 0 | 1 | 1 | 2 | 1 | 2 | 0 | 1 | 0 | 0 | 5 | 0 | 17 |
| ការងារសំណង់ស៊ីវិលស្ទឹងទន្លេ | 1 | 3 | 0 | 0 | 1 | 1 | 1 | 2 | 0 | 1 | 0 | 0 | 0 | 10 |
| ការងារសំណង់ការពារសំណឹក | 2 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 4 |
| កំពង់ផែ/ឆ្នេរ | 0 | 1 | 0 | 0 | 0 | 0 | 1 | 2 | 0 | 1 | 0 | 0 | 1 | 6 |
| សំណង់ស៊ីវិលផ្សេងទៀត | 9 | 0 | 0 | 2 | 4 | 8 | 8 | 2 | 3 | 1 | 2 | 1 | 0 | 44 |
| ការងារសំណង់អគារ | 71 | 0 | 0 | 5 | 15 | 7 | 6 | 0 | 6 | 5 | 2 | 9 | 0 | 139 |
| ផ្ទះប្រើឆ្អឹងដែក/សរសៃដែក | 23 | 0 | 0 | 3 | 5 | 2 | 0 | 0 | 3 | 4 | 0 | 5 | 0 | 48 |
| សំណង់ផ្ទះឈើ | 12 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 1 | 1 | 0 | 19 |
| ការងារបរិក្ខារសំណង់ | 8 | 0 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 1 | 2 | 0 | 16 |
| ការងារសំណង់អគារផ្សេងទៀត | 28 | 0 | 0 | 2 | 7 | 4 | 6 | 0 | 3 | 1 | 0 | 1 | 0 | 56 |
| សំណង់ផ្សេងទៀត | 20 | 0 | 0 | 1 | 3 | 1 | 6 | 1 | 1 | 1 | 4 | 6 | 0 | 47 |
| ការងារទូរគមនាគមន៍ | 4 | 0 | 0 | 0 | 1 | 0 | 2 | 0 | 1 | 0 | 2 | 2 | 0 | 13 |
| ការដំឡើងម៉ាស៊ីនឧបករណ៍ | 4 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 6 |
| សំណង់ផ្សេងទៀត | 12 | 0 | 0 | 1 | 1 | 1 | 4 | 1 | 0 | 1 | 2 | 4 | 0 | 28 |
| សរុបបឋមក្នុងវិស័យសំណង់ | 110 | 5 | 1 | 10 | 31 | 19 | 27 | 10 | 11 | 9 | 8 | 25 | 1 | 288 |

តារាងទី 7-1 ស្ថានភាពកើតឡើងនៃគ្រោះថ្នាក់ការងារស្លាប់តាមប្រភេទគ្រោះថ្នាក់ចម្បងៗក្នុងវិស័យសំណង់ក្នុងឆ្នាំ 2021

(បង្កើតផ្អែកតាមគេហទំព័រសុវត្ថិភាពកន្លែងធ្វើការ របស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)

### 7.1.1 ស្ថានភាពនៃគ្រោះថ្នាក់ស្លាប់ក្នុងការងារសំណង់

**[ការធ្លាក់/រអិលធ្លាក់]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការធ្លាក់ពីកន្លែងខ្ពស់ ការធ្លាក់តាមលំហរវាងជាន់នីមួយៗពេលកំពុងសាងសង់ ឬប្រហោងជាដើមពេលកំពុងជីក។

**[ការដួល]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការដួលដោយជំពប់នឹងវត្ថុជាដើម ឬដួលដោយបាត់លំនឹង។

**[ការបុកប៉ះ]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការបុកប៉ះខ្លាំងនឹងអ្វីមួយ។

**[ការខ្ទាត/ធ្លាក់ត្រូវ]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការធ្លាក់អីវ៉ាន់ដែលកំពុងស្ទូចដោយម៉ាស៊ីនស្ទូច ឬការធ្លាក់ឧបករណ៍ឬសម្ភារពីទីខ្ពស់។

**[ការបាក់រលំ/ដួលរលំ]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការដួលរលំរន្ទាឬការដួលរលំសំណង់ពេលកំពុងរុះរើ។

**[ការត្រូវបានបុកប៉ះ]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការត្រូវបានបុកប៉ះដោយគ្រឿងចក្រធុនធ្ងន់ដែលកំពុងបរ ឬប៉ែលរបស់គ្រឿងចក្រដែលកំពុងបង្វិលជាដើម។

**[ការគាបជាប់/រមួលចូល]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការគាបជាប់ឬរមួលចូលក្នុងម៉ាស៊ីន។

**[ការប៉ះវត្ថុមានផលប៉ះពាល់]** គ្រោះថ្នាក់ការងារដែលបណ្តាលមកពីសារធាតុមានផលប៉ះពាល់ដូចជាសារធាតុគីមីជាដើម ប៉ះនឹងរាងកាយមនុស្ស។

**[ការឆក់ខ្សែភ្លើង]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីចរន្តអគ្គិសនីឆ្លងកាត់រាងកាយតាមរយៈការកាត់ខ្សែភ្លើងដែលមានចរន្តឆ្លងកាត់ ឬការប៉ះគ្រឿងឧបករណ៍ដែលកំពុងលេចធ្លាយអគ្គិសនី។ល។

**[អគ្គិភ័យ]** ជាគ្រោះថ្នាក់ការងារដែលបណ្តាលមកពីការត្រូវបានជាប់ក្នុងអគ្គិភ័យដែលកើតឡើងដោយសារមូលហេតុផ្សេងៗ។

**[គ្រោះថ្នាក់ចរាចរណ៍ (ផ្លូវថ្នល់)]** ជាគ្រោះថ្នាក់ការងារដែលកើតឡើងនៅពេលធ្វើដំណើរទៅមកការដ្ឋានសំណង់ ឬគ្រោះថ្នាក់ការងារដែលកើតឡើងពាក់ព័ន្ធនឹងរថយន្តទូទៅពេលកំពុងធ្វើការងារសំណង់នៅកន្លែងដែលជាប់នឹងផ្លូវថ្នល់។

**[ការលង់]** ជាគ្រោះថ្នាក់ការងារដែលកើតឡើងដោយធ្លាក់ចូលក្នុងទឹកនៅកន្លែងដែលមានទឹកដូច

ជាសមុទ្រ ទន្លេ និងការងារប្រព័ន្ធលូជាដើម។

### 7.1.2 ប្រភេទនៃគ្រោះថ្នាក់ស្លាប់

**(1) ការធ្លាក់**

ដើម្បីធានាបាននូវសុវត្ថិភាពពេលធ្វើការទីខ្ពស់លើប៉មដែក គេប្រើប្រាស់ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយ។

សម្រាប់ការរត់ខ្សែលើអាកាស គឺប្រើរថយន្តធ្វើការងារទីខ្ពស់ដែលអាចធានាបានបន្ទារដែលមានលំនឹង ប៉ុន្តែបើទ្រោបលើបង្កាន់ដៃ អាចនឹងបាត់លំនឹងហើយធ្លាក់។

គ្រោះថ្នាក់ស្លាប់ដោយសារការធ្លាក់ ក៏រួមទាំងគ្រោះថ្នាក់ធ្លាក់ចូលរណ្ដៅដែលបានជីកផងដែរ។ ការធ្លាក់អាចកើតឡើងដោយសារបាត់បង់លំនឹង រអិលជើងជាដើម។

**(2) គ្រោះថ្នាក់ចរាចរណ៍(ផ្លូវថ្នល់)**

គ្រោះថ្នាក់ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍គឺជាគ្រោះថ្នាក់ដែលកើតឡើងច្រើនក្នុងការងារសំណង់ទាំងមូល។ គ្រោះថ្នាក់ចរាចរណ៍ពេលកំពុងធ្វើដំណើរទៅមកការដ្ឋានសំណង់ដើម្បីធ្វើការគឺមានច្រើន ហើយក៏មានគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងនៅពេលដែលរថយន្តសំណង់ឆ្លងកាត់ផ្លូវថ្នល់ទូទៅផងដែរ។ គ្រោះថ្នាក់ដូចជាត្រូវរថយន្តផ្សេងបើកបុកពេលលើកដាក់អីវ៉ាន់នៅផ្លូវសាធារណៈ និងគ្រោះថ្នាក់ដែលរថយន្តបែនដែលផ្ទុកដីសេសសល់ហើយបើកលឿនពេកធ្វើឲ្យក្រឡាប់នៅផ្លូវកោងជាដើមកំពុងកើតមានឡើង។



ពេលធ្វើការលើផ្លូវសាធារណៈដូចជាការងារដាក់បំពង់ជាដើម គឺងាយនឹងមានគ្រោះថ្នាក់កើតឡើងដែលពាក់ព័ន្ធនឹងយានជំនិះទូទៅ។ ដើម្បីការពារកុំឱ្យយានជំនិះឆ្លងកាត់ចូលកន្លែងធ្វើការ ត្រូវត្រៀមបរិក្ខារសុវត្ថិភាពដូចជា ការហ៊ុមព័ទ្ធ របង អ្នកយាមជាដើម ហើយចាត់តាំងអ្នកធ្វើសញ្ញានាំផ្លូវ។ វាក៏សំខាន់ផងដែរដែលកម្មករមិនធ្វើការនៅខាងក្រៅបរិវេណធ្វើការងារ។

**(3) ការត្រូវបានបុកប៉ះ/ត្រូវបានគាប**



ពេលធ្វើការនៅលើផ្លូវសាធារណៈដូចជាការងារដាក់បំពង់ជាដើម ត្រូវប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដោយសារអេស្កាវ៉ាទ័រប៊ែកហូ(Backhoe)។ គឺគ្រោះថ្នាក់ដូចជាការបុកប៉ះរវាងប៉ែលដែលកំពុងបង្វិលនិងមនុស្ស មនុស្សត្រូវបានគាបចន្លោះប៉ែលនិងវត្ថុ។ ម្យ៉ាងទៀត ពេលលើកដាក់ឬទម្លាក់អេស្កាវ៉ាទ័រប៊ែកហូពីរថយន្តដឹកទំនិញជាដើម គឺងាយនឹងកើតមានគ្រោះថ្នាក់អេស្កាវ៉ាទ័រប៊ែកហូក្រឡាប់។

**(4) ការខ្ទាត/ធ្លាក់ត្រូវ**



ការខ្ទាត/ធ្លាក់ត្រូវគឺជាគ្រោះថ្នាក់ដែលកើតឡើងដោយវត្ថុហោះខ្ទាតត្រូវឬធ្លាក់ត្រូវ។ ឧទាហរណ៍ គ្រោះថ្នាក់ដូចជាប៉ះត្រូវនឹងវត្ថុដែលកំពុងដឹកជញ្ជូនដោយម៉ាស៊ីនស្ទូច ត្រូវកិនពីលើដោយអីវ៉ាន់ស្ទូចដែលបានធ្លាក់។ល។ ការថ្លក់មិនបានគ្រប់គ្រាន់ ការធ្វើចលនានៃអីវ៉ាន់ស្ទូចជាដើម គឺជាមូលហេតុនៃគ្រោះថ្នាក់នេះ។ ចំណុចសំខាន់គឺមិនត្រូវចូលក្រោមអីវ៉ាន់ស្ទូចឡើយ។

**(5) ការបាក់រលំ/ដួលរលំ**

ក្នុងការងារអគ្គិសនី មានគ្រោះថ្នាក់ដូចជាគ្រោះថ្នាក់ដោយបង្គោលភ្លើងបណ្តោះអាសន្នបាក់ដួលរលំ និងគ្រោះថ្នាក់ដោយបង្គោលភ្លើងដែលលើកដាក់រថយន្តដឹកទំនិញបានរលំធ្លាក់កិនសង្កត់ជាដើម។

**(6) ការឆក់ខ្សែភ្លើង**

ការឆក់ខ្សែភ្លើងគឺជាការឆក់ខ្លាំងដែលបណ្តាលមកពីចរន្តអគ្គិសនីឆ្លងកាត់ខ្លួនមនុស្ស។ ការឆក់ខ្សែភ្លើងក៏អាចកើតឡើងដោយសារកំហុសដូចជាការប៉ះខ្សែភ្លើងឬឧបករណ៍ដែលមានតង់ស្យុងអគ្គិសនី ការប៉ះឧបករណ៍ដែលលេចធ្លាយអគ្គិសនី ឬការធ្វើឱ្យសៀគ្វីអគ្គិសនីទៅជាសៀគ្វីខ្លីជាដើម។ ដើម្បីការពារការឆក់ខ្សែភ្លើង ត្រូវធ្វើដូចខាងក្រោម។

☐ ធ្វើការងារដោយពាក់ឧបករណ៍ការពារដូចជា ឧបករណ៍ការពារទប់ស្កាត់ស្តាទិច(antistatic)

ស្រោមដៃកៅស៊ូសម្រាប់អគ្គិសនី សម្លៀកបំពាក់អ៊ីសូឡង់ ស្បែកជើងកៅស៊ូសម្រាប់អគ្គិសនី។ល។

□ ត្រូវផ្តល់ដំណឹងដល់អ្នកដែលមិនពាក់ព័ន្ធនឹងការងារ និងចាត់វិធានការហាមឃាត់ការចូលទីតាំងធ្វើការ។

□ ត្រូវប្រាកដថាការងារត្រូវធ្វើនៅក្នុងស្ថានភាពផ្តាច់ចរន្ត។

□ ក៏មានគ្រោះថ្នាក់ឆក់ខ្សែភ្លើងដោយសារស្មានថាបានផ្តាច់ចរន្តផងដែរ។ ត្រូវពិនិត្យបញ្ជាក់ឲ្យសព្វគ្រប់ថាបានផ្តាច់ចរន្តដោយធ្វើតេស្តពិនិត្យថាមានចរន្តអគ្គិសនីឬទេ។

**(7) កង្វះអុកស៊ីសែននៅក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole)**

ពេលធ្វើការងារក្នុងប្រអប់តំណខ្សែកាបកប់ដីខ្នាតធំ(manhole) អាចកើតមានគ្រោះថ្នាក់ស្លាប់ដោយអាការខ្វះអុកស៊ីសែនដោយសារកង្វះអុកស៊ីសែនឬពុលអ៊ីដ្រូសែនស៊ុលផួ។ ក្នុងស្ថានភាពខ្វះអុកស៊ីសែន ក៏អាចកើតមានគ្រោះថ្នាក់ស្លាប់ចំពោះអ្នកដែលចូលទៅជួយសង្គ្រោះដោយមិនបានប្រើឧបករណ៍ផ្តល់អុកស៊ីសែនដកដង្ហើមផងដែរ។

## 7.1.3 លក្ខណៈពិសេសនៃការងារហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន(lifeline)/បរិក្ខារដែលសំបូរករណីគ្រោះថ្នាក់ស្លាប់

**(1) លក្ខណៈពិសេសនៃការងារបរិក្ខារអគ្គិសនីនិងគ្រោះថ្នាក់**

ការងារបរិក្ខារអគ្គិសនីពាក់ព័ន្ធនឹងអគ្គិសនី ដូច្នេះអាចកើតមានគ្រោះថ្នាក់ស្លាប់ដែលហៅថា "ស្លាប់ដោយឆក់ខ្សែភ្លើង"។ ដោយសារមានការងារនៅទីខ្ពស់ដូចជាការងារប្តូរខ្សែតង់ស្យុងខ្ពស់ ការរត់ខ្សែលើអាកាសជាដើម ដូច្នេះក៏មានហានិភ័យនៃគ្រោះថ្នាក់ធ្លាក់ផងដែរ។

គ្រោះថ្នាក់ឆក់ខ្សែភ្លើងអាចកើតឡើងពេលកាត់ខ្សែភ្លើងដែលកំពុងភ្ជាប់បណ្តាញ។ វាជាគ្រោះថ្នាក់ដែលកើតឡើងដោយសារការមិនបានពិនិត្យបញ្ជាក់ថាបានផ្តាច់ចរន្តអគ្គិសនី ការមិនបានប្រើប្រាស់ឧបករណ៍ការពារដើម្បីការពារការឆក់ខ្សែភ្លើង។ល។

គ្រោះថ្នាក់ធ្លាក់កើតឡើងពេលការងារនៅទីខ្ពស់ដូចជាការងារដំឡើងខ្សែកាបនៅលើបង្គោលភ្លើងជាដើម។ ត្រូវធ្វើការងារដោយជានាទ្យបានបន្ទារដែលមានលំនឹងដូចជារថយន្តធ្វើការងារទីខ្ពស់ជាដើមតាមដែលអាចធ្វើបាន។


ការធ្វើការលើរថយន្តធ្វើការងារទីខ្ពស់

**(2) ការងារដំឡើងម៉ាស៊ីន**

ករណីដំឡើងម៉ាស៊ីនខ្នាតធំ អាចកើតមានគ្រោះថ្នាក់ត្រូវកិនសង្កត់ដោយសារម៉ាស៊ីនដួលរលំ។

**(3) ការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ**

ក្នុងការងារប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធលូ គេអនុវត្តការងារជីកចង្អូរលើផ្ទៃដីដើម្បីឲ្យបំពង់ឆ្លងកាត់។ មានគ្រោះថ្នាក់មួយចំនួនអាចកើតឡើងពាក់ព័ន្ធនឹងការងារជីកនេះ។ ឧទាហរណ៍ មានគ្រោះថ្នាក់ដោយដីខ្សាច់ដែលបានជីកបានរលំបាក់កប់មនុស្សទាំងរស់ពេលកំពុងចូលក្នុងរណ្តៅដែលបានជីក។ ក្នុងករណីជម្រៅជីកគឺ 1.5m ឡើងទៅ ជាគោលការណ៍ត្រូវធ្វើការទប់ដីដោយបន្ទះបាំងទប់ធ្វើពីដែកជាដើម។ លើសពីនេះ ក៏មានគ្រោះថ្នាក់រអិលដួលដោយសារ "ជំពប់" នឹងកន្លែងគន្លាក់នៅកម្រាលផ្លូវថ្នល់ ការលិចស្រុតជុំវិញបន្ទះក្រាលធ្វើផ្លូវបណ្តោះអាសន្ន ខ្សែកាប ទុយោជាដើម។

ក្នុងការងារជីក ត្រូវប្រើអេស្កាវ៉ាទ័របែ៊កហូ(backhoe) ដូច្នេះក៏ងាយកើតមានគ្រោះថ្នាក់ពាក់ព័ន្ធនឹងអេស្កាវ៉ាទ័របែ៊កហូផងដែរ។ ឧទាហរណ៍ គ្រោះថ្នាក់ដូចជាគ្រោះថ្នាក់ប៉ះត្រូវដោយសារដងបង្វិលនិងត្រូវបានបុកពេលបើកបរថយក្រោយជាដើម។ ត្រូវចាត់តាំងអ្នកធ្វើសញ្ញានាំផ្លូវប្រចាំការធ្វើការទាក់ទងជាមួយអ្នកបញ្ជាអេស្កាវ៉ាទ័របែ៊កហូដើម្បីធានាសុវត្ថិភាពមនុស្សដែលចូលធ្វើការងារក្នុងចង្អូររណ្តៅ។ អេស្កាវ៉ាទ័របែ៊កហូផ្ទាល់ក៏មានហានិភ័យបង្កគ្រោះថ្នាក់ក្រឡាប់ឬធ្លាក់ចូលចង្អូររណ្តៅផងដែរ។


ការងារប្រអប់តំណប្រព័ន្ធលូកប់ដីខ្នាតធំ (manhole)

## 7.2 សកម្មភាពដើម្បីសុវត្ថិភាពនៅការដ្ឋានសំណង់

### 7.2.1 វដ្តនៃការអនុវត្តការងារដោយសុវត្ថិភាព

ការបង្កើតឲ្យមានវដ្តនៃការអនុវត្តការងារដោយសុវត្ថិភាព អាចធ្វើឲ្យការដ្ឋានក្លាយជាកន្លែងដែលមិនងាយកើតមានគ្រោះថ្នាក់ការងារបាន។ វដ្តនៃការអនុវត្តការងារដោយសុវត្ថិភាពជាការសម្រេចឲ្យបានបំណងដូចខាងក្រោម។

ក. សំដៅរួមបញ្ចូលគ្នានូវការអនុវត្តការងារនិងសុវត្ថិភាព។

ខ. ធ្វើឲ្យមានភាពរលូននូវទំនាក់ទំនងសហការរវាងអ្នកម៉ៅការផ្ទាល់និងអ្នកម៉ៅការពាក់ព័ន្ធផ្សេងទៀត។

គ. បណ្តុះជាទម្លាប់នូវសកម្មភាពដើម្បីសុវត្ថិភាពនិងអនាម័យ។

ឃ. ច្នៃប្រឌិតក្នុងការចាត់វិធានការសុវត្ថិភាពទុកជាមុន។

ង. ជូនដំណឹងដល់គ្រប់គ្នាអំពីការងារសំណង់និងប្រការចាំបាច់ដើម្បីសុវត្ថិភាព។

គេដាក់បញ្ចូលសកម្មភាពដើម្បីសុវត្ថិភាពផ្សេងៗនៅក្នុងការងារប្រចាំថ្ងៃនៃការដ្ឋានសំណង់។ ដើម្បីបង្ការគ្រោះថ្នាក់ការងារ វាសំខាន់ដែលត្រូវកំណត់ហើយបន្តវដ្តនៃការអនុវត្តការងារដោយសុវត្ថិភាពជាប្រចាំថ្ងៃ។



(1) ការប្រជុំពេលព្រឹកដើម្បីសុវត្ថិភាពមុនពេលធ្វើការ

អ្នកម៉ៅការផ្ទាល់និងអ្នកម៉ៅការពាក់ព័ន្ធចូលរួមគ្រប់គ្នា ដែលរួមបញ្ចូលការធ្វើបទបង្ហាញអំពីលទ្ធផលជាដើមនៃការល្បាតដើម្បីសុវត្ថិភាពនៅថ្ងៃមុនដោយប្រធានទីតាំងការងារជាដើម ការណែនាំពីសុវត្ថិភាពការងារក្នុងថ្ងៃនោះ ការហាត់ប្រាណតាមវិទ្យុ។

(2) ការប្រជុំដើម្បីសុវត្ថិភាព

ពិភាក្សាគ្នាដែលដឹកនាំដោយមេការតាមប្រភេទការងារនីមួយៗ។ ពិនិត្យវាយតម្លៃលទ្ធផលនៃដំណាក់កាលការងារក្នុងថ្ងៃមុន ធ្វើសកម្មភាពព្យាករណ៍គ្រោះថ្នាក់ (KY) ដែលពាក់ព័ន្ធនឹងដំណាក់កាលការងារក្នុងថ្ងៃនេះ បណ្តុះបណ្តាលអ្នកចំណូលថ្មី។

(3) ការត្រួតពិនិត្យមុនចាប់ផ្តើមធ្វើការ

ត្រួតពិនិត្យសុវត្ថិភាពដូចជាត្រួតពិនិត្យម៉ាស៊ីននិងឧបករណ៍ជាដើមដែលប្រើប្រាស់ បញ្ជាក់ការងារជាដើម មុនចាប់ផ្តើមការងារ។

(4) ការណែនាំ/មើលការខុសត្រូវកំលុងពេលធ្វើការ

ណែនាំមើលការខុសត្រូវទៅកាន់កម្មករដោយអ្នកគ្រប់គ្រងការដ្ឋាន(មេការ/ប្រធានក្រុមការងារជាដើម)។

(5) ការល្បាតដើម្បីសុវត្ថិភាព

ធ្វើការល្បាតដើម្បីសុវត្ថិភាពដោយប្រធានទីតាំងការងារជាដើមនិងអ្នកម៉ៅការដែលសហការ ហើយណែនាំ/ដឹកនាំបង្ហាញទៅកាន់មេការជាដើមនីមួយៗ។

(6) ការប្រជុំពីដំណាក់កាលសុវត្ថិភាព

ទំនាក់ទំនងនិងសម្របសម្រួលរវាងផ្នែកនីមួយៗនៅថ្ងៃបន្ទាប់ និងពិចារណាលើវិធីសាស្ត្រធ្វើការងារជាដើម ដោយអ្នកម៉ៅការផ្ទាល់និងអ្នកម៉ៅការឯកទេស។

(7) ការរៀបចំទុកដាក់ក្រោយបញ្ចប់ការងារនៅកន្លែងរបស់ខ្លួន

អនុវត្តការសម្រិតសម្រាំង សណ្តាប់ធ្នាប់ ការសម្អាត និងស្តង់ដារជាដើម ចំពោះកន្លែងរបស់ខ្លួនដោយអ្នកពាក់ព័ន្ធគ្រប់រូប។

(8) ការបញ្ជាក់សុវត្ថិភាពពេលចប់ការងារ

ពិនិត្យវិធានការទប់ស្កាត់អគ្គីភ័យ ចោរលួច គ្រោះមហន្តរាយសាធារណៈជាដើម ដោយអ្នកទទួល

ខុសត្រូវរបស់អ្នកម៉ៅការផ្ទាល់និងអ្នកម៉ៅការឯកទេស។

### 7.2.2 ការអប់រំសុវត្ថិភាពអនាម័យសម្រាប់បុគ្គលិកចូលថ្មី

ការអប់រំសុវត្ថិភាពអនាម័យសម្រាប់បុគ្គលិកចូលថ្មី ជាការអប់រំសុវត្ថិភាពដែលនិយោជកអនុវត្ត ពេលទទួលនិយោជិតចូលធ្វើការថ្មី។

[1] ចំណុចពាក់ព័ន្ធនឹងភាពគ្រោះថ្នាក់និងភាពមានផលប៉ះពាល់របស់គ្រឿងម៉ាស៊ីនជាដើម វត្ថុធាតុដើមជាដើម ព្រមទាំងវិធីសាស្ត្រចាត់ចែងវា។

[2] ចំណុចពាក់ព័ន្ធនឹងសមត្ថភាពរបស់ឧបករណ៍សុវត្ថិភាព ឧបករណ៍គ្រប់គ្រងសារធាតុមានផលប៉ះពាល់ និងឧបករណ៍ការពារ ព្រមទាំងវិធីសាស្ត្រចាត់ចែងវា។

[3] ចំណុចពាក់ព័ន្ធនឹងជំហានអនុវត្តការងារ។

[4] ចំណុចពាក់ព័ន្ធនឹងការត្រួតពិនិត្យនៅពេលចាប់ផ្តើមការងារ។

[5] ចំណុចពាក់ព័ន្ធនឹងមូលហេតុព្រមទាំងការបង្ការនៃជំងឺដែលមានហានិភ័យអាចកើតមានពាក់ព័ន្ធនឹងការងារនោះ។

[6] ចំណុចពាក់ព័ន្ធនឹងការសម្រិតសម្រាំង សណ្តាប់ធ្នាប់ និងការរក្សាស្អាតដងារ។

[7] ចំណុចពាក់ព័ន្ធនឹងវិធានការអាសន្ននិងការជម្លៀសក្នុងពេលមានគ្រោះថ្នាក់ជាដើម។

[8] ក្រៅពីអ្វីដែលលើកឡើងក្នុងចំណុចនីមួយៗខាងលើ ប្រការចាំបាច់ដើម្បីសុវត្ថិភាពឬអនាម័យពាក់ព័ន្ធនឹងការងារនោះ។

### 7.2.3 **ការអប់រំសម្រាប់អ្នកចំណូលថ្មី**

កម្មករដែលទើបចូលការដ្ឋានសំណង់ថ្មីហៅថា "អ្នកចំណូលថ្មី"។ គ្រោះថ្នាក់ស្លាប់នៅការដ្ឋានសំណង់ស្ទើរពាក់កណ្តាលគឺកើតឡើងក្នុងរង្វង់ 1 សប្តាហ៍ក្រោយពីចូលការដ្ឋានថ្មី។ អាស្រ័យហេតុនេះ ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពបានកំណត់ជាកាតព្វកិច្ចនូវ "ការអប់រំសម្រាប់អ្នកចំណូលថ្មី"។

【ការអនុវត្តការអប់រំសម្រាប់អ្នកចំណូលថ្មី】

អ្នកម៉ៅការពាក់ព័ន្ធ ក្នុងករណីដែលនិយោជិតរបស់ខ្លួនចូលបម្រើការងារថ្មីនៅការដ្ឋានសំណង់ ត្រូវឲ្យមេការជាដើមជូនដំណឹងដល់និយោជិតនោះអំពីប្រការខាងក្រោមដោយគិតគូរអំពីលក្ខណៈពិសេសរបស់ការដ្ឋានសំណង់នោះ នៅមុនពេលបម្រើការងារនោះ ហើយទន្ទឹមគ្នានេះរាយការណ៍លទ្ធផលនោះដល់អ្នកម៉ៅការផ្ទាល់។

[1] ស្ថានភាពទីកន្លែងដែលនិយោជិតរបស់អ្នកម៉ៅការផ្ទាល់និងអ្នកម៉ៅការពាក់ព័ន្ធ ធ្វើការងារជាមួយគ្នា

[2] ស្ថានភាពទីតាំងដែលមានគ្រោះថ្នាក់ចំពោះនិយោជិត (ទីតាំងមានគ្រោះថ្នាក់និងមានផលប៉ះពាល់ និងតំបន់ហាមឃាត់ការចូល)

[3] ការទាក់ទងនិងទំនាក់ទំនងសម្របសម្រួលទៅវិញទៅមកដែលធ្វើឡើងនៅកន្លែងធ្វើការជាមួយគ្នា

[4] វិធីសាស្ត្រជម្លៀសពេលកើតមានគ្រោះមហន្តរាយ

[5] រចនាសម្ព័ន្ធនៃការដឹកនាំដាក់បញ្ជា

[6] ខ្លឹមសារការងារដែលទទួលខុសត្រូវ និងវិធានការបង្ការគ្រោះថ្នាក់ការងារ

[7] បទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាពអនាម័យ

[8] ផែនការដែលកំណត់ទិសដៅមូលដ្ឋាននិងគោលដៅនៃការគ្រប់គ្រងសុវត្ថិភាពអនាម័យនៅការដ្ឋានសំណង់ និងវិធានការបង្ការគ្រោះថ្នាក់ការងារជាមូលដ្ឋានផ្សេងទៀត

ខ្លឹមសារខាងលើត្រូវបានអនុវត្តដូចខាងក្រោម។

(1) មុនពេលធ្វើការនៅថ្ងៃដែលអ្នកម៉ៅការចូលការដ្ឋានចាប់ផ្តើមការងារលើកដំបូង

អ្នកទទួលបន្ទុកពីខាងអ្នកម៉ៅការផ្ទាល់(អ្នកសាងសង់) មេការ និងអ្នកទទួលខុសត្រូវសុវត្ថិភាពអនាម័យ ធ្វើការអនុវត្តការអប់រំ។

(2) មុនពេលធ្វើការនៅថ្ងៃដែលអ្នកពាក់ព័ន្ធការងារត្រូវបានបន្ថែមចូលថ្មីនៅខាងអ្នកម៉ៅការ

មេការ និងអ្នកទទួលខុសត្រូវសុវត្ថិភាពអនាម័យ ធ្វើការអនុវត្តការអប់រំ។

ការអនុវត្តត្រូវធ្វើឡើងរយៈពេលប្រហែល 30 នាទីនៅបន្ទប់ប្រជុំឬបន្ទប់ជួបពិភាក្សាជាដើមនៃទីស្នាក់ការការដ្ឋាន។

### 7.2.4 គ្រឿងបំពាក់ដើម្បីធ្វើការងារដោយសុវត្ថិភាព

រូបថតខាងក្រោមបង្ហាញពីគ្រឿងបំពាក់ដើម្បីធ្វើការងារដោយសុវត្ថិភាព។ ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយ (1) មួកសុវត្ថិភាព (2) តម្ពក់ (3) ស្បែកជើងសុវត្ថិភាព (4) គឺជាគ្រឿងបំពាក់ជាមូលដ្ឋាន។






[ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយ] ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយ គឺជាឧបករណ៍សម្រាប់ការពារការធ្លាក់។ ចាប់ពីថ្ងៃទី 2 ខែមករា ឆ្នាំ 2022 ការពាក់វាត្រូវបានតម្រូវជាកាតព្វកិច្ចក្នុងករណីដែលកម្ពស់បន្ទារលើសពី 6.75m។ យ៉ាងណាមិញ ចំពោះវិស័យសំណង់ដែលសំបូរគ្រោះថ្នាក់ធ្លាក់ ទោះបីជាការងារនៅកម្ពស់លើស 5m ក៏ដោយ ក៏ត្រូវបានទាមទារឲ្យប្រើប្រាស់ឧបករណ៍ការពារការធ្លាក់ប្រភេទខ្សែក្រវាត់ពេញរាងកាយដែរ។




[វ៉ែនតាការពារ] ជាវ៉ែនតាការពារភ្នែកកម្ទេចលោហៈឬឈើ ផ្កាភ្លើង កម្ដៅ ផ្សែង (រួមទាំងឧស្ម័នពុល) កាំរស្មីមានផលប៉ះពាល់ដូចជាឡាស៊ែរជាដើម ដែលកើតមាននៅការដ្ឋានសំណង់ឬនៅកន្លែងកែច្នៃវត្ថុធាតុដើម។

[ម៉ាសការពារ] ជាម៉ាសសម្រាប់ការពារកម្ទេចកម្ទីដូចជាធូលីជាដើម។ មានប្រភេទប្រើហើយចោល និងប្រភេទប្ដូរតម្រង។

[ស្រោមដៃ] ពេលអនុវត្តការងារកែច្នៃដោយកាត់ឬការងារលាបបាញ់ថ្នាំ ការងារដំឡើងនានា ការងារចាត់ចែងសារធាតុគីមីជាដើម ត្រូវប្រើស្រោមដៃដើម្បីការពារ។ យ៉ាងណាមិញ មិនត្រូវប្រើប្រាស់ស្រោមដៃ(ស្រោមដៃការងារ) ឡើយពេលប្រើប្រាស់ "ផ្លែមុតដែលវិលដូចជា ម៉ូទ័រកាត់ ម៉ាស៊ីនចោះ ម៉ាស៊ីនខាត់គែម ម៉ាស៊ីនកាត់ធ្មេញវីសបំពង់ជាដើម" ដោយសារអាចបង្កគ្រោះថ្នាក់ដោយស្រោមដៃទាក់ចូលផ្លែមុតដែលវិល។

[មួកការពារមានរបាំងមុខ] ជាមួកការពារដែលមានភ្ជាប់របាំងមុខដើម្បីការពារមុខទាំងមូល។ វាត្រូវបានប្រើជាចម្បងសម្រាប់ការងារផ្សារ។

### 7.2.5 វិធានការការពារជំងឺស្ត្រូកកម្ដៅ

នៅរដូវក្ដៅក្នុងប្រទេសជប៉ុនសំបូរ "ថ្ងៃក្ដៅ" ដែលសីតុណ្ហភាពលើសពី 30 ºC និង "ថ្ងៃក្ដៅខ្លាំង" ដែលសីតុណ្ហភាពលើសពី 35 ºC ។ ការធ្វើការនៅកន្លែងក្ដៅនឹងបង្កឲ្យកើតជំងឺស្ត្រូកកម្ដៅ។ បើកើតជំងឺស្ត្រូកកម្ដៅនោះអាចបណ្ដាលឲ្យ វិលមុខ/សន្លប់ ឈឺសាច់ដុំ/រឹងសាច់ដុំ បែកញើសច្រើន ឈឺក្បាល/មិនស្រួលខ្លួន/ចង់ក្អួត/ក្អួត/ល្វិតល្វៃ/អារម្មណ៍គ្មានកម្លាំងកំហែង ស្រវាំងស្មារតី/ប្រកាច់/វិបល្លាសចលនាដៃជើង រាងកាយឡើងកម្ដៅខ្លាំងជាដើម ដែលធ្វើឲ្យមិនត្រឹមតែមិនអាចបន្តការងារបានទេ ថែមទាំងអាចឈានដល់ស្លាប់ទៀតផង។ ដើម្បីធ្វើឲ្យតម្លៃ WBGT ធ្លាក់ចុះ អ្នកគ្រប់គ្រងធ្វើការបំពាក់កង្ហារខ្នាតធំ សំណាញ់បាំងថ្ងៃ ប្រព័ន្ធបាញ់ចំហាយទឹក កន្លែងសម្រាក បរិក្ខារម៉ាស៊ីនត្រជាក់ បរិក្ខារផ្គត់ផ្គង់ទឹក ទូទឹកកក/ម៉ាស៊ីនធ្វើទឹកកក ម៉ាស៊ីនលក់ទឹកស្វ័យប្រវត្តិជាដើម។ នៅថ្ងៃក្ដៅខ្លាំង ក៏មានករណីរំកិលម៉ោងចូលនិងម៉ោងចេញពីធ្វើការឲ្យមកឆាប់ផងដែរ។ កម្មករគួរយកចិត្តទុកដាក់សម្រាកនៅកន្លែងត្រជាក់ដូចជាកន្លែងសម្រាកដែលមានម៉ាស៊ីនត្រជាក់ជាដើមនៅម៉ោងសម្រាកដែលបានកំណត់ ហើយទទួលទានទឹកនិងជាតិអំបិលមុននិងក្រោយធ្វើការងារ។ ម្យ៉ាងទៀត

គួរពាក់សម្លៀកបំពាក់ការងារដែលមិនហប់ អាវកាក់សុវត្ថិភាពដែលងាយស្រួបកម្ដៅជាដើម។

### 7.2.6 ស្លាកសញ្ញាឲ្យយកចិត្តទុកដាក់នឹងការធ្វើការដោយសុវត្ថិភាព

នៅកន្លែងផ្សេងៗក្នុងការដ្ឋានសំណង់ គេឃើញមានស្លាកសញ្ញារាងជាសញ្ញាបូកពណ៌បៃតងដោយមានផ្ទៃខាងក្រោយពណ៌ស។ ស្លាកសញ្ញានេះហៅថា "សញ្ញាបូកបៃតង" ហើយជានិមិត្តសញ្ញានៃសុវត្ថិភាព និងអនាម័យ។ នៅការដ្ឋានសំណង់ ជាដំបូងសុវត្ថិភាពគឺជារឿងសំខាន់បំផុត ដូច្នេះជាញឹកញាប់វាត្រូវបានរចនារួមគ្នាជាមួយពាក្យថា "សុវត្ថិភាពជាចម្បង" ។ មួកសុវត្ថិភាព និង "ប្រអប់សង្គ្រោះបឋម" ដែលមានដាក់ថ្នាំនិងឧបករណ៍សម្រាប់សង្គ្រោះបឋមពេលមានរបួស ក៏ត្រូវបានដាក់ស្លាកសញ្ញាបូកបៃតងនេះផងដែរ។ ក៏មានការដាក់ទង់សុវត្ថិភាពអនាម័យដែលរួមបញ្ចូល "សញ្ញាបូកពណ៌ស" ដែលតំណាងឲ្យអនាម័យផងដែរ។



ឧទាហរណ៍នៃសញ្ញាបូកបៃតង



ឧទាហរណ៍នៃទង់សុវត្ថិភាពអនាម័យ

### 7.2.7 ការយល់ដឹងអំពីកំហុសមនុស្ស

កំហុសដែលបង្កឡើងដោយមនុស្សត្រូវបានហៅថា "កំហុសមនុស្ស" ។ កំហុសមនុស្ស គឺជាកំហុសដែលកើតឡើងដោយសារតែយើងជាមនុស្ស។ វារួមបញ្ចូលមិនត្រឹមតែកំហុសដែលបណ្ដាលមកពីការធ្វេសប្រហែសប៉ុណ្ណោះទេ គឺទាំងកំហុសដែលបណ្ដាលមកពី "ការធ្វើរំលង" ដែលមិនបានធ្វើការងារដែលគប្បីធ្វើផងដែរ។ ដើម្បីកុំឲ្យចូលពាក់ព័ន្ធឬបង្កគ្រោះថ្នាក់នៅការដ្ឋានសំណង់ វាសំខាន់ដែលត្រូវធ្វើការងារដោយយកចិត្តទុកដាក់នឹងកំហុសមនុស្ស។ ម្យ៉ាងទៀត កំហុសមនុស្សមិនត្រឹមតែបង្កគ្រោះថ្នាក់ចំពោះមនុស្សប៉ុណ្ណោះទេ វាថែមទាំងប៉ះពាល់ដល់គុណភាពសំណង់ដែលបានសង់រួច និងធ្វើឲ្យយឺតយ៉ាវដល់ដំណាក់កាលការងារផងដែរ។ គេនិយាយថាមូលហេតុដែលកើតមានកំហុសមនុស្ស

មាន 12 ប្រភេទ។

**(1)** កំហុសក្នុងការយល់ដឹង

វាជាកំហុសមនុស្សដែលកើតឡើងដោយសារការសន្មត។ ឧទាហរណ៍ ការសន្មតថា "ក្នុងស្ថានភាពបែបនេះ ច្បាស់ជាមានការណែនាំបែបនេះ" អាចនាំឱ្យមានការយល់ខុសចំពោះការណែនាំឬការផ្តល់សញ្ញារបស់ដៃគូ។

**(2)** ការធ្វេសប្រហែស

ជាកំហុសមនុស្សដែលបណ្តាលមកពីការខ្វះការយកចិត្តទុកដាក់។ បើផ្តោតទៅលើកិច្ចការមួយជាពិសេស វាអាចធ្វើឲ្យធ្លាក់ចុះសមត្ថភាពប្រុងប្រយ័ត្ននឹងអ្វីដែលនៅជុំវិញខ្លួនហើយនាំឲ្យមានគ្រោះថ្នាក់។ ឧទាហរណ៍ មានករណីដែលកំពុងផ្តោតអារម្មណ៍លើការងារនៅខាងមុខ ហើយបានធ្លាក់ចូលរណ្តៅនៅពីក្រោយដោយសារមិនបានចាប់អារម្មណ៍។

**(3)** ការថយចុះការប្រុងប្រយ័ត្ននិងការចេះចាប់អារម្មណ៍

ការថយចុះការប្រុងប្រយ័ត្ននិងការចេះចាប់អារម្មណ៍ កើតឡើងជាពិសេសពេលធ្វើការងារសាមញ្ញាដដែលៗ។ ពេលធ្វើការងារសាមញ្ញដដែលៗ នោះនឹងឈប់គិតអំពីការងារនោះ ហើយធ្វើវាដោយមិនចាប់អារម្មណ៍។

**(4)** ខ្វះបទពិសោធន៍/ខ្វះចំណេះដឹង

ជាកំហុសមនុស្សដែលបណ្តាលមកពីការខ្វះបទពិសោធន៍ ការមិនយល់ដឹង។ ការមិនចេះប្រើឧបករណ៍បានសមស្រប ការមិនយល់ដឹងត្រឹមត្រូវអំពីដំណាក់កាលការងារ ការមិនអាចព្យាករគ្រោះថ្នាក់ដែលអាចមានក្នុងការងារទាំងនោះជាដើម គឺជាមូលហេតុ។ សកម្មភាព KY មុនចាប់ផ្តើមការងារ គឺជាឱកាសអាចឲ្យអ្នកជំនាញជើងចាស់ចែករំលែកបទពិសោធន៍ពីការព្យាករគ្រោះថ្នាក់ដែលអាចកើតមាន។ ទោះបីជាការងារលើកដំបូងក៏ដោយ ក៏អាចដឹងពីចំណុចសំខាន់ដែលគប្បីយកចិត្តទុកដាក់ផងដែរ។

**(5)** ការធ្វើរំលងដោយសារការសុំ

មនុស្សមានទំនោរជឿជាក់ខ្លួនឯងដោយសារសុំ ហើយជាលទ្ធផលគឺមានទំនោរធ្វើដោយរំលងអ្វីដែលធ្លាប់ប្រុងប្រយ័ត្នកាលខ្លួនទើបចាប់ផ្តើមធ្វើដំបូងឬរំលងជំហានដែលគប្បីធ្វើ។ គ្រោះថ្នាក់ងាយកើតឡើងនៅពេលដែលសុំហើយធូររលុង។

**(6)** កំហុសជាក្រុម

វាជាកំហុសមនុស្សដែលកើតឡើងជាក្រុម។ ឧទាហរណ៍ ក្នុងករណីទំនងជាមិនទាន់រយៈពេលសាងសង់ បរិយាកាសទាំងមូលងាយនឹងទៅជា "បង្ខំចិត្តគ្មានជម្រើសហើយធ្វើសកម្មភាពដែលគ្មានសុវត្ថិភាព"។

**(7)** សកម្មភាពផ្លូវកាត់/សកម្មភាពធ្វើដោយសង្ខេប

ជាកំហុសមនុស្សដែលកើតឡើងដោយការសង្ខេបចោលសកម្មភាពដែលដើមឡើងគប្បីធ្វើដោយសារចង់ធ្វើការប្រកបដោយប្រសិទ្ធផល។

**(8)** កង្វះការទំនាក់ទំនង

ជាកំហុសមនុស្សដែលកើតឡើងដោយសារខ្លឹមសារណែនាំមិនត្រូវបានប្រាប់បានច្បាស់លាស់។ ការធ្វើការងារទាំងមិនយល់ពីខ្លឹមសារណែនាំ អាចបង្កគ្រោះថ្នាក់ឬយឺតយ៉ាវដល់ការងារសាងសង់ជាដើម។

**(9)** សកម្មភាពបែបសភាវគតិតាមស្ថានភាព

ជាសកម្មភាពដែលធ្វើដោយមិនបានគិតពេលស្ថិតក្នុងស្ថានភាពមួយ។ ជាពិសេសពេលផ្តោតអារម្មណ៍លើចំណុចមួយ គឺអាចនឹងមើលមិនឃើញពីអ្វីនៅជុំវិញ។ ឧទាហរណ៍ សកម្មភាពដូចជាពេលនៅលើជណ្តើរជ្រែងហើយរៀបនឹងដួល មនុស្សម្នាក់អាចនឹងព្រលែងចោលឧបករណ៍ដើម្បីការពារសុវត្ថិភាពរបស់ខ្លួន។ល។ ឧបករណ៍ដែលព្រលែងចោលនោះ បើត្រូវកម្មករផ្សេងនឹងបង្កគ្រោះថ្នាក់។

**(10)** ការភ័យស្លន់ស្លោ

ការភ្ញាក់ផ្អើលឬស្លន់ស្លោភ្លាមៗ អាចងាយនឹងនាំឲ្យធ្វើសកម្មភាពដែលគ្មានសុវត្ថិភាពភ្លាមៗឬធ្វើសកម្មភាពណែនាំដែលមិនសមស្រប។

**(11)** ការចុះខ្សោយមុខងារផ្លូវចិត្តនិងផ្លូវកាយ

អ្វីដែលធ្លាប់អាចធ្វើបានកាលពីនៅក្មេងក៏អាចទៅជាធ្វើលែងបានដោយសារការកើនវ័យផងដែរ។ ជាពិសេស ការចុះខ្សោយមុខងារជើងនិងចង្កេះ ការចុះខ្សោយសមត្ថភាពមើលឃើញជាដើម គឺកើតឡើងបន្តិចម្តងៗ ហេតុនេះវាពិបាកចាប់អារម្មណ៍ដឹង។ វាសំខាន់ណាស់ដែលត្រូវចាប់អារម្មណ៍ដោយខ្លួនឯងធ្វើយ៉ាងណាកុំធ្វើសកម្មភាពឬឥរិយាបថទាំងបង្ខំ។

**(12)** ការអស់កម្លាំង

ពេលដែលការអស់កម្លាំងបានសន្សំឡើងច្រើននឹងធ្វើឲ្យធ្លាក់ចុះសមត្ថភាពប្រុងប្រយ័ត្ន ដែលអាចនាំទៅរកគ្រោះថ្នាក់។ វាសំខាន់ដែលត្រូវគ្រប់គ្រងសុខភាពជាប្រចាំថ្ងៃឲ្យបានត្រឹមត្រូវដូចជាការគេងបានសមស្រប ការបំប៉នអាហារូបត្ថម្ភជាដើម។

**"សូមឲ្យសុវត្ថិភាពពេញមួយថ្ងៃនៅថ្ងៃនេះផងដែរ!"**